**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Royal University of Law and Economics

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា

កម្មសិក្សា ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា** (**ផ.ម.ក**)

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ចិត្ត ផានិត**
**ខទ្យ ស្រីលុច្យ**

សាស្ត្រាចារ្យណែនាំ
លោក **អ៊ុង អ៊ូ**

ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំចូលសិក្សា ២០១៥
ជំនាន់ទី១២ ឆ្នាំសរសេររបាយការណ៍ ២០១៩

# អារម្ភកថា

ឆ្លងកាត់ការសិក្សាអស់រយៈពេលបួនឆ្នាំ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនផ្នែកទ្រឹស្តីតាមរយៈការបង្ហាត់បង្រៀន បណ្តុះបណ្តាលដោយយកចិត្តទុកដាក់ពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ និងលោកគ្រូអ្នកគ្រូតាមមុខវិជ្ជា និងចំណេះដឹងផ្សេងៗ។ ជាក់ស្តែងដើម្បីបញ្ចប់ការសិក្សាឲ្យជោគជ័យ សាកលវិទ្យាល័យតម្រូវឲ្យនិស្សិតធ្វើការសិក្សាស្រាវជ្រាវសរសេររបាយការណ៍កម្មសិក្សា ឬសារណាបញ្ចប់ការសិក្សារបស់ខ្លួន ក៏ដូចជាផ្តល់ឱកាសឲ្យនិស្សិតយកទ្រឹស្តីទៅអនុវត្តផ្ទាល់ក្នុងការងារជាក់ស្តែងផងដែរ។

របាយការណ៍កម្មសិក្សានេះ គឺជាលទ្ធផលដែលកើតចេញពីការស្រាវជ្រាវ និងចងក្រងឡើងយ៉ាងយកចិត្តទុកដាក់បំផុត។ ដោយផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា យើងឃើញថា វិស័យមូលបត្រគឺជាផ្នែកមួយដែលដើរតួយ៉ាងសំខាន់ក្នុងការទ្រទ្រង់យុទ្ធសាស្ត្រមួយនេះ។ ចាប់តាំងពីពេលសម្ពោធដាក់ឲ្យដំណើរការផ្សារមូលបត្រកម្ពុជាកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ មក យើងឃើញថា ការអភិវឌ្ឍទីផ្សារមួយនេះ កំពុងបោះជំហ៊ានទៅមុខគួរឲ្យ កត់សម្គាល់ ជាពិសេសមូលបត្របំណុលបានចាប់ផ្តើមមានវត្តមាននៅក្នុងផ្សារមូលបត្រកម្ពុជានាពេលថ្មីៗនេះ។

ហេតុដូចនេះ របាយការណ៍កម្មសិក្សាស្តីពី **"ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា"** ត្រូវបានចងក្រងឡើងក្នុងគោលបំណងស្វែងយល់បន្ថែមពីការវិវត្តន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា ជាពិសេសទីផ្សារមូលបត្របំណុលដើម្បីជាចំណេះដឹងថ្មីមួយបន្ថែមទៀតសម្រាប់យើងខ្ញុំផ្ទាល់ និងអាចជាឯកសារជំនួយដល់កាសិក្សារបស់ប្អូនៗសិស្ស-និស្សិត និងសាធារណជនដែលបានអានរបាយការណ៍កម្មសិក្សានេះ បានយល់ដឹងបន្ថែមទៀតពីវិស័យមូលបត្រនៅកម្ពុជា។

របាយការណ៍កម្មសិក្សា ដែលអស់លោក លោកស្រីសាស្ត្រាចារ្យ និងសិស្ស-និស្សិតកំពុងកាន់នៅនឹងដៃនេះ គឺជាសមិទ្ធផលថ្មីមួយ ដែលយើងខ្ញុំបានស្រាវជ្រាវ និងតាក់តែងឡើងដើម្បីលើកកម្ពស់ការយល់ដឹងពីវិស័យមូលបត្រនៅកម្ពុជា ដែលនឹងបង្ហាញអ្នកអានអំពីសមាសភាព ស្ថានភាពបច្ចុប្បន្ន និងជាពិសេសយុទ្ធសាស្ត្រអភិវឌ្ឍវិស័យមូលបត្របំណុលនៅកម្ពុជាឲ្យកាន់តែរីកចម្រើនឡើង និងជាចំណេះដឹងក្នុងការត្រៀមខ្លួនដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការវិនិយោគ និងអភិវឌ្ឍវិស័យថ្មីមួយនេះឲ្យកាន់តែរឹងមាំ។

ដោយទទួលបានការណែនាំ ពន្យល់និងបកស្រាយយ៉ាងលម្អិតពីសំណាក់សាស្ត្រាចារ្យណែនាំ បុគ្គលិករបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងរៀមច្បងក្នុងការចងក្រងឯកសារទាំងអស់នេះឡើង

និងពឹងផ្អែកលើឯកសារផ្លូវការផ្សេងៗទៀត ទើបធ្វើឲ្យយើងខ្ញុំសម្រេចបានខ្លឹមសារនិងអត្ថន័យនៃស្នាដៃមួយនេះមានភាពប្រសើរ និងច្បាស់លាស់ដើម្បីទុកជាឯកសារសម្រាប់ជាចំណេះដឹងថ្មីមួយសម្រាប់អ្នកអាន និងសិស្សនិស្សិតជំនាន់ក្រោយៗ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍កម្មសិក្សាមួយនេះ នឹងបានចូលរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មាន និងចែករំលែកចំណេះដឹងមួយចំនួនដល់សាធារណជន និងមិត្តអ្នកអានទាំងអស់ក្នុងការយល់ដឹងពីវិស័យមូលបត្រនៅកម្ពុជា។

ជាទីបញ្ចប់ ទោះបីជាយើងខ្ញុំបានខិតខំព្យាយាមរៀបចំ កែសម្រួលនិងពិនិត្យយ៉ាងណាក៏ដោយក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលកើតឡើងដោយអចេតនា។ អាស្រ័យហេតុនេះ យើងខ្ញុំទាំងពីរនាក់សូមអភ័យទោសទុកជាមុនចំពោះរាល់កំហុសឆ្គងដែលមានក្នុងរបាយការណ៍កម្មសិក្សាមួយនេះ និងទទួលមតិរិះគន់ ការកែលម្អពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងរៀមច្បងទាំងអស់ ដើម្បីស្ថាបនាធ្វើឲ្យស្នាដៃមួយនេះកាន់តែមានភាពប្រសើរឡើងថែមទៀត។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ចិត្ត ផានិត** និង **វង្ស ស្រីលុច្ស** ជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុជំនាន់ទី១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច សូមថ្លែងអំណរគុណ និងសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរ គឺលោកឪពុក និងអ្នកម្តាយ ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌ ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅ ផ្តល់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងជានិច្ចកាលតែងតែលះបង់នូវធនធានគ្រប់យ៉ាងទាំងអស់ដើម្បីការសិក្សារបស់កូនៗ រួមមានទាំងផ្នែកសម្ភារៈសិក្សា និងថវិកាផ្គត់ផ្គង់ តាំងពីថ្នាក់បឋមសិក្សារហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដែលធ្វើឲ្យរូបកូនទទួលបានចំណេះដឹងមិនអាចកាត់ថ្លៃបានដូចសព្វថ្ងៃនេះ។ កូនសូមឱនគោរពទាំងកាយវាចាចិត្ត ព្រមទាំងថ្លែងអំណរគុណពោរពេញទៅដោយភាពកត្តញ្ញូ ចំពោះលោកទាំងពីរ និងក្រុមគ្រួសាររបស់យើងខ្ញុំទាំងអស់គ្នាជាពិសេសគឺលោកតានិងអ៊ំប្រុស អ៊ំស្រី ដែលបានមើលថែរ និងផ្តល់នូវឱកាសសម្រាប់យើងខ្ញុំបានមកបន្តការសិក្សា និងការផ្គត់ផ្គង់សព្វគ្រប់បែបយ៉ាងលើការសិក្សារ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី ប្រធាន អនុប្រធានដេប៉ាតឺម៉ង់ ការិយាល័យសិក្សា និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានផ្តល់ឱកាស និងជួយបង្ហាត់បង្រៀន ផ្តល់នូវដំបូន្មានល្អៗ ដើម្បីឲ្យយើងខ្ញុំមានការអភិវឌ្ឍខ្លួនក្លាយជាធនធានល្អក្នុងសង្គម។
- លោកសាស្ត្រាចារ្យ អ៊ឹង អ៊ូ ដែលជាសាស្ត្រាចារ្យណែនាំដ៏ល្អម្នាក់ក្នុងការស្រាវជ្រាវរបាយការណ៍កម្មសិក្សានេះ។ លោកសាស្ត្រាចារ្យតែងតែផ្តល់ជាដំបូន្មាន គំនិតល្អៗ និងគន្លឹះនៃការស្រាវជ្រាវមួយចំនួនដែលធ្វើឲ្យមានភាពងាយស្រួលដល់យើងខ្ញុំក្នុងការស្រាវជ្រាវ និងសរសេររបាយការណ៍កម្មសិក្សារបញ្ចប់ការសិក្សាមួយនេះទទួលបានជោគជ័យ។
- ឯកឧត្តមអគ្គនាយក លោកអគ្គនាយករង ព្រមទាំងបុគ្គលិកទាំងអស់ នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាពិសេស លោកស្រី គឹម សុផានីតា លោក ទ្រី តៃហ៊ី និងបុគ្គលិកនៃនាយកដ្ឋានប្រតិបត្តិការទីផ្សារទាំងអស់ ព្រមទាំងបងប្រុស ឆាយ វណ្ណរិទ្ធ (មន្ត្រីនៅ **គ.ម.ក.**) ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចុះកម្មសិក្សា និងផ្តល់ឯកសារដែលទាក់ទិនទៅនឹងរបាយការណ៍ ព្រមទាំងផ្តល់គំនិតល្អៗនៅអំឡុងពេលចុះកម្មសិក្សា ដើម្បីធ្វើឲ្យរបាយការណ៍កម្មសិក្សាមួយនេះកាន់តែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់លោកអ្នកមានគុណទាំងអស់ដែលបានរៀបរាប់ខាងលើ សូមទទួលបាននូវពរជ័យ សេរីមង្គល វិបុលសុខ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# មាតិកា

បញ្ជីអក្សរកាត់ ......VI
បញ្ជីតារាង ......VIII
បញ្ជីឧបសម្ព័ន្ធ ......IX

# សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ......០១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ......០២
៣. គោលបំណងនៃការស្រាវជ្រាវ ......០២
៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ......០៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ......០៣
៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ......០៤
ក. ការប្រមូលទិន្នន័យ ......០៤
ខ. ការវិភាគទិន្នន័យ ......០៤
៧. រចនាសម្ព័ន្ធ ......០៤

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ

១.១. អ្វីទៅជាមូលបត្រ......០៧
១.១.១. មូលបត្ររដ្ឋ......០៧
១.១.២. មូលបត្រមហាជន ......០៨
១.២.ទីផ្សារមូលបត្រ......០៩
១.២.១. និយមន័យទីផ្សារមូលបត្រ ......០៩
១.២.២. ប្រវត្តិទីផ្សារមូលបត្រ......១០
១.២.៣. រចនាសម្ព័ន្ធទីផ្សារមូលបត្រ......១២
ក. ទីផ្សារមូលបត្រកម្មសិទ្ធិ ......១២
ខ. ទីផ្សារមូលបត្របំណុល ......១៣
គ. យន្តការទីផ្សារក្នុងការជួញដូរមូលបត្រ......១៤
ឃ. ទីកន្លែងជួញដូរ ......១៦

១.៣. អត្ថប្រយោជន៍ទីផ្សារមូលបត្រ ........................................................................................១៧
១.៣.១. ចំពោះសេដ្ឋកិច្ច ........................................................................................១៧
១.៣.២. ចំពោះវិនិយោគិន ........................................................................................១៨
១.៤. គុណវិបត្តិរបស់ទីផ្សារមូលបត្រ ........................................................................................២០
១.៥. អ្នកចូលរួមក្នុងទីផ្សារមូលបត្រ ........................................................................................២១
១.៥.១. តួអង្គក្នុងទីផ្សារដំបូង ........................................................................................២១
១.៥.១.១. គណៈកម្មការមូលបត្រកម្ពុជា ........................................................................................២១
១.៥.១.២. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ........................................................................................២២
១.៥.១.៣. ក្រុមហ៊ុនមូលបត្រ ........................................................................................២៣
១.៥.១.៤. វិនិយោគិនសាធារណៈ ........................................................................................២៣
១.៥.១.៥. ក្រុមហ៊ុនគណនេយ្យ និងសវនកម្ម ........................................................................................២៤
១.៥.១.៦. ភ្នាក់ងារវាយតម្លៃ ........................................................................................២៥
១.៥.១.៧. ក្រុមមេធាវី ឬមេធាវី ........................................................................................២៥
១.៥.២. តួអង្គក្នុងទីផ្សារបន្ទាប់ ........................................................................................២៥
១.៥.២.១. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................................................................២៥
១.៥.២.២. វិនិយោគិនសាធារណៈ ........................................................................................២៦
១.៥.២.៣. ក្រុមហ៊ុនមូលបត្រ ........................................................................................២៦
១.៥.៣. តួអង្គចូលរួមដទៃទៀត ........................................................................................២៨
១.៥.៣.១. ភ្នាក់ងារបញ្ជិកាមូលបត្រ ........................................................................................២៨
១.៥.៣.២. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ........................................................................................២៩
១.៥.៣.៣. ភ្នាក់ងារសុវត្ថិភាពក្នុងវិស័យមូលបត្រ ........................................................................................២៩
១.៥.៣.៤. ភ្នាក់ងារវាយតម្លៃលទ្ធភាពសង ........................................................................................៣០
១.៥.៣.៥. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ........................................................................................៣០

**ជំពូកទី២**

**ស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា**

២.១. វិស័យធនាគារ ........................................................................................៣៤
២.១.១. ធនាគារពាណិជ្ជ ........................................................................................៣៥
២.១.២. ធនាគារឯកទេស ........................................................................................៣៦

២.១.៣. វិស័យមីក្រូហិរញ្ញវត្ថុ...............................................................................................៣៦
២.២. វិស័យហិរញ្ញវត្ថុមិនមែនធនាគារ.......................................................................................៣៩
២.២.១.ធានារ៉ាប់រង......................................................................................................................៤០
២.២.២.វិស័យសោធន ....................................................................................................................៤១
២.៣. ស្ថានភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន................................................................................៤២
២.៤. ស្ថានភាពជញ្ជីងទូទាត់ .........................................................................................................៤៦

## ជំពូកទី៣

## ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣.១. និយមន័យនៃទីផ្សារមូលបត្រកម្ពុជា ........................................................................................៥២
៣.២. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សាមូលបត្រកម្ពុជា ...........................................................................៥២
៣.៣.រចនាសម្ព័ន ...........................................................................................................................៥៤
៣.៤. សមាជិករបស់ផ្សារមូលបត្រកម្ពុជា...........................................................................................៥៤
៣.៥. ចក្ខុវិស័យ ..............................................................................................................................៥៥
៣.៦. បេសកកម្ម ..............................................................................................................................៥៥
៣.៧.តួនាទី និងមុខងារ.....................................................................................................................៥៥
៣.៨. ប្រតិបត្តិករទីផ្សារមូលបត្រ .........................................................................................................៥៦
៣.៩. លក្ខខណ្ឌក្នុងការចុះបញ្ជីបោះផ្សាយសញ្ញាបណ្ណ............................................................................៥៨
៣.១០. អត្ថប្រយោជន៍នៃការចុះបញ្ជីនៅក្នុងផ្សាមូលបត្រកម្ពុជា..................................................................៥៨
៣.១១. បច្ចុប្បន្នភាពរបស់ផ្សារមូលបត្រកម្ពុជា.........................................................................................៦០
៣.១១.១. ការដាក់ឲ្យដំណើរការប្រព័ន្ធ MTS និងប្រព័ន្ធបង្ហាញព័ត៌មាន e-disclosure.......៦០
៣.១១.២. ស្ថានភាពអ្នកចូលរួម.........................................................................................................៦២
៣.១២. ទិដ្ឋភាពទូទៅនៃការជួញដូរក្នុងផ្សារមូលបត្រកម្ពុជា ......................................................................៦៣
ក. ការជួញដូរមូលបត្របំណុល.........................................................................................................៦៧
ខ. វិធានផ្សេងៗទៀតទាក់ទងនឹងការជួញដូរមូលបត្របំណុល..............................................................៦៨

## ជំពូកទី៤

## ការបោះផ្សាយលក់មូលបត្របំណុលនៅកម្ពុជា

៤.១. ការចេញផ្សាយប័ណ្ណរតនាគារ .....................................................................................................៦៩

៤.១.១. គោលបំណងនៃការចេញផ្សាយប័ណ្ណរតនាគារ ....................................................៦៩
៤.១.២. ដំណើរការចេញប័ណ្ណរតនាគារ ....................................................................................៦៩
៤.២. ការចេញផ្សាយមូលបត្រអាចជួញដូរបាន(NCD).........................................................៧១
៤.២.១. គោលបំណងនៃការចេញផ្សាយមូលបត្រអាចជួញដូរបាន.........................................៧១
៤.២.២. ដំណើរការចេញផ្សាយមូលបត្រអាចជួញដូរបាន .......................................................៧២
៤.៣. បច្ចុប្បន្នភាពមូលបត្របំណុលកម្ពុជា .............................................................................៧៤
៤.៣.១. មូលបត្រអាចជួញដូរបាន (NCD)..................................................................................៧៤
៤.៣.២. ប្រតិបត្តិការណ៍ផ្តល់សន្ទនីភាពដោយមានការធានា (LPCO) ....................................៧៥
៤.៣.៣. សញ្ញាបណ្ណសាជីវកម្ម ..................................................................................................៧៦
៤.៣.៣.១. សញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ............៧៦
៤.៣.៣.២.សញ្ញាបណ្ណសាជីវកម្មរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC ....................៧៧
៤.៣.៣.៣. ការចុះបញ្ជីរបស់ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ABA Bank)..................៧៧

## ជំពូកទី៥

## ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា

៥.១. គោលបំណងនៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល .......................................................៧៨
៥.២. សារៈសំខាន់នៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល ........................................................៧៨
៥.២.១. ពង្រីកលទ្ធភាពទទួលបានដើមទុនបន្ថែម ដើម្បីវិនិយោគក្នុងខឿនសេដ្ឋកិច្ច .........៧៩
៥.២.២. ការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ ..............................................................៨០
៥.៣. វឌ្ឍនភាព និងសមិទ្ធផល...................................................................................................៨១
៥.៤. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ..........................................................................៨១
៥.៤.១. កត្តាធនធានមនុស្ស.........................................................................................................៨២
៥.៤.២. ប្រព័ន្ធព័ត៌មានវិទ្យា.........................................................................................................៨៣
៥.៤.៣. ប្រព័ន្ធច្បាប់ បទប្បញ្ញត្តិ និងប្រព័ន្ធតុលាការ ...............................................................៨៣
៥.៤.៤. ប្រព័ន្ធគណនេយ្យ និងសវនកម្ម .....................................................................................៨៥
៥.៤.៥. ក្រុមហ៊ុនចុះបញ្ជី និងសន្ទនីយភាពក្នុងទីផ្សារ...............................................................៨៦
៥.៤.៦.ជំនឿទុកចិត្តលើទីផ្សារ.......................................................................................................៨៦
៥.៥. កត្តាសំខាន់ដែលចូលរួមក្នុងការកែលំអ និងអភិវឌ្ឍទីផ្សារមូលបត្របំណុល ....................៨៧

៥.៥.១.ផែនការរបស់គណៈគម្មការមូលបត្រក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល..........៨៧
៥.៥.២. ផែនការរបស់ក្រុមហ៊ុនផ្សារមូលបត្រក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល ...........៩០
៥.៥.៣. កិច្ចការពារ និងការអប់រំវិនិយោគិន ..........៩៣
៥.៥.៤. ជំរុញការអប់រំ និងការយល់ដឹងរបស់សារព័ត៌មាន ..........៩៤
៥.៥.៥. ការកសាងសមត្ថភាព..........៩៤
៥.៥.៦. ពង្រឹងប្រព័ន្ធគណនេយ្យ និងសវនកម្ម..........៩៥
៥.៦. ផែនការដើម្បីបង្កើនការចុះបញ្ជីនៅលើទីផ្សារ ..........៩៧
៥.៧. ការអភិវឌ្ឍក្របខ័ណ្ឌគ្រប់គ្រង និងគតិយុត្ត..........៩៧
៥.៨. ការផ្សព្វផ្សាយ ..........៩៩
៥.៩. ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ..........១០០
៥.១០. អត្ថប្រយោជន៍នៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល .......... ១០២

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន .......... ១០៥
២. អនុសាសន៍ .......... ១០៧

**ឧបសម្ព័ន្ធ**

**ឯកសារយោង**

# អក្សរកាត់

| | |
|---|---|
| គ.ម.ក. | : គណៈកម្មការមូលបត្រកម្ពុជា |
| ប.ជ.ស | : បេឡាជាតិសន្តិសុខសង្គម |
| ប.ជ.អ | : បេឡាជាតិអតីតយុទ្ធជន |
| ប.ស.ស | : បេឡាជាតិរបបសន្តិសុខសង្គម |
| ផ.ម.ក. | : ផ្សារមូលបត្រកម្ពុជា |
| ផ.ស.ស | : ផលិតផលក្នុងស្រុកសរុប |
| ATM | : Automated Teller Machene |
| CIC | : Cambodia Investor Club |
| CPTPP | : Comprehensive and Progressive Agreement for Trans-Pacific Partnership |
| CSX | : Cambodia Securities Exchange |
| CWEA | : Cambodia Women Entrepreneurs association |
| EBA | : Everything but Arms |
| FASMEC | : Federation of Associations for Small and Medium Enterprises of Cambodia |
| FRTI | : Financial Regulators Training Initiative |
| GDP | : Gross Domestic Product |
| IFRS | : International Financial Reporting Standard |
| IOSCO | : International Organization of Securities Commission |
| IPO | : Initial Public Offering |
| ISA | : International Standard of Auditing |
| KICPPA | : Kampuchea Institute of Certifed Public Accountant & Auditor |
| KOICA | : Korea International Cooperation Agency |
| LOLC | : Lanka Orix Leasing Campany |
| LPCO | : Liquidity Providing Collateratized Operation |
| LIBOR | : London Interbank Offered Rate |

| | |
|---|---|
| MDIs | : Microfinance Deposit Taking Institutions |
| MFI | : Microfinance Institutions |
| MOU | : Memorandum of Understanding |
| MTS | : Mobile trading System |
| NBCP | : National Bank of Cambodia Platform |
| NCDs | : Negotiable Certificates of Deposit |
| OTC | : Over The Counter |
| QIP | : Qualified Institutional Placement |
| REPO | : Repurchase agreement |
| ROA | : Return on Assets |
| ROE | : Return on Equity |
| SECC | : Securities and Exchange Commission of Cambodia |
| SMEs | : Small and Medium Enterprises |

# បញ្ជីតារាង


– តារាងទី១: ទិន្នន័យរបស់ធនាគារពាណិជ្ជគិតត្រឹមឆ្នាំ២០១៥ ដល់២០១៧

– តារាងទី២: ទិន្នន័យធនាគារឯកទេសគិតត្រឹមឆ្នាំ២០១៥ ដល់២០១៧

– តារាងទី៣: ទិន្នន័យរបស់ (MDIs) គិតត្រឹមឆ្នាំ២០១៥ ដល់២០១៧

– តារាងទី៤: ទិន្នន័យរបស់ (MFIs) គិតត្រឹមឆ្នាំ២០១៥ ដល់២០១៧

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ :ប្រកាស ស្តីពី ការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ឧបសម្ព័ន្ធទី២ :ប្រកាស ស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

ឧបសម្ព័ន្ធទី៣ :ច្បាប់ ស្តីពី មូលបត្ររដ្ឋ

ឧបសម្ព័ន្ធទី៤ :កាលបរិច្ឆេទសំខាន់ៗ នៃដំណើរការបង្កើតទីផ្សារមូលបត្រកម្ពុជា

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ បានក្លាយជារបៀបវារៈអាទិភាពមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា តាមរយៈការដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

នាពេលថ្មីៗនេះ ប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍជាច្រើនបានខិតខំពង្រឹង និងអភិវឌ្ឍ វិស័យហិរញ្ញវត្ថុ ដែលជាសរសៃឈាមសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យមានស្ថិរភាព។ ជាក់ស្ដែង ប្រទេសកម្ពុជាបាននិងកំពុងឆ្លងកាត់សម័យកាលសកលភាវូបនីយកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍អាស៊ាន។ ជាកត្តាចាំបាច់កម្ពុជាត្រូវធានាឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមភាព។ ប្រការនេះទាមទារឱ្យកម្ពុជាមានសមត្ថភាពក្នុងការទទួលបាន និងប្រើប្រាស់ចំណេះដឹងនិងនវានុវត្តន៍ ដែលផ្អែកលើវិស័យហិរញ្ញវត្ថុ។ វិស័យហិរញ្ញវត្ថុរីកចម្រើន និងផ្ដល់ដល់យើងនូវលទ្ធភាពក្នុងការបង្កើនការអភិវឌ្ឍលើគ្រប់វិស័យសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិឲ្យកាន់តែជឿនលឿនជាងមុន។

ដោយហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកការអភិវឌ្ឍវិស័យមូលបត្រ បំណុល ដែលជាវិស័យមួយថ្មីបន្ថែមទៀតសម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឲ្យកាន់តែរឹងមាំ។ ក្នុងការអភិវឌ្ឍវិស័យមូលបត្របំណុលនៅកម្ពុជាកម្ពុជាត្រូវការធនធានមនុស្សជាច្រើនដូចជាអ្នកបច្ចេកទេសក្នុងវិស័យមូលបត្របំណុល អ្នកចូលរួមវិនិយោគក្នុងទីផ្សារមូលបត្របំណុលជាពិសេសសាធារណជនទូទៅដើម្បីឱ្យកម្ពុជាទទួលបានកំណើនទីផ្សារមូលធនក្នុងស្រុក ដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនសាជីវកម្មដែលខ្វះដើមទុនអាចប្រមូលមូលធនទាំងនោះ ដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួនដែលជាផ្នែកមួយក្នុងការទ្រទ្រង់ដល់មីក្រូសេដ្ឋកិច្ចកម្ពុជា។

ដោយមើលឃើញនូវតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍវិស័យមូលបត្របំណុល រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងលើកទឹកចិត្តចំពោះការអប់រំចំណេះដឹងក្នុងវិស័យមូលបត្របំណុលដល់ប្រជាជនកម្ពុជា និងការលើទឹកចិត្តផ្នែកផ្សេងៗទៀតដើម្បីជំរុញការចូលរួមក្នុងវិស័យនេះ។ ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទីដ៏សំខាន់ក្នុងការបណ្ដុះបណ្ដាលធនធានលើចំណេះដឹងទាំងនេះ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិតាមរយៈការដាក់បញ្ចូលមុខវិជ្ជាទីផ្សារមូលបត្រទៅក្នុងកម្មវិធីសិក្សាជាតិ។ និងមានបេសកកម្ម

ក្នុងការផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើការអភិវឌ្ឍចំណេះដឹងសម្រាប់សតវត្សទី ២១នេះ។

ហេតុដូច្នេះ ការរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា មានភាពចាំបាច់និងបន្ទាន់បំផុតសម្រាប់ចង្អុលបង្ហាញជាយុទ្ធសាស្ត្រ និងជាផែនទីបង្ហាញផ្លូវសម្រាប់រាល់សកម្មភាពអប់រំចំណេះដឹង និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងវិស័យមូលបត្របំណុលទៅកាន់ប្រជាជន។ ប្រការនេះ កាន់តែធ្វើឱ្យការអភិវឌ្ឍធនធានមនុស្សមានការគាំទ្រកាន់តែខ្លាំងដល់ការសម្រេចដោយជោគជ័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងគោលនយោបាយអភិឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូល។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីជាទីផ្សារមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងអស់រយៈពេលជាង ៧ឆ្នាំកន្លងមកហើយក្តីនិងមានការខិតខំលើកស្ទួយពីសំណាក់ស្ថាប័នពាក់ព័ន្ធយ៉ាងសកម្មក៏ដោយ តែវិស័យនេះនៅតែចាត់ទុកថាជាវិស័យថ្មីមួយដែលនៅមានភាពផុយស្រួយនៅឡើយ។ ជាពិសេសទីផ្សារមូលបត្របំណុល ដែលយើងហៅថាសញ្ញាបណ្ណសាជីវកម្ម ទើបតែមានវត្តមាននៅក្នុងផ្សារមូលបត្រកម្ពុជានាពេលថ្មីៗនេះ ដែលទាមទានូវការយល់ដឹងកាន់តែច្រើនដូចជា៖ អ្វីទៅជាផ្សារមូលបត្របំណុល? អ្វីទៅជាសញ្ញាបណ្ណសាជីវកម្ម? ហេតុដូចនេះ ទើបយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវ និងស្វែងយល់អំពី ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា ថាតើផ្សារមូលបត្របំណុលនៅកម្ពុជាមានបច្ចុប្បន្នភាពបែបណា? និងតើកម្ពុជាមានយុទ្ធសាស្ត្របែបណាដើម្បីអភិវឌ្ឍទីផ្សារមូលបត្របំណុលនេះឲ្យកាន់តែរីកចម្រើនឡើង?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណង បង្កើនចំណេះដឹងក្នុងវិស័យមូលបត្រ យល់ដឹងពីយុទ្ធ-សាស្ត្រអភិវឌ្ឍវិស័យមូលបត្របំណុលនៅកម្ពុជាដើម្បី៖

- ចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមូលបត្រជាមួយរាជរដ្ឋាភិបាល
- ជំរុញការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា
- ស្វែងយល់ឲ្យកាន់តែច្បាស់ពីមូលបត្របំណុល និងទីផ្សារមូលបត្របំណុល
- យល់ដឹងពីតួនាទីរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល
- យល់ដឹងពីតួនាទីរបស់គណៈកម្មការមូលបត្រកម្ពុជាក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល

- យល់ដឹងពីតួនាទីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល
- ស្វែងយល់ពីអត្ថប្រយោជន៍នៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល
- បង្កើនការយល់ដឹងពីវិស័យមូលបត្រនៅកម្ពុជា
- ស្វែងយល់ពីនីតិវិធី ក្របខ័ណ្ឌគតិយុត្ត និងលក្ខខណ្ឌចាំបាច់ក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា។

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារផ្សារមូលបត្រកម្ពុជា មានផលិតផលជាច្រើនក្នុងការផ្តល់ជូនទៅអ្នកវិនិយោគ និងកំពុងអភិវឌ្ឍលើគ្រប់ផ្នែកនៃផលិតផលក្នុងផ្សារមូលបត្រទាំងមូល។ ដូចនេះ របាយការណ៍កម្មសិក្សានេះ នឹងធ្វើការស្រាវជ្រាវជាសំខាន់តែលើ ទីផ្សារមូលបត្របំណុលនៅកម្ពុជា យុទ្ធសាស្ត្រអភិវឌ្ឍ ដោយប្រមូលយកទិន្នន័យនាពេលថ្មីៗនេះ និងផែនការអភិវឌ្ឍរបស់ស្ថាប័នពាក់ព័ន្ធរបស់ទីផ្សារមូលបត្របំណុលនៅកម្ពុជា។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ គឺបានផ្តល់នូវគុណប្រយោជន៍ និងសារៈសំខាន់ដូចជា៖

- ផ្តល់ឲ្យយើងខ្ញុំផ្ទាល់នូវចំណេះដឹងថ្មីមួយទៀត គឺការអនុវត្តផ្ទាល់ ការស្រាវជ្រាវព័ត៌មានថ្មីៗបន្ថែមលើចំណេះដឹងផ្នែកទ្រឹស្តីដែលបានសិក្សារួចមកហើយ។
- ជាឯកសារសម្រាប់ផ្តល់ព័ត៌ជូនប្អូនៗ សិស្ស-និស្សិតជំនាន់ក្រោយក្នុងការជួយសម្រួលដល់ការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមក្នុងវិស័យមូលបត្រ។
- ជាព័ត៌មានក្នុងការចែករំលែកចំណេះដឹងទៅសាធារណជនទូទៅ អ្នកវិនិយោគ ក្រុមហ៊ុនសហគ្រាសផ្សេងៗ ឲ្យយល់ដឹងពីវិស័យមូលបត្របំណុលនៅកម្ពុជាកាន់តែទំលំទូលាយ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសម្រេចនូវលទ្ធផលនៃរបាយការណ៍កម្មសិក្សាមួយនេះ មានវិធីសាស្ត្រពីរក្នុងការប្រមូលបានទិន្នន័យឲ្យបានគ្រប់គ្រាន់ លម្អិត និងច្បាស់លាស់ដូចជា៖

### ក. ការប្រមូលទិន្នន័យ

- **ទិន្នន័យចម្បង**

- ការចុះកម្មសិក្សាក្នុងការអនុវត្ត និងប្រមូលទិន្នន័យផ្ទាល់ពីផ្សារមូលបត្រកម្ពុជា
- ការសួរព័ត៌មានផ្ទាល់ពីសំណាក់បុគ្គលិកក្នុងផ្សារមូលបត្រកម្ពុជា
- ការផ្តល់យោបល់ និងចង្អុលបង្ហាញពីសំណាក់សាស្ត្រាចារ្យណែនាំ។

➢ **ទិន្នន័យបន្ទាប់បន្សំ**

- ការប្រមូលទិន្នន័យតាមរយៈគេហទំព័ររបស់ស្ថាប័នពាក់ព័ន្ធដូចជា គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ធនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នផ្សេងៗទៀត។
- ការប្រមូលទិន្នន័យតាមរយៈ ច្បាប់ ប្រកាស បទប្បញ្ញត្តិ ព្រឹត្តិបត្រព័ត៌មាន និងសៀវភៅផ្សេងៗពាក់ព័ន្ធនឹងវិស័យមូលបត្រ។
- ការសួរ-សុំព័ត៌មានពីរៀមច្បង និងតាមរយៈនិក្ខេបបទ និងសៀវភៅរបាយការណ៍កម្មសិក្សារបស់រៀមច្បងជំនាន់មុនជាដើម។

### ខ. ការវិភាគទិន្នន័យ

ទិន្នន័យទាក់ទងនឹងផ្សារមូលបត្រកម្ពុជាត្រូវបានធ្វើការវិភាគ និងពិពណ៌នាតាមរយៈឯកសារដែលទទួលបានដោយផ្អែកលើតួលេខដែលបានបង្ហាញ និងធ្វើការប្រៀបធៀបទិន្នន័យទាំងនោះពីឆ្នាំមួយទៅមួយទៀតដើម្បីវិភាគពីភាពខុសគ្នា និងការរីកចម្រើនរបស់វិស័យមូលបត្រនៅកម្ពុជា។

## ៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ដើម្បីធ្វើឲ្យមានភាពងាយស្រួលនៅក្នុងការស្រាវជ្រាវ ឲ្យបានល្អ និងរលូន របាយការណ៍នេះយើងបានបែងចែកជា ៥ជំពូកដូចខាងក្រោម:

❖ សេចក្តីផ្តើម៖ នឹងនិយាយពីស្ថានភាពទូទៅ គោលបំណង និងចំណោទបញ្ហានៃការសរសេរលើប្រធានបទនេះ

❖ ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ នឹងនិយាយអំពីទ្រឹស្តីផ្សេងៗ តួអង្គ និងតួនាទីរបស់ទីផ្សារមូលបត្រជារួម

❖ ជំពូកទី២៖ ស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា នឹងនិយាយពីចំណូល ចំណាយ និងវិស័យដែលចូលរួមបង្កើនកំណើនសេដ្ឋកិច្ចជាតិ ការព្យាករណ៍ពីសេដ្ឋកិច្ចនៅឆ្នាំខាងមុខ។

❖ ជំពូកទី៣៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងនិយាយពីសមាសភាព និងបច្ចុប្បន្នភាពរបស់ផ្សារមូលបត្រកម្ពុជា

- ជំពូកទី៤៖ ការបោះផ្សាយលក់មូលបត្របំណុលនៅកម្ពុជា នឹងនិយាយអំពីស្ថានភាពមូលបត្របំណុលនៅកម្ពុជា
- ជំពូកទី៥៖ ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា នឹងនិយាយអំពីបញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## គម្រោងនៃការស្រាវជ្រាវមានដូចខាងក្រោម

**ការកំណត់បញ្ហានៃការស្រាវជ្រាវ**

**ការសិក្សាទៅលើទ្រឹស្តី**

- និយមន័យមូលបត្រ
- ប្រវត្តិទីផ្សារមូលបត្រ
- និយមន័យទីផ្សារមូលបត្រ
- រចនាសម្ព័ន្ធទីផ្សារមូលបត្រ
- ប្រភេទទីផ្សារមូលបត្រ
- ទីកន្លែងនៃការជួញដូរ
- មុខងារ និងសារៈសំខាន់នៃទីផ្សារមូលបត្រ
- គុណវិបត្តិនៃទីផ្សារមូលបត្រ

**ស្ថានភាពទូទៅ**

- វិស័យធនគារ និងវិស័យមីក្រូហិរញ្ញវត្ថុ
- វិស័យមិនមែនធនាគារ
- ស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន
- ការវិវត្តន៍នៃទីផ្សារមូលបត្របំណុល
- ការបោះផ្សាយលក់មូលបត្របំណុលនៅកម្ពុជា
- ឧបសគ្គនៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល
- ដំណោះស្រាយ និងការកែលម្អទីផ្សារមូលបត្របំណុល

**ការវិភាគរួម**

- តើអ្វីទៅជាឧបសគ្គក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា?
- តើកត្តាអ្វីខ្លះនាំឲ្យមានការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា?
- តើនឹងទទួលបានផលប្រយោជន៍អ្វីខ្លះពីការអភិវឌ្ឍទីផ្សារមូលបត្របំណុល?

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

# ជំពូកទី១
# ទស្សនៈផ្សេងៗទាក់ទងនឹងទីផ្សារមូលបត្រ

## ១.១. អ្វីទៅជាមូលបត្រ

មូលបត្រ គឺជាគំរូប័ណ្ណដែលអាចដោះដូរជាសាធារណៈក្នុងទីផ្សារមូលបត្រ ឬលិខិតស្នាមទាំងឡាយណាដែលចេញដោយក្រុមហ៊ុនណាមួយ។

នៅក្នុងទីផ្សារហិរញ្ញវត្ថុបច្ចុប្បន្ន ការស្វែងយល់ឲ្យច្បាស់ពីពាក្យ មូលបត្រ (Securities) និង ភាគហ៊ុន (Stock)ហាក់មានភាពស្រពិចស្រពិលនៅក្នុងចំណោមមហាជនភាគច្រើន។ ជាទូទៅ ពាក្យទាំងពីរនេះត្រូវបានប្រើប្រាស់ជំនួសគ្នាបានដែលសំដៅលើក្រដាសមួយសន្លឹក ដែលប្រកាសភាពជាកម្មសិទ្ធិស្របច្បាប់នៅក្នុងក្រុមហ៊ុនណាមួយដែលឲ្យឈ្មោះថាវិញ្ញាបនបត្រទិញភាគហ៊ុន។

យ៉ាងណាមិញ និយាយឲ្យត្រឹមត្រូវតាមបច្ចេកទេស ពាក្យទាំងពីរនេះមានន័យខុសគ្នា។ តាមពិតពាក្យថា ភាគហ៊ុន (Stock) គ្រាន់តែជាផ្នែកមួយប៉ុណ្ណោះនៃ មូលបត្រ (Securities)។ នេះមានន័យថា ក្រៅពីភាគហ៊ុននៅមានប្រភេទមូលបត្រផ្សេងៗជាច្រើនទៀត ដែលគេយកមកធ្វើការទិញលក់នៅក្នុងទីផ្សារមូលបត្រដែរ ដូចជា មូលបត្របំណុល មូលបត្រជាវត្ថុធាតុដើម ឬជារូបិយវត្ថុ។[1] មូលបត្រនៅប្រទេសកម្ពុជាមាន ពីរប្រភេទ គឺ មូលបត្ររដ្ឋ និងមូលបត្រមហាជន។ (យោងតាមច្បាប់ស្តីពី "មូលបត្ររដ្ឋ និងមូលបត្រមហាជន")។

### ១.១.១. មូលបត្ររដ្ឋ

មូលបត្ររដ្ឋ សំដៅដល់ ប័ណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលនៅក្រោមច្បាប់ដែលមានដូចជា៖

- ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។
- សញ្ញាបណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ។
- សញ្ញាបណ្ណដែលផលចំណូលផ្សាភ្ជាប់នឹងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។
- មូលបត្ររដ្ឋផ្សេងៗដទៃទៀត។

[1] https://channyfx.blogspot.com/2017/03/stocks-shares.html

មូលបត្ររដ្ឋទាំងអស់ខាងលើនេះមិនរួមបញ្ចូលនូវមូលបត្រដែលបោះផ្សាយដោយអាជ្ញាធរខេត្ត ក្រុង និងសហគ្រាសសារធារណៈ ឬការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់នេះ។ ក្រៅពីនេះនៅមានប្រភេទមូលបត្ររដ្ឋមួយចំនួនទៀតដូចជា[2]៖

- **មូលបត្ររដ្ឋមិនអាចជួញដូរបាន** សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឲ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬសន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និងការកំណត់របស់ប្រកាសដែលដាក់ឲ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនមានសិទ្ធិស្នើសុំការទូទាត់សងមុនឥណប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ
- **វិញ្ញាបនបត្រមូលបត្ររដ្ឋ** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ដោយមានការធានានូវការបំពេញកាតព្វកិច្ចទូទាត់ពេញលេញពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានចែងអំពីរយៈពេល លក្ខខណ្ឌ និងកាតព្វកិច្ចផ្សេងៗទៀតរបស់មូលបត្រនោះ។
- **គណនី** សំដៅដល់គណនីទូទៅ និងគណនីពិសេសរបស់រតនាគារជាតិដូចមានចែងនៅក្នុងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ និងគណនីពិសេសផ្សេងទៀតដែលបានបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- **សន្តតិជន** សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

### ១.១.២. មូលបត្រមហាជន

មូលបត្រមហាជន (Non-government Securities) សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអនុលោមតាមច្បាប់។ មូលបត្រទាំងនោះមាន៖

1. មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន សំដៅដល់ផលប្រយោជន៍ ឬសិទ្ធស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនបោះផ្សាយ ដោយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ឬភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា។

[2] ជំពូកទី១នៃច្បាប់ស្តីពីមូលបត្ររដ្ឋ មាត្រា ២ ឆ្នាំ ២០០៧

2. មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាបណ្ណ សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុ ដែលបោះផ្សាយដោយបុគ្គលណាមួយ ដោយបញ្ជាក់ ឬទទួលស្គាល់បំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឲ្យប្រាក់ខ្ចី ឬទិញប័ណ្ណបំណុលនោះ ឬដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះហើយទោះបីជាមាន ឬគ្មានទ្រព្យធានាក្តី។
3. ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម សំដៅដល់ផលប្រយោជន៍ស្រប់ច្បាប់ទោះបីដោយផ្ទាល់ ឬនៅក្នុងគម្រោងវិនិយោគដែលមានលក្ខណៈដូចជា៖

- បុគ្គលផ្តល់វិភាគទានជាសាច់ប្រាក់ ឬផ្តល់វត្ថុមានតម្លៃដើម្បីមានសិទ្ធិទទួលផលកម្រៃដែលបានមកពីគម្រោងវិនិយោគរួម។
- រាល់វិភាគទានដែលប្រមូលបាន ហើយត្រូវបានយកទៅប្រើប្រាស់នៅក្នុងគម្រោងវិនិយោគដើម្បីបង្កើតផលកម្រៃហិរញ្ញវត្ថុ ឬផលកម្រៃដែលបានមកពីសិទ្ធិ ឬជាផលប្រយោជន៍លើទ្រព្យសម្បត្តិសម្រាប់សមាជិកដែលមានផលប្រយោជន៍ក្នុងគម្រោងវិនិយោគនោះ

4. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ ដែលទាក់ទងនឹងមូលបត្រមួយគឺយោងទៅលើចំណុច(1) (2) ឬ(3)ខាងលើ។
5. ឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលកំណត់ថាជាមូលបត្រ។[3]

## ១.២ ទីផ្សារមូលបត្រ

### ១.២.១. និយមន័យទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀតតាមនិយមន័យនៃច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើ ផ្ទេរ ឬការទិញ-លក់មូលបត្រ វាជាផ្នែកមួយនៃទីផ្សារហិរញ្ញវត្ថុដ៏ទូលំទូលាយដែលមូលបត្រអាចត្រូវបានទិញ-លក់ ជួញដូរក្នុងនៃបម្រើឲ្យសេដ្ឋកិច្ចដោយផ្អែកលើតម្រូវការ និងការផ្គត់ផ្គង់។ ផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយដោយវាអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរាជរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជនមកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម៉្យាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយមានជម្រើសក្នុងការធ្វើពិពិធកម្មវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ (ជាមួយមូលបត្រដែលមានហានិភ័យ

[3] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់មានលំហូរពីអ្នកមានទៅអ្នកដែលត្រូវការវាប្រកបដោយភាពពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជាផលិតកម្ម និងពាណិជ្ជកម្ម និងរីកលូតលាស់ទៅតាមនោះដែរព្រមទាំងបង្កើតឱ្យមានការងារ និងទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។

### ១.២.២. ប្រវត្តិទីផ្សារមូលបត្រ

ការសិក្សាអំពីការអភិវឌ្ឍទីផ្សារមូលបត្រនាពេលកន្លងមក គឺហាក់ដូចជាមិនសូវមានការយកចិត្តទុកដាក់ពីការផ្លាស់ប្តូរភាគហ៊ុនបុគ្គល ឬការសិក្សាអំពីព្រឹត្តិការណ៍ជាក់លាក់ដែលទាក់ទាញចំណាប់អារម្មណ៍របស់សាធារណជន។ ចំពោះអ្នកសង្កេតការជាច្រើនមិនថាពួកអ្នកនយោបាយឆ្វេងនិយម ឬស្តាំនិយមបានចាត់ទុកទីផ្សារមូលបត្រគឺជាមជ្ឈមណ្ឌលដែលមានការចូលរួមរកស៊ី ឬវិនិយោគយ៉ាងតិចតួចបំផុតដែលត្រូវបានគិតថាតម្លៃអាចឡើងចុះ ហើយមានការក្លែងបន្លំយ៉ាងច្រើនពីអន្តរការី។ ប៉ុន្តែលោក Raines បានយល់ឃើញថាផ្សារភាគហ៊ុន គឺជាចំណុចដ៏សំខាន់បំផុតនៃមូលធននិយម។ ដោយសារមុខងារទីផ្សារមូលបត្រ គឺជាវេទិកាសម្រាប់ជួញដូរមូលបត្រនៅពេលដែលមូលបត្រត្រូវបានចេញផ្សាយ ហើយនេះជាចំណុចដែលមូលបត្រទាំងនោះត្រូវបានចាប់ផ្តើមទទួលស្គាល់។

មានសំណួរមួយបានសួរថា តើផ្សារមូលបត្រពិតជាបានជំរុញកំណើតសេដ្ឋកិច្ចរបស់ប្រទេសមួយក្នុងពេលវេលាជាក់លាក់ ឬសេដ្ឋកិច្ចពិភពលោកទាំងមូលឬទេ? ទីផ្សារមូលបត្រត្រូវបានគេស្គាល់ថា បានអនុវត្តមុខងារជាក់លាក់មួយចំនួន ប៉ុន្តែទាំងនេះគឺមានភាគច្រើននៅក្នុងវិស័យនៃការបញ្ចូលសញ្ញាតាមរយៈយន្តការកំណត់តម្លៃរបស់ពួកគេដោយសម្រួលដល់ការផ្ទេរការគ្រប់គ្រងនៅក្នុងសេដ្ឋកិច្ចសាជីវកម្មដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច។ ចំណុចល្អរបស់ផ្សារមូលបត្រដែលត្រូវបានគេមើលឃើញថា ជាកន្លែងរកដើមទុនសម្រាប់តម្រូវការនៃដំណើរការសាជីវកម្ម។ នេះរួមបញ្ចូលទាំងការសិក្សាអំពីការអភិវឌ្ឍន៍ និងតួនាទីរបស់ផ្សារមូលបត្រប្រសិនបើមានការយល់ដឹងពិតប្រាកដអំពីវិធីនៃប្រព័ន្ធហិរញ្ញវត្ថុកំពុងដំណើរការ។ ទីផ្សារមូលបត្របានដើរតួនាទីផ្សេងៗគ្នានៅក្នុងប្រទេសនីមួយៗតាមពេលវេលាផ្សេងៗគ្នាដែលឆ្លុះបញ្ចាំងពីរបៀបដែលពួកគេត្រូវបានរៀបចំទំនាក់ទំនងរបស់ពួកគេក្នុងផ្នែកផ្សេងៗគ្នា។ មានការពិចារណាលើ ផលវិបាករយៈពេលវែងសម្រាប់ទីផ្សារមូលបត្ររបស់សហរដ្ឋអាមេរិកនៅពេលដែលច្បាប់ស្តីពី Glass-Steagall ត្រូវបានអនុវត្តនៅទសវត្សរ៍ឆ្នាំ ១៩៣០ បន្ទាប់មកយើងអាចសន្និដ្ឋានបានអំពីតួនាទីរបស់ទីផ្សារមូលបត្រក្នុងការលើកកម្ពស់ឬសម្របសម្រួលកំណើនសេដ្ឋ-កិច្ចជាទូទៅ។(C.Michie, 2006)

ដំណើរការនៃការបង្កើតទីផ្សារភាគហ៊ុន បានចាប់ផ្តើមតាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុនត្រូវបានចាប់ផ្តើមឡើងនៅពេលដែលបណ្តាប្រទេសនៅក្នុងទ្វីបអាមេរិក បានចាប់ផ្តើមធ្វើពាណិជ្ជកម្ម ជាមួយប្រទេសដទៃទៀតដែលមានដូចជា ហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុបមានបំណងចាប់ផ្តើមអាជីវកម្មទំហំធំ ដែលទាមទាឲ្យមានចំនួនទឹកប្រាក់ច្រើន តែពុំមានឈ្មួញណាម្នាក់មានប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំបានតែម្នាក់ឯងនោះទេ។ ជាលទ្ធផល វិនិយោគិន បានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួមហើយបានក្លាយទៅជាដៃគូអាជីវកម្ម និងជាសហាកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួននៅក្នុងអាជីវកម្មមួយដែលមានទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុនដែលមានកំណើតនៅក្នុងប្រទេសហូឡង់ បានក្លាយជាគំរូអាជីវកម្មមួយសម្រាប់អាជីវកម្មដទៃដែលកំពុងជួបផលវិបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ ១៦០២ ក្រុមហ៊ុន ឌឺ ឌាយហ៍ អីស ឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុនជាលើកដំបូង។ ឧបករណ៍ដែលអាចជួញដូរបាននេះអនុញ្ញាតឲ្យភាគហ៊ុ-និក មានភាពងាយស្រួលក្នុងការទិញ-លក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួនជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។

គំនិតនេះ ទទួលបានជោគជ័យដោយការលក់ភាគហ៊ុនបានរីករាលដាលដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀត ដូចជា ប្រទេស ព័រទុយហ្គាល់ អេស្ប៉ាញ និងបារាំង។ នៅទីបំផុតការអនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។

ឧស្សាហកម្មដទៃទៀតក្នុងអំឡុងពេលបដិវត្តឧស្សាហកម្ម បានចាប់ផ្តើមប្រើការលក់ភាគហ៊ុនជាវិធីដើម្បីប្រមូលមូលធនសម្រាប់ការធ្វើអាជីវកម្ម។ ការហូរចូលនៃមូលធននេះបានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុនបានជំរុញឲ្យ មានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផល ពាណិជ្ជករភាគហ៊ុនបានសម្រេចចិត្តទៅជួបគ្នានៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមកហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ ១៧៧៣។

ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនដំបូងគេ។ គំនិតនៃការរៀបចំបែបនេះក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្តើមនៅទីក្រុងភីឡាឌែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០។[4]

### ១.២.៣. រចនាសម្ព័ន្ធទីផ្សារមូលបត្រ

របៀបដែលទីផ្សារមូលបត្រមានដំណើរការប្រកបដោយប្រសិទ្ធិភាព គឺវាពឹងផ្អែកទៅលើរចនាសម្ព័ន្ធទីផ្សារដែលត្រូវបានកំណត់ដោយសំណុំនៃការជួញដូរមូលបត្រនៅក្នុងទីផ្សារ។(JENNIFER HUANG, JIANG WANG, 1997) រចនាសម្ព័នទីផ្សារមូលបត្រត្រូវបានបែងចែកតាមផលិតផល គឺទីផ្សារមូលបត្រកម្មសិទ្ធិ ទីផ្សារមូលបត្របំណុល យន្តការទីផ្សារក្នុងការជួញដូរមូលបត្រ និងទីកន្លែងជួញដូរ៖

#### ក. ទីផ្សារមូលបត្រកម្មសិទ្ធិ

ទីផ្សារមូលបត្រកម្មសិទ្ធិ គឺសំដៅដល់ទីកន្លែងដែលប្រមូលផ្តុំទៅដោយការជួញដូរ ទិញ-លក់ភាគហ៊ុនរបស់ក្រុមហ៊ុនដែលចេញផ្សាយជាសាធារណៈ ដែលធ្វើឡើងតាមរយៈទីផ្សារប្រតិស្រុត (OEM) ឬទីផ្សាររំលងបញ្ជា (OTC Market) ដែលធ្វើប្រតិបត្តិការក្រោមបទបញ្ជាដែលបានកំណត់។ វាជាទីផ្សារមួយដើរតួនាទីដ៏សំខាន់ក្នុងចំណោមទីផ្សារផ្សេងទៀត ដែលជួញដូរផលិតផលទ្រព្យកម្មសិទ្ធិ ដែលជាមូលបត្របោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ជាសាធារណៈ ដើម្បីកៀរគរមូលនិធិពីសាធារណជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឲ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិកគឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួល នូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ មានមូលបត្រ២ប្រភេទ ដែលអាចដាក់ជួញដូរនៅលើផ្សារមូលបត្រកម្មសិទ្ធិ៖

- **ភាគហ៊ុនធម្មតា (Common stock)** គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈ ភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។ វាបានផ្តល់ឲ្យម្ចាស់ភាគ

[4] គណៈកម្មាការមូលបត្រកម្ពុជា, ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយ លេខ ២ ខែមករា ឆ្នាំ២០១៧

ហ៊ុននូវសិទ្ធិបោះឆ្នោត និងសិទ្ធិក្នុងការទទួលបាននូវភាគលាភតាមទំហំនៃប្រាក់ចំណេញប្រតិបត្តិការណ៍របស់ក្រុមហ៊ុន។[5]

- **ភាគហ៊ុនបុរិមា (Preferred Stock)** ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ វាសំដៅដល់ភាគហ៊ុនដែលផ្តល់ឲ្យអ្នកទិញមានសិទ្ធិទទួលបានភាគលាភថេរ ដែលមិនអាស្រ័យលើទំហំនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនទេ។ ភាពខុសគ្នារវាងភាគហ៊ុនបុរិមា និងភាគហ៊ុនធម្មតាគឺ អ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា តែមិនទទួលបានសិទ្ធិបោះឆ្នោត ឬសិទ្ធិដើម្បីបញ្ចេញមតិយោបល់ក្នុងការសម្រេចរាល់កិច្ចការផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។[6]

### ខ. ទីផ្សារមូលបត្របំណុល

ទីផ្សារមូលបត្របំណុល គឺសំដៅទៅលើទីកន្លែងដែលធ្វើការជួញដូរមូលបត្របំណុល ឬជាប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើទិញ-លក់ ឬផ្ទេរមូលបត្របំណុល។ វាគឺជាទីផ្សារដែលធ្វើការជួញដូរប្រភេទមូលបត្របំណុល ឬសញ្ញាបណ្ណ ដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឲ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងតែសញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "តណាប្រទិទាន"។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុន ឬអង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឲ្យវិនិយោគិនដោយផ្ទាល់តាមរយៈ ទីផ្សារមូលបត្របំណុលនៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីបន្តប្រតិបត្តិការក្រុមហ៊ុន ឬដើម្បីទូទាត់បំណុល។

បច្ចុប្បន្ន នៅផ្សារមូលបត្រកម្ពុជាមានតែប្រភេទសញ្ញាបណ្ណសាជីវកម្មមួយប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនៅ **ផ.ម.ក.** ដោយសារតែមិនទាន់មាន សញ្ញាបណ្ណរដ្ឋ។ សញ្ញាបណ្ណសាជីវកម្ម ជាប្រភេទមួយនៃមូលបត្របំណុលដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈចេញដោយ **គ.ម.ក.** សញ្ញាបណ្ណសាជីវកម្មអាចចែកចេញជា៖[7]

---
[5] http://csx.com.kh/kh/product/equities.jsp?MNCD=4020
[6] http://csx.com.kh/kh/product/equities.jsp?MNCD=4020
[7] http://www.csx.com.kh/kh/product/bond.jsp?MNCD=4040

១. សញ្ញាបណ្ណធម្មតា ( Plain Vanilla Bond) សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ កំណត់តណប្រតិទានជាមុននៅ កាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រលប់ (Call Option) ឬ សិទ្ធិលក់ (Put Option) និងមិនមានការធានា។

២.សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond) សំដៅដល់សញ្ញាបណ្ណដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើមនឹងត្រូវបានទូទាត់សងដោយភាគីទីបី ដែលជានីតិបុគ្គលករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជាអសាធនភាព ឬក្ស័យធន។

៣.សញ្ញាបណ្ណមានវត្ថុធានា (Secured Bond) សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែ មូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

**គ. យន្តការទីផ្សារក្នុងការជួញដូរមូលបត្រ**

មុនពេលរៀបរាប់លំអិតអំពីលក្ខណៈនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ វាជាការសំខាន់ណាស់ដើម្បីបញ្ជាក់ភាពខុសគ្នារវាងទីផ្សារដំបូង និងទីផ្សារបន្ទាប់។ ភាគច្រើននៃទីផ្សារដ៏ពេញនិយមដូចជាផ្សារហ៊ុនញូវយ៉ក និងទីផ្សារភាគហ៊ុនតូក្យូជាទីផ្សារបន្ទាប់ដែលមូលបត្រមានស្រាប់ត្រូវបានជួញដូររវាងបុគ្គលនិងស្ថាប័ន ឬវិនិយោគិនសាធារណៈ និងវិនិយោគិនសារធារណៈ។[8]

- **ទីផ្សារដំបូង (Primary Market)** គឺជាផ្នែកមួយនៃទីផ្សារមូលធន ដែលវាជាកន្លែងដែលមូលបត្រត្រូវបានជួញដូរជាលើកដំបូងពីក្រុមហ៊ុនបោះផ្សាយទៅអ្នកវិនិយោគសារធារណៈ ដែលទាក់ទងនឹងការចេញលក់មូលបត្រ ដែលផ្តល់ភាគលាភដល់អ្នកវិនិយោគដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយលក់ភាគហ៊ុន។ វិនិយោគិនធ្វើការទិញមូលបត្រដែលមិនធ្លាប់បានជួញដូរពីមុនមកពីក្រុមហ៊ុនបោះផ្សាយផ្ទាល់ជាលើកដំបូងនៅក្នុងទីផ្សារនេះ។ រាល់មូលធនដែលប្រមូលបានពីការលក់មូលបត្រ ត្រូវបានទៅដល់ក្រុមហ៊ុនបោះផ្សាយផ្ទាល់សម្រាប់ដំណើរការនៃការវិនិយោគ។ គោលបំណងសំខាន់នៃការបោះផ្សាយភាគហ៊ុនលក់ក្នុងទីផ្សារដំបូងគឺ៖
  - ដើម្បីផ្តល់មូលធនដល់ក្រុមហ៊ុនថ្មី
  - ដើម្បី ពង្រឹង និងពង្រីកក្រុមហ៊ុនដែលមានស្រាប់

[8] Chapter 6, The Structure and Performance of Securities Markets, Page 97, 98

- ដើម្បីធ្វើពិពិធកម្មផលិតកម្ម
- ដើម្បីបំពេញតាមតម្រូវការទុនបង្វិលជាប្រចាំដែលត្រូវការ
- ដើម្បីទុកធ្វើជាទុនបម្រុង

➢ **ទីផ្សារបន្ទាប់ (Secondary Market)** គឺជាទីផ្សារហិរញ្ញវត្ថុរយៈពេលវែងដែលធ្វើការជួញដូរមូលបត្រដូចជា សញ្ញាបណ្ណ ភាគហ៊ុនធម្មតា ភាគហ៊ុនបុរិមា និងភាគហ៊ុនផ្សេងៗទៀត ដែលបានបោះផ្សាយលក់នៅក្នុងទីផ្សារដំបូងម្តងរួចមកហើយ។ ដែលធ្វើការជួញដូរទៅវិញទៅមករវាងវិនិយោគិនសាធារណៈ និងវិនិយោគិនសាធារណៈផ្សេងទៀត ដោយពុំមានការចូលរួមពីក្រុមហ៊ុនបោះផ្សាយមូលបត្រទេ ហើយក្រុមហ៊ុនបោះផ្សាយនឹងមិនទទួលបានទឹកប្រាក់ដែលបានមកពីការជួយដូរនោះឡើយ។ មូលបត្រដែលបានចរាចរនៅលើទីផ្សារត្រូវបានជួញដូរនៅក្នុងទីផ្សារបន្ទាប់ ដែលគេបានដឹងជាទូទៅថាជាផ្សារហ៊ុនដែលមានដើមទុនដ៏ច្រើនលើសលប់។ (Mr. Siddharth Bagri, Mr. G.C. Sharma, Mr. Ashok Wadhwa, Mr. Ramakara Jha, Mr. A. Palanivel, 2007, p. 108) ។ រាល់ការជួញដូរមូលបត្រត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រ និងប្រតិបត្តិករទីផ្សារមូលបត្រដែលដើរតួយ៉ាងសំខាន់ក្នុងការជានាឲ្យមាននូវសន្ទនីយភាពមូលបត្រខ្ពស់ (High Liquidity) តម្លាភាព (Transparency) ភាពនៃការជួញដូរ ភាពត្រឹមត្រូវនៃការកំណត់ថ្លៃមូលបត្រ ព្រមទាំងកាត់បន្ថយប្រតិបត្តិការជួញដូរ ព្រោះការផ្តល់ព័ត៌មានមានភាពច្បាស់លាស់ និងទាន់ពេលវេលាទាក់ទងនឹងថ្លៃ និងបរិមាណមូលបត្រដែលជួញដូរជាដើម។

ទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រ នឹងអនុញ្ញាតឲ្យមានការជួញដូរនៅលើទីផ្សារបន្ទាប់ តាមរយៈប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងនីតិវិធីពាក់ព័ន្ធ ដើម្បីឲ្យអ្នកចូលរួមនៅក្នុងទីផ្សារអាចទទួលបានសិទ្ធិក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនេះ។[9]

➢ **ទំនាក់ទំនងរវាងទីផ្សារដំបូង និងទីផ្សារបន្ទាប់ គឺ**

- ទីផ្សារដែលទើបតែបង្កើតមិនអាចដំណើរការបានទេបើគ្មានទីផ្សារបន្ទាប់។ ទីផ្សារបន្ទាប់ឬផ្សារហ៊ុនផ្តល់ភាពងាយស្រួលក្នុង ការបំលែងជាសាច់ប្រាក់នៃមូលបត្រដែលបានចេញលក់ ដែលត្រូវបានជួញដូរនៅទីផ្សារបន្ទាប់។

[9] ហេង ធានី ចាន់ ហួរ, *ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា*,(ភ្នំពេញ ២០១២) ទំព័រ ១៥

- ការជួញដូរភាគហ៊ុនតាមរយៈលក្ខខណ្ឌចុះបញ្ជីរបស់ពួកគេ នឹងត្រូវគ្រប់គ្រងសកម្មភាពដោយទីផ្សារដំបូង។ ក្រុមហ៊ុនស្វែងរកការចុះបញ្ជីនៅផ្សារហ៊ុននីមួយៗត្រូវគោរពតាមបទបញ្ជា និងបទប្បញ្ញត្តិទាំងអស់ដែលផ្តល់ដោយផ្សារមូលបត្រ។
- ទីផ្សារដំបូងផ្តល់នូវទំនាក់ទំនងដោយផ្ទាល់រវាងវិនិយោគិនសាធារណៈ និងក្រុមហ៊ុនបោះផ្សាយភាគហ៊ុន។ តាមរយៈការផ្តល់សាច់ប្រាក់ងាយ និងសុវត្ថិភាពផ្សារហ៊ុនលើកទឹកចិត្តសាធារណជនវិនិយោគទៅលើមូលបត្រថ្មីៗ។ សមត្ថភាពទីផ្សារ និងការបង្កើនដើមទុនដែលផ្តល់ឱ្យនៅក្នុងទីផ្សារហ៊ុន គឺជាកត្តាសំខាន់ដែលទាក់ទាញសាធារណជនដែលវិនិយោគទៅរកទីផ្សារភាគហ៊ុន។ ដូច្នេះវាផ្តល់នូវទំនាក់ទំនងដោយប្រយោលរវាងអ្នកសន្សំនិងក្រុមហ៊ុន។
- ថ្វីបើផ្សារទាំងពីនេះបំពេញឲ្យគ្នាទៅវិញទៅមកក៏ដោយ តែមុខងារ និងការរៀបចំរបស់ផ្សារទាំងពីរនេះគឺខុសពីគ្នា។ ភាពរបស់ទីផ្សារដំបូង គឺពឹងផ្អែកលើទីផ្សារបន្ទាប់។ (Mr. Siddharth Bagri, Mr. G.C. Sharma, Mr. Ashok Wadhwa, Mr. Ramakara Jha, Mr. A. Palanivel, 2007)

### ឃ. ទីកន្លែងជួញដូរ

ទីកន្លែងក្នុងការជួញដូរមូលបត្រត្រូវបានគេកំណត់ជាពីប្រភេទ គឺទីផ្សារមូលបត្រប្រតិស្រុត និងទីផ្សារមូលបត្ររំលងបញ្ជរ៖[10]

- **ទីផ្សារមូលបត្រប្រតិស្រុត (Organized Exchange Market)** គឺសំដៅទៅលើទីផ្សារដែលមានទីតាំងច្បាស់លាស់សម្រាប់ឲ្យអ្នកទិញ និងអ្នកលក់បានជួបគ្នា ដើម្បីធ្វើការជួញដូរនូវឧបករណ៍ហិរញ្ញវត្ថុបានតាមរយៈការបញ្ជាទិញ ឬដេញថ្លៃមូលបត្រ។ ដែលទីផ្សារនេះស្ថិតក្រោមការគ្រប់គ្រងត្រួតពិនិត្យពីសំណាក់អាជ្ញាអាណាព្យាបាលនៃវិស័យមូលបត្រ។

ជាក់ស្តែងគណៈកម្មការមូលបត្រកម្ពុជា គឺដើរតួនាទីជាអាជ្ញាអាណាព្យាបាល ដោយត្រួតពិនិត្យរាល់កិច្ចប្រតិបត្តិការទាំងអស់នៅក្នុងទីផ្សារមូលបត្រ។ ស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យមូលបត្រត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាត ឬទទួលបានការអនុញ្ញាតពី **គ.ម.ក.** មុននឹងអាចធ្វើប្រតិបត្តិការអាជីវកម្មបាន។ ក្នុងទីផ្សារនេះ **គ.ម.ក.** បានបង្កើត និងរៀបចំនូវច្បាប់ បទប្បញ្ញត្តិ និងវិធានការនានាយ៉ាងតឹងរឹងដែលធានាឲ្យបាននូវសណ្តាប់ធ្នាប់ សុវត្ថិភាព ភាព តម្លាភាពនៃការផ្សព្វផ្សាយ និងទទួលបានព័ត៌មានជាសាធារណៈ (Public Disclosure) ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់វិនិ-

[10] ហេង ធានី ចាន់ ហួរ, *ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា*,(ភ្នំពេញ ២០១២) ទំព័រ ១៥

យោគិនក្នុងការសម្រេចចិត្តវិនិយោគ។ កត្តាទាំងនេះជាធាតុដ៏សំខាន់ដែលជំរុញដល់ការប្រព្រឹត្តទៅដោយរលូននៃប្រតិបត្តិការ ទិញ-លក់ មូលបត្រនៅលើទីផ្សារ។

- **ទីផ្សាររំលងបញ្ជរ (OTC Market)** សំដៅទៅលើទីផ្សារដែលជួញដូរឧបករណ៍ហិរញ្ញវត្ថុដោយគ្មានកន្លែងច្បាស់លាស់ ហើយរាល់មូលបត្រដែលត្រូវបានបោះផ្សាយសម្រាប់ការជួញដូរមិនត្រូវបានចុះបញ្ជីលក់នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រឡើយ។ ក្នុងទីផ្សារនោះឈ្មួញជើងសាមូលបត្រ (Securities Broker) ត្រៀមខ្លួនជាស្រេចដើម្បី ទិញ-លក់ ទៅឲ្យអ្នកណាដែលធ្វើការទាក់ទងមកពួកគេហើយយល់ព្រមយកតម្លៃដកស្រង់ (Quoted Price) ណាមួយដែលច្រើនតែប្រព្រឹត្តទៅតាមប្រព័ន្ធអេឡិចត្រូនិច (Electronic Market) ។

## ១.៣. អត្ថប្រយោជន៍ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ គេតែងនិយាយថា ទីផ្សារមូលបត្រ គឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិទាំងមូល។ ជាការពិតណាស់រាល់បម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ចសង្គម និងនយោបាយ) វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សាមូលបត្រភ្លាមៗ ដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ចយ៉ាងណា ពីព្រោះសន្ទស្សន៍ហ៊ុនរបស់ទីផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះ ស្ទើរតែគ្រប់បណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍទាំងអស់មានទីផ្សារមូលបត្រនេះ ហើយវាបានដើរតួយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ច។

### ១.៣.១.ចំពោះសេដ្ឋកិច្ច[11]

ទីផ្សារមូលបត្រមានសារៈប្រយោជន៍យ៉ាងខ្លាំង ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយវាជាឧបករណ៍មួយសម្រាប់ឲ្យរដ្ឋាភិបាលអនុវត្តកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនយកទៅប្រើប្រាស់ឲ្យចំទិសដៅ។ អត្ថប្រយោជន៍ដែលសេដ្ឋកិច្ចទទួលបានពីទីផ្សារមូលបត្រមានដូចខាងក្រោម៖

- ជំរុញការវិនិយោគ និងបង្កើនការងារ៖ ទីផ្សារមូលបត្រជំរុញឲ្យក្រុមហ៊ុនធ្វើការវិនិយោគ និងពង្រីកអាជីវកម្មបន្ថែមតាមរយៈការបោះផ្សាយលក់មូលបត្រដើម្បីបង្កើនដើមទុន។ ការកើនឡើងនៃការវិនិយោគរបស់ក្រុមហ៊ុនទាំងនោះនឹងផ្តល់ការងារដល់ប្រជាជនក្នុងស្រុកដែលក្នុងន័យនេះអត្រាអត់ការងារធ្វើនឹងត្រូវកាត់បន្ថយ។

[11] អ៊ឹង អ៊ូ, គុណសម្បត្តិ និងគុណវិបត្តិរបស់ទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ (ភ្នំពេញ, ០៦ មករា ២០១២)

- ជំរុញឲ្យមហាជនបង្កើននូវការសន្សំ និងការវិនិយោគ៖ ទីផ្សារមូលបត្រផ្តល់នូវឱកាសនៃការវិនិយោគដ៏ទាក់ទាញតាមរយៈ ភាគហ៊ុនរបស់ក្រុមហ៊ុនជាច្រើននៅក្នុងទីផ្សារដែលឱកាសនេះលើកទឹកចិត្តប្រជាជនឲ្យមានការសន្សំច្រើនជាងមុន និងជំរុញឲ្យប្រជាជនធ្វើការវិនិយោគក្នុងទីផ្សារមូលបត្រ ជាជាងការយកប្រាក់ទៅទុកទំនេរចោល ឬយកទៅវិនិយោគលើទ្រព្យដែលគ្មានផលិតកម្មដូចជា មាស ឬប្រាក់ជាដើម ការវិនិយោគអាចបង្កើនចំណូលប្រជាជនដែលនេះជាកត្តាជំរុញកំណើនសេដ្ឋកិច្ចជាតិ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគនៅក្នុងសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រ គឺជាមធ្យោបាយមួយ សម្រាប់ប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយសម្រាប់ទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស ។
- ទីផ្សារមូលបត្រជួយជំរុញឲ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធិភាព និងមានតម្លាភាព។
- ទីផ្សារមូលបត្រជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។

### ១.៣.២.ចំពោះវិនិយោគិន

ទីផ្សារមូលបត្រ គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិននានាក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។ ហេតុនេះហើយបានជាគ្រប់ប្រទេសទាំងអស់លើពិភពលោកមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ខ្លាំងក្នុងការបង្កើត និងអភិវឌ្ឍទីផ្សារនេះឲ្យមានការរីកចម្រើន ហើយធានាសក្តានុពលនៃប្រព័ន្ធហិរញ្ញវត្ថុឲ្យមានភាពរឹងមាំ និងចីរភាព ក្នុងទិសដៅរក្សានូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច។តាមរយៈទីផ្សារមូលបត្រនេះវិនិយោគិនក៏ទទួលបានផលប្រយោជន៍ជាច្រើនដូចជា៖

- **ប្រាក់ចំណេញមូលធន (Capital Gains)** អត្ថប្រយោជន៍ចម្បងនៃការវិនិយោគនៅក្នុងទីផ្សារភាគហ៊ុននេះ គឺជាឱកាសលូតលាស់ប្រាក់របស់អ្នកវិនិយោគដោយការកើនឡើង

តម្លៃនៃទ្រព្យសកម្មមួយចាប់ពីពេលទិញរហូតដល់ពេលលក់។ ប្រាក់ចំណេញដែលជាលទ្ធផលនៅពេលថ្លៃរបស់មូលបត្រកម្មសិទ្ធិដែលកាន់កាប់ដោយអ្នកវិនិយោគកើនឡើងលើថ្លៃដែលបានទិញរហូតដល់មូលបត្រកម្មសិទ្ធិ នោះត្រូវបានលក់ចេញ។ ដូច្នេះ ការវិនិយោគនៅក្នុងក្រុមហ៊ុន ដែលមានស្ថិរភាពល្អអាចធ្វើឲ្យប្រាក់ចំណេញរបស់វិនិយោគិនមានការកើនឡើង។[12]

- **ចំណូលភាគលាភ ឬការប្រាក់ (Dividend or Interesr)** ការវិនិយោគលើមូលបត្រ និងទទួលបានភាគលាភ ឬការប្រាក់ ពីប្រភេទនៃការវិនិយោគក្នុងផ្សារមូលបត្រ. ភាគលាភគឺសំដៅដល់ការបែងចែកផ្នែកមួយនៃប្រាក់ចំណេញ ទៅឲ្យភាគហ៊ុននិកដែលបានសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហើយជាធម្មតាត្រូវទូទាត់ក្នុងទម្រង់ជាសាច់ប្រាក់ ឬទទួលបានភាគហ៊ុនបន្ថែម ឬទ្រព្យផ្សេងៗទៀត ។ ការប្រាក់ គឺសំដៅលើចំនួនទឹកប្រាក់ ដែលបានផ្តល់ទៅឲ្យម្ចាស់បំណុលតាមភាគរយដែលក្រុមហ៊ុនបោះផ្សាយ បានកំណត់ក្នុងកិច្ចសន្យានៃសញ្ញាបណ្ណសាជីវកម្មរៀងរាល់អំឡុងពេលជាក់លាក់ និងមានចំនួនថេរ។ ដូចនេះវិនិយោគិននឹងទទួលបានផលចំណេញជាភាគលាភ ឬការប្រាក់ បន្ទាប់ពីបានទិញមូលបត្រកម្មសិទ្ធិ ឬប័ណ្ណបំណុល ពីក្រុមហ៊ុនបោះផ្សាយតាមគោលការរបស់ក្រុមហ៊ុន។
- **ពិពិធកម្ម (Diversification)** សម្រាប់វិនិយោគិនដែលបានដាក់ប្រាក់វិនិយោគទៅក្នុងប្រភេទផ្សេងៗគ្នានៃការវិនិយោគលើផ្សារមូលបត្រ នឹងទទួលបានផលប្រយោជន៍ជាច្រើនពីពិពិធកម្ម។ ពិពិធកម្ម មានន័យថាការយកទុនទៅវិនិយោគក្នុងទម្រង់ផ្សេងៗគ្នាដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុល ក្នុងគោលបំណងកាត់បន្ថយហានិភ័យនៃការវិនិយោគលើមូលបត្រ។
- **ភាពជាម្ចាស់កម្មសិទ្ធិ ឬម្ចាស់បំណុល (Ownership or creditor)** ការទិញភាគហ៊ុនមានន័យថាទទួលយកបង្គោលកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនដែលវិនិយោគិនបានទិញ។ ការវិនិយោគនៅក្នុងទីផ្សារមូលបត្រ ក៏បាននាំមកនូវផលប្រយោជន៍នៃការធ្វើជាម្ចាស់កម្មសិទ្ធិដែលហៅថាភាគហ៊ុនិក ឬម្ចាស់បំណុល។ ភាគហ៊ុនិក មានសិទ្ធិបោះឆ្នោតរើស ឬដកហូតសមាជិកក្រុមប្រឹក្សាភិបាល និងការសម្រេចចិត្តផ្លាស់ប្តូរឯកសារចុះបញ្ជីរបស់ក្រុមហ៊ុន។

[12] មាស លីដាវ៉ាន់ វល័ក្ខណ៍, *ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជា*(ភ្នំពេញ ២០១៦) ទំព័រ១១,១២

- **ទទួលបានការលើកទឹកចិត្តពន្ធដារ (Tax Incentive)** ជាពិសេសសហគ្រាសធុនតូច និងមធ្យមក៏អាចទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធដារផងដែរ ដោយយោងតាមអនុក្រឹត្យស្តីពី "**ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាពរាជរដ្ឋាភិបាល**" បានចែងថាសហគ្រាសដែលបានចុះបញ្ជីថ្មីបច្ចុប្បន្នកម្មក្នុងការចុះបញ្ជីពន្ធដាររួចរាល់ នឹងទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលចំនួន ៣ឆ្នាំ ហើយសហគ្រាសក៏ទទួលបានការលើកទឹកចិត្តរហូតដល់ ៥ឆ្នាំទៀត បើសហគ្រាសនោះបំពេញនូវលក្ខខណ្ឌបន្ថែមដែលបានចែងក្នុងអនុក្រឹត្យរួមមាន៖
- ប្រើវត្ថុធាតុដើមក្នុងស្រុកចាប់ពី ៦០% ឡើងទៅ ឬ
- បង្កើនចំនួនវិនិយោជិតបន្ថែមយ៉ាងតិច ២០% ឬ
- មានទីតាំងក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម (SME Cluster)។

## ១.៤. គុណវិបត្តិរបស់ទីផ្សារមូលបត្រ[13]

ទោះជាទីផ្សារមូលបត្រ មានគុណសម្បត្តិដ៏សំខាន់សម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិក៏ដោយ ក៏មានគុណវិបត្តិមួយចំនួនដែរ ជាពិសេសបណ្តាប្រទេសមានប្រព័ន្ធច្បាប់អន់ខ្សោយដែលតែងតែជួបប្រទះនូវបញ្ហាដូចជា៖

- ការឆក់ឱកាសកេងចំណេញក្នុងការជួញដូរ (speculation) គឺជាការទិញ-លក់មួយដែលមានការគិតគូរយ៉ាងហ្មត់ចត់ ដើម្បីទទួលបានផលចំណេញដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការជួញដូរនេះអាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុបន្ន ដោយរំពឹងថានាពេលអនាគតនឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការជួញដូររបៀបនេះវានិងបង្កឲ្យមាន ឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះធ្វើឲ្យមានភាពងាយស្រួលនៅពេលពួកគេព្រមព្រៀងគ្នាក្នុងការជួញដូរ ដែលនាំឲ្យស្ថានភាពនៅលើទីផ្សារនៅពេលខ្លះធ្វើឲ្យភាគហ៊ុនខ្វះ ឬលើសហើយធ្វើឲ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។
- ការជួញដូរផ្ទៃក្នុង គឺមានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុនដើម្បីធ្វើការជួញដូរភាគហ៊ុន ដើម្បីស្វែងរកចំណេញរបស់

[13] https://khemsaritheducation.wordpress.com

ខ្លួនដែលមានឥទ្ធិពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសារធារណៈ (ព័ត៌មានសម្ងាត់)។

- ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកល់ក្នុងទីផ្សារ គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឲ្យ មានលក្ខណៈក្លែងបន្លំ ឬនាំឲ្យមានការយល់ខុសចំពោះការជួញដូរមូលបត្រ ឬធ្វើប្រត្តិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។
- សេចក្តីថ្លែងការណ៍ ការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលមានការយល់ដឹងខុសធ្ងន់ធ្ងរដែលបណ្តាលឲ្យសាធារណៈជនទិញលក់មូលបត្រ ឬបណ្តាលឲ្យមានការកើនឡើងឬនៅថេរចំពោះតម្លៃនៃការជួញដូរនៅលើទីផ្សារមូលបត្រ។
- ក្រុមហ៊ុនដែលបោះពុម្ពផ្សាយលក់មូលបត្រតម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចអាជីវកម្មល្អដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុម-ហ៊ុន ប៉ុន្តែក្រុមហ៊ុនទទួលបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

## ១.៥. អ្នកចូលរួមក្នុងទីផ្សារមូលបត្រ

បច្ចុប្បន្នអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

### ១.៥.១.តួអង្គក្នុងទីផ្សារដំបូង

#### ១.៥.១.១. គណៈកម្មការមូលបត្រកម្ពុជា[14]

គណៈកម្មការមូលបត្រកម្ពុជា **គ.ម.ក.** ជាស្ថាប័នដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ **គ.ម.ក.** ត្រូវបានធ្វើឡើងដោយ អនុលោមតាមអនុ-ក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។

**គ.ម.ក.** ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយ សណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ គណៈគម្មការមូលបត្រកម្ពុជា ជាអ្នកពិនិត្យ

[14] គេហទំព័រគណៈកម្មការមូលបត្រកម្ពុជា

ពាក្យស្នើសុំ និងឯកសារពាក់ព័ន្ធនឹងការសុំបោះផ្សាយលក់មូលបត្រជាលើកដំបូងរបស់ក្រុមហ៊ុនចុះបញ្ជី ដែលមានតួនាទី និងគោលបំណងដូចជា៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជំរុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ និងបង្ការនិងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

#### ១.៥.១.២. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺសំដៅលើក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលបានស្នើសុំ ឬអនុញ្ញាតឲ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ។

- **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (Public Limited Company)** សំដៅលើក្រុមហ៊ុនដែលបានបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- **នីតិបុគ្គលប្រតិស្រុត (Permitted Entity)** សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់នេះ និងបទប្បញ្ញាត្តិផ្សេងៗ។ នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជា។[15]

[15] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន (សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ), ឆ្នាំ២០០៧

### ១.៥.១.៣. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រ ជាក្រុមហ៊ុនសហកម្មសិទ្ធិដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រ ដែលមានតួនាទីមើលការខុសត្រូវនូវការបោះផ្សាយជាសាធារណៈ និងការចែកចាយមូលបត្រ នៅក្នុងទម្រង់ជា ប័ណ្ណភាគហ៊ុនធម្មតា ឬភាគហ៊ុនបុរិមា របស់សាជីវកម្ម សញ្ញាបណ្ណសាជីវកម្ម ពីស្ថាប័នដែលធ្វើការបោះផ្សាយ។ តួនាទីចម្បងរបស់ក្រុមហ៊ុនធានាទិញមូលបត្រ គឺការផ្តល់ប្រឹក្សាក្នុងដំណើរការបោះផ្សាយមូលបត្រជាលើកដំបូង (Initial Public Offering)។ ក្រុមហ៊ុនធានាទិញមូលបត្រ គឺជាអ្នកឯកទេសផ្នែកហិរញ្ញវត្ថុដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នបោះផ្សាយដើម្បីកំណត់ថ្លៃលក់មូលបត្រដំបូង (Pricing) ទំហំទឹកប្រាក់មូលបត្រ (Issue Amount) ចំនួនមូលបត្រត្រូវបោះផ្សាយ (Number of Securities Issued) និងពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution Timeline) ទៅវិនិយោគិនតាមរយៈបណ្តាញចែកចាយរបស់ក្រុមហ៊ុនធានាទិញមូលបត្រ។

ក្រុមហ៊ុនធានាទិញមូលបត្រ ជាទូទៅជាធនាគារវិនិយោគដែលមានអ្នកឯកទេស IPO ។ ធនាគារវិនិយោគទាំងនោះមានទំនាក់ទំនងជាមួយបណ្តាញនៃអង្គភាពវិនិយោគទុនធំៗ ជាច្រើនដូចជា មូលនិធិសង្គម និងក្រុមហ៊ុនធានារ៉ាប់រងដើម្បីវាស់ស្ទង់ពីផលប្រយោជន៍នៃការវិនិយោគ។ ចំនួនការប្រាក់ដែលវិនិយោគិនទាំងនេះទទួលបាន ជួយឲ្យក្រុមហ៊ុនធានាទិញមូលបត្រអាចកំណត់តម្លៃ IPO នៃភាគហ៊ុន។ ក្រៅពីនេះក្រុមហ៊ុនធានាទិញមូលបត្រមានតួនាទីផ្សេងទៀតដូចជា៖

- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដោយចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។[16]
- ទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយ ដើម្បីធានានូវភាពជោគជ័យរបស់ក្រុមហ៊ុនបោះផ្សាយនោះ។
- ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈពីក្រុមហ៊ុនបោះផ្សាយ។

### ១.៥.១.៤. វិនិយោគិនសាធារណៈ

វិនិយោគិនសាធារណៈ (Public Investor) សំដៅដល់សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងវិនិយោគិនបរទេសដែលគណៈកម្មការមូលបត្រកម្ពុជាបានអនុញ្ញាត រួមទាំងរូបវន្ត

[16] លឹម វិភា, *ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា,* (ភ្នំពេញ ២០១៨) ទំព័រ ១៥

បុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនមហាជនទទួលត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសហការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ។[17]

### ១.៥.១.៥. ក្រុមហ៊ុនគណនេយ្យ និងសវនកម្ម[18]

ក្រុមហ៊ុនគណនេយ្យជំនាញ គឺជាក្រុមហ៊ុនគណនេយ្យដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

សវនករឯករាជ្យ គឺជាសវនករប្រតិស្រុតដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ហើយបម្រើការងារនៅក្នុងក្រុមហ៊ុនគណនេយ្យជំនាញ។

សវនកម្ម គឺជាការត្រួតពិនិត្យឡើងវិញ ឬការត្រួតពិនិត្យប្រកបដោយលក្ខណៈជាប្រព័ន្ធទៅលើការអះអាង ឬលើសកម្មភាព ឬរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្មដើម្បីឲ្យអង្គភាពនោះ គោរពតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់ត្រូវមានកាតព្វកិច្ចក្នុងការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ស្វែងរកកំហុសលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រក្នុងទីផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនគណនេយ្យជំនាញនឹងជួយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌតម្រូវក្នុងឯកសារផ្តល់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។

ក្រុមហ៊ុនផ្តល់សេវាសវនកម្មជាក្រុមហ៊ុនដែល៖

- ទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ក្នុងការផ្តល់សេវាសវនកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។
- ធានាថាក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រអនុវត្តនូវស្តង់ដាគណនេយ្យបានត្រឹមត្រូវ
- ផ្តល់នូវរបាយការណ៍គណនេយ្យដែលអាចជឿជាក់បាន
- ផ្តល់នូវសុវត្ថិភាពខាងគ្រប់គ្រងគណនេយ្យ។

[17] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ឆ្នាំ២០០៧

[18] ប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ

#### ១.៥.១.៦. ភ្នាក់ងារវាយតម្លៃ

ក្រុមហ៊ុនវាយតម្លៃ ឬបុគ្គលវាយតម្លៃឯករាជ្យ គឺជាក្រុមហ៊ុនដែលផ្តល់សេវាវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ប្រសិនបើក្រុមហ៊ុនកាន់កាប់ទ្រព្យសម្បត្តិ ដីធ្លី ឬបរិក្ខារនោះត្រូវវាយតម្លៃឡើងវិញ។ ក្រុមហ៊ុនវាយតម្លៃត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជី និងរបាយការណ៍បំពេញកាតព្វកិច្ចច្បាប់។

#### ១.៥.១.៧. ក្រុមមេធាវី ឬមេធាវី

ក្រុមហ៊ុនមេធាវី ឬមេធាវី ជាអ្នកផ្តល់ការប្រឹក្សាយោបល់លើបញ្ហាផ្លូវច្បាប់ទាំងអស់ដែលទាក់ទងទៅនឹងពាក្យស្នើសុំ និងឯកសារផ្តល់ព័ត៌មាន ជាពិសេសលើការពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់របស់ក្រុមហ៊ុនដែលមានបំណងចុះបញ្ជី និងធ្វើការផ្ទៀងផ្ទាត់ឯកសារផ្សេងៗឱ្យបានត្រឹមត្រូវតាមការតម្រូវរបស់ច្បាប់។

### ១.៥.២. តួអង្គក្នុងទីផ្សារបន្ទាប់

#### ១.៥.២.១. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រជាលើកទីពីរ។ នៅក្នុងទីផ្សារបន្ទាប់ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានតួនាទីជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធទូទាត់និងផាត់ទាត់ និងប្រតិបត្តិកររក្សារទុកមូលបត្រ។

- **ប្រតិបត្តិករទីផ្សារមូលបត្រ** ជានិយ័តករជួរមុខ ក្នុងការកំណត់នូវវិធីសាស្ត្រ យន្តការនីតិវិធី និងការគ្រប់គ្រងការជួញដូរមូលបត្រ នៅក្រុមហ៊ុនផ្សារមូបត្រកម្ពុជា ដោយស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញាត្តិពាក់ព័ន្ធជាធរមាន។
- **ប្រតិបត្តិករប្រព័ន្ធទូទាត់និងផាត់ទាត់** ប្រតិបត្តិករនេះជាអ្នកធានាថា មូលបត្រត្រូវបានដល់ដៃអ្នកទិញ និងលុយបានដល់ដៃអ្នកលក់ក្នុងពេលតែមួយ ក្រោយពីការផ្គូផ្គងទទួលបានជោគជ័យ។ ប្រតិបត្តិករនេះ ក៏ធ្វើការត្រួតពិនិត្យមូលបត្រខាងអ្នកលក់ ថាតើមានមូលបត្រគ្រប់គ្រាន់សម្រាប់លក់ដែរ ឬទេ និងខាងអ្នកទិញ ថាគាត់មានលុយគ្រប់គ្រាន់សម្រាប់ទិញ ឬទេ ក្នុងគោលបំណងបញ្ចៀសនូវហានិភ័យក្នុងការទូទាត់។
- **ប្រតិបត្តិកររក្សាទុកមូលបត្រ** ប្រតិបត្តិករនេះកំណត់អំពីលក្ខខណ្ឌចាំបាច់នានាសម្រាប់រក្សាទុក និងផ្ទេរមូលបត្រ។

**១.៥.២.២. វិនិយោគិនសាធារណៈ**

វិនិយោគិន នៅក្នុងទីផ្សារបន្ទាប់នេះ ក៏ដូចនឹងវិនិយោគិនទីផ្សារដំបូងដែរ សំដៅដល់សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងវិនិយោគិនបរទេសដែលគណៈកម្មការមូលបត្រកម្ពុជាបានអនុញ្ញាត រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនមហាជនទទួលត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសហការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិ-ស្រុតនោះ។

**១.៥.២.៣. ក្រុមហ៊ុនមូលបត្រ**

នៅក្នុងតួអង្គទីផ្សារបន្ទាប់នេះ ក្រុមហ៊ុនមូលបត្រ គឺជាតួអង្គយ៉ាងសំខាន់ក្នុងកិច្ចដំណើរការទីផ្សារ ព្រោះក្រុមហ៊ុនមូលបត្រជាអ្នកជួយវិនិយោគិនក្នុងការទិញ-លក់មូលបត្រនៅក្នុងទីផ្សារ ដោយសារតែវិនិយោគិន មិនអាចធ្វើការជួញដូរមូលបត្រដោយផ្ទាល់នៅលើផ្សារមូលបត្របានដោយខ្លួនឯងនោះទេ។ ក្រុមហ៊ុនមូលបត្រត្រូវអនុវត្តបញ្ជា ទិញ-លក់ ពីអតិថិជនឱ្យបានត្រឹមត្រូវទាន់ពេលវេលា និងមិនលំអៀង។ ដែលអាចអនុវត្តបញ្ជាទិញ ឬលក់ក្នុងនាមអតិថិជនបានលុះត្រាតែទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអតិថិជនមានសាច់ប្រាក់ និងមូលបត្រគ្រប់គ្រាន់សម្រាប់ទូទាត់ប្រតិបត្តិការជួញដូរ។ ត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមប្រព័ន្ធអេឡិចត្រូនិច។

ទីផ្សារមូលបត្រមានដូចជាអាជីវកម្មធានាទិញមូលបត្រ(Underwriter)អាជីវកម្មរបស់ពាណិជ្ជករមូលបត្រ(Securities Dealers) អាជីវកម្មរបស់ឈ្មួញជើងសាមូលបត្រ (Securities Brokers) អាជីវ-កម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ (Investment Advisors) ។

- **អាជីវកម្មរបស់ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter)** ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) ជាស្ថាប័នដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចេញលក់ និងផ្សព្វផ្សាយមូលបត្រជាសាធាណៈពីសាជីវកម្មមានដូចជា៖
    - **អាជីវកម្មធានាទិញមូលបត្រ** រួមមាន៖[19]
    - – ការផ្តល់ប្រឹក្សាលើហិរញ្ញវត្ថុសាជីវកម្ម

[19] ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ

- ការជួយរៀបចំ ត្រួតពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់ និងបញ្ជាក់លើឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសំណើលក់មូលបត្រជាសាធារណៈ ឬសំណើលក់មូលបត្រជាឯកជន និងការចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ការទិញលក់មូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងគោលដៅចែកចាយ ឬលក់បន្ត។
- ការទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។

- **អាជីវកម្មរបស់ពាណិជ្ជករមូលបត្រ (Securities Dealers)** គឺជាអ្នកធ្វើការទិញ លក់មូលបត្រដោយផ្ទាល់នៅលើទីផ្សារហិរញ្ញវត្ថុ ដែលធ្វើការជួញដូរតាមបញ្ជារបស់អតិថិជន និងមានសិទ្ធិក្នុងការជួញដូរផ្ទាល់ខ្លួនដើម្បីរកប្រាក់ចំណេញខ្លួនឯងផង។
  - **អាជីវកម្មជួញដូរមូលបត្រ** គឺជាការជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយហានិភ័យដោយខ្លួនឯង។
  - **អាជីវកម្មជើងសាមូលបត្រ** គឺជាការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបាននូវប្រាក់កម្រៃជើងសា។
- **អាជីវកម្មផ្តល់ប្រឹក្សាហិរញ្ញវត្ថុ (Financal Advisors)** គឺជាអាជីវកម្មដូចមានចែងដូចជា៖
  - ការផ្តល់ប្រឹក្សាលើហិរញ្ញវត្ថុសាជីវកម្ម
  - ការជួយរៀបចំ ត្រួតពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់ និងបញ្ជាក់លើឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសំណើលក់មូលបត្រជាសាធារណៈ ឬសំណើលក់មូលបត្រជាឯកជន និងការចាត់ចែងរៀបដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- **ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ (Investment Advisors)** គឺដើរតួជាអ្នកផ្តល់យោបល់ក្នុងការវិនិយោគក្នុងវិស័យមូលបត្រនេះហើយទទួលបានប្រាក់កម្រៃតាមរយៈការផ្តល់សេវាកម្ម។ អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគរួមមាន៖
  - វត្ថុ និងផែនការការផ្តល់ប្រឹក្សាអំពីការវិនិយោគមូលបត្រ រួមទាំងការរៀបចំផែនការហិរញ្ញវត្ថុដែលមានដូចជា ការវិភាគស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន ការរៀបចំផែនការហិរញ្ញវិនិយោគលើមូលបត្រតាមតម្រូវការ និងគោលដៅរបស់អតិថិជន។

- ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនអ្នកវិនិយោគសាធារណៈ។

### ១.៥.៣. តួអង្គចូលរួមដទៃទៀត

ក្រៅពីតួអង្គសំខាន់ៗ ដែលបានរៀបរាប់ខាងលើ វិស័យមូលបត្រក៏មានតួអង្គចូលរួមដទៃទៀតដែលមានដូចជា៖[20]

#### ១.៥.៣.១. ភ្នាក់ងារបញ្ជិកាមូលបត្រ

ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលផ្តល់សេវាកម្មក្នុងការរៀបចំកត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រជូនក្រុមហ៊ុនបោះផ្សាយមូលបត្រដូចខាងក្រោម៖

១.វិនិយោគិនត្រូវចុះឈ្មោះទិញមូលបត្រតាមរយៈក្រុមហ៊ុនធានាទិញមូលបត្រ។

២.ក្រុមហ៊ុនត្រូវបញ្ជូនពាក្យស្នើសុំធ្វើបរិវិសកម្ម និងឯកសារពាក់ព័ន្ធរបស់វិនិយោគិនទៅភ្នាក់ងារបញ្ជិកាមូលបត្រ។

៣.ភ្នាក់ងារបញ្ជិកាមូលបត្ររៀបចំឯកសារពាក់ព័ន្ធនឹងការធ្វើបរិវិសកម្ម។

៤.ភ្នាក់ងារបញ្ជិកាមូលបត្រ ធ្វើការផ្ទៀងផ្ទាត់ពីទំហំនៃការធ្វើបរិវិសកម្មរបស់វិនិយោគិននីមួយៗ និងធ្វើការពិនិត្យពីភាពត្រឹមត្រូវនៃចំនួនទឹកប្រាក់ទៅតាមចំនួនមូលបត្រ ដែលបានធ្វើបរិវិសកម្មនីមួយៗ ក្រោយពីការទទួលបានសំនុំបែបបទនៃការធ្វើបរិវិសកម្មពីក្រុមហ៊ុនធានាទិញមូលបត្រ

៥.ភ្នាក់ងារបញ្ជិកាមូលបត្រ ធ្វើការបូកសរុបបញ្ជីឈ្មោះអ្នកធ្វើបរិវិសកម្ម និងចំនួនមូលបត្រដែលបានធ្វើបរិវិសកម្មដើម្បីបែងចែងមូលបត្របន្ទាប់ពីរយៈពេលធ្វើបរិវិសកម្មបានបញ្ចប់។

៦.តាមរយៈការបូកសរុបបញ្ជីនេះ ភ្នាក់ងារបញ្ជិកាមូលបត្រអាចកំណត់យ៉ាងច្បាស់លាស់ថាការធ្វើបរិវិសកម្មនេះជាប្រភេទ Over-subscription ឬ Under-subscription។

- ក្នុងករណីបរិមាណបរិវិសកម្មលើសពីចំនួនមូលបត្រដែលបោះផ្សាយលក់ជាសាធារណៈ (Over-subscription) ភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវចាប់ផ្តើមនីតិវិធីបែងចែកដោយមិនរើសអើងដល់អ្នកធ្វើបរិវិសកម្មទៅតាមវិធីសាស្ត្រសមាមាត្រ (Pro Rata) ដោយកំណត់ចំនួនមូលបត្រអប្បរមា ដែលត្រូវបានបែកចែកឲ្យអ្នកធ្វើបរិវិសកម្មដែលបំពេញបែបបទត្រឹមត្រូវដោយមានការចូលរួមពីក្រុមហ៊ុនធានាទិញបូលបត្រ។
- ក្នុងករណីបរិមាណបរិវិសកម្មតិចជាងចំនួនមូលបត្រ ដែលបោះផ្សាយលក់ជាសាធារណៈ (Under-subscription) ក្រុមហ៊ុនធានាទិញជាអ្នកទទួលខុសត្រូវទិញយកមូលបត្រដែល

[20] លឹម វិភា, *ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា,* (ភ្នំពេញ ២០១៨) ទំព័រ ២០

នៅសល់តាមតម្លៃ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងធានាទិញ ជាមួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

**១.៥.៣.២. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់**

- ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agent) សំដៅដល់បុគ្គលដែលត្រូវបានតែងតាំងដោយក្រុមហ៊ុនបោះផ្សាយ ដើម្បីរក្សាបញ្ជីកម្មសិទ្ធិករ បញ្ជីគណនេយ្យ និងបញ្ជីប្រតិបត្តិការ។
- ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលបានការទូទាត់មូលបត្រពីក្រុមហ៊ុនបោះផ្សាយ ហើយធ្វើការបែងចែកការទូទាត់នោះទៅឲ្យកម្មសិទ្ធិករមូលបត្រ។

**១.៥.៣.៣. ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ**

ភ្នាក់ងាររក្សាសុវត្ថិភាពបង្កើតឡើងដើម្បីធ្វើឲ្យមាននូវយន្តការប្រតិបត្តិការ និងការពារផលប្រយោជន៍របស់វិនិយោគិន ដែលមានការរៀបចំឲ្យមានរចនាសម្ព័ន្ធច្បាស់លាស់ក្នុងការទទួលខុសត្រូវ ដើម្បីធានាឲ្យមានការផ្តល់សេវាជូនអតិថិជនឲ្យមានភាពខ្ពស់។ ភ្នាក់ងារសុវត្ថភាពក្នុងវិស័យមូលបត្រ មានគោលការណ៍ស្តីពីសេវារក្សាសុវត្ថិភាព ជូនអតិថិជនដូចជា[21]៖

- ផ្តល់សេវាជូនអតិថិជនរបស់ខ្លួនតាមគោលការណ៍
- អនុវត្តប្រតិបត្តការរក្សាសុវត្ថិភាពសាច់ប្រាក់ មូលបត្រ និងទ្រព្យដ៏ទៃទៀតក្នុងនាមអតិថិជន
- ទូទាត់សាច់ប្រាក់ មូលបត្រ និងទ្រព្យដ៏ទៃទៀតក្នុងនាមអតិថិជន
- ផ្តល់សេវាចាត់ចែង និងតាមដានសាច់ប្រាក់ មូលបត្រ និងទ្រព្យដ៏ទៃទៀតក្នុងនាមអតិថិជនសម្រាប់ការវិនិយោគទាក់ទងនឹងមូលបត្រ
- អនុវត្តវិធីសាស្ត្រនៃការគណនាទ្រព្យសកម្មសុទ្ធ និងការកត់ត្រាទ្រព្យរបស់អតិថិជនតាមតម្លៃទីផ្សារ (Mark-to-Market Valuation) និងនីតិវិធីស្តីពីការពិនិត្យ និងការរាយការណ៍ទ្រព្យសកម្ម
- រៀបចំការងារពាក់ព័ន្ធនឹងផលប្រយោជន៍ និងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រ (Corporate Actions) រួមទាំងការប្រមូលចំណូលពីការវិនិយោគពាក់ព័ន្ធនឹងមូលបត្រ និងធ្វើសកម្មភាពដើម្បីអត្ថប្រយោជន៍ដ៏ទៃទៀតក្នុងនាមអតិថិជន
- ផ្តល់ព័ត៌មានដល់អតិថិជន និងភាគីពាក់ព័ន្ធដ៏ទៃទៀតនូវសេវានានាដែលបានអនុវត្ត

[21] គណៈកម្មការមូលបត្រកម្ពុជា, ប្រកាសស្តីពី *ការទទួលស្គាល់ភ្នាក់ងារសុវត្ថិភាពក្នុងវិស័យមូលបត្រ*, (ភ្នំពេញ ២០១៨)

- គ្រប់គ្រងនូវរាល់អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទឹនទៅនឹងវិស័យមូលបត្រ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- ផ្តល់សេវាដ៏ទៃទៀតដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ជាដើម។

### ១.៥.៣.៤. ភ្នាក់ងារវាយតម្លៃលទ្ធភាពសង

សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីផ្តល់សេវាធ្វើចំណាត់ថ្នាក់លើបុគ្គលរងការធ្វើចំណាត់ថ្នាក់និងការងារតាមដានការវិវត្តន៍នៃចំណាត់ថ្នាក់បុគ្គលរងការធ្វើចំណាត់ថ្នាក់ ឬមូលបត្របំណុលដែលត្រូវបោះផ្សាយលក់។ ភ្នាក់ងារនេះបំរើដល់ការផ្តល់សេវាធ្វើចំណាត់ថ្នាក់លទ្ធភាពសងក្នុងវិស័យមូលបត្រកម្ពុជា ជួយសម្រួលដល់ការផ្តល់យោបល់ និងធ្វើចំណាត់ថ្នាក់លទ្ធភាពសងប្រកបដោយឯករាជ្យភាព ភាពមិនលម្អៀង និងភាពអាចជឿទុកចិត្តបាន ដូចខាងក្រោម៖[22]

- មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ដើម្បីផ្តល់សេវាចំណាត់ថ្នាក់លើមូលបត្របំណុលដែលអាចជឿទុកចិត្តបាន
- មានប្រព័ន្ធរក្សាទិន្នន័យ (Data base) និងប្រព័ន្ធការពារ (Firewall)
- មានប្រព័ន្ធទ្រទ្រង់ (Back-up Systems) គ្រប់គ្រាន់ និងប្រព័ន្ធប្រមូលទិន្នន័យមកវិញ (Recovery System)។

### ១.៥.៣.៥. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល តំណាងឲ្យវិនិយោគិនក្នុងការទំនាក់ទំនងជាមួយបុគ្គលបោះផ្សាយ ត្រួតពិនិត្យបុគ្គលបោះផ្សាយ ផ្តល់ព័ត៌មានទៅម្ចាស់មូលបត្របំណុល និងការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល ស្របទៅតាមលក្ខខណ្ឌក្នុងការបោះផ្សាយមូលបត្របំណុល ។ សព្វថ្ងៃនៅកម្ពុជា មានភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលមួយគឺក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACLEDA Securities Plc.)។ ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលមានតួនាទី និងភារកិច្ចលម្អិត ដូចខាងក្រោម[23] ៖

- ត្រូវការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល ។
- ត្រូវតាមដានទ្រព្យធានា ដែលបានធានាសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដោយគោរពទៅតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ភ្នាក់ងារតំណាងម្ចាស់មូល

[22] គណៈកម្មការមូលបត្រកម្ពុជា, ប្រកាសស្តីពី *ការទទួលស្គាល់ភ្នាក់ងារវាយតម្លៃលទ្ធភាពសង*, (ភ្នំពេញ ២០១៧)
[23] http://www.acledasecurities.com.kh/as/khm/md_ln20180517

បត្របំណុល និងមិនត្រូវប្រើប្រាស់ទ្រព្យធានាទាំងនេះ ដើម្បីស្វែងរកប្រាក់ចំណេញឡើយ។

- ត្រូវតាមដានកម្រិតសោធនភាពរបស់បុគ្គលបោះផ្សាយ ដែលមានចែងក្នុងលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់ ។
- ត្រូវតាមដានការអនុវត្តលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់ (Term and Conditions) និងកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ។
- ត្រូវអនុវត្តរាល់សកម្មភាពដែលចាំបាច់ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល និងដោះស្រាយការទាមទាររបស់ម្ចាស់មូលបត្របំណុល។
- ត្រូវធានាថាមូលបត្របំណុលដែលបានធ្វើបរិវត្ត ឬទូទាត់សងត្រូវធ្វើឡើងដោយអនុលោមតាមលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់ ។
- ត្រូវរាយការណ៍ជូនម្ចាស់មូលបត្របំណុលយ៉ាងតិច ៦ (ប្រាំមួយ) ខែម្តង អំពីការអនុវត្តលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់។
- ត្រូវស្នើសុំ ឬរៀបចំឲ្យមានកិច្ចប្រជុំរវាងម្ចាស់មូលបត្របំណុលទាំងអស់ជាមួយនឹងបុគ្គលបោះផ្សាយ ក្នុងករណីមានបណ្តឹងជាលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខាដោយម្ចាស់មូលបត្របំណុលយ៉ាងតិច ១/១០ (មួយភាគដប់) នៃតម្លៃមូលបត្របំណុលដែលកំពុងចរាចរ និងមានការកើតឡើងនូវព្រឹត្តិការណ៍ណាមួយ ដែលចាត់ទុកថាជាការខកខានមិនបានសងបំណុល ឬភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលយល់ឃើញថា មានការប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល ។

# ជំពូកទី២

# ស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា

សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនបំផុតបន្ទាប់ពីមានការធ្លាក់ចុះខ្លាំងនៅឆ្នាំ២០០៩ នៅអត្រា០.១%។ រយៈពេល ១០ឆ្នាំចុងក្រោយនេះកម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧%ជារៀងរាល់ឆ្នាំដែលឆ្លុះបញ្ចាំងពីការរីកចម្រើនស្ទើរគ្រប់វិស័យ។

កម្ពុជា សម្រេចបាននូវកំណើនតាមការកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ(២០១៤-២០១៨)។ ទោះបីជាកម្ពុជាជួបប្រទះនូវគ្រោះរាំងស្ងួតធ្ងន់ធ្ងរក្នុងឆ្នាំ២០១៥ ដែលធ្វើឲ្យប៉ះពាល់ដល់វិស័យកសិកម្មក្តី ក៏សេដ្ឋកិច្ចកម្ពុជាអាចរក្សាបាននូវស្ថិរភាពនៃកំណើន ដោយសារតែវិស័យមិនមែនកសិកម្មមានកំណើនខ្ពស់ ដែលជួយបំពេញបន្ថែមដល់ការថមថយនៃវិស័យកសិកម្ម។ កម្ពុជាបានរក្សាកំណើនសេដ្ឋកិច្ចយ៉ាងរឹងមាំ ក្នុងបរិការណ៍សេដ្ឋកិច្ចពិភពលោកដែលមានការធ្លាក់ចុះ។ នៅឆ្នាំ២០១៦ កំណើនសេដ្ឋកិច្ចពិភពលោកដែលគ្រោងថា នឹងមានកំណើន ៣% ឬ៤% នោះ បានចុះរហូតដល់២,៥% ប៉ុន្តែសម្រាប់កម្ពុជាកំណើន៧%នៅតែទៅរួច។

នៅឆ្នាំ២០១៨ កន្លងទៅកម្ពុជាសម្រេចបានកំណើន ៧.៥%។ កំណើននេះ គឺជាអត្រាកំណើនល្អ ជាងការរំពឹងទុក កាលពីខែតុលាឆ្នាំមុនទៅទៀត។

កំណើននេះ គឺបានមកដោយមានការជំរុញមួយផ្នែកធំ ពីការកើនឡើងយ៉ាងឆាប់រហ័សនៃការនាំចេញ និងការបន្តលូតលាស់នៃវិស័យសំណង់នៅក្នុងប្រទេសកម្ពុជា។ នេះបើយោងតាមរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ធនាគារពិភពលោក (World Bank) បានចេញផ្សាយនៅថ្ងៃទី ០៦ ខែឧសភានេះ ដោយអះអាងថា សេដ្ឋកិច្ចរបស់កម្ពុជាមានកំណើនស្វាហាប់ក្នុងឆ្នាំ២០១៨ កន្លងទៅ ដោយសម្រេចបានកំណើន៧.៥%។

ការនាំចេញរបស់ផលិតផលសម្លៀកបំពាក់ ស្បែកជើង និងមុខទំនិញធ្វើដំណើរមានជាង២ភាគ៣នៃមុខទំនិញនាំចេញសរុប គឺជាកំណត់ត្រាកំណើនខ្ពស់៥ឆ្នាំជាប់ៗគ្នា ហើយវាបានកើនដល់ ១៧.៦% ក្នុងឆ្នាំ២០១៨ ប្រៀបធៀបជាមួយ ៨.៣% ក្នុងឆ្នាំ២០១៧។ ក្រៅពីនេះ វិស័យសំណង់ អចលនទ្រព្យ និងទេសចរណ៍ដែលសរុបចូលគ្នាមក មានចំណែក ៦០% នៃចំនួនគម្រោងវិនិយោគទាំងអស់ ដែលត្រូវបានអនុម័តរួចក្នុងឆ្នាំ២០១៨។

ដោយឡែកការផលិតសម្ភារៈផ្គត់ផ្គង់ការសាងសង់ដែកគ្រឿងសង្ហារឹមនិងផលិតផលប្លាស្ទិកក៏មានការកើនឡើងយ៉ាងលឿនដែរ ដើម្បីគាំទ្រដល់ការលូតលាស់របស់វិស័យសំណង់។ ប៉ុន្តែ

យ៉ាងណាក៏ដោយ ជាមួយនឹងអត្រាកំណើននេះ លទ្ធភាពដែលកម្ពុជានឹងអាចបាត់បង់ភាពអនុគ្រោះនាំទំនិញចូលទីផ្សារអឺរ៉ុបដោយរួចពន្ធ ក្រោមប្រព័ន្ធអនុគ្រោះពន្ធ «គ្រប់មុខទំនិញទាំងអស់លើកលែងតែគ្រឿងសព្វាវុធ» ឬ EBA ទំនងជានឹងអាចបន្ថយល្បឿននៃការនាំចេញពីកម្ពុជា។

បច្ចុប្បន្ននេះ ទីផ្សារសហភាពអឺរ៉ុបដែលរួមមានទាំងអង់គ្លេសផង បានស្រូបយកជាង ១ភាគ៣ នៃទំហំការនាំចេញសរុបរបស់កម្ពុជា។ ជាពិសេសផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទោចក្រយានជាដើម។ បន្ថែមលើនេះ វិស័យសំណង់ និងអចលនទ្រព្យកាន់តែងាយធ្លាក់ក្នុងវដ្តស្ថានភាពឆាប់ប៉ោងហើយឆាប់ផ្ទុះបែកទៅវិញ ហើយកំណើនការផ្តល់ហិរញ្ញប្បទានក្នុងស្រុកនៅក្នុងវិស័យសំណង់ នឹងកាន់តែបង្កើនហានិភ័យថែមទៀត ដល់វិស័យហិរញ្ញវត្ថុនៅកម្ពុជាដែរ។ ការធ្វើឲ្យប្រសើរឡើងដល់បរិយាកាសវិនិយោគ និងការកាត់បន្ថយថ្លៃចំណាយក្នុងការធ្វើធុរកិច្ច ព្រមទាំងការកសាងជំនាញសម្រាប់សេដ្ឋកិច្ចនាពេលអនាគត គឺសុទ្ធតែជាអាទិភាពគន្លឹះសម្រាប់រក្សាកំណើនខ្លាំងក្នុងរយៈពេលមធ្យម។ ការវិនិយោគទៅលើប្រជាជន មានសារៈសំខាន់ណាស់ ដើម្បីជំរុញឲ្យមានវឌ្ឍនភាពសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

វិស័យហិរញ្ញវត្ថុកម្ពុជាបានបង្ហាញពីភាពរឹងមាំនៅឆ្នាំ២០១៨ តាមរយៈកំណើនខ្លាំងនៃទំហំប្រាក់កម្ចី និងប្រាក់បញ្ញើ ស្របពេលកម្ចីដែលអតិថិជនមិនបានសងទាន់ពេល នៅរក្សាបានអត្រាទាប។ នេះបើតាមរបាយការណ៍ឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា។ របាយការណ៍របស់ NBC បង្ហាញថា ទំហំកម្ចីនៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជាដែលរួមបញ្ចូលទាំងកម្ចីពីធនាគារ និងមីក្រូហិរញ្ញវត្ថុ បូកបញ្ចូលគ្នាមានចំនួនសរុប ២៤,៥ ពាន់លានដុល្លារនៅត្រឹមដំណាច់ឆ្នាំ ២០១៨ គឺកើនឡើង ១៩ ភាគរយពីដំណាច់ឆ្នាំ ២០១៧។ ទំហំប្រាក់បញ្ញើក្នុងវិស័យនេះវិញ មានចំនួនសរុប ២២,១ ពាន់លានដុល្លារ គឺកើនឡើង ១៥,៣ ភាគរយ។

យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា បានបង្ហាញថាបច្ចុប្បន្នកម្ពុជាមានធនាគារពាណិជ្ជចំនួន ៤៣ធនាគារ (ធនាគារក្នុងស្រុក ១៥ បុត្តសម្ព័ន្ធធនាគារ ១៥ និងសាខាធនាគារបរទេស ១៣) ធនាគារឯកទេសមានចំនួន ១៤ធនាគារ (ធនាគាររដ្ឋ១ និងធនាគារឯកជន ១៣)។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជនមានចំនួន ៧ ស្ថាប័ន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៧៣ ស្ថាប័ន គ្រឹះស្ថានឥណទានជនបទ ២៧៣ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ អ្នកដំណើរការតតីយភាគី ៥ គ្រឹះស្ថានផ្តល់សេវាទូទាត់ ១៤ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា ១ ការិយាល័យតំណាងធនាគារបរទេស ៥ និង អាជីវករប្តូរប្រាក់ ២.៧៣៧ ។[24]

[24] របាយការចេញដោយធនាគារជាតិនៃកម្ពុជា ឆ្នាំ ២០១៨

គិតត្រឹមដំណាច់ឆ្នាំ២០១៨ វិស័យហិរញ្ញវត្ថុទាំងមូលមានទ្រព្យសកម្មសរុប ៤០ ពាន់លានដុល្លារ គឺកើនឡើង ១៩,៤ ភាគរយពីកាលពីដំណាច់ឆ្នាំ២០១៧។ វិស័យហិរញ្ញវត្ថុនៅកម្ពុជាបានរក្សាកំណើនរឹងមាំ និងបានពង្រីកប្រតិបត្តិការទូទាំងប្រទេសដែលបានរួមចំណែកយ៉ាងសកម្មដល់ការជំរុញកំណើនសេដ្ឋកិច្ច។

## ២.១. វិស័យធនាគារ

គ្រឹះស្ថានធនាគារបានបន្តរីកចម្រើនគួរឲ្យកត់សម្គាល់ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារមានការកើនឡើង ២០% (ឆ្នាំលើឆ្នាំ) ដល់ ១៣៨,៦ ទ្រីលានរៀល (៣៤ ប៊ីលានដុល្លារអាមេរិក) ដោយសារកំណើនឥណទានសរុប ២០,១% ដល់ ៧៩,២ ទ្រីលានរៀល (១៩,៦ ប៊ីលានដុល្លារអាមេរិក) និងគាំទ្រដោយកំណើនដើមទុន ២៣,៣% ដល់ ២៦,២ ទ្រីលានរៀល កំណើនមូលនិធិកម្ចី ១០,២% ដល់ ៦,៦ ទ្រីលានរៀល និងកំណើនប្រាក់បញ្ញើ ១៤% ដល់ ៧៩,៥ ទ្រីលានរៀល។ ទន្ទឹមនេះ ដើម្បីជួយសម្រួលដល់ការផ្តល់សេវាហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយ និងងាយស្រួលជាងមុន គ្រឹះស្ថានធនាគារបានពង្រីកសាខារហូតដល់ ៨៧៧ សាខា និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្ត (ATM) ដល់ ១.៨៣២ ម៉ាស៊ីននៅតាមរាជធានីខេត្ត។ ចំពោះការប្រើប្រាស់ ប័ណ្ណឥណទានមានកំណើន ៤៧,៨% ដល់ ១០៩.៥៦១ ប័ណ្ណ និងប័ណ្ណឥណពន្ធមានកំណើន ១៧,៥% ដល់ ២.១៣០.៤៤២ ប័ណ្ណ។

គ្រឹះស្ថានធនាគារបានផ្តល់ឥណទានទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗដូចជា៖ ការជួញដូររាយ ១៧% ការជួញដូរដុំ ១១,២% ការឲ្យខ្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន ៩,៨% ការជួញដូរអចលនទ្រព្យ ៧% សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត ៦,៨% កម្មន្តសាលកម្ម ៥,៥% សណ្ឋាគារ និងភោជនីដ្ឋាន ៤,៩% និងវិស័យផ្សេងៗ ១១,៧%។

ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារភាគច្រើនបាននិងកំពុងអភិវឌ្ឍសេវាហិរញ្ញវត្ថុឌីជីថល ហើយសេវាទាំងនេះបានផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការប្រើប្រាស់សេវាធនាគារតាមរយៈប្រព័ន្ធអ៊ីនធើណែតនិងទូរសព្ទដៃជាដើម ដែលរួមចំណែកក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។ គ្រឹះស្ថានធនាគារបន្តអភិវឌ្ឍ និងពង្រីកបណ្តាសាខា ធ្វើពិពិធ-កម្មផលិតផលនិងសេវាហិរញ្ញវត្ថុ ដើម្បីឆ្លើយតមនឹងការកើនឡើងនៃតម្រូវការរបស់អតិថិជនដោយគ្រឹះស្ថានបន្តលើកកម្ពស់ភាពនិងគុណភាពនៃប្រតិបត្តការ ពង្រឹងភាពរឹងមាំនៃដើមទុន និងសន្ទ-នីយភាព ពង្រឹងអភិបាលកិច្ចល្អ ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យា និងកសាងសមត្ថភាពធនធានមនុស្សប្រកបដោយគុណវិឌ្ឍិ។ ស្ថេរភាពនយោបាយ ការរីកចម្រើនគ្រប់ផ្នែកនៃវិស័យសេដ្ឋកិច្ច

និងភាពរឹងមាំនៃប្រព័ន្ធធនាគារនាពេលបច្ចុប្បន្ន គឺជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា។[25]

វិស័យធនាគារនៅកម្ពុជា ត្រូវបានទទួលស្គាល់ថា មានលក្ខណៈបើកទូលាយហើយ មានសមាហរណកម្មខ្ពស់ក្នុងតំបន់ ដោយបច្ចុប្បន្នគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមកពីប្រទេសក្នុងតំបន់ភាគច្រើន មានវត្តមាននៅកម្ពុជា។ ម្យ៉ាងទៀតកម្ពុជា បានតភ្ជាប់ប្រព័ន្ធទូទាត់របស់ខ្លួនជាមួយប្រទេសក្នុងតំបន់ និងពិភពលោក។ បច្ចុប្បន្នធនាគារជាតិនៃកម្ពុជា កំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ តាមរយៈបច្ចេកវិទ្យាទំនើបរួមមាន៖ ប្រព័ន្ធ QR Code ជាមួយប្រទេសក្នុងតំបន់ដូចជាប្រទេសថៃជាដើម។ ការទូទាត់តាមប្រព័ន្ធ QR Code នឹងរួមចំណែកលើកកម្ពស់ភាពទូទាត់ ឱ្យមានសុវត្ថិភាពនិងចំណាយទាបសមរម្យ។[26]

### ២.១.១. ធនាគារពាណិជ្ជ[27]

ធនាគារពាណិជ្ជកម្ម គឺជាប្រភេទអន្តរការីហិរញ្ញវត្ថុ។ វាជាធនាគារដែលផ្តល់នូវគណនីត្រួតពិនិត្យ គណនីសន្សំ និងទទួលយកការសន្សំរយៈពេលកំណត់។ នៅក្នុងប្រទេសខ្លះ ធនាគារពាណិជ្ជសំដៅលើធនាគារដែលទទួលបញ្ញើ និងផ្តល់កម្ចីដល់តែសហគ្រាស ឬក្រុមហ៊ុនពាណិជ្ជ-កម្មប៉ុណ្ណោះ ដែលខុសប្លែកពីធនាគារលក់រាយ (Retail Banking) ដែលផ្តល់សេវាហិរញ្ញវត្ថុដោយផ្ទាល់ដល់អតិថិជន។ បច្ចុប្បន្នកម្ពុជាមានធនាគារពាណិជ្ជចំនួន ៤៣ធនាគារ (ធនាគាក្នុងស្រុក ១៥ បុត្តសម្ព័ន្ធធនាគារ ១៥ និងសាខាធនាគារបរទេស ១៣)។

តារាងទី១: ទិន្នន័យរបស់ធនាគារពាណិជ្ជគិតត្រឹមឆ្នាំ២០១៥ ដល់២០១៧ (គិតជាលានរៀល)

| ធនាគារពាណិជ្ជ | ឆ្នាំ | | |
|---|---|---|---|
| | 2015 | 2016 | 2017 |
| ទ្រព្យសកម្ម | 78,363,630 | 94,439,502 | 113,292,081 |
| ដើមទុនបានចុះបញ្ជី | 8,188,367 | 9,373,538 | 12,539,265 |
| ប្រាក់ចំណេញសុទ្ធ | 1,547,220 | 1,686,556 | 1,745,256 |
| ប្រាក់បញ្ញើសរុប | 45,863,078 | 55,693,992 | 69,674,584 |
| ឥណទានសរុប | 45,987,812 | 54,780,875 | 64,806,875 |

ប្រភព: ធនាគារជាតិនៃកម្ពុជា, របាយការណ៍ទិន្នន័យរបស់ធនាគារ (ឆ្នាំ ២០១៥ ដល់ ២០១៧)

[25] ធនាគារជាតិកម្ពុជា, *របាយការណ៍ប្រចាំឆ្នាំ២០១៨*, (ភ្នំពេញ ២០១៨)
[26] http://www.freshnewsasia.com/index.php/en/localnews/118546-2019-04-08-07-42-28.html
[27] https://km.wikipedia.org/wiki/ធនាគារពាណិជ្ជកម្ម

### ២.១.២. ធនាគារឯកទេស

ធនាគារឯកទេស ត្រូវបានកំណត់ជាធនាគារដែលមានឯកទេសក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិដែលមានលក្ខណៈពាណិជ្ជកម្មជាធនាគារពាណិជ្ជ។ ធនាគារឯកទេស គឺជាធនាគារដែលដំណើរការក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងសេដ្ឋកិច្ចឧស្សាហកម្ម និងពាណិជ្ជកម្មដែលអាស្រ័យលើជំនាញរបស់ពួកគេ ។

ធនាគារឯកទេសគឺជាស្ថាប័នហិរញ្ញវត្ថុ ដែលទាក់ទងនឹងឧបករណ៍ឥណទានផ្សេងៗនៅក្នុងទីផ្សាររូបិយវត្ថុ និងហិរញ្ញវត្ថុ ហើយភារកិច្ចរបស់ធនាគារនេះគឺជាអន្តរការីហិរញ្ញវត្ថុរវាងប្រភេទជាក់លាក់នៃអ្នកផ្តល់ប្រាក់កម្ចីនិងអ្នកខ្ចី។ វាត្រូវបានកំណត់ថាជាធនាគារដែលប្រតិបត្តិការធនាគារត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ចមួយចំនួនដូចជា សកម្មភាពឧស្សាហកម្ម សកម្មភាពកសិកម្ម ឬសកម្មភាពអចលនទ្រព្យស្របតាមដំណោះស្រាយនៃការបង្កើត និងមិនទទួលយកប្រាក់បញ្ញើជាផ្នែកសំខាន់មួយនៃសកម្មភាពរបស់ខ្លួន។ នេះគឺជាគ្រឹះស្ថានឯកទេស ឬក្រុមហ៊ុនភាគហ៊ុនដែលមានគោលបំណងចម្បងគឺផ្តល់ប្រាក់កម្ចីដល់បុគ្គល ឬនីតិបុគ្គលដើម្បីអនុវត្តប្រភេទផ្សេងៗនៃគម្រោងសេដ្ឋកិច្ចគម្រោងកសិកម្មមួយចំនួន ឬគម្រោងនានានៅក្នុងវិស័យអចលនទ្រព្យ និងមានច្បាប់ធនាគារ។[28] បច្ចុប្បន្ន នៅប្រទេសកម្ពុជាគិតត្រឹមចុងឆ្នាំ២០១៨ មានធនាគារឯកទេស ចំនួន ១៤ធនាគារ (ធនាគាររដ្ឋ១ និងធនាគារឯកជន ១៣)។

តារាងទី២: ទិន្នន័យធនាគារឯកទេសគិតត្រឹមឆ្នាំ២០១៥ ដល់២០១៧ (គិតជាលានរៀល)

| ធនាគារឯកទេស | ឆ្នាំ | | |
|---|---|---|---|
| | 2015 | 2016 | 2017 |
| ទ្រព្យសកម្ម | 1,193,652 | 1,776,764 | 2,285,399 |
| ដើមទុនបានចុះបញ្ជី | 670,304 | 1,010,380 | 997,019 |
| ប្រាក់ចំណេញសុទ្ធ | 41,266 | 38,175 | 35,043 |
| ប្រាក់បញ្ញើសរុប | 5,301 | 5,788 | 9,858 |
| ឥណទានសរុប | 789,271 | 1,238,721 | 1,573,049 |

ប្រភព: ធនាគារជាតិនៃកម្ពុជា, របាយការណ៍ទិន្នន័យរបស់ធនាគារ (ឆ្នាំ ២០១៥ ដល់ ២០១៧)

### ២.១.៣ វិស័យមីក្រូហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុកម្ពុជា បានបន្តរីកចម្រើនឡើងគួរឲ្យកត់សម្គាល់និងប្រកបដោយនិរន្តរភាពទាំងវិសាលភាព ទំហំប្រតិបត្តិការ និងប្រាក់ចំណេញ។ ក្នុងឆ្នាំនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន

[28] THE ROLE OF SPECIALIZED BANKS IN ECONOMIC DEVELOPMENT.

ចំនួន ៧៩គ្រឹះស្ថាន ដែលក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ៧ រួមមានៈ ប្រាសាក់ ហត្ថាកសិករ អម្រិត ក្រេឌីត អេអឹមខេ អិលអូអិលស៊ី និងដាប់ប៊ែលយូប៊ីហ្វាយនែន (អតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីស៊ិនហ្វាន់)។

វិស័យនេះបានផ្តល់ឥណទានប្រមាណ ២១,៨ ទ្រីលានរៀល (៥,៤ ប៊ីលានដុល្លារអាមេរិក) ដល់អតិថិជនសរុប ១,៨ លាននាក់ ព្រមទាំងបានកេណ្ឌប្រមូលប្រាក់បញ្ញើសរុបប្រមាណ ១០,១ ទ្រីលានរៀល (២,៥ ប៊ីលានដុល្លារអាមេរិក) ពីអ្នកដាក់ប្រាក់បញ្ញើសរុប ២,១ លាននាក់។ ទន្ទឹមនឹងការបន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនទូទាំងប្រទេស វិស័យនេះបានធ្វើពិពិធកម្មសេវានិងផលិតផលហិរញ្ញវត្ថុថ្មីៗ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុទំនើបៗផងដែរ ដែលបានជួយដល់អតិថិជនមីក្រូហិរញ្ញវត្ថុ ជាពិសេសប្រជាជននៅតំបន់ជនបទ ឲ្យកាន់តែមានភាពងាយស្រួលនិងសុវត្ថិភាព ក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។

ជាមួយគ្នានេះ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានៅតែបន្តនិរន្តរភាពប្រតិបត្តិការហិរញ្ញវត្ថុ ឆ្លុះ-បញ្ចាំងតាមរយៈស្ថិរភាពអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) ៣,៦% និងអនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុននិក (ROE) ១៧,៧% រួមទាំងអនុបាតឥណទានមិនដំណើរការ ១,៣%។

ទោះបីវិស័យនេះបានបន្តការរីកចម្រើនប្រកបដោយមោទនភាពយ៉ាងណាក្តី ប៉ុន្តែនៅប្រឈមនឹងបញ្ហាចម្បងៗមួយចំនួនដូចជា ១).ការប្រកួតប្រជែងទីផ្សារកាន់តែខ្លាំងក្លាជាងមុនទាំងគ្រឹះស្ថានផ្លូវការ និងមិនផ្លូវការ ២).ការកសាងសមត្ថភាពធនធានមនុស្សឲ្យស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ៣).ការអនុវត្តឲ្យបានពេញលេញតាម IFRS និង ៤).ការស្វែងរកប្រភពទុនដែលមានតម្លៃកាន់តែសមរម្យ។

ចំពោះគ្រឹះស្ថានឥណទានជនបទ បច្ចុប្បន្នមានចំនួន ២៧៣គ្រឹះស្ថាន និងមានសំពៀតឥណទានសរុបប្រមាណ ៤៤២ ប៊ីលានរៀល (១០៩,១ លានដុល្លារអាមេរិក) ដោយបានផ្តល់ដល់អតិថិជន ២១៣.៥៧៤នាក់ និងមានអនុបាតឥណទាមិនដំណើរការ១១%។ ទោះបីជាមានគ្រឹះស្ថានឥណទានជនបទជាច្រើនបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា ហើយយ៉ាងណាក្តី ក៏មានគ្រឹះស្ថានមួយចំនួនទៀតនៅតែបន្តធ្វើប្រតិបត្តិការហិរញ្ញវត្ថុដោយពុំមានច្បាប់អនុញ្ញាតនៅឡើយ។ ក្នុងបរិការនេះ ធនាគារជាតិនៃកម្ពុជានៅតែបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីចាត់ទុកវិធានការទប់ស្កាត់សកម្មភាពអាជីវកម្មខុសច្បាប់ទាំងនេះ។

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរប្រាក់សន្សំរបស់សាធារណជន និងប្រភពទុនផ្សេងៗទៀតក្នុងទីផ្សារអន្តរជាតិ មកចាក់បញ្ចូលទៅក្នុងសេដ្ឋកិច្ចជាតិ តាមរយៈការផ្តល់ហិរញ្ញប្បទាន និងឥណទានដល់ការវិនិយោគ ជាពិសេសដល់វិស័យផលិតកម្ម សហគ្រាសធុនតូច និងមធ្យម ដែលជាការជួយបង្កើនសមត្ថភាពផលិតកម្ម ការធ្វើទំនើបកម្មផលិតកម្ម និងការលើកកម្ពស់ស្តង់ដារផលិតផលកម្ពុជា ដែលជាការរួមចំណែកបង្កើនភាពសេដ្ឋ-កិច្ចជាតិ។

ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ វិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ ទាំងផ្នែកវិសាលភាព ទំហំប្រតិបត្តិការ ផលិតផល និងបណ្តាញសេវា ប្រជាជនយល់ដឹងពីសារៈសំខាន់នៃវប្បធម៌ឥណទាន និងបានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ហើយវិស័យនេះក៏ត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ មិនតែប៉ុណ្ណោះ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក៏ត្រូវបានទទួលស្គាល់ថា ជាវិស័យមីក្រូហិរញ្ញវត្ថុមួយដ៏រីកចម្រើនក្នុងពិភពលោក និងជាគំរូដ៏ល្អសម្រាប់បណ្តាប្រទេសដទៃទៀតផងដែរ។ សមិទ្ធផលទាំងនេះ កើតឡើងដោយការខិតខំប្រឹងប្រែងរួមគ្នា និងកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជាជាមួយអាជ្ញាធរពាក់ព័ន្ធសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ជាពិសេសរាជរដ្ឋាភិបាលដែលតែងតែគាំទ្រដល់ការអភិវឌ្ឍវិស័យទាំងមូល។[29]

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់តួនាទីដ៏សំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសជាង៣០ ដែលបានបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមីក្រូហិរញ្ញវត្ថុ។ ក្នុងចំណោមប្រទេសទាំងនេះ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សនិងត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដោយសារកម្ពុជាមានក្របខ័ណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យលើការគ្រប់គ្រងអ្នកផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយមានប្រសិទ្ធភាព។ បច្ចុប្បន្ននេះ ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង និងបានពង្រីកសកម្មភាពរបស់ខ្លួនរហូតដល់អាចទទួលប្រាក់បញ្ញើ សម្រាប់បម្រើប្រជាពលរដ្ឋដែលមានចំណូលទាបទៀតផង។

[29] https://kohsantepheapdaily.com.kh/article/141386.html

តារាងទី៣: ទិន្នន័យរបស់ (MDIs) គិតត្រឹមឆ្នាំ២០១៥ ដល់២០១៧ (គិតជាលានរៀល)

| ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) | ឆ្នាំ (គិតលានរៀល) | | |
|---|---|---|---|
| | 2015 | 2016 | 2017 |
| ទ្រព្យសកម្ម | 12,911,754 | 13,314,051 | 17,447,534 |
| ដើមទុនបានចុះបញ្ជី | 538,65 | 617,317 | 942,763 |
| ប្រាក់បញ្ញើសរុប | 503,418 | 479,704 | 505,848 |
| ឥណទានសរុប | 8,922,509 | 10,868,481 | 14,969,616 |
| ប្រាក់ចំណេញសុទ្ធ | 4,246,610 | 5,955,140 | 8,007,107 |

ប្រភព: ធនាគារជាតិនៃកម្ពុជា, របាយការណ៍ទិន្នន័យរបស់(MDIs) (ឆ្នាំ ២០១៥ ដល់ ២០១៧)

តារាងទី៤: ទិន្នន័យរបស់ (MFIs) គិតត្រឹមឆ្នាំ២០១៥ ដល់២០១៧ (គិតជាលានរៀល)

| ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) | ឆ្នាំ (គិតលានរៀល) | | |
|---|---|---|---|
| | 2015 | 2016 | 2017 |
| ទ្រព្យសកម្ម | 1,714,170.00 | 2,239,887 | 2,862,484 |
| ដើមទុនបានចុះបញ្ជី | 565,206 | 821,676.12 | 1,100,362.90 |
| ប្រាក់បញ្ញើសរុប | 1,783 | 1,884 | N/A |
| ឥណទានសរុប | 1,297,131 | 1,793,006 | 2,266,829 |
| ប្រាក់ចំណេញសុទ្ធ | 34,403 | 59,804 | 44,761 |

ប្រភព: ធនាគារជាតិនៃកម្ពុជា, របាយការណ៍ទិន្នន័យរបស់(MFIs) (ឆ្នាំ ២០១៥ ដល់ ២០១៧)

## ២.២. វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

ក្រៅពីគ្រឹះស្ថានធនាគារ ក៏មានអ្នកផ្តល់សេវាមិនមែនធនាគារដែលដើរតួនាទីជាអ្នកដំណើរការតតិយភាគីផងដែរ។ អ្នកដំណើរការតតិយភាគី គឺជាគ្រឹះស្ថានមួយដែលផ្តល់សិទ្ធដោយធនាគារក្នុងការផ្តល់នូវសេវាទូទាត់សងប្រាក់មួយឬច្រើនប្រភេទឲ្យទៅអតិថិជន។ អ្នកដំណើរការតតិយភាគីត្រូវបានផ្តល់សិទ្ធតាមរយៈការចុះកិច្ចព្រមព្រៀងជាមួយធនាគារ និងត្រូវស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។ អនុលោមទៅតាមច្បាប់ ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ អ្នកដំណើរការតតិយភាគីអាចធ្វើសកម្មភាពជំនួសឲ្យធនាគារដែលបានផ្តល់សិទ្ធដូចខាងក្រោម៖ [30]

- ជាកន្លែងផ្តល់សេវាទំនាក់ទំនង

[30] https://www.nbc.org.kh/payment_systems/non_bank_institutions.php

- ជាកន្លែងផាត់ទាត់អន្តរធនាគារដែលអាចនឹងបញ្ជូនព័ត៌មានស្តីពីការទូទាត់អន្តរធនាគារ រួមទាំងធនាគារដែលការទូទាត់ត្រូវបានបញ្ចប់
- ជាអ្នកផ្តល់សេវាផ្ទេរប្រាក់តាមរយៈទូរស័ព្ទ ឬមធ្យោបាយផ្សេងទៀត
- ជាអ្នកគ្រប់គ្រងឬភ្នាក់ងារប្រតិបត្តិការណ៍សម្រាប់គណនីធនាគារឬអតិថិជន
- ជាអ្នកផ្ញើឬបញ្ជូនបញ្ជាទូទាត់ប្រាក់ដែលបានផ្ញើ ឬទទួលដោយធនាគារ

### ២.២.១.ធានារ៉ាប់រង[31]

វិស័យធានារ៉ាប់រងនៅកម្ពុជា នៅតែបន្តការរីកចម្រើនគួរឲ្យកត់សម្គាល់នៅក្នុងឆ្នាំ២០១៨ ដោយបុព្វលាភធានារ៉ាប់រងដុលបានកើនឡើងជិត៣០% ធៀបទៅនឹងឆ្នាំ២០១៧ ពី១៥១,៦ លានដុល្លារអាមេរិកទៅ ១៩៦,៤ លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។ កំណើននេះមានការចូលរួមចំណែកពីការកើនឡើងនៃវិស័យធានារ៉ាប់រងទូទៅចំនួន១៥% និងចំនួន៥០,៦% នៃវិស័យធានារ៉ាប់រងអាយុជីវិត។ វិស័យធានារ៉ាប់រងទូទៅ និងអាយុជីវិតនៅកម្ពុជានៅតែបន្តការរីកច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ គិតត្រឹមឆ្នាំ២០១៨ នៅកម្ពុជាមានក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន ១២ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន៨ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៨ ក្រុមហ៊ុនទីផ្សារធានារ៉ាប់រងចំនួន ១២ ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន១៦ ក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន១ និងក្រុមហ៊ុនវាយតម្លៃហានិភ័យចំនួន២ កំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា។ សមាគមន៍ធានារ៉ាប់រងកម្ពុជាបានឲ្យដឹងថា កំណើនជាមធ្យមប្រចាំឆ្នាំចាប់ពីឆ្នាំ២០១៣ ដល់២០១៨ គឺស្ថិតក្នុងកម្រិត១៥,៧% សម្រាប់វិស័យធានារ៉ាប់ទូទៅ និង ១២០,៥៥% សម្រាប់វិស័យធានារ៉ាប់រងអាយុជីវិត។

វិស័យធានារ៉ាប់រង បានបោះទុនជាទឹកប្រាក់សរុបចំនួន ១១២លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះ ផ្នែកធានារ៉ាប់រងទូទៅមានចំនួន ៥៤.៤លានដុល្លារសហរដ្ឋអាមេរិក ធានារ៉ាប់រងអាយុ-ជីវិត ៤៩.៧លានដុល្លារសហរដ្ឋអាមេរិក ធានារ៉ាប់រងខ្នាតតូចចំនួន ៧.៣លានដុល្លារសហរដ្ឋអាមរិក។ វិស័យធានារ៉ាប់រង ត្រូវបានរាជរដ្ឋាភិបាល ចាត់ទុកជាសសរស្តម្ភមួយនៃវិស័យហិរញ្ញវត្ថុបន្ទាប់ពីវិស័យធនាគារ និងទីផ្សារមូលបត្រ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៦-២០២៥ ដែលក្នុងនោះ សកម្មភាពអាទិភាពចម្បងៗមួយចំនួនត្រូវបានដាក់ចេញយ៉ាងច្បាស់ ដូចជាការលើកកម្ពស់បរិស្ថាន បទប្បញ្ញត្តិ ឲ្យកាន់តែប្រសើរ ការពង្រឹងយន្តការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារឱ្យកាន់តែមានស្តង់ដារខ្ពស់ ស្របតាមភាពចាំបាច់នៃការអភិវឌ្ឍ ទីផ្សារធានា

[31] សមាគមន៍ធានារ៉ាប់រងកម្ពុជា

រ៉ាប់រងនៅកម្ពុជា។ វិស័យទាំងបីនេះ ជាដៃគូបំពេញគ្នាទៅវិញទៅមក ដើម្បីជំរុញវិស័យហិរញ្ញវត្ថុឲ្យមានការរីកចម្រើន។

ដោយសារប្រជាជនកម្ពុជាកាន់តែច្រើនឡើងបានយល់ដឹងពី សារៈសំខាន់នៃការធានារ៉ាប់រង ប្រធានសមាគមន៍ធានារ៉ាប់រងកម្ពុជាបានរំពឹងថា វិស័យនេះនឹងនៅតែបន្តការរីកចម្រើនខ្លាំងក្នុងឆ្នាំ២០១៩ និងនៅឆ្នាំបន្តបន្ទាប់ទៀត។ សមិទ្ធផលនៃវិស័យធានារ៉ាប់នៅក្នុងឆ្នាំ២០១៨ ធ្វើឲ្យគេកាន់តែមានទំនុកចិត្តចំពោះការវិវឌ្ឍន៍របស់វិស័យនេះ។ ជាក់ស្តែង កត្តាសំខាន់ៗដែលរួមចំណែកក្នុងការធ្វើឲ្យរីកចម្រើនរបស់វិស័យធានារ៉ាប់រងទូទៅមានដូចជា៖ ធានារ៉ាប់រងយានយន្តមានកំណើន ២៦,៣% ធានារ៉ាប់រងទ្រព្យសម្បត្តិឬអគ្គិភ័យ ១៥,២% និងធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលនិងសុខភាព ១២,១%។ ការចូលរួមពីវិស័យធានារ៉ាប់រងទូទៅ និងវិស័យធានារ៉ាប់រងខ្នាតតូចក្នុងការការពារអាជីវកម្ម និងបុគ្គលពីការបាត់បង់ផ្នែកហិរញ្ញវត្ថុដោយសារហានិភ័យនានា ដែលមានសំណងគិតជាទឹកប្រាក់សរុបមានចំនួន ២២,៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។

ជាមួយនឹងការទទួលបានបុព្វលាភដ៏ច្រើនសន្ធឹកសន្ធាប់នេះ វិស័យធានារ៉ាប់រងបានជួយដល់ការលើកស្ទួយវិស័យហិរញ្ញវត្ថុនៅកម្ពុជាយ៉ាងខ្លាំង និងផ្នែកផ្សេងៗទៀតនៃសេដ្ឋកិច្ចដោយក្រុមហ៊ុនធានារ៉ាប់រង យកមូលធនដែលទទួលបានតាមរយៈបុព្វលាភទាំងនោះទៅវិនិយោគបន្តដូចជា បង្វែមូលធនដែលទទួលបានទៅក្រុមហ៊ុនសាជីវកម្ម និងស្ថាប័នផ្សេងៗដ៏ទៀតដែលកំពុងត្រូវការមូលធនជាដើមទុនសម្រាប់ពង្រីកប្រតិបត្តិការរបស់ខ្លួនតាមរយៈវិស័យមូលបត្រជាអន្តរការីដែលពួកគេទិញសញ្ញាបណ្ណសាជីវកម្ម ដែលបោះផ្សាយដោយសហគ្រាសសាជីវកម្ម ឬស្ថាប័នមីក្រូហិរញ្ញវត្ថុដែលចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រកម្ពុជា។ ក្រៅពីជំរុញ និងពង្រឹងវិស័យហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង បានចូលរួមធ្វើឲ្យវិស័យមូលបត្រនៅកម្ពុជាកាន់តែមានសន្ទុះកាន់តែខ្លាំងក្លាជាពិសេសទីផ្សារមូលបត្រកម្ពុជា ដែលអាចធ្វើឲ្យពួកគេរកប្រាក់ចំណេញបន្ថែមតាមរយៈការប្រាក់ និងជំរុញសហគ្រាសសាជីវកម្មដទៃទៀតឲ្យកាន់តែមានកំណើន ជាពិសេសក្នុងការចូលរួមបង្កើតសក្តានុពលសេដ្ឋកិច្ចជាតិឲ្យកាន់តែរីកចម្រើន។

### ២.២.២.វិស័យសោធន

រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិចំនួន៣ សម្រាប់គ្រប់គ្រងរបបសោធននៅកម្ពុជាដែលមានដូចជា៖ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (**ប.ជ.ស.**) បេឡាជាតិអតីតយុទ្ធជន (**ប.ជ.អ.**) និងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស.**)។

- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល **(ប.ជ.ស.)** និងបេឡាជាតិអតីតយុទ្ធជន **(ប.ជ.អ.)** ត្រូវបានបង្កើតឡើងដោយស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា។ **ប.ជ.ស.** មានតួនាទីផ្ដល់តាវកាលិកចំនួន៦ដល់មន្ត្រីរាជការស៊ីវិលៈ (១)សោធននិវត្តជន(២)សោធនពិការភាព (៣) មាតុភាព (៤) មរណភាព (៥) អ្នកនៅក្នុងបន្ទុក និង (៦) គ្រោះថ្នាក់ការងារ។ ចំណែក **ប.ជ.អ.** វិញមានតួនាទីជាអ្នកចាត់ចែងតាវកាលិកសម្រាប់អតីតយុទ្ធជនមួយចំនួនដូចជាៈការចូលនិវត្តន៍ការបាត់បង់សមត្ថភាពការងារការលំហែមាតុភាពអាពាហ៍ពិពាហ៍ដំបូង ពលីមរណភាព និងអ្នកនៅក្នុងបន្ទុក។
- បេឡាជាតិរបបសន្តិសុខសង្គម **(ប.ស.ស.)** ដែលត្រូវបានបង្កើតឡើង និងស្ថិតនៅក្រោមអាណាព្យាបាលក្រសួងរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គឺជាស្ថាប័នដែលមានតួនាទីគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គម សម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[32]

មូលនិធិសោធនទាំងនោះ បង្កើតឡើងដើម្បីជាផ្នែកមួយនៃការគាំពារសង្គម និងដើម្បីកសាងមធ្យោបាយនានា ក្នុងការបង្កើតកញ្ចប់សាច់ប្រាក់ដែលអាចយកទៅវិនិយោគនៅក្នុងវិស័យហិរញ្ញវត្ថុរយៈពេលវែង។

## ២.៣. ស្ថានភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន[33]

ស្ថិតនៅក្នុងបរិស្ថានអំណោយផលពីកំណើនសេដ្ឋកិច្ចពិភពលោក បានចូលរួមចំណែកគាំទ្រដល់ការរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ចចម្បងៗរបស់កម្ពុជា ស្របពេលដែលជំនឿទុកចិត្ត និងទស្សនវិស័យវិនិយោគិនមកលើកម្ពុជាមានភាពរឹងមាំ និងវិជ្ជមាន។ កំណើននៃការនាំចេញវិស័យសំណង់ និងទេសចរណ៍ នៅតែបន្តជាសសរស្ដម្ភនៃកំណើនសេដ្ឋកិច្ច ខណៈដែលវិស័យកសិកម្មនៅតែមានកំណើនទាប។ ជាមួយនឹងភាពអំណោយផលទាំងនេះ សេដ្ឋកិច្ចកម្ពុជា សម្រេចបានកំណើនល្អប្រសើរនៅឆ្នាំ២០១៨ ក្នុងអត្រា ៧,៣%។

បច្ចុប្បន្ននេះ ដោយមានការរីកចំរើនស្ទើគ្រប់វិស័យបានធ្វើឲ្យសេដ្ឋកិច្ចប្រទេសកម្ពុជារីកចម្រើនខ្លាំងគួរឲ្យកត់សម្គាល់ ខាងក្រោមនេះជាវិស័យសំខាន់ៗដែលជាសសរស្តម្ភនៃកំណើនសេដ្ឋកិច្ចជាតិ មានដូចជាៈ

---

[32] យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០១៥, ទំព័រ ៤០

[33] របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិកម្ពុជា, (ភ្នំពេញ ២០១៨)

**ក. វិស័យកសិកម្ម**

វិស័យកសិកម្មបានរួមចំណែក ១៨,១% នៃ**ផ.ស.ស.** បានបន្តកើនឡើងក្នុងល្បឿនយឺត និងត្រូវបានប៉ាន់ស្មានថាមានកំណើនប្រមាណ ១,៣% ទាបជាងឆ្នាំមុនបន្តិច (១,៧%) ដែលបណ្តាលមកពីផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់ និងកង្វះទឹកនៅតំបន់មួយចំនួនដែលធ្វើឲ្យប៉ះពាល់ដល់ដំណាំនិងការចិញ្ចឹមសត្វ ទោះជាផលបានពីការនេសាទមានកំណើនបង្គួរក៏ដោយ។ គ្រោះទឹកជំនន់ទន្លេមេគង្គដែលបណ្តាលមកពីការបាក់ទំនប់វារីអគ្គិសនីនៅប្រទេសឡាវ គួបផ្សំនឹងទឹកជំនន់ទឹកភ្លៀង និងដោយសារនៅរដូវវស្សានេះមានតំបន់មួយចំនួនមិនសូវមានទឹកភ្លៀងបានធ្វើឲ្យខូចខាតផ្ទៃដីដាំដុះស្រូវប្រមាណ ២៣០,៦ពាន់ហិកតា និងដំណាំរួមផ្សំ ៨,៣ពាន់ហិកតាព្រមទាំងប៉ះពាល់ដល់ការចិញ្ចឹមសត្វផងដែរ។

បរិមាណផលស្រូវរដូវប្រាំងបានកើនប្រមាណ ៦,៧% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុនដល់ ២,៥ លានតោន ហើយទិន្នផលស្រូវប្រាំងបានកើនពី៤,៤៧ តោនក្នុងមួយហិកតានៅឆ្នាំ២០១៧ ដល់ ៤,៥១ តោនក្នុងមួយហិកតា។ ទន្ទឹមនិងនេះផ្ទៃដីដាំដុះដំណាំឧស្សាហកម្មនិងដំណាំរួមផ្សំរដូវប្រាំងបានកើនឡើង ២,៤ ដង និង ៤០,៦% រៀងគ្នា។ ជាមួយគ្នានេះ ទំហំផ្ទៃដីដាំដុះស្រូវរដូវវស្សានិងដំណាំឧស្សាហកម្មបានកើនឡើង ៤,៥% និង ៥,៨% រៀងគ្នា ធៀបនឹងឆ្នាំមុន ខណៈផ្ទៃដីដាំដុះដំណាំរួមផ្សំបានថយចុះប្រមាណ ៤,៥%។ បរិមាណផលស្រូវរដូវវស្សាសម្រេចបាន៣លានតោន (៣២,៤%នៃផ្ទៃដីដាំដុះ) ដោយកើនឡើង ៩,៨%។ វិស័យជលផលបន្តមានកំណើនល្អបង្គួរក្នុងអត្រា ៨,៦%ដោយសារការកើនឡើងនៃផលនេសាទ និងផលពីការចិញ្ចឹមត្រីនិងបង្គា។

ការនាំចេញកៅស៊ូ(គិតជាតម្លៃ)ត្រូវបានប៉ាន់ស្មានថាត្រូវធ្លាក់ចុះប្រមាណ១២% ដោយសារតម្លៃកៅស៊ូមានការធ្លាក់ចុះនៅឆ្នាំ២០១៨នេះប៉ុន្តែបើគិតជាប្រមាណបានកើនឡើង៨%។ ទីផ្សារនាំចេញកៅស៊ូចម្បងៗរបស់កម្ពុជារួមមាន៖ ប្រទេសជប៉ុន កូរ៉េ ម៉ាឡេស៊ី វៀតណាម សង្ហបុរី និងចិន។ ចំណែកឯការនាំចេញអង្ករ (គិតជាតម្លៃ)បានកើនឡើង ២៨% ហើយការនាំចេញគិតជាបរិមាណបានកើនត្រឹម ២% ដែលភាគច្រើននាំចេញទៅប្រទេសចិន បារាំង និងម៉ាឡេស៊ី។

នៅឆ្នាំ២០១៩ វិស័យកសិកម្មត្រូវបានរំពឹងឡើងខ្ពស់ជាងឆ្នាំ២០១៨បន្តិច ក្នុងអត្រា២% ដោយសារកំណើនលំហូរចូលនៃវិនិយោគផ្ទាល់បរទេស យន្តូបនីយកម្មកសិកម្ម និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យនេះ។ ទោះយ៉ាងណា វិស័យកសិកម្មនៅមានបញ្ហាប្រឈមមួយចំនួនដូចជា ការកើនឡើងថ្លៃដើមផលិតកម្ម និងភាពមិននិងនរនៃទីផ្សារផលិតផលកសិកម្ម ស្របពេលដែលបច្ចេកទេសដាំដុះនិងការធ្វើទំនើបកម្មនៅមានកម្រិតនៅឡើយ។

**ខ. វិស័យឧស្សាហកម្ម**

វិស័យឧស្សាហកម្មនៅតែបន្តគាំទ្រជាចម្បងដោយកំណើនក្នុងវិស័យកម្មន្តសាលនិងការបន្តកំណើតក្នុងវិស័យសំណង់។ វិស័យនេះមានកំណើន ១០,៥% ធៀបនឹង ៩,៧% នៅឆ្នាំ២០១៧ ហើយបានរួមចំណែកប្រមាណ ៣៤,៩% ក្នុង **ផ.ស.ស.**។

- **វិស័យកម្មន្តសាល**

វិស័យកម្មន្តសាល បន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាកំណើនសេដ្ឋកិច្ចកម្ពុជាដែលវិស័យនេះអាចផ្តល់ការងារជូនប្រជាពលរដ្ឋប្រមាណ១លាននាក់ ក្នុងនោះចំនួនពលកម្មផ្នែកកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងមានចំនួនប្រមាណ៨០ម៉ឺននាក់។ ចំនួនរោងចក្រសរុបមានចំនួន ១.៥៨៥ រោងចក្រ កើនឡើង ៤,១% ធៀបនឹងឆ្នាំ២០១៧ ក្នុងនោះរោងចក្រដែលបានបើកថ្មីមាន ១៥៦ រោងចក្រ។ ទន្ទឹមនឹងនេះ រោងចក្រផលិតទំនិញសម្រាប់ការធ្វើដំណើរបានកើនឡើងគួរឲ្យកត់សម្គាល់ដែលបង្ហាញពីឥទ្ធិពលវិជ្ជមានពីសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិនមកលើវិស័យនេះ។

ការនាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនៅឆ្នាំនេះ សម្រេចបានប្រមាណ ១០ ប៊ីលានដុល្លារអាមេរិក(៧៣,៧%នៃការនាំចេញសរុប) និងបានកើនឡើងគួរកត់សម្គាល់ក្នុងអត្រា ២៤,៧% ស្របពេលដែលការនាំចេញផលិតផលកម្មន្តសាលផ្សេងទៀតបានបន្តកើតឡើងដូចជា គ្រឿងបន្លាស់យានយន្ត (៣ដង) និងទោចក្រយាន (១២%)។ កំណើននៃការនាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងត្រូវបានជំរុញដោយភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក ជាពិសេសប្រទេសគោលដៅនាំចេញចម្បងៗដូចជាសហភាពអឺរ៉ុប (៤៦% នៃការនាំចេញផលិតផលកាត់ដេរសរុប) សហរដ្ឋអាមេរិក (២៤%) កាណាដា (៩%) និងជប៉ុន (៨%)។

- **វិស័យសំណង់**

ក្នុងរយៈពេល ១ទសវត្សរ៍ចុងក្រោយនេះវិស័យសំណង់បន្តមានកំណើនរឹងមាំ ដែលទាក់ទាញវិនិយោគិនជាច្រើន និងបានចូលរួមកាន់តែច្រើន និងបានចូលរួមកាន់តែច្រើនក្នុងកំណើនសេដ្ឋកិច្ច។ នៅឆ្នាំ២០១៨នេះ វិស័យសំណង់ត្រូវបានប៉ាន់ស្មានថាថយល្បឿនបន្តិចមក១៧% (១៨%នៅឆ្នាំមុន) ដែលបានរួមចំណែកប្រមាណ១/៥ នៅក្នុងកំណើនសេដ្ឋកកិច្ច។ វឌ្ឍនភាពក្នុងវិស័យនេះឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗដូចជា ការកើនឡើងការនាំចូលសម្ភារៈសំណង់ (១៥%) កំណើនឥណទានចំពោះវិស័យសំណង់ (២៣%) និងផ្ទៃក្រលាសំណង់សរុប (៨% ជា

សំណង់លំនៅដ្ឋាន)ហើយតម្លៃគម្រោងបានធ្លាក់ចុះ២០%។ វិស័យសំណងបានផ្តល់ការងារឲ្យអ្នកជំនាញនិងកម្មករប្រមាណ ២២ម៉ឺននាក់ ដែលធ្វើការតាមការដ្ឋាសំណង់ទូទាំងប្រទេស ហើយវិនិយោគិនបរទេសភាគច្រើនមកពីប្រទេសចិន កូរ៉េ ជប៉ុន ថៃ តៃវ៉ាន់ សិង្ហបុរី និងអង់គ្លេស។

នៅឆ្នាំ២០១៩ វិស័យឧស្សាហកម្មត្រូវបានរំពឹងថាមានកំណើនប្រមាណ១១% ដែលបន្តគាំទ្រជាចម្បងដោយកំណើននៃវិស័យកម្មន្តសាល និងសំណង់។ ទោះជាយ៉ាងណា វិស័យឧស្សាហកម្មជាពិសេស វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងនៅតែបន្តមានបញ្ហាប្រឈមលើការរក្សាវថ្លៃប្រកួតប្រជែងក្នុងតំបន់ (វៀតណាម បង់ក្លាដែស និងមីយ៉ាន់ម៉ា) ដោយសារប្រាក់ ឈ្នួលអប្បបរមារបស់កម្ពុជាបានបន្តកើនឡើងយ៉ាងឆាប់រហ័ស ការប្រឈមនឹងការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងអាវុធពីសហភាពអឺរ៉ុប (EBA) ការអនុវត្តកិច្ចព្រមព្រៀងភាពជាដៃអន្តរប៉ាស៊ីហ្វិក (CPTPP) និងកិច្ចព្រមព្រៀងទ្វេភាគីរវាងសហភាពអឺរ៉ុប និងអាមេរិកជាមួយដៃគូរប្រកួតប្រជែងនឹងការនាំចេញរបស់កម្ពុជា។ ក្នុងឆ្នាំនេះ ប្រាក់ឈ្នួលអប្ប-បរមារបស់កម្ពុជាត្រូវបានតំឡើងពី១៥៣ដុល្លារអាមេរិកក្នុង១ខែនៅឆ្នាំ២០១៧ ដល់១៧០ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ប្រហាក់ប្រហែលនឹងប្រទេសវៀតណាម តែខ្ពស់ជាងប្រទេសបង់ក្លាសដែស និងមីយ៉ាន់ម៉ា ហើយនៅឆ្នាំ២០១៩ ខាងមុខប្រាក់ឈ្នួលអប្បបរមារបស់កម្ពុជានឹងត្រូវតំឡើងដល់ ១៨២ ដុល្លារអាមេរិកក្នុងមួយខែ។

**គ.វិស័យសេវាកម្ម**

វិស័យសេវាកម្មដែលមានសមាមាត្រ ៣៩,៤% ក្នុង**ផ.ស.ស** បន្តមានកំណើតរឹងមាំក្នុងអត្រា ៦.៨% តែថយចុះបន្តិចធៀបនឹងឆ្នាំមុន (៧%)។ កំណើតនេះត្រូវបានជំរុញដោយសន្ទុះនៃតម្រូវការក្នុងវិស័យពាណិជ្ជកម្ម និងដឹកជញ្ជូន ដែលគាំទ្រដោយកំណើននៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋានដែលត្រូវបានគ្រាំទ្រដោយកំណើនភ្ញៀវទេសចរ គួបផ្សំនឹងការរីកលូតលាស់នៃវិស័យឧស្សាហកម្ម។

ភ្ញៀវទេសចរអន្តរជាតិបានកើនឡើងដល់ ៦,២ លាននាក់ដែលគិតជាកំណើនមាន អត្រា ១១,៥% ទាបជាឆ្នាំមុនបន្តិច (១១,៨%)។ កំណើតភ្ញៀវទេសចរត្រូវបានគាំទ្រជាចម្បងដោយភ្ញៀវទេសចរចិនដែលបានកើនឡើងរហូតដល់៧១% (៤៦%នៅឆ្នាំមុន) ដោយឈរនៅលំដាប់លេខ១ ខណៈដែលភ្ញៀវទេសចរវៀតណាម (ថយ ៥%) និងឡាវ (ថយ ១៩%) ឈរនៅលំដាប់លេង២ និងលេខ៣រៀងគ្នា។ កិច្ចសហប្រតិបត្តិការណ៍ល្អលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុរវាងកម្ពុជា និងចិនគឺជាកត្តាដ៏សំខាន់មួយក្នុងការរួមចំណែកទាក់ទាញភ្ញៀវទេសចរចិនបន្ថែមលើការបង្កើនការផ្សព្វ-

ផ្សាយពីគោលដៅទេសចរណ៍របស់កម្ពុជា នៅក្នុងប្រទេសចិនការអភិវឌ្ឍ និងលើកកម្ពស់បដិស-ណ្ឋារកិច្ចរបស់កម្ពុជាសម្រាប់ទទួលភ្ញៀវទេសចរចិន និងការបង្កើនជើងយន្តហោះហើររវាងតំបន់ជាច្រើននៃប្រទេសចិន និងប្រទេសកម្ពុជា។ ទោះយ៉ាងណា ភ្ញៀវទេសចរមកពីបណ្តាលប្រទេសក្រៅពីចិនបានថយចុះជាបន្តបន្ទាប់ជាពិសេសភ្ញៀវទេសចរមកពីទ្វីបអឺរ៉ុប អាមេរិក និងអូសេអានីដោយបានថយចុះ ៦% ៣% និង ៨%រៀងគ្នា។

រាជធានីភ្នំពេញគឺជាគោលដៅទេសចរណ៍ធំជាងគេដោយទទួលបានសមាមាត្រភ្ញៀវទេសចរអន្តរជាតិប្រមាណ៤៨% បន្ទាប់មកគឺខេត្តសៀមរាប (៣៧%) តំបន់ឆ្នេរ (២៥%) និងអេកូទេសចរណ៍(១%)។ កំណើនភ្ញៀវទេសចរដែលចូលទស្សនាតំបន់អង្គរបានថយល្បឿននៅត្រឹមប្រមាណ ៦%ធៀប១២% នៅឆ្នាំមុន ហើយចំណូលពីការលក់សំបុត្រមានប្រមាណ ១០៥ លានដុល្លារអាមេរិក (កើន៩%ធៀបនិង ៧៣%នៅឆ្នាំ២០១៧)។ គួរកត់សម្គាល់ថា សមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិដែលមកកម្ពុជាក្នុងគោលបំណងធុរកិច្ចបានកើនឡើងដល់ ១១% ធៀបនឹង ៧% នៅឆ្នាំ២០១៧។

នៅឆ្នាំ២០១៩ វិស័យសេវាកម្មត្រូវបានរំពឹងថាបន្តមានកំណើនប្រមាណ ៧% ដែលគាំទ្រដោយភាពល្អប្រសើរនៃវិស័យទេសចរណ៍ អចលនទ្រព្យ និងឧស្សាហកម្ម។ ចំនួនភ្ញៀវទេសចររំពឹងថាកើនដល់ប្រមាណ ៦,៦លាននាក់ ដែលគាំទ្រជាចម្បងដោយការបន្តកើនឡើងនៃភ្ញៀវទេសចរចិន ទោះយ៉ាងណា វិស័យសេវាកម្មនៅប្រឈមនឹងបញ្ហាមួយចំនួនដូចជា កង្វះពិពិធកម្មភ្ញៀវទេសចរនិងគោលដៅទេសចរណ៍ ការទាក់ទាញភ្ញៀវទេសចរដែលមានចំណូលខ្ពស់នៅមានកំណត់និងកង្វះហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។

## ២.៤. ស្ថានភាពជញ្ជីងទូទាត់

ស្ថិតនៅក្រោមស្ថានភាពអំណោយផលនៃកំណើនសេដ្ឋកិច្ចពិភពលោក និងភាពប្រសើរឡើងនៃសេដ្ឋកិច្ចក្នុងស្រុក ជញ្ជីងទូទាត់កម្ពុជាបន្តមានអតិរេកប្រមាណ ១,១ប៊ីលានដុល្លារអាមេរិក ឬស្មើនឹង ៤,៥% នៃ **ផ.ស.ស.**។ បើធៀបនឹងឆ្នាំ ២០១៧ (៧,៣% នៃ **ផ.ស.ស.**) អតិរេកនេះមានកម្រិតទាបជាង ដែលកត្តាចម្បងបណ្តាលមកពីការកើនឡើងនៃឱនភាពជញ្ជីងពាណិជ្ជកម្មទំនិញ និងការថយចុះអតិរេកបង្វែចរន្ត ស្របពេលដែលលំហូរចូលសុទ្ធគណនីដើមទុននិងហិរញ្ញវត្ថុបានថយល្បឿន។ ការបន្តទទួលបានអតិរេកជញ្ជីងទូទាត់ បានបង្កើនទុនបម្រុងអន្តរជាតិឲ្យកើនឡើងជាលំដាប់ដល់ប្រមាណ ១០ ប៊ីលានដុល្លារអាមេរិក ឬប្រាមាណ ៨០% នៃបំណុលក្រៅប្រទេស

និងអាចធានាបានការនាំចូលទំនិញ និងសេវាកម្មសម្រាប់ឆ្នាំ២០១៩ បានប្រមាណ ៥ខែ។ គួរកត់សម្គាល់ថា ក្នុងរយៈពេល ២ទសវត្សរ៍នេះ ទុនបម្រុងអន្តរជាតិដុលបានបន្តការកើនឡើងប្រមាណ ២៥ដង ពីកម្រិតត្រឹមតែ ៣៩០លានដុល្លាអាមេរិកប៉ុណ្ណោះនៅឆ្នាំ១៩៩៨។

**ក. គណនីចរន្ត**

ឱនភាពគណនីចរន្តធៀបនឹង**ផ.ស.ស.** បានកើនឡើង១,៨% ទោះបីជាការនាំចេញមានកំណើនលឿន និងអតិរេកគណនីសេវាមានភាពប្រសើរឡើងក៏ដោយ។ គណនីចរន្តមានឱនភាព ២,៥ប៊ីលានដុល្លាអាមេរិក ឬ ៩,៨% នៃ**ផ.ស.ស.** ធៀបនឹង ៨% នៃ**ផ.ស.ស.** ឆ្នាំមុន។ ឱនភាពគណនីចរន្តកើនឡើងដោយកំណើនឱនភាពនៃជញ្ជីងពាណិជ្ជកម្មទំនិញរួមនឹងការថយចុះអតិរេកគណនីបង្វែចរន្ត។

ឱនភាពជញ្ជីងពាណិជ្ជកម្មបានកើណឡើង ២,៣% នៃ**ផ.ស.ស.** ដោយសារតែការនាំចូលទំនិញមានកំណើនលឿនជាងការនាំចេញ។ ការនាំចូលបានកើនឡើង ២១,៣% ធៀបនឹង ៩,៨% ក្នុងឆ្នាំ២០១៧ កំណើនតម្រូវការក្នុងស្រុក លើផលិតផលមួយចំនួនដូចជា សម្ភារៈសំណង់ យានយន្ត និងគ្រឿងបរិភោគ គួបផ្សំនឹងការកើនឡើងថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិ និងកំណើនតម្រូវការវត្ថុធាតុដើមពីបរទេសសម្រាប់ផលិតផលនាំចេញ (ក្នុងវិស័យកាត់ដេរ) គឺជាកត្តាចម្បងជំរុញកំណើនការនាំចូល។

កំណើនការនាំចេញទំនិញបានកើនឡើង ២១% ធៀបនឹងឆ្នាំមុន ៩%។ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងបានកើនឡើង ២៤,៧% ស្របពេលការនាំចេញផលិតផលចម្បងៗផ្សេងទៀតដូចជា៖ ទោចក្រយាន បរិក្ខាអគ្គិសនី និងគ្រឿងបន្លាស់យានយន្ត បានរួមចំណែកដល់កំណើននាំចេញសរុប។ គួរបបញ្ជាក់ថា សមាមាត្រនៃការនាំចេញផលិតផលកាត់ដេរបានថយចុះពី ៩៦% មក៧៤% ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ។ ការនាំចេញទោចក្រយាន បរិក្ខាអគ្គិសនី និងគ្រឿងបន្លាស់យានយន្តរួមគ្នាដែលមានសមាមាត្រ ៥% នៃការនាំចេញទំនិញសរុប និង ២០% នៃការនាំចេញផលិតផលក្រៅពីសម្លៀកបំពាក់ និងស្បែកជើងបានកើនឡើងសន្សឹមៗ។

ក្រៅពីជញ្ជីងពាណិជ្ជកម្មទំនិញ ឱនភាពគណនីចរន្តក៏បានរួមចំណែកដោយការថមថយអតិរេកបង្វែចរន្ត និងកំណើនតិចតួចនៃឱនភាពគណនីប្រាក់ចំណូល ខណៈដែលកំណើនអតិរេកសេវាសុទ្ធបានជួយជាត់ទាត់មួយផ្នែកលើឱនភាពនេះ។ ការថយចុះបង្វែរាជរដ្ឋាភិបាលក្រោមទម្រង់ ជាជំនួយក្រោយពីប្រទេសកម្ពុជាបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបបានរួមចំណែកនាំឲ្យអតិរេកគណនីបង្វែសុទ្ធធៀបនឹង**ផ.ស.ស.** បានថយចុះ(ប្រមាណ ១% នៃ**ផ.ស.ស.**)

ខណៈដែលចំណូលពីវិស័យទេសចរណ៍បានជួយឲ្យគណនីសេវាសុទ្ធកើនឡើង (ប្រមាណ ១,៥% នៃ**ផ.ស.ស**)។

**ខ. គណនីដើមទុន និងហិរញ្ញវត្ថុ**

លំហូរចូលរឹងមាំនៃវិនិយោគផ្ទាល់បរទេស បានជួយឲ្យគណនីដើមទុននិងហិរញ្ញវត្ថុបន្តជាត់ទាត់ឱនភាពគណនីចរន្តទាំងស្រុង ព្រមទាំងជួយគរពូនទុនបម្រុងអន្តរជាតិឲ្យកើនឡើងជាលំដាប់។ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធដែលមានសមាមាត្រ ១២,៧% នៃ**ផ.ស.ស** បានកើនឡើងធៀបនឹងឆ្នាំមុន (១២%)។

វិស័យធនាគារ និងអចលនទ្រព្យទទួលបានលំហូរវិនិយោគផ្ទាល់ បរទេសយ៉ាងរឹងមាំស្របពេលដែលលំហូរវិនិយោគផ្ទាល់បរទេសក្នុងវិស័យកម្មន្តសាល និងកសិកម្មបាននូវកំណើនឡើងវិញចាប់ពីឆ្នាំ២០១៧មក បន្ទាប់ពីបានថយចុះជាបន្តបន្ទាប់នាប៉ុន្មានឆ្នាំចុងក្រោយ។ សម្រាប់ឆ្នាំ ២០១៩ ស្ថានភាពជញ្ជីងទូទាត់បានព្យាករថានឹងរក្សាបានភាពល្អប្រសើរ ដែលគាំទ្រដោយលំហូរវិនិយោគទុនបរទេស ការនាំចេញ និងវិស័យទេសចរណ៍។ អតិរេកជញ្ជីងទូទាត់រំពឹងថាមានកម្រិត ៥% នៃ**ផ.ស.ស.** ដែលនឹងបន្តរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិឲ្យកើនឡើងដល់ ១១,៣ប៊ីលានដុល្លាអាមេរិក ដែលអាចធានាការនាំចូលទំនិញនិងសេវានៅឆ្នាំបន្ទាប់បានប្រមាណជាង ៥ខែ។

**គ. ការគ្រប់គ្រងទុនបម្រុង**

គោលបំណងចម្បងនៃការគ្រប់គ្រងទុនបម្រុងវិនិយោគ គឺដើម្បីឲ្យធានាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ ដោះស្រាយវិបត្តិជញ្ជីងទូទាត់ ពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុ គរពូនទ្រព្យសម្បត្តិជាតិ និងបង្កើនជំនឿទុកចិត្តមកលើប្រទេស។

- **ការងារវិនិយោគទុនបម្រុងវិនិយោគ**

ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងទុនបម្រុងវិនិយោគ ស្របទៅតាមសេចក្តីណែនាំការវិនិយោគទុនបម្រុងអន្តរជាតិឆ្នាំ២០១៨ និងនិន្នាការទីផ្សារហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន។ ទុនបម្រុងវិនិយោគ ត្រូវបានវិនិយោគក្រោមរូបភាពជាអូវើណាយ ឧបករណ៍ហិរញ្ញវត្ថុរយៈពេលមធ្យម សញ្ញាប័ណ្ណ (រដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ) មាស និងប្រាក់បញ្ញើរយៈពេលខ្លីជាមួយធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ និងគ្រឹះស្ថានធនាគារពាណិជ្ជអន្តរជាតិធំៗដែលមានក្រេឌីតរ៉េតធីងខ្ពស់។ ទន្ទឹមនេះ ធនាគារជាតិកម្ពុជាបានបង្កើតបរិមាណទុនបម្រុងជាមាសជាបន្តបន្ទាប់ ដែលមានសមាមាត្រប្រមាណ ៥%នៃទុនបម្រុងសរុប។ ទុនបម្រុងវិនិយោគសរុបគិតជាប្រាក់ដុល្លារអាមេរិកបានកើនឡើងប្រមាណ ៩,១% ធៀបនឹងឆ្នាំ២០១៧។

- **ការគ្រប់គ្រងហានិភ័យវិនិយោគ**

ការគ្រប់គ្រងហានិភ័យវិនិយោគ មានតួនាទីសំខាន់ក្នុងការគ្រប់គ្រងទុនបម្រុងវិនិយោគ ដើម្បីធានាថាកម្រិតហានិភ័យដែលកំពុងប្រឈមស្ថិតនៅក្នុងកម្រិតដែលបានកំណត់។ ដំណើរការនៃការគ្រប់គ្រងហានិភ័យគឺជាការកំណត់កម្រិតហានិភ័យដែលអាចទទួលយកបាន ការវាស់វែងហានិភ័យ និងការតាមដានកម្រិតហានិភ័យជាទៀងទាត់។ ការកំណត់កម្រិតហានិភ័យ ចាំបាច់ត្រូវគោរពតាមគោលបំណងរួមរបស់ទុនបម្រុងវិនិយោគដែលមានលំដាប់អាទិភាព i. ការរក្សាដើមទុន ii. សន្ទនីយភាព និង iii.ចំណូល។ ជាទូទៅ ការគ្រប់គ្រងទុនបម្រុងវិនិយោគអាចប្រឈមនឹងហានិ-ភ័យសំខាន់ៗដូចជា ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព ហានិភ័យឥណ-ទាន និងហានិភ័យប្រតិបត្តិការ។

នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបែងចែកជាដំណាក់កាលបន្តបន្ទាប់ ដែលដំណាក់កាលចុងក្រោយនេះគឺយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។ ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះឲ្យរីកចម្រើនរដ្ឋាភិបាលកម្ពុជាបានកំណត់យកផែនការសកម្មភាពសម្រាប់អភិវឌ្ឍទៅលើវិស័យដូចជា: (១). វិស័យធនាគារ (២).ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវនកម្ម (៣).វិស័យមីក្រូហិរញ្ញវត្ថុ (៤). ភតិសន្យា (៥). ធានារ៉ាប់រងនិងសោធន(៦). ទីផ្សារទុន និង(៧). អភិបាលកិច្ច និងរចនាសម្ព័ន្ធ។ ក្នុងនោះដែរ ទីផ្សារមូលបត្រក៏ជាធាតុដ៏សំខាន់មួយក្នុងការចូលរួមអភិឌ្ឍវិស័យហិរញ្ញវត្ថុ ដែលមានតួនាទីជាផ្សារទុនសម្រាប់អាជីវកម្មគ្រប់ប្រភេទដើម្បីពង្រីកប្រតិបត្តិការណ៍របស់ខ្លួន។

គោលដៅនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គឺដើម្បីសម្រេចឲ្យបានប្រព័ន្ធហិរញ្ញវត្ថុមួយប្រកបដោយភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធកម្ម ភាពរឹងមាំ និងបរិយាប័ន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភព និងភាព កាត់បន្ថយភាពក្រីក្រ បង្កើនចំណូលរបស់ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់។

- **ការព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចកម្ពុជា**

ក៏ប៉ុន្តែតាមរយៈរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ចេញផ្សាយនៅថ្ងៃទី ០៦ ខែឧសភានេះ ធនាគារពិភពលោកក៏បានព្រមានដែរថា ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធរបស់

សហភាពអឺរ៉ុប(EBA) និង ប្រព័ន្ធអនុគ្រោះពន្ធរបស់សហរដ្ឋអាមេរិក(GSP) នឹងបង្កហានិភ័យខ្លាំងដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅពេលអនាគត។

តាមរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ដែលធ្វើឡើងដោយធនាគារពិភពលោកក្នុងរយៈពេល២ដងក្នុងមួយឆ្នាំ ដើម្បីផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពស្តីពី ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជាក្នុងរយៈពេលខ្លី និងមធ្យម។ ដោយឡែក នៅក្នុងរបាយការណ៍ដាច់ដោយឡែកមួយទៀតដែលធ្វើឡើង កាលពីថ្ងៃទី២៤ ខែមេសា ធនាគារពិភពលោក ឬ World Bank បានព្យាករណ៍ថាប្រទេសកម្ពុជានឹងថមថយអនុភាពបន្តិចវិញ ដោយកំណើនសេដ្ឋកិច្ចកម្ពុជាថយមកនៅជិត ៧% ក្នុងរយៈពេល៣ឆ្នាំខាងមុខនេះគឺអាស្រ័យលើការបន្តមាន ឬគ្មានប្រព័ន្ធអនុគ្រោះពន្ធ (EBA)&(GSP) ពីសហភាពអឺរ៉ុប។[34]

កម្ពុជាកំពុងផ្លាស់ប្តូរឥទ្ធិពលសេដ្ឋកិច្ចពីខាងលិចមកខាងកើត នៅពេលដែលកំពុងស្ថិតក្នុងភាពគ្មានប្រព័ន្ធអនុគ្រោះពន្ធ (EBA)&(GSP) ដែលនេះអាចនឹងធ្វើឲ្យមានផលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ កម្ពុជាកំពុងបង្វែទិសដៅនៃការនាំចេញពីលោកខាងលិចដែលមានដូចជាសហរដ្ឋអាមេរិក អង់គ្លេស និងសហគមន៍អឺរ៉ុប ទៅកាន់លោកខាងកើតដែលមានប្រទេសចិនជាគោលដៅធំរបស់កម្ពុជា ការផ្លាស់ប្តូរនេះ គឺដើម្បីធ្វើឲ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានលំនឹង និងរក្សាស្ថិរភាពកំណើន ដោយកម្ពុជា នឹងបង្កើនសហប្រតិបត្តិការពាណិជ្ជកម្មជាមួយប្រទេសលោកខាងកើត ដូចជាប្រទេសចិន និងជប៉ុនជាដើម ការផ្លាស់ប្តូរនេះអាចធ្វើឲ្យកម្ពុជារក្សាបាននូវកំណើននៃការនាំចេញ និងកាត់បន្ថយផលប៉ះពាល់នៃប្រាក់ចំណូលជាតិ។ តាមគោលនយោបាយរបស់កម្ពុជាបច្ចុប្បន្ន ចិនកំពុងដើរតួនាទីដ៏សំខាន់សម្រាប់រក្សារលំនឹងនៃសេដ្ឋកិច្ចរបស់កម្ពុជា បន្ទាប់ពីកម្ពុជាកំពុងស្ថិតនៅក្នុងការពិចារណាដកប្រព័ន្ធអានុគ្រោះពន្ធពីប្រទេសលោកខាងលិចកាលពីពេលថ្មីៗនេះ។

### ❖ កត្តានុពលនៃក្រុមហ៊ុនខ្នាតតូច មធ្យម និងធំនៅកម្ពុជា

ការមានកំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ធ្វើឲ្យក្រុមហ៊ុន សហគ្រាសសាជីវកម្មខ្នាតតូច មធ្យម និងធំ នៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងធ្វើឲ្យក្រុមហ៊ុនទាំងនោះមានស្ថេរភាពប្រតិបត្តិការ ជាពិសេសមានកំណើនប្រាក់ចំណូលនិងប្រាក់ចំណេញ មានការប្រកួតប្រជែងខ្ពស់ ក្នុងនោះដែរ កម្ពុជាក៏មានវិនិយោគិនដ៏ច្រើនកំពុងតែវិនិយោគស្ទើតែគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា ហើយក្រុមហ៊ុនទាំងនោះកំពុងដែរស្ថិតនៅក្នុងភាពរីកចំរើន ដែលទាំងនេះគឺ

[34] http://km.rfi.fr/cambodia/economy-prediciton-from-WB-06-05-2019

ជាសក្តានុពលសម្រាប់ក្រុមហ៊ុនទាំងនោះមានលទ្ធភាពអាចចុះបញ្ជីបោះផ្សាយលក់មូលបត្រ នៅក្នុងផ្សារមូលបត្រកម្ពុជា ក៏ដូចជាសញ្ញាបណ្ណសាជីវកម្ម ជាពិសេសមូលបត្ររបស់ក្រុមហ៊ុនទាំងនោះអាចទទួលបាននូវការជួញដូរច្រើនពីសំណាក់អ្នកវិនិយោគ និងការកើនឡើងតម្លៃភាគហ៊ុនជាដើម ចំណុចទាំងនេះជាកត្តាដែលចូលរួមក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជាឲ្យកាន់តែរីកចំរើនផងដែរ។ បច្ចុប្បន្ន ក្រុមហ៊ុនសក្តានុពលនៅកម្ពុជាដែលមានលទ្ធភាពអាចចុះបញ្ជីនៅក្នុងផ្សារមូលបត្រមានចំនួនច្រើនប្រមាណ៥០ ទៅ៦០ក្រុមហ៊ុន។

# ជំពូកទី ៣
# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.១. ផ្សារមូលបត្រកម្ពុជា

ផ្សារមូលបត្រកម្ពុជា គឺជាសហគ្រាសចំរុះរដ្ឋ ដែលរួមទុនរវាងរដ្ឋាភិបាលកម្ពុជា (ដំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) កាន់កាប់ភាគហ៊ុនចំនួន ៥៥% និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុន៤៥%។ វាគឺជាឱកាសសម្រាប់វិនិយោគិនក្នុងការចូលរួមក្នុងការវិនិយោគ ហើយក៏អាចរកប្រាក់ចំណេញបានច្រើនជាងការសន្សំប្រាក់នៅក្នុងធនាគារផងដែរ។




## ៣.២. ប្រវត្តិរបស់ផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជានៅ ខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនាឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ (ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា) ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលការអនុញ្ញាតជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និង

ទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។[35]

ទីផ្សារមូលបត្រកម្ពុជាត្រូវបានសព្វថ្ងៃត្រូវបានគេបែងចែកផ្សារជាពីរប្រភេទគឺ ទីផ្សារគោល (Main board) និងទីផ្សារកំណើន (Growth board)៖

- **ទីផ្សារគោល (Main Board)** ជាកន្លែងដែល ក្រុមហ៊ុនធំៗមានឈ្មោះល្បី និងមានលំនឹងល្អបោះផ្សាយលក់ភាគហ៊ុន។ ក្រុមហ៊ុនដែលនូវក្នុងផ្សារគោលភាគច្រើនជាក្រុមហ៊ុនដែលល្អ មានឈ្មោះបោះសំឡេងរួចទៅហើយ។ ក្នុងទីផ្សារគោលដើម្បីទទួលបានការអនុញ្ញាតក្នុងការចុះបញ្ជីក្នុងផ្សារមូលបត្រនៅកម្ពុជា៖
  - ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លានរៀល) គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ **ផ.ម.ក.**។
  - ប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លានរៀល) នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លានរៀល) សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។
  - ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោះតិចជាង១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅត្រូវមានចំនួនយ៉ាងតិច២០០ នាក់គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** តាមការស្នើសុំរបស់ **ផ.ម.ក.**។
  - ភាគហ៊ុនមានសិទ្ធិបោះឆ្នោត របស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង១% ត្រូវមានចំនួនសរុបយ៉ាងតិច៧% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** តាមស្នើសុំរបស់ **ផ.ម.ក.**។
- **ទីផ្សារកំណើន (Growth Board)** ដែលជាទីផ្សារសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងការស្វែងរកមូលនិធិបន្ថែមសម្រាប់ធុរកិច្ចរបស់ខ្លួន។ យោងតាមប្រកាសស្តីពី**"ការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ"** សហគ្រាសត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ដើម្បីទទួលបានការអនុញ្ញាតក្នុងការចុះបញ្ជីក្នុងផ្សារមូលបត្រនៅកម្ពុជា៖

[35] គេហទំព័រផ្សារមូលបត្រកម្ពុជា csx.com.kh

- សហគ្រាសត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លានរៀល) ឬ ៥០០,០០០ (ប្រាំសែនដុល្លារ) ដោយគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ **ផ.ម.ក.**។
- សហគ្រាសត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយ ដូចខាងក្រោមៈ
  ១. ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
  ២. ត្រូវមានលំហូរសាច់ប្រាក់ប្រតិបត្តិការវិជ្ជមាន (Positive Operating Cash flow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០%។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ ភាគហ៊ុនឡើងទៅ ត្រូវកាន់កាប់ចំនួនយ៉ាងតិច១០០ នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** តាមសំណើរបស់ **ផ.ម.ក.**។
- ភាគហ៊ុនមានសិទ្ធបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់តិចជាង ១% ត្រូវមានចំនួនសរុបយ៉ាងតិច ១០% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយអគ្គនាយកនៃ **គ.ម.ក.** តាមសំណើរបស់ **ផ.ម.ក.**។

## ៣.៣. រចនាសម្ព័ន្ធផ្សារមូលបត្រកម្ពុជា

**រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ឧបសម្ព័ន្ធនៃបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រង **ផ.ម.ក.**




## ៣.៤. សមាជិករបស់ផ្សារមូលបត្រកម្ពុជា

- ក្រុមប្រឹក្សាភិបាលនៃ**ផ.ម.ក.** រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ប្រធានក្រុមប្រឹក្សាភិបាលនិងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។

ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

- សមាជិកចំនួន ៤រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

## ៣.៥. ចក្ខុវិស័យ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានគោលដៅយ៉ាងច្បាស់លាស់ដើម្បីស្របទៅតាមមាគ៌ាយ៉ាងត្រឹមត្រូវលើចក្ខុវិស័យរបស់ខ្លួន ពោលគឺដើម្បីសាងនូវ **មហាវិថីហិរញ្ញវត្ថុសម្រាប់កម្ពុជា**។

## ៣.៦. បេសកកម្ម

ក្នុងការសម្រេចបានចក្ខុវិស័យរបស់ខ្លួន ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានកំណត់បេសកម្មមួយចំនួនដូចជា៖

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនៅបរិយាកាសជួញដូរមូលបត្រដែលអំណោយផល ដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើតនូវផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់ អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការសហគ្រាសសាធារណៈមួយដែលមាន ស្វ័យចិរភាពក្រោមមគ្គទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាល។

## ៣.៧. តួនាទី និងមុខងារ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ជាក្រុមហ៊ុនមួយដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបំពេញមុខងារជាប្រតិបត្តិករទីផ្សារមូលបត្រ (Securities Market Operator) ប្រតិបត្តិករប្រព័ន្ធទូទាត់ និងផាត់ទាត់មូលបត្រ (Clearance and Settlement Facilities Operation) ប្រតិបត្តិកររក្សាទុកមូលបត្រ (Securities Depository Operator)។ ក្នុងការបំពេញអាជីវកម្មទាំងបីខាងលើក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ធ្វើឲ្យប្រតិបត្តិការណ៍របស់ខ្លួនដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាព។
- ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់រាល់ហានិភ័យដែលអាចកើតឡើងពីប្រតិបត្តិការអាជីវកម្ម។

– បំពេញឲ្យអស់ពីសមត្ថភាពនូវកាតព្វកិច្ចដែលចែងក្នុងច្បាប់ ដោយមិនប្រព្រឹត្តិផ្ទុយពីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍វិនិយោគិន។
– អនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការរបស់ខ្លួន និងបទប្បញ្ញត្តិជាធរមានដែលបានកំណត់ដោយ **គ.ម.ក.** ធនាគារជាតិនៃកម្ពុជា និងក្រសួងស្ថាប័នដែលមានសមត្ថកិច្ចពាក់-ព័ន្ធ។
– ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន និងប្រាកដថាសមាជិកអ្នកចូលរួមក្នុងទីផ្សារគោរពតាមវិធានប្រតិបត្តិការ ដើម្បីធានាបានសុវត្ថិភាព និងប្រសិទ្ធិភាពនៃប្រតិបត្តិការ និងការពារផលប្រយោជន៍វិនិយោគិន។
– ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ផ្សេងៗតាមការកំណត់របស់ **គ.ម.ក.**។
– អភិបាល និងបុគ្គលិករបស់ប្រតិបត្តិករគ្រប់រូបត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវប្រព្រឹត្តិអាកប្បកិរិយាដែលត្រូវហាមឃាត់ពាក់ព័ន្ធទៅ និងការជួញដូរក្លែងក្លាយ និងការប្រើប្រាស់ឧបាយកលក្នុងទីផ្សារ សេចក្តីថ្លែង ឬការផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឲ្យយល់ខុសនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។
– រាល់ការប្រជុំរបស់អភិបាលប្រតិបត្តិករ ដែលមានការពាក់ព័ន្ធពីផលប្រយោជន៍តាមគ្រប់រូបភាពទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីក្នុងការសម្រេចណាមួយ ឬការអនុម័តកិច្ចសន្យាណាមួយ ដែលធ្វើឡើងដោយកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលតាមរយៈលិខិតជាលាយលក្ខណ៍អក្សរក្នុងពេលមួយសមស្រប មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដែលនិងសម្រេចទាក់ទងនឹងបញ្ហានោះ។

## ៣.៨. ប្រតិបត្តិករទីផ្សារមូលបត្រ

- **ប្រតិបត្តិករទីផ្សារមូលបត្រ** ជានិយ័តករជួរមុខ ក្នុងការកំណត់នូវវិធីសាស្ត្រ យន្តការនីតិវិធី និងការគ្រប់គ្រងការជួញដូរមូលបត្រ នៅក្រុមហ៊ុនផ្សារមូបត្រកម្ពុជា ដោយស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញាត្តិពាក់ព័ន្ធជាធរមាន។[36] ប្រតិបត្តិករទីផ្សារមូលបត្រ ធ្វើប្រតិបត្តិការដូចជា៖
  – ផ្តល់សេវាសម្រាប់សម្របសម្រួលដល់អ្នកចូលរួមក្នុងទីផ្សារដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឲ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបានការបន្សុី

[36] ប្រកាសស្តីពី, *ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការណ៍ទីផ្សារមូលបត្ររបស់ទីផ្សារមូលបត្រកម្ពុជា*, (ភ្នំពេញ, ២០១៧)

លើប្រតិបត្រការបញ្ជា ទិញ-លក់ មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិច។[37]

- ធានានូវបរិស្ថានជួញដូរឲ្យមានយុត្តិធម៌ និងការពារវិនិយោគិនក្នុងផ្សារមូលបត្រកម្ពុជា អាចដាក់ចេញនូវយន្តការបង្ការមួយចំនួនដើម្បីទប់ស្កាត់ការជួញដូរមូលបត្រមិនស្មោះត្រង់ ឬមិនប្រក្រតី។
- ធ្វើការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី ដោយប្រើប្រាស់នូវព័ត៌មានមួយចំនួនដូចជារបៀបនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំនៃការជួញដូរ ព្រមទាំងកម្រិតនៃទំនាក់ទំនងរវាងថ្លៃទីផ្សារ និងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។[38]

- **ប្រតិបត្តិករប្រព័ន្ធទូទាត់និងផាត់ទាត់** ប្រតិបត្តិករនេះជាអ្នកធានាថា មូលបត្រត្រូវបានដល់ដៃអ្នកទិញ និងលុយបានដល់ដៃអ្នកលក់ក្នុងពេលតែមួយ ក្រោយពីការផ្គូផ្គងទទួលបានជោគជ័យ។ ប្រតិបត្តិករនេះ ក៏ធ្វើការត្រួតពិនិត្យមូលបត្រខាងអ្នកលក់ ថាតើមានមូលបត្រគ្រប់គ្រាន់សម្រាប់លក់ដែរ ឬទេ និងខាងអ្នកទិញថាគាត់មានលុយគ្រប់គ្រាន់សម្រាប់ទិញ ឬទេ ក្នុងគោលបំណងបញ្ចៀសនូវហានិភ័យក្នុងការទូទាត់។
- **ប្រតិបត្តិកររក្សាទុកមូលបត្រ** ប្រតិបត្តិករនេះកំណត់អំពីលក្ខខណ្ឌចាំបាច់នានាសម្រាប់រក្សាទុក និងផ្ទេរមូលបត្រ។[39] សំដៅដល់បុគ្គលយល់ព្រមជាមួយបុគ្គលមួយទៀតដែលជាអតិថិជនដែលផ្តល់សេវាកម្ម ដូចខាងក្រោម៖
    - ទទួលរក្សាទុកមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃផ្សេងទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬទម្រង់អរូបី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សារទុកមូលបត្រ ក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
    - ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងទៀត ដែលទាក់ទងនឹងការផ្តល់សេវាកម្មដូចមានចែងនៅក្នុងប្រតិបត្តិការទាំងពីរខាងលើ។

[37] លឹម វិភា, *ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា,* (ភ្នំពេញ ២០១៨) ទំព័រ ១៦
[38] ប្រកាសស្តីពី, *ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការណ៍ទីផ្សារមូលបត្ររបស់ទីផ្សារមូលបត្រកម្ពុជា,* (ភ្នំពេញ, ២០១៧)
[39] ប្រកាស ស្តីពី, *ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សារទុកមូលបត្រ,* (ភ្នំពេញ ២០១៧)

ប្រតិបត្តិករនេះជាអ្នករក្សាទុកមូលបត្រជូនវិនិយោគិន ព្រោះវិនិយោគិនមិនអាចយកមូលបត្រទៅរក្សាទុកនៅផ្ទះបានទេហើយថ្លៃសេវានៅក្នុងការរក្សាទុកមូលបត្រដោយប្រតិបត្តិករនេះគឺ ០.១%។

## ៣.៩. លក្ខខណ្ឌក្នុងការចុះបញ្ជីបោះផ្សាយសញ្ញាបណ្ណ

### លក្ខខណ្ឌចុះបញ្ជីសម្រាប់មូលបត្របំណុល

បុគ្គលដែលស្នើសុំ ចុះបញ្ជីលក់មូលបត្របំណុលអាចចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការបាននៅ **ផ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**៖

- មូលធនភាគហ៊ុនិកសរុប ត្រូវមានយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល លើកលែងចំពោះការចុះបញ្ជីសញ្ញាបណ្ណមានវត្ថុធានា។
- ទំហំមូលបត្របំណុលដែលត្រូវបោះផ្សាយ និងចុះបញ្ជី កំណត់ឲ្យមានយ៉ាងតិចចំនួន ១.០០០.០០០.០០០ (មួយប៊ីលានរៀល) ឬយ៉ាងតិចចំនួន ៥០០.០០០.០០០ (ប្រាំរយលានរៀល) ចំពោះសញ្ញាបណ្ណមានវត្ថុធានា។
- តម្លៃចារឹកត្រូវមានតម្លៃ ១០០.០០០ (មួយរយពាន់) រៀល។
- មូលបត្របំណុលទាំងអស់ដែលបោះផ្សាយត្រូវបានដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.**។

## ៣.១០. អត្ថប្រយោជន៍នៃការចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា[40]

អត្ថប្រយោជន៍នៃការចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានដូចជា

❖ **ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង** នៅពេលគិតគូរអំពីគម្រោងពង្រីកអាជីវកម្មរបស់ខ្លួន សហគ្រាសខ្នាតតូច និងមធ្យម ជានិច្ចកាលតែងជួបប្រទះ បញ្ហាខ្វះខាតទុនសម្រាប់វិនិយោគ និងសម្រាប់ប្រើប្រាស់ជាទុនបង្វិល។ សហគ្រាសជាទូទៅមានប្រភពហិរញ្ញប្បទានច្រើនពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ប៉ុន្តែភាគច្រើននៃប្រភពហិរញ្ញប្បទានទាំងនោះ ជាហិរញ្ញប្បទានរយៈពេលខ្លី ដែលអាចជារនាំងនៃការអភិវឌ្ឍផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន។ ផ្ទុយទៅវិញ ជាមួយនឹងទីផ្សារមូលបត្រ សហគ្រាសទាំងនេះអាចទទួលបានហិរញ្ញប្បទានរយៈពេលវែងតាមរយៈការបោះផ្សាយសញ្ញាបណ្ណ និងលក់ទៅឲ្យសាធារណៈជន ហើយទទួលបាននូវមូលនិធិសម្រាប់រួមចំណែកក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែងរបស់សហគ្រាសដោយសហគ្រាស

[40] គេហទំព័រក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

គ្រាន់តែទូទាត់ត្រលប់ទៅវិនិយោគិនវិញនូវការប្រាក់ទៅតាមគោលការណ៍របស់សហគ្រាស និងលទ្ធភាពក្នុងការដកសាច់ប្រាក់។

❖ **ទទួលបានការលើទឹកចិត្តពន្ធដារ និងមិនមែនពន្ធ** នេះគឺជាការលើកទឹកចិត្តសំខាន់មួយសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដែលកំពុងសម្លឹងមើលការប្រមូលមូលនិធិ តាមរយៈការបោះផ្សាយ ប័ណ្ណបំណុលនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**)។ ក្រុមហ៊ុនទាំងអស់ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ **ផ.ម.ក.** នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% ក្នុងរយៈពេលបីឆ្នាំ ហើយការលើកទឹកចិត្តនេះនឹងត្រូវផ្តល់ជូនចំពោះការចុះបញ្ជីនៅមុនខែមករា ឆ្នាំ២០១៨។ ស្របពេលជាមួយគ្នានេះផងដែរ ក្រុមហ៊ុនក៏ទទួលបានការលើកលែងទាំងស្រុង ចំពោះបំណុលពន្ធលើប្រាក់ចំណេញសម្រាប់រយៈពេល១០ឆ្នាំសារពើពន្ធកន្លងទៅ ដែលបានរកឃើញដោយស្ទង់ការសវនកម្មឯករាជ្យ ក្រោយការធ្វើសវនកម្មពេញលេញរបស់អគ្គនាយកដ្ឋានពន្ធដារ។ បន្ថែមលើនេះទៀត ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% ប្រចាំខែ ត្រូវបានព្យួរជាបណ្តោះអាសន្នរយៈពេល៣ឆ្នាំ។ ក្រៅពីនេះ ក្នុងពេលកន្លងទៅថ្មីៗនេះ ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ បានធ្វើសេចក្តីថ្លែងការណ៍រួមក្នុងការផ្តល់កម្ចី ក្នុងអត្រាការប្រាក់ពិសេសដល់ក្រុមហ៊ុនចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

❖ **ទទួលបាននិរន្តរភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន** ការបង្កើតសហគ្រាសអាជីវកម្មមួយ គឺត្រូវប្រឈមនឹងបញ្ហាជាច្រើន ប៉ុន្តែការរក្សាអាជីវកម្មឲ្យមានចីរភាព គឺរឹតតែជាការងារដ៏លំបាកមួយ និងជាការប្រឈមដ៏ធំសម្រាប់ម្ចាស់អាជីវកម្ម។ សហគ្រាសខ្នាតតូច និងមធ្យម តែងតែជាកម្មវត្ថុនៃការបារម្ភនានាអំពីអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន។ យ៉ាងណាមិញនៅពេលដែលសហគ្រាសទាំងនេះបានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឲ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលនឹងមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀត ម្ចាស់អាជីវកម្មអាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬការកែបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផល អភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងនឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឲ្យមានការរីកចំរើនប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម នឹងអាចជួយដល់ការត្រៀមខ្លួនរបស់សហគ្រាសខ្នាតតូចនិងមធ្យមក្នុងការប្រកួតប្រជែងក្នុងតំបន់អាស៊ានដទៃទៀត។

❖ **ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងភាពមើលឃើញរបស់ក្រុមហ៊ុន** ក្រុមហ៊ុនចុះបញ្ជីមួយ ជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេសតាមរយៈប្រព័ន្ធព័ត៌មាន និងសាធារណជន ហើយកិច្ចប្រតិបត្តិការអាជីវកម្ម ឬហិរញ្ញវត្ថុតែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត និងទូរទស្សន៍ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះអាចជួយកែលម្អនូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលអាចឲ្យសាធារណៈជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះ ក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែង ដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ នៅក្នុងបរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្មដែលពោរពេញដោយការប្រកួតប្រជែង។ ជាក់ស្តែង នៅក្នុងពេលថ្មីៗនេះ ព័ត៌មានពាក់ព័ន្ធនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC ត្រូវបានផ្សាយនៅលើគេហទំព័រដ៏ល្បីរបស់សហរដ្ឋអាមេរិក គឺ Nasdaq ។

❖ **ការត្រៀមខ្លួនជាមុនចំពោះបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល** ក្រុមហ៊ុនទាំងអស់ កំពុងតែត្រូវបានឃ្លាំមើលដោយរាជរដ្ឋាភិបាល អំពីការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់របស់ពួកគេដែលរួមទាំងការអនុវត្តពន្ធ ការកាន់បញ្ជីគណនី និងការធ្វើសវនកម្មជាដើម។ សេរីភាពដែលកំពុងថមថយនេះ នឹងជំរុញឲ្យចាប់ផ្តើមអនុវត្តឲ្យបានឆាប់នូវកាតព្វកិច្ចច្បាប់នានា និងការក្លាយខ្លួនជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រ។ ដូច្នេះ សូមចាប់យកឱកាសនេះ ដើម្បីទទួលបានអត្ថប្រយោជន៍ក្នុងនាមជាក្រុមហ៊ុននាំមុខគេ។

## ៣.១១. បច្ចុប្បន្នភាពរបស់ផ្សារមូលបត្រកម្ពុជា

### ៣.១១.១. ការដាក់ឲ្យដំណើរការប្រព័ន្ធជួញដូរថេរMTS និងប្រព័ន្ធបង្ហាញព័ត៌មាន e-disclosure[41]

ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ផ្សារមូលបត្រកម្ពុជាបានឈានមកដល់ជំនាន់ថ្មីមួយទៀត ដោយដាក់ជាប្រេនឌីងថា CSX 2.0។ បន្ថែមលើប្រភេទផលិតផលវិនិយោគតែមួយនៅក្នុងទីផ្សារ គឺភាគហ៊ុន បច្ចុប្បន្ននេះផ្សារមូលបត្រកម្ពុជាមាននូវការចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មផងដែរ ដែលសញ្ញាបណ្ណទីមួយត្រូវបានបោះផ្សាយ និងចុះបញ្ជីដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុLOLC (Cambodia) ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទីពីរបានចុះបញ្ជីលក់សញ្ញាបណ្ណនៅក្នុងផ្សារមូបត្រកម្ពុជា ក្នុងពេលថ្មីៗនេះ ហើយនឹងមានក្រុមហ៊ុនទីបីមកចុះបញ្ជី

[41] របាយការណ៍ផ្សារមូលបត្រកម្ពុជា និងសន្ទរកថារបស់ថ្នាក់ដឹកនាំក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

សញ្ញាបណ្ណមួយទៀតគឺ ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ABA Bank) និងក្រុមហ៊ុនមួយចំនួនទៀត។ បច្ចុប្បន្ន ចំនួនវិនិយោគិនរបស់ផ្សារមូលបត្រកម្ពុជាបានកើនដល់ជាង២ម៉ឺននាក់។

➢ **ប្រព័ន្ធជួញដូរចល័តMTS** (mts.csx.com.kh) ត្រូវបានដាក់ឱ្យប្រើប្រាស់ជាបឋមតាំងពីថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨។ ប៉ុន្តែ បានដាក់ឱ្យដំណើរការជាផ្លូវការ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៩។ MTS គឺជាប្រព័ន្ធជួញដូរតាមអ៊ិនធើណេតដែលត្រូវបានអភិវឌ្ឍឡើងក្រោមការជួយគាំទ្រពីសំណាក់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ក្នុងគោលដៅជួយសម្រួល និងជំរុញការជួញដូរមូលបត្រដែលបានចុះបញ្ជីជួញដូរនៅ **ផ.ម.ក.**។ ប្រព័ន្ធនេះដំណើរការនៅលើ web browser ដែលមានស្រាប់នៅលើស្មាតហ្វូន និងថេបប្លេត ដែលនឹងអនុញ្ញាតឱ្យវិនិយោគិនពិនិត្យមើលសមតុល្យសាច់ប្រាក់ និងមូលបត្រធ្វើការដាក់បញ្ជាជួញដូរ កែប្រែ និងលុបចោលបញ្ជាបានដោយខ្លួនឯង ក៏ដូចជាពិនិត្យមើលបញ្ជា និងទិន្នន័យជួញដូរកន្លងមក ព្រមទាំងស្នើរដក-ដាក់ប្រាក់ផងដែរ (ដូចនេះ វិនិយោគិន មិនចាំបាច់ត្រូវទៅធនាគារដោយផ្ទាល់ ដើម្បីដាក់ប្រាក់ ឬដកប្រាក់ទេ ដោយគ្រាន់តែប្រើMTS ដើម្បីបញ្ជាទៅក្រុមហ៊ុនមូលបត្ររបស់ខ្លួន ឬបុគ្គលិកធនាគារ ជាការស្រេច)។ ផ្សារមូលបត្រកម្ពុជាក៏បានផ្តល់ជូននូវភាពងាយស្រួលដល់វិនិយោគិនដែលអាចតាមដានមើលទិន្នន័យទីផ្សារ សេចក្តីជូនដំណឹងផ្សេងៗបានទាន់ពេលវេលា ដែលមានសារៈសំខាន់សម្រាប់ការសម្រេចចិត្តវិនិយោគ។

➢ **ប្រព័ន្ធបង្ហាញព័ត៌មាន** e-disclosur កាលពីមុន ដំណើការនៃការផ្តល់ព័ត៌មានទាន់ពេល (Timely disclosure) ត្រូវបានផ្ញើមកក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាតាមរយៈអ៊ីម៉ែល ហើយក្រុមការងាររបស់**ផ.ម.ក.**នឹងរៀបចំបញ្ចូលព័ត៌មានទៅក្នុងគេហទំព័រ។ ដោយឡែក នាពេលបច្ចុប្បន្ននេះផ្សារមូលបត្រកម្ពុជាបានបង្កើតប្រព័ន្ធបង្ហាញព័ត៌មាន e-disclosure គឺជាប្រព័ន្ធសម្រាប់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រទាំងអស់នៅ**ផ.ម.ក.** អាចប្រើប្រាស់ web browser ដើម្បីផ្តល់ព័ត៌មានជូនវិនិយោគិន និងសាធារណជនបានឆាប់រហ័ស ទាន់ពេលវេលាជាងមុន ដែលចាប់ពីពេលនេះតទៅក្រុមហ៊ុនចុះបញ្ជីជួញដូរមូលបត្រនឹងផ្ញើព័ត៌មានទាន់ពេលទាំងអស់ទៅកាន់គេហទំព័រ **ផ.ម.ក.** បានដោយខ្លួនឯងបន្ទាប់ពីក្រុមការងារបានធ្វើការពិនិត្យ។ ដូចនេះ ប្រព័ន្ធនេះកាត់បន្ថយទាំងពេលវេលា និងចំណាយរបស់ក្រុមហ៊ុនចុះបញ្ជី ក្នុងការផ្តល់ព័ត៌មានទៅកាន់សាធារណជន ហើយប្រព័ន្ធនេះក៏ជួយឱ្យវិនិយោគិន អាចទទួលបានព័ត៌មានក្រុមហ៊ុនចុះបញ្ជីបានលឿនជាងមុនផងដែរ។

### ៣.១១.២. ស្ថានភាពអ្នកចូលរួម[42]

ក្នុងរយៈពេល ១០ ឆ្នាំមកនេះ សមិទ្ធផលជាច្រើនត្រូវបានបង្កើតឡើង និងអភិវឌ្ឍជាបន្តបន្ទាប់នៅក្នុងទីផ្សារ ដែលក្នុងនោះរួមមានទាំងតួអង្គនិងផលិតផល ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ដែលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាតួអង្គដ៏សំខាន់នៅក្នុងការផ្តល់នូវប្រព័ន្ធជួញដូរ។ រហូតមកដល់ពេលនេះ មានក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណចំនួន១០ កំពុងផ្តល់សេវានៅក្នុងទីផ្សារមូលបត្រកម្ពុជា ខណៈដែលតួអង្គសំខាន់ៗផ្សេងទៀតត្រូវបានផ្តល់ការអនុញ្ញាត និងការទទួលស្គាល់ជាបន្តបន្ទាប់ ហើយចំនួនវិនិយោគិនក៏មានការកើនឡើងពី១ ឆ្នាំទៅ ១ ឆ្នាំ ដែលលេខអត្តសញ្ញាណវិនិយោគិនគិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៩ គឺមានចំនួន ២០.៥៤៩ ដែលរួមមានវិនិយោគិនរូបវន្តបុគ្គលជាជនជាតិខ្មែរចំនួន ១៧.៦១១នាក់ និងបរទេស ៣.២៨៨នាក់ខណៈដែលវិនិយោគិននីតិបុគ្គលសញ្ជាតិខ្មែរមានចំនួន ២៥ក្រុមហ៊ុន និងសញ្ជាតិបរទេសចំនួន ៩០ក្រុមហ៊ុន។ ផលិតផលដែលកំពុងដាក់ឲ្យដំណើរការជួញដូរនៅក្នុងផ្សារមូលបត្រកម្ពុជាមានចំនួន ២ រួមមានមូលបត្រកម្មសិទ្ធ ដែលហៅថាភាគហ៊ុន និង មូលបត្របំណុល ដែលហៅថាសញ្ញាបណ្ណ។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រចំនួន ៥ បានចុះបញ្ជីជួញដូរមូលបត្រកម្មសិទ្ធ និងក្រុមហ៊ុនចុះបញ្ជីពីរទៀតជាក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC Cambodia។ ក្រុមហ៊ុនទាំងនេះនេះបានប្រមូលទុនពីទីផ្សារមូលបត្រ សរុបប្រមាណជា ១៣០ លានដុល្លារ រួចមកហើយ។ ក្រុមហ៊ុនទាំងនេះ មិនត្រឹមតែទទួលបានទុនរយៈពេលវែងសម្រាប់វិនិយោគផងទេ តែបានទទួលការលើកទឹកចិត្តពន្ធ ដែលបច្ចុប្បន្ននេះមានកម្រិតស្មើនឹង ៥០%នៃពន្ធលើប្រាក់ចំណេញដែលត្រូវបង់ ហើយនឹងកេរ្តិ៍ឈ្មោះ និងទំនុកចិត្តពីសាធារណជន មកលើក្រុមហ៊ុនផងដែរ។ នៅក្នុងឆ្នាំ២០១៩ ឆាប់ៗខាងមុខនេះ នឹងមានក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណទី៣ដែលនឹងចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ABA Bank) ហើយនាពេលដ៏ខ្លីខាងមុខនេះ ផ្សារមូលបត្រកម្ពុជានឹងមានក្រុមហ៊ុន ៣ទៅ៤ទៀត ដែលនឹងបន្តចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលរបស់ខ្លួន មុនបំណាច់ឆ្នាំនេះ។

ជាមួយនឹងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រទាំង ៥ គិតត្រឹមត្រីមាសទី១ ឆ្នាំ ២០១៩ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨ មូលធនទីផ្សារមានការកើនឡើងប្រមាណជា ២១% ពី១,៧៧ ទ្រីលានរៀល (ប្រហែលជា៤៤២,៩២ លានដុល្លារ) ដល់ ២,១៤ ទ្រីលានរៀល (ប្រហែលជា៥៣៤,៣ លាន

[42] របាយការណ៍គណៈកម្មការមូលបត្រកម្ពុជា

ដុល្លារ), ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានការកើនឡើង ៩ដង ខណៈដែលតម្លៃជួញដូរ មានការកើនឡើង២ដង។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩ គឺមានសញ្ញាណវិជ្ជមានគួរឲ្យកត់សម្គាល់ គឺការជួញដូរដោយវិនិយោគិនក្នុងស្រុកមានការកើនឡើង១៨%ខណៈដែលការជួញដូរដោយវិនិយោគិនបរទេសថយចុះ ១៨%។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩ សន្ទស្សន៍ **ផ.ម.ក.** កើនឡើងពី ៤៨០,៩៨ ពិន្ទុ ទៅ ៥៨០,២១ ពិន្ទុ ដែលមានកំណើនស្មើនឹង២១%។ គួរឲ្យកត់សម្គាល់ផងដែរថា សន្ទស្សន៍ **ផ.ម.ក.** បានឡើងខ្ពស់បំផុតរហូតដល់៦៧១,៦៥ ពិន្ទុ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ច្រើនជាងឆ្នាំ២០១៨ ដែលឡើងខ្ពស់បំផុតត្រឹម៤៨០,៩៨ ពិន្ទុ។ ទាំងអស់នេះសុទ្ធតែជាលទ្ធផលដែលកំពុងឆ្លុះបញ្ចាំងពីវឌ្ឍនភាពដ៏ល្អប្រសើរមិនធ្លាប់មាន របស់ផ្សារមូលបត្រកម្ពុជា។

## ៣.១២. និដ្ឋភាពទូទៅនៃការជួញដូរក្នុងផ្សារមូលបត្រកម្ពុជា

➢ **ការបើកគណនី និងនីតិវិធីក្នុងការជួញដូរ**
**នីតិវិធីក្នុងការបើកគណនី**

– **ជ្រើសរើសក្រុមហ៊ុនមូលបត្រ**

វិនិយោគិនត្រូវជ្រើសក្រុមហ៊ុនមូលបត្រមួយក្នុងចំណោមក្រុមហ៊ុនមូលបត្រទាំង១០ ដែលជាសមាជិករបស់**ផ.ម.ក.**ហើយក្រុមហ៊ុនមូលបត្រនោះនឹងជួយវិនិយោគិនក្នុងការបើកគណនីជួញដូរ។

– **បើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើស**

ឯកសារតម្រូវដើម្បីបើកគណនីជួញដូរ រួមមាន៖

១.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស) ភ្ជាប់ជាមួយរូបថត ៤×៦មួយសន្លឹក

២.លេខអត្តសញ្ញាណវិនិយោគិន (ក្រុមហ៊ុនមូលបត្រអាចជួយធ្វើការស្នើសុំពីគណៈកម្មការមូលបត្រកម្ពុជា)

– **តើវិនិយោគិនអាចជួញដូរបាននៅពេលណា?**

យ៉ាងហោចណាស់មួយថ្ងៃបន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** បាន។

**ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ**

វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាតែមានសាច់ប្រាក់យ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោច

មួយរយភាគរយ (សម្រាប់បញ្ជាលក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិក ក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព។




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។

(២) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 ទៅកាន់ក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬមធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រោយពីត្រួតពិនិត្យមូលបត្រ និងសាច់ប្រាក់នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ) អ្នកតំណាងនៅក្នុងទីផ្សារដាក់បញ្ជាតាមការបង្គាប់មកក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** នៅថ្ងៃ T+0។ សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

(៤) ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) **ផ.ម.ក.** ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦). ក្រុមហ៊ុនមូលបត្រ បញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗ

របស់ខ្លួននៅថ្ងៃT+0។

(៧) ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ **ផ.ម.ក.** ដើម្បីកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃ ថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ ផ.ម.ក. ។

- **ថ្ងៃ និងម៉ោងជួញដូរ**

- **ថ្ងៃជួញដូរ**

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។

- **ម៉ោងជួញដូរ**

ម៉ោងជួញដូរត្រូវបានកំណត់តាមវិធីសាស្ត្រជួញដូរដូចខាងក្រោមៈ

១. វិធីសាស្ត្រដេញថ្លៃ

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង៨:០០ព្រឹក ដល់ម៉ោង១១:៣០ព្រឹក ដែលបែងចែកទៅតាមវគ្គដូចខាងក្រោមៈ

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងជួញដូរ | វិធីសាស្ត្រដេញថ្លៃ |
|---|---|---|---|
| **វគ្គបើក** | ៨:00-៩:00 | ៩:00 | ដេញថ្លៃដោយយកម៉ោងតែមួយ |
| **វគ្គនិរន្តរ៍** | ៩:00-១១:00 | | ដេញថ្លៃដោយយកថ្លៃច្រើន |
| **វគ្គបិទ** | ១១:00-១១:៣០ | ១១:៣០ | ដេញថ្លៃដោយយកម៉ោងតែមួយ |

ចំណាំៈ ប្រសិនបើគ្មានការផ្គូផ្គងបញ្ជានៅម៉ោង៩:០០នាទីព្រឹកទេ នោះវគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

២.វិធីសាស្ត្រជួញដូរតាមការចរចា

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា ម៉ោងជួញដូរគឺចាប់ពីម៉ោង៩:០០នាទីព្រឹក ដល់ម៉ោង ១១:៣០នាទីព្រឹក។

ដោយយោងតាមអង្គប្រជុំនៅឯ **គ.ម.ក.** នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ បានអនុម័តលើវិសោធនកម្មប្រកាសស្តីពី ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារ

មូលបត្រកម្ពុជា ដោយបន្ថែមម៉ោងជួញដូរចាប់ពីម៉ោង ៨:០០នាទីព្រឹក រហូតដល់ម៉ោង៣:០០រសៀល រៀងរាល់ថ្ងៃធ្វើការ។ (មិនទាន់បានអនុវត្តជាក់ស្តែង)

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងជួញដូរ | វិធីសាស្ត្រដេញថ្លៃ |
|---|---|---|---|
| **វគ្គបើក** | ៨:០០-៩:០០ | ៩:០០ | ដេញថ្លៃដោយយកម៉ោងតែមួយ |
| **វគ្គនិរន្តរ៍** | ៩:០០-២:៥០ | | ដេញថ្លៃដោយយកថ្លៃច្រើន |
| **វគ្គបិទ** | ២:៥០-៣:០០ | ៣:០០ | ដេញថ្លៃដោយយកម៉ោងតែមួយ |

➢ **បញ្ជា**

បញ្ជាចំនួន៣ប្រភេទសំខាន់ៗដែលត្រូវដាក់ឱ្យដំណើរការនៅ **ផ.ម.ក.** មានដូចខាងក្រោម៖

- **បញ្ជាដែនកំណត់** ជាបញ្ជាដែលថ្លៃបញ្ជាទិញគឺជាថ្លៃដែលហ៊ានទិញខ្ពស់បំផុត ហើយថ្លៃបញ្ជាលក់គឺជាថ្លៃដែលហ៊ានលក់ទាបបំផុត។
- **បញ្ជាទីផ្សារ** ជាបញ្ជាដើម្បីទិញឬលក់មូលបត្រកម្មសិទ្ធិមួយភ្លាមៗ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទ-នីយភាពមូលបត្រនិងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូងឡើយ។ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌ២គឺ លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល និងលក្ខខណ្ឌជួញដូរ ហើយលុបចោល។ លក្ខខណ្ឌទាំងពីរនេះអាចប្រើប្រាស់បានតែក្នុងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន និងនៅពេលដែលមានបញ្ជាផ្ទុយគ្នានៅផ្នែកម្ខាងទៀត។
- **បញ្ជាតាមការចរចា** ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា។ បញ្ជាប្រភេទនេះធានាដល់ការជួញដូររបស់វិនិយោគិននៅក្នុងតែមួយប្រតិបត្តិការធំប៉ុណ្ណោះ និងផ្តល់ភាពសម្ងាត់ដល់បញ្ជានិងការជួញដូររបស់វិនិយោគិនក្នុងអំឡុងម៉ោងជួញដូរ។

➢ **វិធីសាស្ត្រជួញដូរ**

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រដេញថ្លៃ (ATM) ឬវិធីសាស្ត្រជួញដូរតាមការចរចា (NTM)។

- **វិធីសាស្ត្រដេញថ្លៃ**

១.**គោលការណ៍ដេញថ្លៃ** រាល់ការជួញដូរត្រូវបានអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន យោងទៅតាមអាទិភាពថ្លៃ និងអាទិភាពពេលវេលាដូចមានខាងក្រោម៖

ក.អាទិភាពថ្លៃបញ្ជាលក់ដែលមានថ្លៃទាបជាងគេ មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង និងបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងមានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

ខ. អាទិភាពពេលវេលា ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

**២.វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ** ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវអនុវត្តតាមថ្លៃកំណត់មួយ ដែលហៅថា ថ្លៃជួញដូរ។

**៣.វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន** បញ្ជាមួយអាចជួញដូរបាននៅថ្លៃច្រើនខុសពីគ្នា។ នៅពេលបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងគេ ត្រូវផ្គូផ្គងជាមួយបញ្ជាលក់ដែលមានថ្លៃទាបជាងគេ ថ្លៃជួញដូរគឺជាថ្លៃនៃបញ្ជាដែលទទួលបានមុន។

- **វិធីសាស្ត្រជួញដូរតាមការចរចា**

វិធីសាស្ត្រជួញដូរតាមការចរចា ជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូបន្ទាប់ពីអ្នកទិញនិងអ្នកលក់បានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ ដើម្បីផ្គូផ្គងបញ្ជាទិញនិងលក់តាមការចរចាមួយគូបាន ចាំបាច់ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងចំនួន៤គឺ ឈ្មោះមូលបត្រ, ថ្លៃ, បរិមាណ និងលេខកូដជួញដូរតាមការចរចា។

លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារៈ

**បញ្ជាអប្បបរមា** បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច៥០.០០០ភាគហ៊ុន ឬតម្លៃជួញដូរ២០០.០០០.០០០រៀល (យកមួយណាដែលតូចជាង)។

**ឯកតាគម្លាតថ្លៃ** ១រៀល។

**ដែនកំណត់ថ្លៃប្រចាំថ្ងៃ** មិនអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។

**ការលុបចោលបញ្ជា** ដរាបណាបញ្ជាមិនទាន់អនុវត្តការជួញដូរ នោះបញ្ជាតាមការចរចាអាចលុបបាន តែពុំអាចកែប្រែបានឡើយ។

## គ. ការជួញដូរមូលបត្របំណុល

- **វិធីសាស្ត្រជួញដូរតាមការដេញថ្លៃ** ការជួញដូរមូលបត្របំណុលតាមការដេញថ្លៃ ត្រូវអនុវត្តតាមវិធីសាស្ត្រដេញថ្លៃ សម្រាប់ភាគហ៊ុនលើកលែងតែករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងទៅនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ ដែលថ្លៃជួញដូរគឺជាមធ្យមនព្វន្តនៃថ្លៃផ្គូផ្គងខ្ពស់បំផុត និងថ្លៃផ្គូផ្គងទាបបំផុត។
- ករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ សម្រាប់ការជួញដូរមូលបត្របំណុល។ (សូមមើលតារាងឧទាហរណ៍ខាងក្រោម)

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៩០.៤០០ | ២.០០០ |
| | **៩០.២០០ (ថ្លៃជួញដូរ)** | |
| | ៩០.០៥០ (ថ្លៃដែលបានជួញដូរកាលពី១ខែមុន) | |
| ២.០០០ | ៩០.០០០ | |

- ក្នុងករណីនេះ ថ្លៃដែលអាចផ្គូផ្គងបានមានច្រើន គឺពី ៩០.០០០ ដល់ ៩០.៤០០ ប៉ុន្តែថ្លៃជួញដូរគឺ (៩០.៤០០ + ៩០.០០០)/២ = ៩០.២០០ រៀល។
- ក្នុងករណីថ្លៃទទួលបានពីការគណនានេះមិនចំនឹងឯកតាគម្លាតថ្លៃ នោះថ្លៃជួញដូរត្រូវបង្គត់ឡើងតាមឯកតាគម្លាតថ្លៃ។

➢ **វិធីសាស្ត្រជួញដូរតាមការចរចា** ការជួញដូរមូលបត្របំណុលតាមការចរចា ត្រូវអនុវត្តតាមវិធីសាស្ត្រជួញដូរតាមការចរចាសម្រាប់ភាគហ៊ុន ។

## ខ. ទិដ្ឋភាពផ្សេងៗទៀតទាក់ទងនឹងការជួញដូរមូលបត្របំណុល

➢ **ឯកតាគម្លាតថ្លៃ** ឯកតាគម្លាតថ្លៃគឺ ១ (មួយ) រៀល សម្រាប់ការជួញដូរមូលបត្របំណុលដែលមានតម្លៃចារិក ១០០.០០០ រៀល។

➢ **ប្រភេទនៃបញ្ជា** ប្រភេទនៃបញ្ជាសម្រាប់មូលបត្របំណុលគឺ បញ្ជាដែនកំណត់ និងបញ្ជាតាមការចរចា។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតឡើយ។

➢ **ឯកតាបញ្ជា** ឯកតាបញ្ជានៃមូលបត្របំណុលគឺ ១ (មួយ) ឯកតាមូលបត្របំណុល។

➢ **បញ្ជាអតិបរមា** បញ្ជាអតិបរមាសម្រាប់ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃគឺ ១០.០០០ (មួយម៉ឺន) ឯកតាមូល បត្របំណុល។ មិនមានបរិមាណបញ្ជាអតិបរមាសម្រាប់ការជួញដូរតាមការចរចាឡើយ។

➢ **ដែនកំណត់ថ្លៃប្រចាំថ្ងៃ** មិនអនុវត្តចំពោះការជួញដូរមូលបត្របំណុលឡើយ។

➢ **ថ្លៃពិសេស** មិនមានថ្លៃពិសេសនៅក្នុងការជួញដូរមូលបត្របំណុលឡើយ។

➢ **ថ្លៃបញ្ជា** ថ្លៃបញ្ជា និងថ្លៃជួញដូរមូលបត្របំណុល គឺជាថ្លៃដុល ដែលគិតបញ្ចូលនូវការប្រាក់បង្ករ។

# ជំពូកទី៤

# ការបោះផ្សាយលក់មូលបត្របំណុលនៅកម្ពុជា

## ៤.១. ការចេញផ្សាយប័ណ្ណរតនាគាររយៈពេលខ្លី[43]

រដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការបោះផ្សាយមូលបត្ររដ្ឋដំបូងគឺប័ណ្ណរតនាគារ កាលពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០០៦ ទើបផ្អាក់ការបោះផ្សាយ។

ចាប់ពីដំណើរការដេញថ្លៃលើកដំបូងថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៣ មកដល់ដំណាច់ឆ្នាំ២០០៦ ប័ណ្ណរតនាគារត្រូវបានចេញផ្សាយចំនួន ៣៣លើក ព្រមទាំងបានសងវិញចំនួន ៣៣លើកដែលមានទឹកប្រាក់សរុប ៤៧២.៩ ពាន់លានរៀល។

### ៤.១.១. គោលបំណងនៃការចេញផ្សាយប័ណ្ណរតនាគាររយៈពេលខ្លី

ប័ណ្ណរតនាគារ (Treasury Bill) ចេញផ្សាយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងជំនួសឲ្យខ្ចីប្រាក់រៀលដែលមានរយៈពេលកំណត់ស្មើឬតិចជាងពីរឆ្នាំ។ ប័ណ្ណរត-នាគារអាចបោះផ្សាយជាពីរប្រភេទ គឺប័ណ្ណរតនាគារគណនីចរន្ត ( Treasury Bill Current Account) សម្រាប់លក់ជូនតែគ្រឹះស្ថានធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងអន្តរការីហិរញ្ញវត្ថុផ្សេងៗ និងប័ណ្ណរតនាគារជារូបវន្ត (Treasury Bill on Tap) សម្រាប់លក់ឲ្យឯកត្តជន សហគ្រាស និងអង្គភាពផ្សេងទៀតដែលមិនមែនជាអង្គភាពហិរញ្ញវត្ថុ (មិនទាន់បានអនុវត្ត)។ ប័ណ្ណនេះអាចដាក់លក់អាចដាក់ជាការធានា ឬអាចខ្ចីដោយការបង្វែរពីគណនីមួយទៅគណនីមួយផ្សេងទៀត។ នាយកដ្ឋានប្រតិបត្តិការក្នុងនាមជាធនាគារជាតិនៃកម្ពុជាបានដើរតួនាទីជាអ្នកចេញផ្សាយពីឆ្នាំ២០០៣ ដល់២០០៦ ហើយត្រូវបានផ្អាកទៅវិញដោយសាររាជរដ្ឋាភិបាលពុំមានត្រូវការ។

### ៤.១.២. ដំណើរការចេញប័ណ្ណរតនាគារ

ការបោះផ្សាយប័ណ្ណរតនាគារ ត្រូវធ្វើឡើងដោយសហការរវាងធនាគារជាតិនៃកម្ពុជានិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើតាមរបៀបពីរយ៉ាងគឺ ការចុះឈ្មោះទិញ និងការដេញថ្លៃ។ ការចេញផ្សាយតាមរយៈការដេញថ្លៃ ត្រូវធ្វើឡើងបន្ទាប់ពីគណៈកម្មការចម្រុះអន្តរក្រសួង សម្រេចជាគោលការណ៍ចេញផ្សាយប័ណ្ណរតនាគារ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ញើលិខិតស្នើសុំឲ្យធនាគារជាតិនៃកម្ពុជារៀបចំសម័យប្រជុំដេញថ្លៃប័ណ្ណរតនាគារគណនីចរន្ត ដោយមានការិយាល័យ

[43] ប្រភពឯកសារ, ធនាគារជាតិនៃកម្ពុជា, នាយដ្ឋានប្រតិបត្តិការ

គ្រប់គ្រងមូលបត្រក្នុងនាមនាយកដ្ឋានប្រតិបត្តិការជាអ្នកចាត់ចែង និងដំណើរការដេញថ្លៃ។ ដំណើរការនេះត្រូវធ្វើឡើងដូចតទៅៈ

**១-នីតិវិធីនៃការដេញថ្លៃ**

- បន្ទាប់ពីការទទួលបានសំណើពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធនាគារជាតិនៃកម្ពុជា ចេញផ្សាយសេចក្តីជូនដំណឹងពីការដេញថ្លៃប័ណ្ណរតនាគារគណនីចរន្ត ដល់បណ្តាគ្រឹះដ្ឋានធនាគារនិងហិរញ្ញវត្ថុ ដែលបានចុះកិច្ចព្រមព្រៀងស្តីពីការដេញថ្លៃប័ណ្ណរតនាគារ។
- ទទួលពាក្យដេញថ្លៃចាប់ពីចេញផ្សាយសេចក្តីជូនដំណឹងរហូតដល់ម៉ោង ៨:៤៥ នាទីព្រឹកនៃថ្ងៃដេញថ្លៃ។

**២-ការប្រព្រឹត្តទៅនៃការដេញថ្លៃរយៈពេលខ្លី**

- នៅវេលាម៉ោង ៩ ព្រឹកនៃថ្ងៃដេញថ្លៃ គណៈកម្មការចម្រុះអន្តរក្រសួងជួបជុំដើម្បីបើកប្រអប់សំបុត្រដេញថ្លៃនីមួយៗមកពិនិត្យនៅចំពោះមុខតំណែង
- ពេលពិនិត្យឃើញត្រឹមត្រូវបញ្ជូនពាក្យសុំទាំងនោះទៅក្រុមការងារប្រព័ន្ធបញ្ជីមូលបត្រ ( Book Entry System Service) ដើម្បីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ។
- បន្ទាប់មកក្រុមការងារដេញថ្លៃ បោះពុម្ពតារាងដេញថ្លៃ ( Bid List) ចំនួនពីរច្បាប់ មកប្រគល់ជូនគណៈកម្មការចម្រុះអន្តរក្រសួងពិនិត្យ និងសម្រេចលើឈ្មោះស្ថាប័នដែលទទួលបានជោគជ័យ និងស្ថាប័នដែលត្រូវបដិសេធលើការដេញថ្លៃ។
- បន្ទាប់ពីការសម្រេចចិត្តចុងក្រោយលើចំនួនប្រាក់សរុបចេញផ្សាយត្រូវប្រគល់តារាងដេញថ្លៃនេះឲ្យក្រុមការងារប្រព័ន្ធបញ្ជីមូលបត្រយកមកធ្វើជាសំអាងក្នុងការបញ្ជាក់លទ្ធផល ឈ្នះ-ចាញ់លើការដេញថ្លៃរួចកត់ត្រាក្នុងប្រព័ន្ធ ហើយបង្ហាញឈ្មោះស្ថាប័នដែលទទួលជោគជ័យក្នុងការដេញថ្លៃ និងស្ថាប័នត្រូវបដិសេធលើការដេញថ្លៃ។
- បន្ទាប់មកក្រុមការងារបោះពុម្ពលទ្ធផលដេញថ្លៃជូនដល់ស្ថាប័ន ដែលទទួលជោគជ័យ ដើម្បីកំណត់ចំនួនប្រាក់ត្រូវទូទាត់ក្នុងគណនីចរន្ត និងថ្ងៃភាពនៃការទូទាត់ ដែល និងត្រូវធ្វើ៣ថ្ងៃក្រោយថ្ងៃដេញថ្លៃ។
- ចំណែកឯ ធនាគារដែលទទួលបរាជ័យក្នុងការដេញថ្លៃត្រូវជូនដំណឹងពីការបដិសេធផងដែរ។

### ៣-ការទូទាត់ និងប្រគល់ប័ណ្ណ

- ការទូទាត់ និងការប្រគល់ប័ណ្ណ ប្រព្រឹត្តិឡើង ៣ ថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃ ដោយពិនិត្យមើលសមតុល្យគណនីចរន្តរបស់ខ្លួន ដើម្បីផ្ទេរប្រាក់ទៅគណនីចរន្តរបស់គ្រឹះស្ថានដេញថ្លៃឈ្នះជាទូទៅធនាគារដេញថ្លៃឈ្នះ ចេញមូលប្បទានបត្រលើគណនីចរន្តរបស់ខ្លួន ដើម្បីផ្ទេរប្រាក់ទៅគណនីប្រាក់បញ្ញើប័ណ្ណរតនាគាររបស់រតនាគារជាតិ។
- ពេលពិនិត្យឃើញមានសមតុល្យគ្រប់គ្រាន់ នាយកដ្ឋានប្រតិបត្តិការ ចុះឥណពន្ធគណនីចរន្តរបស់ធនាគារដេញថ្លៃឈ្នះ តាមចំនួនប្រាក់ ថ្លៃទិញហើយបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើប័ណ្ណរតនាគារ។

### ៤-ការទូទាត់សងប្រាក់នៅពេលដល់កាលវសាន

- នៅពេលដល់កាលវសាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកធ្វើការទូទាត់សងវិញ លើប័ណ្ណរតនាគារគណនេយ្យចរន្ត តាមតម្លៃចារឹក ដោយប្រគល់សិទ្ធិឲ្យធនាគារជាតិនៃកម្ពុជា ដកប្រាក់ពីគណនីប្រាក់បញ្ញើប័ណ្ណរតនាគារពុំមានសមតុល្យគ្រប់គ្រាន់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់សិទ្ធិឲ្យធនាគារជាតិនៃកម្ពុជា ផ្ទេរប្រាក់ជាស្វ័យប្រវត្តិពីគណនីប្រាក់បញ្ញើចរន្តរបស់រតនាគារជាតិ រហូតដល់គ្រប់ចំនួនដើម្បីបង្គ្រប់សមតុល្យ ត្រូវទូទាត់សងប័ណ្ណរតនាគារវិញ។

## ៤.២. ការចេញផ្សាយមូលបត្រអាចជួញដូរបាន[44]

### ៤.២.១. គោលបំណងនៃការចេញផ្សាយមូលបត្រអាចជួញដូរបាន

- មូលបត្រអាចជួញដូរបាន (NCDs) ជាប័ណ្ណបំណុលមានការប្រាក់ ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាមានកាលវសានចាប់ពី ១៤ថ្ងៃដល់១ឆ្នាំ ដោយអនុវត្តតាមអត្រាការប្រាក់ប្រចាំថ្ងៃកំណត់ដោយធនាគាជាតិនៃកម្ពុជា។ មូលបត្រនេះអាចផ្ទេរកម្មសិទ្ធិ តាមរយៈការលក់ផ្តាច់ ដាក់ជាវត្ថុធានាបំណុល និងប្រតិបត្តិ-ការលក់សន្យាទិញយកមកវិញ REPO ក្នុងទីផ្សារហិរញ្ញវត្ថុ ដើម្បីបំពេញនូវតម្រូវការសន្ទនីយភាពរយៈពេលខ្លី។ គោលបំណងនៃការចេញផ្សាយ NCDs គឺចង់ឲ្យមានទីផ្សារអន្តរធនាគារមួយកើតឡើងដើម្បីជួយសម្រួលសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ ដោយសារមូលបត្រនេះ ជាឧបករណ៍ទីផ្សារហិរញ្ញវត្ថុមួយយ៉ាងសំខាន់ក្នុងការអនុវត្តទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ និងមានគោលដៅប្រើប្រាស់

[44] ប្រភពឯកសារ, ធនាគារជាតិនៃកម្ពុជា, នាយដ្ឋានប្រតិបត្តិការ

ជាឧបករណ៍គោលនយោបាយរូបិយវត្ថុ។ មូលបត្រនេះត្រូវបានចេញផ្សាយជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក តាមការស្នើសុំរបស់អ្នកជាវដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានហិរញ្ញវត្ថុ)។

**ការចេញផ្សាយនេះមានគោលបំណងខាងដូចក្រោម៖**

- ជំរុញការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងការផ្តល់ឥណទានអន្តរធនាគារផ្អែកលើមូល-ដ្ឋានសុវត្ថិភាព ដោយមូលបត្រត្រូវបានចេញផ្សាយអាចយកមកប្រើប្រាស់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការទទួលទិញវិញ (REPO)។
- ផ្តលឲ្យអ្នកចូលរួមទីផ្សារនូវជម្រើសទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលមួយទៀតបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិនៃកម្ពុជា
- បង្កើតឧបករណ៍បន្ថែមក្នុងគោលដៅជួយគាំទ្រដល់ដំណើរការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។

សរុបមកតាមរយៈការចេញផ្សាយ NCDs ធនាគារជាតិនៃកម្ពុជាសង្ឃឹមថាបណ្តាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចប្រើប្រាស់ NCD ជាផ្នែកមួយក្នុងការគ្រប់គ្រងសន្ទនីយភាពរបស់ខ្លួនដោយមានប្រសិទ្ធិភាព ដើម្បីទទួលបាននូវប្រាក់ចំណូលបន្ថែមជាជាងរក្សាទុកសាច់ប្រាក់សេសសល់រយៈកាលខ្លីនៅទំនេរ និងមិនមានសុវត្ថិភាព។ ម្យ៉ាងទៀតការវិនិយោគលើ NCDរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងក្លាយជាការចាប់ផ្តើមនិងជាការរួមចំណែកដ៏សំខាន់ចំពោះការនាំឲ្យមានការចាប់ផ្តើមកើតឡើងនូវទីផ្សាររូបិយវត្ថុ និងទីផ្សារអន្តរធនាគារនៅកម្ពុជាដោយសារ NCD ជាឧបករណ៍ធានាដ៏រឹងមាំ មានសុវត្ថិភាព និងទុកចិត្តបំផុតសម្រាប់អ្នកវិនិយោគ។ ធនាគារជាតិនៃកម្ពុជាជឿជាក់យ៉ាងមុតមាំថា កិច្ចសហការណ៍រវាងបណ្តាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ពិតជាអាចរួមចំណែកក្នុងការចាប់ផ្តើមបង្កើតទីផ្សាររូបិយវត្ថុ និងទីផ្សារអន្តរធនាគារថ្មីមួយឡើង ដើម្បីបង្កើតឲ្យមានទីផ្សារសុំខ្ចីនិងទីផ្សារឲ្យខ្ចីប្រកបដោយសុវត្ថិភាពភាព និងទាន់ពេលវេលា សំដៅជួយជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា និងក្នុងតំបន់នាពេលអនាគត។

### ៤.២.២. ដំណើរការចេញផ្សាយមូលបត្រអាចជួញដូរបាន[45]

អនុលោមតាមប្រកាសស្តីពី ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃ

[45] ប្រភពឯកសារ, ធនាគារជាតិនៃកម្ពុជា, នាយដ្ឋានប្រតិបត្តិការ

កម្ពុជាចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជា បានសម្រេចចេញផ្សាយ NCD នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ សម្រាប់ផ្តល់ជាឧបករណ៍ថ្មីមួយដល់បណ្តាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងការគ្រប់គ្រងនិងប្រើប្រាស់សន្ទនីយភាពតាមការចាំបាច់ ចៀសវាងការរក្សាទុកសាច់ប្រាក់ទំនេរដោយមិនទទួលបានអត្ថប្រយោជន៍។

**១.លក្ខណៈនៃ NCD**

មូលបត្រអាចជួញដូរបានត្រូវបានផ្សាយជាលក្ខណៈអរូបិយ និងតម្លៃចារឹក (Face value) ហើយធនាគារជាតិនៃកម្ពុជាបំពេញតួនាទីជាអ្នកបោះផ្សាយផងនិងជាអ្នករក្សាមូលបត្រផង។ NCD គឺជាប័ណ្ណបំណុលរយៈពេលខ្លីមានការប្រាក់ ដែលចេញផ្សាយដោយធនាគារនៃកម្ពុជា។ ប័ណ្ណនេះចេញផ្សាយជារូបិយវត្ថុរៀល (KHR) និងរូបិយប័ណ្ណដុល្លារអាមេរិក (USD) ដោយមានតម្លៃនាមចារឹកអប្បបរមា គឺ ៥០.០០០ ដុល្លារអាមេរិក ឬ ២០០.០០០.០០០ រៀល។ អត្រាការប្រាក់រួមជាមួយនឹងអាយុកាលរបស់ NCD ដែលចេញដោយធនាគារជាតិនៃកម្ពុជារៀងរាល់ថ្ងៃធ្វើការនៅលើគេហទំព័រ www.nbc.org.kh។

**១.ការផ្ទេរម្ចាស់កម្មសិទ្ធិ**

NCD អាចត្រូវបានប្តូរកម្មសិទ្ធិលើទីផ្សារអន្តរធនាគារតាមរយៈ៖

- **ការលក់ផ្តាច់** គឺជាប្រភេទផ្ទេរម្ចាស់កម្មសិទ្ធិទាំងស្រុង និងអនុញ្ញាតឲ្យអ្នកទទួលសិទ្ធិចុងក្រោយអាចប្រើប្រាស់សម្រាប់ប្រតិបត្តិការផ្សេងៗទៀតដូចជា លក់ ដាក់បញ្ចាំ និងដាក់ជា (អ្នកទិញ) REPO ជាដើម។
- **REPO** គឺជាប្រភេទផ្ទេរកម្មសិទ្ធិមួយដែលអ្នកផ្ទេរកម្មសិទ្ធិបានសន្យាជាមួយនិងអ្នកទទួលកម្មសិទ្ធិថានិងទទួលយក NCD វិញតាមពេលវេលាជាក់លាក់ណាមួយ។ ក្នុងករណីនេះ អ្នកទទួលកម្មសិទ្ធិ មិនអាចប្រើប្រាស់ NCD សម្រាប់ធ្វើប្រតិបត្តិការផ្សេងទៀតដូចជា លក់ ដាក់បញ្ចាំ ឬដាក់ REPO បានឡើយ។
- **ដាក់ធានា** គឺជាប្រភេទផ្ទេរកម្មសិទ្ធិដែលអនុញ្ញាតឲ្យម្ចាស់កម្មសិទ្ធិអាចដាក់ NCD ធានាដើម្បីទទួលបានមូលនិធិតាមការព្រមព្រៀងជាមួយអ្នកទទួលកម្មសិទ្ធិ ហើយអ្នកទទួលកម្មសិទ្ធិមិនអាចប្រើប្រាស់ NCD សម្រាប់ធ្វើប្រតិបត្តិការផ្សេងទៀត ដូចជា លក់ ដាក់បញ្ចាំ ឬដាក់ REPO បានឡើយ។

**3-ការលក់ NCD ឲ្យធនាគារជាតិនៃកម្ពុជាវិញ**

បន្ថែមលើការផ្ទេរកម្មសិទ្ធិរវាងទីផ្សារអន្តរធនាគារ NCD អាចលក់ឲ្យធនាគារជាតិនៃកម្ពុជាវិញ ដោយផ្អែកលើមូលដ្ឋានហេតុផលដែលអាចទទួលយកបាន នៅពេលដែលម្ចាស់ NCD មានតម្រូវការសន្ទនីយភាពបន្ទាន់ ដោយអនុវត្តតាមអត្រាទិញត្រឡប់វិញជាក់ស្តែងកំណត់ដោយធនាគារជាតិនៃកម្ពុជាដែលមាននៅគេហទំព័រធនាគារជាតិនៃកម្ពុជា។

## ៤.៣. បច្ចុប្បន្នភាពមូលបត្របំណុលកម្ពុជា

### ៤.៣.១. មូលបត្រអាចជួញដូរបាន (NCD)

ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយជាផ្លូវការលើកដំបូងនូវមូលបត្រអាជជួញដូរបាន កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣។ ដោយគិតចាប់ពីខែកញ្ញាដល់ដំណាច់ឆ្នាំ២០១៣ ធនាគារជាតិនៃកម្ពុជាបានលក់ NCD ចំនួន១២ ដែលមានតម្លៃសរុប ១៥លានដុល្លារអាមេរិក។

ការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកមានការកើនឡើងខ្ពស់ ខណៈដែលការចេញផ្សាយ NCD ចារឹកជារៀលបានថមថយ។ NCD ចារឹកជាប្រាក់ដុល្លារអាមេរិកដែលបានចេញផ្សាយមានចំនួន ២២,១ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១០% និងស្រូបយកសន្ទនីយភាពលើសជាដុល្លារអាមេរិកប្រមាណ ៥៥% ខ្ពស់ជាងឆ្នាំមុនបន្តិច (៥១%)។ ការកើនឡើងនេះបង្ហាញពីភាពទាក់ទាញរបស់ NCD ចារឹកជាដុល្លារអាមេរិក ដោយសារ NCD ជាជម្រើសល្អមួយជំនួសការទុកសាច់ប្រាក់ចោល។ ចំណែក NCD ចារឹកជាប្រាក់រៀលដែលបានចេញផ្សាយមានចំនួន ១១,៦ ទ្រីលានរៀល បានថមថយ១៦,៨% និងស្រូបយកសន្ទនីយភាពលើស ៣៥% ទាបជាងឆ្នាំ២០១៧ (៤៣%)។ ការថយចុះនេះ បណ្តាលមកពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានបង្កើនការផ្តល់ឥណទានជាប្រាក់រៀល ស្របតាមប្រកាសរបស់ធនាគារជាតិកម្ពុជា ដែលតម្រូវឲ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុមានឥណទានជារូបិយវត្ថុជាតិ យ៉ាងតិច ១០% នៃសំពៀតឥណទានសរុបនៅត្រឹមចុងឆ្នាំ២០១៩។

ក្នុងគោលដៅបន្តអភិវឌ្ឍ NCD ឲ្យក្លាយជាឧបករណ៍គ្រប់គ្រងសន្ទនីយភាពកាន់តែមានភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរួមចំណែកអភិវឌ្ឍទីផ្សារអន្តរធនាគារ កាលពី ខែវិច្ឆកា ឆ្នាំ២០១៧កន្លងទៅ ធនាគារជាតិនៃកម្ពុជាបានសម្រេចកំណត់អត្រាការប្រាក់ NCD ចារឹកជាដុល្លារអាមេរិកដែលមានឥណប្រតិទានរយៈពេលខ្លី ទាបជាងមុន ដើម្បីជំរុញឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ងាកទៅវិនិយោគសន្ទនីយភាពដែលនៅសល់ក្នុងទីផ្សារអន្តរធនាគារឲ្យបានកាន់តែច្រើន។

### ៤.៣.២. ប្រតិបត្តិការណ៍ផ្តល់សន្ទនីភាពដោយមានការធានា (LPCO)

នៅឆ្នាំ២០១៧ ប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើងជារៀងរាល់ខែ ដោយបានផ្តល់សន្ទនីយភាពជាប្រាក់រៀលសរុបចំនួនប្រមាណ១៣៤ប៊ីលានរៀលជាមួយនឹងអត្រាការប្រាក់ជាមធ្យម៣%។

ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តប្រតិបត្តិការ LPCO ដើម្បីរួមចំណែកចម្រុញការប្រើប្រាស់ប្រាក់រៀល ក៏ដូចជាបំពេញសេចក្តីត្រូវការសន្ទនីយភាពជារៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្ថានភាពដែលទីផ្សារអន្តរធនាគារមិនទាន់សកម្មនៅឡើយ។

ក្នុងឆ្នាំ២០១៨ ប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើង ១២លើក ដោយបានផ្តល់សន្ទនីយភាពជាប្រាក់រៀលសរុបប្រមាណ ១៩៦,៩ប៊ីលានរៀល (១៧២,១ លានដុល្លារអាមេរិក) កើនឡើង ៥ដងធៀបនឹងឆ្នាំ២០១៧ ជាមួយនឹងអត្រាការប្រាក់ដេញថ្លៃបានជាមធ្យម ២,៦២% ២,៨៧% និង ៣,០៥% ចំពោះប្រភេទឥណប្រតិទាន ៣ខែ ៦ខែ និង ១ឆ្នាំ រៀងគ្នា។ គ្រឹះស្ថានចូលរួមក្នុងប្រតិបត្តិការ LPCO កើនឡើងដល់ ១២ គ្រឹះស្ថាន ធៀបនឹងឆ្នាំកន្លងទៅ ដែលមានតែ ៥គ្រឹះស្ថានប៉ុណ្ណោះ។ គិតត្រឹមដំណាច់ឆ្នាំ២០១៨ ទំហំទឹកប្រាក់ប្រតិបត្តិការ LPCO ដែលមិនទាន់ដល់ឥណប្រតិទានមានចំនួន ៥៦៤,៦ ប៊ីលានរៀល (១៣១,១ លានដុល្លារអាមេរិក)។

**តួនាទីរបស់ប្រតិបត្តិការ LPCO**

តាមរយៈប្រតិបត្តិការLPCOកន្លងមក ធនាគារជាតិនៃកម្ពុជាបានចូលរួមដើរតួនាទីសំខាន់ៗដូចជា៖

- ឆ្លើយតបទៅនឹងកង្វះសន្ទនីយភាពប្រាក់រៀល៖ ប្រតិបត្តិការ LPCO បានជួយដោះស្រាយកង្វះសន្ទនីយភាពជារៀលដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ក្នុងបរិការណ៍ដែលទីផ្សារអន្តរធនាគារនៅមានកម្រិត ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀលដែលបន្តកើនឡើងក្នុងសេដ្ឋកិច្ច។
- សម្រួលលទ្ធភាពបង្កើនសំពៀតឥណទានជារៀល៖ ប្រតិបត្តិការ LPCO អនុញ្ញាតឲ្យធនាគារនិងមីក្រូហិរញ្ញវត្ថុទទួលបានសន្ទនីយភាពជារៀល ដែលជាកត្តាចូលរួមចំណែកសម្រួលដល់គ្រឹះស្ថាន ដែលមានបំណងបង្កើនសំពៀតឥណទានជារៀលឲ្យបានយ៉ាងតិច១០%នៅឆ្នាំ២០១៩ តាមសេចក្តីប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។
- ជួយបន្ទាបអត្រាការប្រាក់កម្ចីជាប្រាក់រៀល៖ កន្លងមកឥណទានជារៀលដែលគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុផ្តល់ដល់អតិថិជន មានអត្រាការប្រាក់ខ្ពស់ជាងឥណទានជាប្រាក់ដុល្លារអាមេរិក ដោយសារហេតុផលមួយចំនួន ដែលក្នុងនោះក៏មានការ

លើកឡើងពីកង្វះប្រភពមូលនិធិជាប្រាក់រៀល ឬការចំណាយខ្ពស់ក្នុងប្រតិបត្តិការស្វប់ជាដើម។ ដូចនេះការដាក់ឲ្យដំណើរការប្រតិបត្តិការ LPCO បានជួយបង្កើនប្រភពមូលនិធិជាប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងបានរួមចំណែកកាត់បន្ថយគម្លាតរវាងអត្រាការប្រាក់កម្ចីជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកឲ្យកាន់តែមានកម្រិតតូច ដែលធ្វើឲ្យប្រាក់រៀលកាន់តែមានភាពទាក់ទាញ។

### ៤.៣.៣. សញ្ញាបណ្ណសាជីវកម្ម

មូលបត្របំណុលរបស់ក្រុមហ៊ុន ឬ (សញ្ញាបណ្ណសាជីវកម្ម) គឺបោះផ្សាយដោយក្រុមហ៊ុនឯកជនដើម្បីលក់ទៅឲ្យសាធារណជនក្នុងរយៈពេលកំណត់ណាមួយ។ អ្នកដែលទិញមូលបត្របំណុលពីក្រុមហ៊ុន មានន័យថា ជាអ្នកកាន់កាប់លើមូលបត្របំណុល និងក្លាយជាម្ចាស់បំណុលហើយនឹងទទួលបានប្រាក់ដើម រួមទាំងការប្រាក់ត្រឡប់មកវិញក្នុងកាលកំណត់មួយ។

#### ៤.៣.៣.១. សញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ

នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ គឺជាថ្ងៃដែលមានការបោះផ្សាយសញ្ញាបណ្ណសារជីវកម្មដំបូងបង្អស់មិនធ្លាប់មាននៅកម្ពុជា ហើយក៏ជាដំណើរការមួយដ៏មានសារៈសំខាន់ក្នុងការបន្តការរីកចំរើន និង ការអភិវឌ្ឍទីផ្សារមូលធនកម្ពុជាផងដែរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត បានក្លាយជាក្រុមហ៊ុនបោះផ្សាយទី៦ ដែលបានចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងជាស្ថាប័នមីក្រូហិរញ្ញវត្ថុទីមួយក្នុងការបោះផ្សាយសញ្ញាបណ្ណសាជីវកម្មនេះ។

សញ្ញាបណ្ណនេះ ទទួលបានចំណាប់អារម្មណ៍ពីសាជីវកម្មហិរញ្ញវត្ថុកម្ពុជា ដែលហៅកាត់ថា អាយអេសស៊ី ដែលបានទិញសញ្ញាបណ្ណនេះ រហូតដល់ ៨០ពាន់លានរៀល ដើម្បីចូលរួមជួយបង្កើតទីផ្សារសញ្ញាបណ្ណនៅកម្ពុជា។ ធនាគារវឌ្ឍនៈ ធនាគារកម្ពុជាពាណិជ្ជចំកាត់ និងក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ក៏បានសន្យាវិនិយោគជាមួយនឹងសញ្ញាបណ្ណនេះផងដែរ។ គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុហត្ថាកសិករ បានបោះផ្សាយសញ្ញាបណ្ណសាជីវកម្មចំនួន ១,២០០,០០០ ប័ណ្ណ ក្នុងតម្លៃចារឹក ១០០,០០០រៀល មានឥណប្រតិទានចំនួន៣ឆ្នាំដែលមានអត្រាការប្រាក់ ៨,៥០% ហើយរាល់ការទូទាត់ត្រូវធ្វើឡើងជារៀងរាល់ឆមាស។ តាមរយៈការបោះផ្សាយនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករបានរកមូលធនបានចំនួន ១២០ពាន់លៀនរៀល (៣០លានដុល្លារអាមេរិក)។

ការបោះផ្សាយសញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ គឺជាព្រឹត្តិ-ការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀត ដែលផ្សារមូលបត្រកម្ពុជាចាប់ផ្តើមមានសញ្ញាបណ្ណសាជីវកម្មដំបូងបង្អស់នៅក្នុងទីផ្សារដែលកន្លងមក ទីផ្សារនេះមានតែការចុះបញ្ជីលក់មូលកម្មសិទ្ធិតែប៉ុណ្ណោះ។

**៤.៣.៣.២. សញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី**

ថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១៩ ជាថ្ងៃប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់ផ្សារមូលបត្រកម្ពុជា ដែលទទួលបាន ការចុះបញ្ជីសញ្ញាបណ្ណសាជីវកម្ម ដែលជាសញ្ញាបណ្ណសាជីវកម្មទី២នៅប្រទេសកម្ពុជារបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា)។ ដែលបានសម្រេចជោគជ័យ ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មទី២នៅកម្ពុជា ចំនួន ៨សែនប័ណ្ណ សរុបជាទឹកប្រាក់ចំនួន ៨០ ប៊ីលានរៀល(ប្រមាណជា ២០លានដុល្លារសហរដ្ឋអាមេរិក) និងបានក្លាយជាក្រុមហ៊ុនទីប្រាំពីរ និងជាគ្រឹះស្ថាន ហិរញ្ញវត្ថុទី២ ដែលបានចុះបញ្ជីលក់មូលបត្របំណុលរបស់ខ្លួនជាផ្លូវការនៅលើផ្សារមូលបត្រកម្ពុជា។ ហើយនេះក៏ជាឱកាសមួយដែលអនុញ្ញាតឱ្យ អិលអូអិលស៊ី ផ្តល់ជូនទីផ្សារនូវផលិតផលហិរញ្ញវត្ថុមួយថ្មីបន្ថែមទៀតគឺ សញ្ញាបណ្ណសាជីវកម្មដែលគ្មានការការពារហានិភ័យអត្រាប្តូរប្រាក់ (Plain Bond) ក្នុងអត្រា៩% និងសញ្ញាបណ្ណសាជីវកម្មដែលមានការការពារហានិភ័យអត្រាប្តូរប្រាក់ (Fx-indexed Bond) ក្នុងអត្រា៨% នឹងត្រូវទូទាត់ជារៀងរាល់ឆមាសដែលមានឥណប្រតិទានរយៈពេល ៣ឆ្នាំ។

**៤.៣.៣.៣. ការចុះបញ្ជីរបស់ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ABA Bank)**

ក្នុងកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជា លើកទី៥៦ នៅរសៀលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ក្រោមអធិបតីភាពអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** គណៈកម្មការមូលបត្រអនុម័តដោយផ្តល់ការអនុញ្ញាត ជាគោលការណ៍លើសំណើ សុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈរបស់ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ធនាគារ ABA)។

ធនាគារ ABA បានស្នើសុំបោះផ្សាយលក់មូលបត្របំណុល ដែលជាប្រភេទសញ្ញាបណ្ណធម្មតាគ្មានវត្ថុធានា ក្នុងអត្រាគូប៉ុងប្រចាំឆ្នាំចន្លោះពី ៧%-៧,៧៥% ក្នុងមួយឆ្នាំ ជាមួយនឹងការទូទាត់ គូប៉ុងប្រចាំឆមាស។ ធនាគារ ABA គ្រោងបោះផ្សាយក្នុងទំហំប្រាក់សរុប ១២៨ប៊ីលានរៀល (ប្រហែល៣២លានដុល្លារ) មានតម្លៃចារឹកក្នុងមួយឯកតាមូលបត្របំណុល ១០០,០០០រៀល និងមានឥណប្រតិទាន ៣ឆ្នាំ។ ធនាគារត្រូវបន្តនីតិវិធីនៃការបោះផ្សាយលក់មូលបត្របំណុលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន មុនទទួលបានការអនុញ្ញាតជាផ្លូវការ ក្នុងការចុះបញ្ជីលើទីផ្សារមូលបត្រកម្ពុជា។

ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីទី (SBI Royal Securities) គឺជាទីប្រឹក្សាហិរញ្ញវត្ថុ និងក្រុមហ៊ុនធានាទិញមូលបត្រតែមួយគត់ សម្រាប់ការបោះផ្សាយនេះ។

# ជំពូកទី៥៖
# ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា

## ៥.១. គោលបំណងនៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល

ស្របតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាទីផ្សារមូលបត្រត្រូវបានបង្កើតឡើងដើម្បីជាមធ្យោបាយក្នុងការកៀរគរមូលធន ព្រមទាំងបែងចែកទុនសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជាគឺដើម្បីឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) និងសហគ្រាសដំទៃទៀតអាចបោះផ្សាយសញ្ញាបណ្ណសាជីវកម្មបាន ដែលនេះនឹងក្លាយជាឧបករណ៍ហិរញ្ញវត្ថុដ៏ល្អមួយដើម្បីជួយកាត់បន្ថយគម្លាតរវាងតម្រូវការនិងការផ្គត់ផ្គង់ប្រភពទុននៅទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា ដែលនឹងមិនចាំបាច់ពឹងផ្អែកខ្លាំងពេកលើកម្ចីពីបរទេសខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនទៀតជាច្រើនតែងពឹងលើកម្ចីពីបរទេសសម្រាប់អាជីវកម្ម។ ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជាអនុញ្ញាតឲ្យគ្រឹះស្ថានហិរញ្ញវត្ថុធំៗ និងក្រុមហ៊ុនមួយចំនួនមានជម្រើស ក្នុងការកៀរគរដើមទុនពីក្នុងស្រុកបានច្រើនជាងមុន ជាជាងកម្ចីពីបរទេសដែលមានអត្រាការប្រាក់ខ្ពស់។ នៅពេល គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនទាំងនោះ អាចកៀរគរដើមទុនតាមរយៈការបោះផ្សាយលក់សញ្ញាបណ្ណ វាអាចជាយន្តការដ៏ល្អមួយសម្រាប់គ្រឹះស្ថានធនាគារដែលមានដើមទុនលើសក្នុងការទិញប័ណ្ណបំណុលទាំងនោះពី MFI ដែលកត្តាទាំងនេះនឹងជួយដោះស្រាយបញ្ហាភាពមិនស៊ីចង្វាក់គ្នានៃតម្រូវការ និងការផ្គត់ផ្គង់នាពេលកន្លងមក។ នៅពេលដែលសញ្ញាបណ្ណសាជីវកម្មបានក្លាយជាជម្រើសថ្មីមួយក្នុងការទទួលបានហិរញ្ញវត្ថុនៅកម្ពុជា វានឹងក្លាយជាដំណោះស្រាយដ៏ល្អបំផុតសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុជាច្រើនជាពិសេស MFI ក្នុងការកៀរគរប្រភពទុនបន្ថែម។

## ៥.២. សារៈសំខាន់នៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល

ដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) និងក្រុមហ៊ុនសាជីវកម្មមានតម្រូវការដើមទុនបន្ថែមជាចំបាច់ ជាពិសេសមូលធនរយៈពេលវែង។ ការអភិវឌ្ឍទីផ្សារមូលបត្របំណុលជាឱកាសមួយដ៏ល្អបំផុតសម្រាប់ MFIនិងក្រុមហ៊ុនសាជីវកម្មផ្សេងៗប្រមូលបានមូលធនជាច្រើន ពីការបោះផ្សាយសញ្ញាបណ្ណ បន្ថែមលើភាគហ៊ុនកម្មសិទ្ធដែលមានស្រាប់នៅក្នុងទីផ្សារមូលបត្រកម្ពុជា ដែលនេះជាការបំពេញបន្ថែមនៃតម្រូវការរបស់អ្នកវិនិយោគណាដែលចង់បានការវិនិយោគដែលមានហានិភ័យទាប មានស្ថិរភាពប្រាក់ចំណូល និងមានអាទិភាពក្នុងការទទួលបានសំណង។ សារៈសំខាន់នៃការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា គឺជា

យុទ្ធសាស្ត្រទាញយកមូលនិធិមួយបន្ថែមទៀត ក្នុងការធ្វើឱ្យប្រភពដើមទុនរបស់គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ (MFI) មានភាពសម្បូរបែប សុវត្ថិភាព និងយូរអង្វែង បន្ថែមពីលើប្រភពទុនដែលមានស្រាប់ដូចជា កម្ចីពីធនាគារក្នុងស្រុក កម្ចីពីក្រៅប្រទេស និងប្រាក់បញ្ញើរបស់អតិថិជន។ ការទទួលបានមូលធនបន្ថែមពីសញ្ញាបណ្ណសាជីវកម្មនឹងធ្វើឱ្យ (MFI) អាចពង្រីកប្រតិបត្តិការរបស់ខ្លួនកាន់តែធំទូលាយមួយកម្រិតទៀត។ បន្ថែមលើនេះ ការបោះផ្សាយលក់មូលបត្របំណុលនឹងធ្វើឱ្យ (MFI) និងក្រុមហ៊ុនមួយចំនួនទៀត កាន់តែមានកេរ្តិ៍ឈ្មោះនិងកិត្តិស័ព្ទល្បីល្បាញនៅលើ ទីផ្សារហិរញ្ញវត្ថុនិងចំពោះសាធារណជន។

លើសពីនេះទៅទៀត ការបោះផ្សាយសញ្ញាបណ្ណសាជីវកម្មនេះ នឹងបានចូលរួមចំណែកគាំទ្រដល់គោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញសេដ្ឋកិច្ចជាតិឲ្យកាន់តែរីកចម្រើនឡើង និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដែលសញ្ញាបណ្ណសាជីវកម្មទាំងនោះត្រូវបោះផ្សាយជារូបិយវត្ថុជាតិ និងការប្រាក់ទទួលបាននឹងត្រូវទូទាត់ជារូបិយវត្ថុរៀលខ្មែរ។

តាមរយៈទីផ្សារមូលបត្របំណុល សហគ្រាសអាចធ្វើការប្រមូលទុន ដោយមិនចាំបាច់ចំណាយលើការប្រាក់ច្រើនដូចកម្ចីពីធនាគារ ហើយសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុក៏អាចធ្វើការពង្រីកដើមទុនរបស់ខ្លួនបន្ថែមពីលើបានទៀតផងដែរ។មិនតែប៉ុណ្ណោះការកកើតនូវក្រុមហ៊ុនផ្សារមូលបត្រកាន់តែច្រើន ជួយឲ្យគេអាច ទស្សន៍ទាយអំពីការគ្រប់គ្រងសហគ្រាស ចូលរួមចំណែកបន្តស្ថិរភាពក្នុងការពង្រីកលទ្ធភាពប្រមូលពន្ធអាករជាដើម ដែលវានឹងដើរតួនាទីយ៉ាងធំធេង ក្នុងការអភិវឌ្ឍន៍នូវកម្លាំងប្រកួតប្រជែងរបស់ប្រទេសជាតិក្នុងរយៈពេលវែង។

ជាមួយគ្នានេះដែរ ប្រជាជនកម្ពុជាក៏អាចធ្វើការវិនិយោគលើតម្លៃនៃសហគ្រាសដែលកំពុងលូតលាស់តាមរយៈទីផ្សារមូលបត្រនេះ ហើយតាមរយៈការចែករំលែកនូវលទ្ធផលជាផ្លែផ្កាអំពីការរីកលូតលាស់នៃសហគ្រាសតាមរយៈទីផ្សារមូលបត្រនេះ ក៏នឹងបង្កើតបានជា ការវិនិយោគ ចម្រុះ និងឱកាសក្នុងការប្រមូល ពង្រីកដើមទុនផងដែរ។

### ៥.២.១. ពង្រីកលទ្ធភាពទទួលបានដើមទុនបន្ថែម ដើម្បីវិនិយោគក្នុងខឿនសេដ្ឋកិច្ច

សហគ្រាសធនតូច និងមធ្យម (SMEs) ត្រូវបានចាត់ទុកថាជាកតាលីករដ៏សំខាន់មួយក្នុងការជួយជំរុញសេដ្ឋកិច្ចកម្ពុជា តាមរយៈសកម្មភាពអាជីវកម្មដ៏មមាញឹក និងការផ្តល់ការងារដល់ប្រជាជនក្នុងស្រុក។ អាស្រ័យហេតុនេះ ក្នុងគោលដៅឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ SMEs ក្នុងស្រុកបន្ទាប់ពីមានការបើកសហគមន៍សេដ្ឋកិច្ចអាស៊ាន ក៏ដូចជាការអភិវឌ្ឍវិស័យមូលបត្របំណុល

នៅកម្ពុជាតាមរយៈការជំរុញការយល់ដឹងរបស់ SMEs ពាក់ព័ន្ធនឹងវិស័យមូលបត្របំណុល និងបង្កើនលទ្ធភាពចូលរួមរបស់សហគ្រាសទាំងនេះក្នុងវិស័យនេះ គណៈកម្មការមូលបត្រកម្ពុជា បានសហការជាមួយសមាគមធុរកិច្ចចំនួន ៤ រួមមាន សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) សមាគមសហគ្រិនវ័យក្មេងកម្ពុជា (CWEA) និងក្លឹបវិនិយោគិនកម្ពុជា(CIC) ក្នុងការបណ្តុះបណ្តាលស្តីពី **ការទទួលបានដើម្បីទុនបន្ថែមតាមរយៈទីផ្សារមូលបត្របំណុលនៅកម្ពុជា** ដល់សមាជិកសមាគមទាំង៤នេះ។ អត្ថប្រយោ-ជន៍លើសពីដើមទុនរយៈពេលវែង ដែលក្រុមហ៊ុននឹងទទួលបានពីទីផ្សារមូលបត្របំណុល កម្ពុជាការពង្រឹងការគ្រប់គ្រង ការរៀបចំ និងការអភិវឌ្ឍអភិបាលកិច្ចសាជីវកម្មល្អរបស់ក្រុមហ៊ុនដែលជាកត្តាកំណត់នូវភាពជោគជ័យក្នុងប្រតិបត្តិការអាជីវកម្មក៏ដូចជាការប្រកួតប្រជែងរបស់SMEs។ ការអប់រំអំពីចំណេះដឹងពាក់ព័ន្ធនឹងវិស័យមូលបត្របំណុល បានបើកឱកាសនិងជួយបង្កើនទំនាក់ទំនងរវាងអ្នកចូលរួមទាំងអស់ជាមួយនឹងគណៈកម្មការមូលបត្រកម្ពុជា។

ទន្ទឹមនឹងនេះផងដែរ ដើម្បីបង្កើតនូវកិច្ចសហការលើកកម្ពស់ និងបង្កើតការយល់ដឹងពាក់ព័ន្ធនឹងវិស័យមូលបត្របំណុល គណៈកម្មការមូលបត្រកម្ពុជា និងសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា ក៏បានរៀបចំកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី **កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការជំរុញការចូលរួមរបស់សហគ្រាសធនតូច និងមធ្យមនៅក្នុងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា** នៅសណ្ឋាគារ រ៉ាហ្វលឡឺរ៉ូយ៉ាល់ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា។

### ៥.២.២. ការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ

ក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល ឲ្យមានសញ្ញាបណ្ណសាជីវកម្មរបស់ក្រុមហ៊ុនជាច្រើនត្រូវបានជួញដូរនៅក្នុងទីផ្សារ។ ដំណើរការទិញ-លក់ទាំងនេះនឹងជួយក្នុងការវិនិយោគលើគម្រោងវិនិយោគដែលមានផលិតភាពខ្ពស់ដែលអាចឈានទៅដល់ការបង្កើតមូលធននិងនាំឲ្យមានកំណើនសេដ្ឋកិច្ច។ ការវិនិយោគទៅលើមូលបត្របំណុល វិនិយោគិនមិនត្រឹមតែបានទទួលនូវប្រាក់ចំណេញនោះទេ ក៏ប៉ុន្តែទឹកប្រាក់ទាំងនោះនឹងជួយឲ្យក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណទទួលបានដើមទុនបន្ថែមសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន និងមានសមត្ថភាពជួលបុគ្គលិកឲ្យធ្វើការបន្ថែម។ ក្នុងន័យនេះ ការវិនិយោគលើសញ្ញាបណ្ណគឺជាការចូលរួម

ចំណែកជួយបង្កើនការងារ បង្កើនប្រាក់ចំណូលដល់បុគ្គល គ្រួសារ សង្គម និងជាពិសេស បង្កើនចំណូលពន្ធដើម្បីជួយជំរុញក្នុងការបង្កើនសេដ្ឋកិច្ចជាតិឲ្យកាន់តែរីកចម្រើនឡើង។

## ៥.៣. វឌ្ឍនភាព និងសមិទ្ធផល

ក្នុងកិច្ចខិតខំអភិវឌ្ឍទីផ្សារមូលបត្ររបស់រាជរដ្ឋាភិបាលកម្ពុជាកន្លងមកយើងឃើញថា ផ្សារមូលបត្របានលេចឡើងនូវសមិទ្ធផលជាច្រើនដូចជា ការកើនឡើងនៃក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់ភាគហ៊ុនកម្មសិទ្ធិ ដែលមកទល់ពេលនេះមានក្រុមហ៊ុនចំនួន៥ បានចុះបញ្ជីក្នុងផ្សារហ៊ុនកម្ពុជា ការមានវត្តមានរបស់ក្រុមហ៊ុនបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មចំនួនពីរ ដែលមិនធ្លាប់មាននៅក្នុងផ្សារមូលបត្រកម្ពុជាពីមុនមកនាពេលថ្មីៗនេះ និងមានក្រុមហ៊ុន ៣ទៅ ៤ ទៀតនឹងរៀបចំបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីបោះផ្សាយសញ្ញាបណ្ណសាជីវកម្មជាបន្តទៀត។ កត្តាទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញថា ទីផ្សារមូលបត្របំណុលបានចាប់ផ្តើមមានដំណើរការនៅលើទីផ្សារមូលបត្រកម្ពុជា ទោះបីជាចំនួននេះនៅតិចនៅឡើយ តែនេះបានបង្ហាញឲ្យឃើញថា ទីផ្សារមូលបត្របំណុលកំពុងអភិវឌ្ឍខ្លួនបន្តិចម្តងៗពីចំណុចសូន្យមកដល់ដំណាក់កាលនេះ។ ផ្អែកលើសមិទ្ធផលទាំងអស់នេះរាជរដ្ឋាភិបាលកម្ពុជាបានរំពឹងថា ទីផ្សារមូលបត្របំណុលនៅកម្ពុជានឹងមានការរីកចម្រើនកាន់តែខ្លាំងឡើងៗ និងបានដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីផ្សារនេះឲ្យកាន់តែមានសន្ទុះកាន់តែខ្លាំងខ្លាដើម្បីគាំទ្រដល់វិស័យហិរញ្ញវត្ថុកម្ពុជា ជាពិសេសជំរុញកំណើនសេដ្ឋកិច្ចជាតិឲ្យកាន់តែល្អប្រសើរឡើង។

ក្នុងដំណាក់កាលរីកចម្រើននេះ ទីផ្សារមូលបត្របំណុលបានជួយទ្រទ្រង់ដល់ការរីកចម្រើនរបស់ក្រុមហ៊ុនសាជីវកម្ម និងគ្រឹះស្ថានប័នមីក្រូហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត និងបានបង្កើននូវផលិតផលថ្មីៗផ្តល់ជូនទៅវិនិយោគិនទាំងរូបវន្តបុគ្គល និងនីតិបុគ្គលក្នុងស្រុក និងក្រៅស្រុកសម្រាប់ការជ្រើសរើសក្នុងការវិនិយោគនៅក្នុងទីផ្សារមូលធនកម្ពុជា ជាពិសេសការផ្តល់ប្រាក់ចំណេញជាច្រើនដល់វិនិយោគិន។

## ៥.៤. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

យ៉ាងណាក៏ដោយភាពជោគជ័យនៃការអភិវឌ្ឍឧបករណ៍ហិរញ្ញវត្ថុ (សញ្ញាបណ្ណ) ថ្មីនេះត្រូវបានអ្នកជំនាញលើកឡើងថានឹងត្រូវប្រឈមនឹងបញ្ហាជាច្រើន រាប់ទាំងធនធានមនុស្ស ចំណេះដឹងសាធារណជន និងទំនុកចិត្តសាធារណជន សារព័ត៌មានមិនទាន់ទូលំទូលាយ និងមានកម្រិតប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការ សន្ទនីយភាពនៅក្នុងទីផ្សារ ភាពនៃប្រព័ន្ធ និងបទដ្ឋានដើម្បីគាំទ្រដល់ការអភិវឌ្ឍថ្មីៗជាដើម។ បញ្ហាប្រឈមនាពេលបច្ចុប្បន្ន សម្រាប់កិច្ចអភិវឌ្ឍទីផ្សារមូលបត្រ គឺ

ការសម្រេចបាននូវសកម្មភាពផ្សេងៗ ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល។ សមត្ថភាពគ្រប់គ្រង គឺមនុស្សដែលជាអ្នកគ្រប់គ្រងមិនទាន់មានសមត្ថភាពគ្រប់គ្រាន់។ ការពង្រឹងនូវបទដ្ឋានគតិយុត្តិ គឺច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណ៍ សមត្ថភាពទីផ្សារចង់សំដៅលើទីផ្សារដែលដំណើរការដោយមានប្រព័ន្ធត្រឹមត្រូវ និងការដែលធ្វើឲ្យអ្នកចូលរួមក្នុងទីផ្សារមានជំនឿទុកចិត្តលើទីផ្សារ។

**៥.៤.១. កត្តាធនធានមនុស្ស**

ដោយសារទីផ្សារមូលបត្រនៅកម្ពុជា ទើបតែបានចាប់ផ្តើមនាពេលថ្មីៗនេះ ជាពិសេសដោយសារកម្ពុជាខ្វះធនធានមនុស្ស និងខ្វះបទពិសោធន៍លើកិច្ចការផ្សារទុនដែលជាហេតុធ្វើឲ្យប្រជាជនពុំសូវមានការយល់ដឹងពីវិស័យនេះ ជាពិសេសធនធានមនុស្សដែលជាអ្នកជំនាញក្នុងកិច្ចដំណើរការរបស់ទីផ្សារមូលបត្រនៅមានកម្រិតនៅឡើយ។ កង្វះខាតការចូលរួមក្នុងវិស័យមូលបត្រពីសំណាក់ប្រជាជនទូទៅ ជាបញ្ហាប្រឈមដ៏ចម្បងមួយនៃការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជាឲ្យរីកចម្រើន។ ការបណ្តុះបណ្តាលប្រជាជនឲ្យមានការយល់ដឹងក្នុងវិស័យមូលបត្រ ដើម្បីបង្កើនការចូលរួមត្រូវចំណាយពេលយូរ ជាពិសេសប្រជាជនមួយចំនួនធំហាក់មិនទាន់យល់ពីសារៈសំខាន់ពីការចូលរួមអភិវឌ្ឍទីផ្សារមូលបត្រនៅឡើយ។

ចំពោះសិស្សនិស្សិត ក៏នៅមានកម្រិតការយល់ដឹង ដោយសារការបញ្ចូលមុខវិជ្ជាពាក់ព័ន្ធនឹងវិស័យមូលបត្រនៅមិនទាន់ទូលំទូលាយនៅឡើយ កង្វះខាតឯកសារ គ្រូបង្គោល និងមានចំនួនសិស្សនិស្សិតតិចតួចប៉ុណ្ណោះដែលចាប់អារម្មណ៍ក្នុងវិស័យនេះ។ ចំណែកឯអ្នកជំនាញផ្នែកបច្ចេកទេសក្នុងប្រតិបត្តិការណ៍ទីផ្សារនៅមានចំនួនតិច និងសមត្ថភាពនៅមានកម្រិតនៅឡើយដែលមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។ ឧបករណ៍ដែលជាប្រព័ន្ធទ្រទ្រង់សម្រាប់ដំណើរការវិស័យនេះក៏នៅមានកម្រិត និងមិនទាន់ទំនើបបើធៀបនឹងប្រទេសជិតខាង ដែលនេះជាបញ្ហាមួយធ្វើឲ្យពិបាកក្នុងការបង្ហាញពីសកម្មភាព ព្រឹត្តិការណ៍ផ្សេងៗ ចំណេះដឹងទៅសាធារណជនការចូលរួមរបស់តួអង្គ និងប្រតិបត្តិការទីផ្សារ។

អ្នកយកព័ត៌មាន គឺជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា ដែលជាអ្នកបញ្ជូន ផ្សព្វផ្សាយចំណេះដឹង និងព្រឹត្តិការណ៍ផ្សេងៗដែលទាក់ទងនឹងវិស័យមូលបត្រទៅសាធារណជនទូទៅ។ អ្នកសារព័ត៌មានមិនត្រឹមតែបាននាំព័ត៌មានដល់សាធារណជនវិនិយោគិន អំពីដំណាក់កាលជាបន្តបន្ទាប់នៃការដាក់ឲ្យដំណើរការទីផ្សារមូលបត្រកម្ពុជា ប៉ុណ្ណោះទេ រហូតមកដល់ពេលនេះ អ្នកសារព័ត៌មាននៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការពាំនាំព័ត៌មានដូច

ជាស្ថានភាព បច្ចុប្បន្នភាព និងព្រឹត្តិការផ្សេងៗនៃទីផ្សារដល់សាធារណជន វិនិយោគិន ឲ្យមានការយល់ដឹងយ៉ាងទូលំទូលាយ និងទាន់ពេលវេលា ចំពោះការប្រែប្រួលនិងការវិវឌ្ឍរបស់ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាស្ថានភាពទីផ្សារទាំងមូល។ ប៉ុន្តែអ្នកយកព័ត៌មានភាគច្រើនពាក់ព័ន្ធនឹងវិស័យមូលបត្រនៅកម្ពុជានាពេលបច្ចុប្បន្ននៅពុំទាន់មានសមត្ថភាពនិងចំណេះដឹងគ្រប់គ្រាន់នៅឡើយ។ ជាពិសេសបើសិនជាអ្នកយកព័ត៌មានទាំងនោះពុំមានសមត្ថភាព និងចំណេះដឹងគ្រប់គ្រាន់ និងគ្មានវិជ្ជាជីវៈត្រឹមត្រូវទេការផ្សព្វផ្សាយព័ត៌មានរបស់ពួកគេទៅសាធារណជនអាចនឹងគ្មានភាពត្រឹមត្រូវ ច្បាស់លាស់ និងពុំបានគ្រប់គ្រាន់នោះទេ។

### ៥.៤.២. ប្រព័ន្ធព័ត៌មានវិទ្យា

ការទទួលបានព័ត៌មាន ជាកត្តាដ៏សំខាន់មួយរបស់ប្រជាពលរដ្ឋខ្មែរ ដែលធានាដោយច្បាប់កម្ពុជា។ ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជាមិនអាចប្រព្រឹត្តទៅបានដោយគ្មានតម្លាភាពប្រកបដោយយុត្តិធមិបានឡើយ ប្រសិនបើប្រជាពលរដ្ឋមិនអាចទទួលបានព័ត៌មានសំខាន់ៗ ដែលស្ថិតនៅក្នុងដៃរបស់ស្ថាប័នពាក់ព័ន្ធនឹងវិស័យមូលបត្រ។ ភាពពេញនិយម និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅកម្ពុជានៅមិនទាន់មានភាពសម្បូបែបនៅឡើយ និងមានតម្លៃខ្ពស់ដែលនេះជាហេតុបណ្តាលឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា។ បើប្រៀបធៀបនៅប្រទេសជិតខាងដែលមានការរីកចម្រើនទីផ្សារមូលបត្រ គឺបំពាក់ដោយឧបករណ៍បច្ចេកទេសទំនើបៗ សម្រាប់ពាំនាំព័ត៌មានផ្សេងៗពាក់ព័ន្ធនិងការប្រែប្រួលថ្លៃមូលបត្រនិងជួយដល់ការប្រតិ-បត្តិការណ៍បញ្ជាទិញ-លក់បានឆាប់រហ័ស។ ប្រព័ន្ធគ្រប់គ្រងនិងការផ្សព្វផ្សាយព័ត៌មានទីផ្សារ ការសិក្សាស្រាវជ្រាវ ឬទំនាក់ទំនងសុទ្ធសឹងធ្វើឡើងដោយប្រព័ន្ធបច្ចេកវិទ្យាខ្ពស់។ ភាពរីកចម្រើននៃប្រព័ន្ធព័ត៌មានវិទ្យានិងជួយបង្កើតភាពទីផ្សារ កាត់បន្ថយចំណាយចម្លងការ (Transaction Cost) និងព័ត៌មាន Asymmetric បង្កើនការប្រកួតប្រជែង និងការបើកច្រកដែលសម្រួលដល់ការវិនិយោក្រៅប្រទេស។

### ៥.៤.៣. ប្រព័ន្ធច្បាប់ បទប្បញ្ញត្តិ និងប្រព័ន្ធតុលាការ

ទោះបីជាច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗជាច្រើនត្រូវបានអនុម័តឡើងស្របពេលដែលដំណើរការបោះផ្សាយលក់មូលបត្រជាលើកដំបូងរបស់កម្ពុជា ត្រូវបានធ្វើឡើងនាពេលថ្មីៗនេះក៏ដោយ។ កម្ពុជានៅតែត្រូវការប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការដែលមានភាពរឹងមាំនិងច្បាស់លាស់ជាមួយនិងសមត្ថភាពខ្ពស់ ក្នុងការដោះស្រាយបញ្ហាដែលកើតមានពាក់ព័ន្ធទៅនឹងអាជីវកម្មនៅក្នុងទីផ្សារមូលបត្រ។ ទោះជាគណៈកម្មការមូលបត្រកម្រិតនូវលក្ខខណ្ឌតម្រូវចាំបាច់ និងមានយន្តការដោះ

ស្រាយវិវាទផ្សេងៗក្នុងអាជីវកម្មមូលបត្រ ចំពោះក្រុមហ៊ុនចុះបញ្ជីបោះផ្សាយមូលបត្រលើតម្លាភាពនៃរបាយការណ៍ក៏ដោយ។ និយាយរួមអវត្តមាននៃតុលាការពាណិជ្ជកម្ម នឹងអាចនាំឲ្យវិនិយោគិនប្រឈមនិងហានិភ័យនៃការខាតបង់ នៅពេលដែលក្រុមហ៊ុនបោះផ្សាយលក់មូលបត្រព្យាយាមបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលមិនត្រឹមត្រូវ។ កម្រិតទាបនៃតម្លាភាពហិរញ្ញវត្ថុដែលមានលក្ខណៈជាប្រពៃណីក្នុងវិស័យឯកជនរបស់កម្ពុជា ជាឧបសគ្គមួយផងដែររបស់វិនិយោគិន។ មួយផ្នែកនៃភាពជោគជ័យនៃការវិនិយោគមូលធន គឺពឹងផ្អែកលើអភិបាលកិច្ចល្អ និងតម្លាភាពរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។ ទោះបីជាច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់កន្លងមកក្តី ប៉ុន្តែគេមិនឃើញមានសមិទ្ធិផលណាមួយកើតមានឡើងជាដុំកំភួននៅឡើយ។ សមត្ថភាពនៃប្រព័ន្ធតុលាការ ប្រាក់បៀវត្ស និងសុច្ចរិត ពុំទាន់ត្រូវបានដោះស្រាយឲ្យសមស្របនៅឡើយ។ កង្វះការអនុវត្តច្បាប់ និងកាតព្វកិច្ចផ្សេងៗឲ្យមានភាព និងតម្លាភាពនៅកម្ពុជាមិនទាន់មានភាពរឹងមាំនៅឡើយ ដែលនាំឲ្យវិនិយោគិនមិនសូវមាននូវទំនុកចិត្ត និងអាចបង្កឲ្យមានភាពមិនប្រក្រតីនៅក្នុងទីផ្សារ។ បញ្ហាប្រឈមទាំងនោះក៏អាចមានឡើងដោយសារៈ

- ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិៈ ១).កង្វះមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (Central Law Registry) ដោយសារមិនទានមានការប្រមូលផ្តុំច្បាប់ និងលិខិតបទដ្ឋានជាធរមានជាហេតុបណ្តាលឲ្យមានការលំបាកដល់មន្ត្រី និងសាធារណជនក្នុងការស្វែងយល់ពីច្បាប់។ ២). កង្វះអង្គភាពបណ្តុះបណ្តាលជំនាញសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ ដែលមានអ្នកឯកទេសច្បាប់មានសមត្ថភាពពិនិត្យច្បាប់ និងបទប្បញ្ញត្តិហិរញ្ញវត្ថុបានគ្រប់ជ្រុងជ្រោយ។
- សកម្មភាពកំណែទម្រង់ឆាប់រហ័សបានបង្កឲ្យមានបញ្ហាប្រឈម ក្នុងការអនុវត្តច្បាប់ វិធានបទប្បញ្ញត្តិដែលនាំឲ្យមានការបកស្រាយខុសគ្នាៗ។ បញ្ហាប្រឈមរួមមានៈ ១). ការរៀបចំច្បាប់ និងបទប្បញ្ញត្តិពឹងផ្អែកលើកម្មវិធីរបស់ម្ចាស់ជំនួយ ២). ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តយល់ខុសដែលទាមទារឲ្យមានការសម្របសម្រួល ក្នុងការអនុវត្តខ្លឹមសារច្បាប់ ៣). ការពឹងផ្អែកលើជំនាញការបរទេសផ្នែកច្បាប់ ដោយសារតែមានសមត្ថភាពជំនាញផ្នែកច្បាប់នៅមានកម្រិត និងជំនាញការដែលមានចំណេះដឹងផ្សេងគ្នាអាចស្នើវិធីសាស្ត្រខុសៗគ្នា។ ក្នុងន័យនេះ រដ្ឋាភិបាលត្រូវធ្វើសុខដុមនីយកម្មយន្តការអនុវត្តច្បាប់និងបទប្បញ្ញត្តិហិរញ្ញវត្ថុឲ្យស្របតាមស្ថានភាពវិស័យហិរញ្ញវត្ថុកម្ពុជាដោយគិតគូរពីផលប៉ះពាល់ដល់ការអភិវឌ្ឍវិស័យ

ហិរញ្ញវត្ថុ។ ចំណុចទាំងនេះ គឺជាឧបសគ្គរាំងស្ទះដល់ដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជាដែលជាកម្មវត្ថុដែលរាជរដ្ឋាភិបាលគួរពិនិត្យពិច័យ និងធ្វើការកែលំអរឡើងវិញ។[46]

### ៥.៤.៤. ប្រព័ន្ធគណនេយ្យ និងសវនកម្ម

គណនេយ្យ និងសវនកម្ម ផ្តល់នូវក្របខ័ណ្ឌដើម្បីផលិតចេញជាព័ត៌មានហិរញ្ញវត្ថុសម្រាប់រាយការណ៍នៃគ្រប់វិស័យទាំងអស់នៅក្នុងសេដ្ឋកិច្ច។ វាដើរតួយ៉ាងសំខាន់នៅក្នុងការផ្តល់ព័ត៌មានដែលគ្រប់គ្រាន់និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ។ គ្រប់អង្គភាពសាជីវកម្មទាំងអស់ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្រប់តាមលក្ខខណ្ឌស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវរបស់ព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្តែង ដើម្បីចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា គ្រប់ក្រុមហ៊ុនទាំងអស់ត្រូវតម្រូវឲ្យរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដែលស្របតាមស្តង់ការគណនេយ្យកម្ពុជា។ កម្ពុជាបានអនុម័ត និងអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ International Financial Reporting Standard (IFRS) ពេញលេញ តែនៅមានក្រុមហ៊ុនជាច្រើនមិនទាន់បានអនុវត្តតាមស្តង់ដារនៅឡើយទេ។ មានក្រុមហ៊ុនមួយចំនួនមានការរារែកក្នុងការអនុវត្តព្រោះការងារនេះត្រូវចំណាយពេលវេលាយូរ និងថវិកាច្រើន និងមានភាពស្មុគស្មាញដោយក្រុមហ៊ុនខ្លះត្រូវធ្វើកំណែទម្រង់ ឬរៀបចំប្រព័ន្ធគណនេយ្យរបស់ខ្លួនឡើងវិញស្ទើតែទាំងស្រុង។

ភាពទន់ខ្សោយក្នុងការគ្រប់គ្រង ការអនុវត្តទៅតាមស្តងដារនិងច្បាប់គណនេយ្យ និងសវនកម្មនៅតែបន្តមាននៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ស្តង់ដារគណនេយ្យ និងសវនកម្មគឺផ្អែកតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) និងស្តង់ដាសវនកម្មអន្តរជាតិ International Standard of Auditing (ISA)។ កំហុសឆ្គងនៃប្រតិបត្តិការណ៍ផ្សេងៗក្នុងការអនុវត្តគណនេយ្យ និងសវនកម្មដែលមូលហេតុចម្បងកើតចេញពីកង្វះការយល់ដឹងដោយគណនេយ្យករដែលគ្មានវិជ្ជជីវៈ កង្វះសមត្ថភាពផ្នែកបច្ចេកទេសនៃនិយ័តករ និងប្រតិបត្តិករ អវត្តមាននៃការប្រតិបត្តិតាមសេចក្តីណែនាំ ភាពខ្វែងគ្នាក្នុងការអនុវត្តបទប្បញ្ញត្តិរបស់ស្ថាប័នពាក់ព័ន្ធ កង្វះឯករាជ្យភាព និងការអប់រំបណ្តុះបណ្តាលថ្នាក់ជាតិសម្រាប់គណនេយ្យករជំនាញ និងការលំបាកក្នុងការប្រើប្រាស់ភាសាបច្ចេកទេសគណនេយ្យ និងសវនកម្ម។

សម្រាប់វិស័យមូលបត្រកម្ពុជា ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចុះបញ្ជីដោយមិនគោរពតាមស្តង់ដារគណនេយ្យ និងសវនកម្មដ៏ត្រឹមត្រូវ ធ្វើឲ្យការវិនិយោគលើភាគហ៊ុន និងសញ្ញាបណ្ណសាជីវកម្មរបស់ក្រុមហ៊ុនទាំងនោះមានហានិភ័យខ្ពស់ ដែលបណ្តាលឲ្យអ្នកវិនិ-

[46] ហេង ធានី ចាន់ ហួរ, *ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា*,(ភ្នំពេញ ២០១២) ទំព័រ ៧២

យោគគ្មានទំនុកចិត្តនៅក្នុងទីផ្សារ បាត់បង់អ្នកចូលរួម និងធ្វើឲ្យភាពគ្មានភាពនៅលើទីផ្សារអាចកើតមានឡើង។

**៥.៤.៥. ក្រុមហ៊ុនចុះបញ្ជី និងសន្ទនីយភាពក្នុងទីផ្សារ**

នៅក្នុងវិស័យមូលបត្រនៅកម្ពុជា ក្រុមហ៊ុនចុះបញ្ជីនៅមានចំនួនតិចតួចណាស់ ជាពិសេសក្រុមហ៊ុនចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្ម។ នេះគឺជាក្តីព្រួយបារម្មណ៍ខ្លាំងបំផុតរបស់ថ្នាក់ដឹងនាំនៃវិស័យមូលបត្រកម្ពុជា។ កង្វះខាតក្រុហ៊ុនចុះបញ្ជី ធ្វើឲ្យផ្សារមូលបត្រកម្ពុជាមិនមានផលិតផលគ្រប់គ្រាន់ សម្រាប់ផ្តល់ជូនអ្នកវិនិយោគ ជាពិសេសមូលបត្របំណុលដែលជាផលិតផលដ៏សំខាន់មួយក្នុងចំណោមផលិតផលផ្សេងទៀតក្នុងវិស័យមូលបត្រ។

ទោះបីជាផ្សារមូលបត្រកម្ពុជា មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនពីរបានចុះបញ្ជីបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មជាសាធារណៈរួចហើយក្តី តែការជួញដូរនៅលើទីផ្សារបន្ទាប់ពុំទាន់មានសកម្មភាពនៅឡើយទេ។ ដូចនេះ សន្ទនីយភាពទីផ្សារមូលបត្របំណុល គឺជាបញ្ហាមួយដែលជាផលវិបាករបស់វិនិយោគិនដែលវិនិយោគលើសញ្ញាបណ្ណ។ បញ្ហានេះ បណ្តាល់មកពីសញ្ញាបណ្ណសាជីវកម្មនៅក្នុងទីផ្សារនៅមានចំនួនតិចតួចនៅឡើយ ភាគច្រើននៃអ្នកវិនិយោគលើសញ្ញាបណ្ណទាំងនេះមិនបានលក់បន្តទៅវិនិយោគិតដ៏ទៃផ្សេងទៀត ជាពិសេសសញ្ញាបណ្ណសាជីវកម្មទាំងនោះទុកសម្រាប់លក់ជូនតែវិនិយោគិនធំៗតែប៉ុណ្ណោះ។ បញ្ហាទាំងនេះគឺជាឧបសគ្គក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា។

**៥.៤.៦. ជំនឿទុកចិត្តលើទីផ្សារ**

ដោយភាពក្មេងខ្ចីនៃផ្សារមូលបត្រកម្ពុជា ការកសាងទំនុកចិត្តចំពោះវិនិយោគិននៅតែជាបញ្ហាចោទសម្រាប់វិស័យនេះ។ វិនិយោគិនមួយចំនួន នៅតែមានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងប្រតិបត្តិការទីផ្សារ ជាក់ស្តែងដូចជាក្រុមហ៊ុនចុះបញ្ជី និងតួអង្គផ្សេងទៀតដើម។ បញ្ហាកង្វះទំនុកចិត្តលើទីផ្សារ ធ្វើឲ្យតួអង្គអ្នកចូលរួមដូចជា ក្រុមហ៊ុនចុះបញ្ជីមានការបារម្មណ៍ខ្លាចបរាជ័យក្នុងការបោះផ្សាយសញ្ញាបណ្ណខ្លាចក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្របសម្រួលប្រតិបត្តិការ ជាពិសេសគ្មានអ្នកវិនិយោគលើសញ្ញាបណ្ណដែលបានបោះផ្សាយនោះ។ ក្នុងនោះដែរ វិនិយោគិនក៏នៅមានភាពភ័យខ្លាចក្នុងការចូលរួមវិនិយោគក្នុងវិស័យមូលបត្រនៅកម្ពុជា នៅខ្វាយខ្វល់ពីសន្ទនីយភាព តម្លាភាពក្នុងទីផ្សារ ជាពិសេសការឆបោកផ្សេងៗដែលអាចកើតមានឡើងក្នុងទីផ្សារមូលបត្រ។ ក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា ការកសាងទំនុកចិត្តគឺជាកត្តាមួយដ៏សំខាន់ក្នុងការទាក់ទាញអ្នកចូលរួមឲ្យបានកាន់តែច្រើនមកលើទីផ្សារ។

## ៥.៥. កត្តាសំខាន់ដែលចូលរួមក្នុងការកែលំអ និងអភិវឌ្ឍទីផ្សារមូលបត្របំណុល

ប្រទេសកម្ពុជាមានឱកាសវិនិយោគនិងសន្សំក្នុងស្រុកតិចតួចសម្រាប់ប្រជាជន។ ដូចនេះ ប្រជាជនរក្សាទុកសាច់ប្រាក់ដោយខ្លួនឯង ដាក់ប្រាក់បញ្ញើនៅធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ ឬវិនិយោគទៅក្រៅប្រទេស។ គោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្តោតលើការបង្វែរប្រាក់សន្សំក្នុងស្រុកទៅជាការវិនិយោគក្នុងស្រុកកាត់បន្ថយការពឹងផ្អែកលើប្រភពមូលនិធិក្រៅប្រទេស និងកាត់បន្ថយលំហូរប្រាក់សន្សំក្នុងស្រុកទៅវិនិយោគក្រៅប្រទេស។ ដូចនេះការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងស្រុកធ្វើឲ្យមានភាពរស់រវើក និងភាពជាតម្រូវការចាំបាច់ដើម្បីអនុវត្តគោលនយោបាយនេះ។

រាជរដ្ឋាភិបាលមានបំណងជំរុញការអភិវឌ្ឍ និងពង្រីកវិសាលភាពវិស័យមូលបត្របំណុល ដោយធ្វើការជម្រះចេញនូវឧបសគ្គសម្រាប់ការចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្ម របស់ស្ថាប័នហិរញ្ញវត្ថុមួយចំនួនធំ។ **គ.ម.ក.** ស្នើសុំរាជរដ្ឋាភិបាលផងដែរ ដើម្បីបន្លឿនការអភិវឌ្ឍ ដោយលើទឹកចិត្តដើម្បីឲ្យសហគ្រាសទាំងនោះធ្វើការចុះបញ្ជីលក់មូលបត្របំណុល ស្ថាប័នពាក់ពាន់ដ៏ទៃទៀត ដែលកំពុងស្វែងរកការចុះបញ្ជីលក់មូលបត្របំណុល ក៏គួរទទួលបានការអនុញ្ញាតផងដែរតាមរយៈការបង្កើនដើមទុន និងទុនបម្រុងរបស់ស្ថាប័ន ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ (មិនតិចជាង២០% នៃមូលធនភាគទុនិកសរុបរបស់ស្ថាប័ន)។

### ៥.៥.១. ផែនការរបស់ គ.ម.ក. ក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល

គណៈកម្មការមូលបត្រកម្ពុជា ក្នុងនាមជាអាជ្ញាធរក្នុងវិស័យមូលបត្រ ក៏បាននិងកំពុងធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំនូវបទប្បញ្ញត្តិនានាដើម្បីដាក់ចេញនូវផលិតផលថ្មីៗបន្ថែមទៀតនៅក្នុងទីផ្សារ ដើម្បីបង្កើននូវក្រុមហ៊ុនចុះបញ្ជី និងជំរុញនូវសន្ទនីយភាពក្នុងទីផ្សារ ព្រមទាំងបង្កើននូវទំនុកចិត្តក្នុងទីផ្សារ។ ព្រមជាមួយគ្នានេះ ក្នុងទិសដៅដើម្បីបង្កើននូវក្រុមហ៊ុនចុះបញ្ជីជួញដូរនៅក្នុងទីផ្សារ និងសន្ទនីយភាពនៅក្នុងទីផ្សារ **គ.ម.ក.** បានដាក់ចេញនូវសកម្មភាពមួយចំនួនរួមមាន ការជំរុញនូវការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ការពិនិត្យឡើងវិញនូវបទប្បញ្ញត្តិ និងគោលនយោបាយលើកទឹកចិត្តនានា និងការកសាងទំនុកចិត្តនៅក្នុងទីផ្សារ តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងពង្រីកនូវកិច្ចសហការប្រតិបត្តិការអន្តរជាតិ ដែលគណៈកម្មការមូលបត្រកម្ពុជា ក៏ក្លាយជាសមាជិកនៃគណៈកម្មការមូលបត្រអន្តរជាតិផងដែរ។

ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងវិស័យមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើការអភិវឌ្ឍទីផ្សារមូលបត្របំណុល សម្រាប់ទីផ្សារដែលទើបបង្កើតថ្មីដូចកម្ពុជា។

ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយជាមធ្យោបាយក្នុងការផ្តល់ព័ត៌មាន ក៏ដូចជាបញ្ញាបចំណេះដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រដល់សាធារណជន និងវិនិយោគិនកម្ពុជា។ ដូចនេះ **គ.ម.ក.** តែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំនូវការបណ្តុះបណ្តាលនានានិងធ្វើការផ្សព្វផ្សាយឲ្យបានកាន់តែទំលំទូលាយទៅដល់សាធារណជន វិនិយោគិន សិស្ស-និស្សិត មន្ត្រីរាជការ អ្នកសារព័ត៌មាន បុគ្គលផ្តល់សេវាក្នុងវិស័យមូលបត្រ និងក្រុមហ៊ុនសក្តានុពលផ្សេងៗ។

- **គ.ម.ក.** នឹងធ្វើការរួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតាមដានទៅលើជម្រើសសម្រាប់ការចុះបញ្ជីលក់មូលបត្របំណុលរបស់សហគ្រាសសាធារណៈ បន្ថែមរួមមាន ការពិនិត្យមើលឡើងវិញទៅលើភ្នាក់ងារ ដើម្បីពិនិត្យមើលលទ្ធភាពរបស់សហគ្រាសសាធារណៈ និងផ្តោតសំខាន់ទៅលើការគ្រប់គ្រង ការរៀបចំសម្រាប់ការចុះបញ្ជីមូលបត្របំណុលបន្ថែម។
- ពិនិត្យឡើងវិញ និងរៀបចំចំណាត់ការសមស្របសម្រាប់ការខ្ចី និងការឲ្យខ្ចីមូលបត្រដោយការពិចារណាលើលទ្ធភាពបង្កើតសាជីវកម្មហិរញ្ញវត្ថុមូលបត្រ។

**ដើម្បីផ្តល់ភាពកាន់តែងាយស្រួលចំពោះការចូលទៅកាន់ទីផ្សារមូលបត្រ គ.ម.ក. នឹង**

- ពិនិត្យឡើងវិញ និងរៀបចំសម្រួលនីតិវិធី និងបទប្បញ្ញត្តិសម្រាប់ការចុះបញ្ជីរបស់សហគ្រាសធុនតូច និងមធ្យម។
- ពិនិត្យទៅលើយោបល់ក្នុងការសម្រួលមាតិកានៃឯកសារផ្តល់ព័ត៌មាន និងកែសម្រួលនូវបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលក្នុងចំនួនតិច និងការចុះបញ្ជីលក់មូលបត្របំណុលរបស់ស្ថាប័នហិរញ្ញវត្ថុឲ្យកាន់តែមានភាពសាមញ្ញ និងងាយស្រួល។
- ធ្វើការស្រាវជ្រាវ និងបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់ក្រោដហ្វាន់ឌីង និងផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវា និងបន្តពិនិត្យកិច្ចការពារវិនិយោគិន និងការតភ្ជាប់ទីផ្សារ។

**ដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការលើកទឹកចិត្តចូលរួមនៅក្នុងទីផ្សារមូលបត្រ គ.ម.ក. នឹង**

- បន្តធ្វើការជាមួយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យឡើងវិញលើអនុក្រឹត្យស្តីពីពន្ធដារដែលរួមបញ្ចូលទាំងការពិនិត្យឡើងវិញពីបញ្ហាពន្ធដារ ដែលក្រុមហ៊ុនមានចំណាប់អារម្មណ៍ចុះបញ្ជីជួញដូរនៅលើទីផ្សារមូលបត្រកំពុងជួបប្រទះ និងការពិចារណាលើការផ្តល់នូវផលប្រយោជន៍សម្រាប់ក្រុមហ៊ុនចុះបញ្ជីដែលអាចនឹងស្មើ ឬដូចនិងការលើទឹកចិត្តដែលផ្តល់ទៅឲ្យគម្រោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ (QIP) ។

- ធ្វើការស្រាវជ្រាវពីការលើទឹកចិត្តមិនមែនពន្ធដារ និងដាក់ឲ្យអនុវត្តគោលនយោបាយលើកទឹកចិត្តមិនមែនពន្ធដារ។
- បន្តពិនិត្យឡើងវិញដើម្បីឲ្យច្បាស់ថា ច្បាប់ឬបទប្បញ្ញត្តិដែលគ្រប់ដណ្តប់វិស័យមូលបត្ររួមបញ្ចូលការប្រឆាំងអំពើពុករលួយ។

**ដើម្បីជំរុញស្ថិរភាព និងទំនុកចិត្តក្នុងទីផ្សារ គ.ម.ក. នឹង**

- ធ្វើបច្ចុប្បន្នកម្ម និងអនុវត្តកម្មវិធីបណ្តុះបណ្តាលវិនិយោគិន និងបញ្ជ្រាបការយល់ដឹងដល់សាធារណជន តាមរយៈយោបល់ និងតម្រូវការអភិវឌ្ឍទីផ្សារ តម្រូវការទីផ្សារ និងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា លើការបង្កើនការដាក់បញ្ចូលមូលដ្ឋានគ្រឹះហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាជាតិ។
- បន្តគាំទ្រសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន តាមរយៈការពិនិត្យ និងបន្ស៊ីបទប្បញ្ញត្តិចុះបញ្ជីលក់មូលបត្រ និងទីផ្សារមូលបត្រជាមួយបទដ្ឋាន និងគោលការណ៍របស់អាស៊ានរួមទាំង បទប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទ និងសហការដើម្បីឆ្ពោះទៅដល់ការទទួលស្គាល់គ្នាទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណដល់អ្នកចូលរួមក្នុងទីផ្សារមូលបត្រ។
- បន្តសហការជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ ដើម្បីពង្រឹងការត្រួតពិនិត្យក្រុមហ៊ុនគណនេយ្យជំនាញ ដែលទទួលបានការទទួលស្គាល់ក្នុងការផ្តល់សេវាក្នុងវិយមូលបត្រ។
- បំពេញការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទដោយយោងតាមបទដ្ឋានអាស៊ាន និងគោលការណ៍ណែនាំ ក្នុងការគាំទ្រការបោះផ្សាយ និងការចុះបញ្ជីលក់មូលបត្របំណុលឆ្លងដែនព្រមទាំងពិនិត្យកែសម្រួលបទប្បញ្ញត្តិ និងនីតិវិធីដោះស្រាយវិវាទផ្លូវការ។
- ពង្រឹងកិច្ចសហប្រតិបត្តិការតាមរយៈការចុះអនុស្សរណៈយោគយល់គ្នា សម្រាប់ការចែករំលែកព័ត៌មាន និងសហប្រតិបត្តិការនៃប្រព័ន្ធផាត់ទាត់និងទូទាត់ ជាមួយនឹងធនាគារជាតិកម្ពុជា និងពង្រឹងភាពជាដៃគូ និងសហប្រតិបត្តិការទៅវិញទៅមកជាមួយនឹងនិយ័តករ និងផ្សារមូលបត្របរទេស។
- បន្តផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចសាជីវកម្ម និងបទដ្ឋានអភិបាលកិច្ច។
- ដឹកនាំការវាយតម្លៃអំពីលទ្ធភាពក្នុងការចូលជាសមាជិកអង្គការអន្តរជាតិនៃគណៈកម្មការមូលបត្រ (IOSCO) ។

**ដើម្បីបន្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រ គ.ម.ក. នឹង**

- បន្តការរៀបចំបទប្បញ្ញត្តិ សម្រាប់គម្រោងវិនិយោគរួមក្នុងនោះរួមទាំងការត្រួតពិនិត្យមូលនិធិ និងបុគ្គលគ្រប់គ្រងមូលនិធិ ព្រមទាំងប្រតិបត្តិការបរធនបាលកិច្ច។
- ពិនិត្យឡើងវិញ និងធ្វើឲ្យប្រាកដថាច្បាប់ ឬបទប្បញ្ញត្តិក្នុងវិស័យមូលបត្រមានភាពរឹងមាំ និងគ្រប់ជ្រុងជ្រោយ។

ទន្ទឹមនឹងនេះ គណៈកម្មការមូលបត្រកម្ពុជា ក៏បានផ្សារភ្ជាប់ខ្លួនយ៉ាងជិតស្និទ្ធជាមួយនិយ័តករក្នុងនិងក្រៅតំបន់ រួមទាំងដៃគូអភិវឌ្ឍនានា ហើយជាពិសេស **គ.ម.ក.** បានក្លាយទៅជាសមាជិកនៃអង្គការគណៈកម្មការមូលបត្រពិភពលោកក្នុងឆ្នាំ២០១៧ ផងដែរ។

### ៥.៥.២. ផែនការរបស់ ផ.ម.ក. ក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុល.

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) បានបន្តប្រឹងប្រែងបញ្ជ្រាបការយល់ដឹងពីសារៈសំខាន់នៃការចុះបញ្ជីក្នុងទីផ្សារភាគហ៊ុន ក្នុងគោលបំណង ដើម្បីផ្តល់ក្របខណ្ឌសម្រាប់ការបណ្តុះបណ្តាលដល់សហគ្រិននានា ឲ្យយល់កាន់តែច្បាស់ អំពីសារៈប្រយោជន៍នៃការចុះបញ្ជីនៅ ផ្សារបំណុល និងរបៀបនៃការរៀបចំខ្លួន ឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការចូលទីផ្សារមួយនេះ។

ការប្រឹងប្រែងនេះ ត្រូវបានបង្ហាញឡើង តាមរយៈការបើកសិក្ខាសិលា និងការតាំងពិព័រណ៌នានាជាច្រើនដើម្បីបញ្ជ្រាបការយល់ដឹងពីវិស័យមូលបត្រ។ ផ្សារមូលបត្រកម្ពុជាបានរំពឹងថាយ៉ាងយូរ៥ឆ្នាំទៀត ក្រុមហ៊ុនជាច្រើននឹងចុះបញ្ជីនៅក្នុងទីផ្សារ ក្រោយពីមានការសហការផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងជំរុញឲ្យបានសកម្មជាពិសេសរួមចំណែកក្នុងការផ្តល់ចំណេះដឹង ជំនាញ ហើយនិងការបំផុសគំនិត។

ទីផ្សារមូលបត្រកម្ពុជា បានបង្កើតកម្មវិធីមួយមានឈ្មោះថា Listing Incubator Program ដែលតាមរយៈកម្មវិធីនេះ ក្រុមការងាររបស់ទីផ្សារមូលបត្រកម្ពុជា បានចុះជួយផ្តល់ប្រឹក្សាយោបល់ដោយឥតគិតថ្លៃដល់ក្រុមហ៊ុននានា អំពីនីតិវិធីលម្អិតក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ការត្រៀមលក្ខណៈផ្សេងៗ មុនសម្រេចចិត្តចូលទីផ្សារ ការចំណាយផ្សេងៗ និងបញ្ហាប្រឈមនានា ដើម្បីជាមូលដ្ឋានសម្រាប់ក្រុមហ៊ុនធ្វើការសម្រេចចិត្តចូលមកទីផ្សារមូលបត្រកម្ពុជា។

តំណាងផ្សារមូលបត្រកម្ពុជា (CSX) បានធ្វើការចុះកិច្ចសហការជាមួយក្រុមហ៊ុនក្នុងស្រុកដែលមានជំនាញផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍន៍ភាពជាសហគ្រិននៅកម្ពុជាក្នុងគោលដៅសហការបង្កើនការយល់ដឹងរបស់ពាណិជ្ជករខ្នាតតូចអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងលទ្ធភាពទទួលបានប្រភពទុនពីផ្សារមូលបត្របំណុល។

កិច្ចព្រមព្រៀងនេះគឺជាជំហានដំបូងសម្រាប់ CSX ហើយផ្សារហ៊ុននេះគ្រោងនឹងចុះហត្ថលេខាលើ MOU ផ្សេងទៀតជាមួយនឹងអគ្គនាយកក្រុមហ៊ុន Master Club ជាក្រុមហ៊ុនមួយដែលផ្តល់ការបណ្តុះបណ្តាលអាជីវកម្ម និងបណ្តាញដល់អ្នកគ្រប់គ្រង និងម្ចាស់ក្រុមហ៊ុនធុនតូច និងមធ្យម។

**ការធ្វើទំនើបកម្មដើម្បីអភិវឌ្ឍទីផ្សារមូលបត្របំណុល ផ្សារមូលបត្រកម្ពុជាចាំបាច់ត្រូវផ្តោតសំខាន់លើ ៖**

- ចេញសេចក្តីណែនាំអំពីការចុះបញ្ជីដល់បណ្តាក្រុមហ៊ុនសាជីវកម្ម និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗដែលមានគម្រោងចុះបញ្ជីបោះផ្សាយសញ្ញាបណ្ណសាជីវកម្ម និងបង្ហាញពីប្រព័ន្ធអេឡិចត្រូនិចថ្មីចុងក្រោយដើម្បីបង្កើនភាពងាយស្រួលក្នុងការផ្តល់ និងទទួលព័ត៌មានដែលពាក់ព័ន្ធនឹងការចុះបញ្ជី។
- សិក្សាទៅលើលទ្ធភាពទទួលបានការចុះបញ្ជីនៃការកៀរគរមូលនិធិ និងការចុះបញ្ជីលើការផ្សព្វផ្សាយសហគ្រាសរដ្ឋ និងរៀបចំវគ្គបណ្តុះបណ្តាសម្រាប់ក្រុមហ៊ុនចុះបញ្ជីថ្មីៗ
- ពង្រីកម៉ោងជួញដូរចាប់ពី ៣,៥ ម៉ោងទៅដល់ ៧ ម៉ោងក្នុងមួយថ្ងៃ ដោយពន្យាម៉ោងជួញដូរហូតដល់ម៉ោង ៣រសៀល ដែលបច្ចុប្បន្នអាចជួញដូរបានត្រឹមម៉ោង ១១និង៣០នាទីព្រឹក។
- បង្កើនការណែនាំនៃគម្រោងវិនិយោគលើទីផ្សារ
- បន្តការបង្ហាញពីសក្តានុពលទីផ្សារដល់វិនិយោគិនស្ថាប័ន និងទីផ្សារក្រៅប្រទេស
- បង្កើនភាពនៃការផ្សព្វផ្សាយព័ត៌មានទីផ្សារដល់វិនិយោគិនសក្តានុពល
- សិក្សាពីលទ្ធភាពនៃអ្នកបង្កើតទីផ្សារមូលបត្របំណុល
- សិក្សាលទ្ធភាពនៃវេទិការកៀរគរមូលនិធិ
- បង្កើតការរៀបចំការចុះបញ្ជីនិងការទូទាត់
- សិក្សាលើប្រធានបទ Listing Foreign Companies on CSX ក្នុងការបង្កើនក្រុមហ៊ុនចុះបញ្ជី
- គម្រោងបើកគណនីជួញដូរតាមអ៊ិនធើណេត
- លើកកម្ពស់ការយល់ដឹងតាមរយៈសិក្ខាសាលានិងកម្មវិធីជាសាធារណៈដូចជា៖
  - ការធ្វើពិព័រណ៍ផ្សារហ៊ុន
  - បង្កើនការប្រកួតប្រជែងលើការជួញដូរភាគហ៊ុន
  - បើកវគ្គបំណ្តុះបណ្តាលជាប្រចាំខែ
  - បង្កើតវេទិកាក្រុមហ៊ុនដែលបានចុះបញ្ជី
  - វគ្គបណ្តុះបណ្តាលសម្រាប់សាស្ត្រាចារ្យ

- ➢ សិក្ខាសាលាតាមខេត្តនានា ជាពិសេសតាមបណ្តាសាកលវិទ្យាល័យ
- បើកដំណើរការយន្តការនៃការបង្កើតគម្រោងកិច្ចសន្យានិងការផ្ទេរប្រាក់តាមកិច្ចសន្យា
- បង្កើតជម្រើសការទូទាត់ជាដុល្លារអាមេរិក
- រៀបចំភ្នាក់ងាររក្សាសិទ្ធដើម្បីធ្វើជាសមាជិកនិងអ្នកថៃក្សារសក្តានុពលការងារ
- សិក្សាអំពីការគ្រប់គ្រងហានិភ័យនៃការជួញដូរនិងការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា
- គាំទ្រប្រព័ន្ធជួញដូរៈ សញ្ញាបណ្ណ, ម៉ាស៊ីនផ្គូផ្គង់, ផាត់ទាត់និងទូទាត់, សន្ទស្សន៍, បណ្តាញ, ជំនួញការជួញដូរ, ប្រាក់បញ្ញើ, បញ្ជីកត់ត្រា, ដែនកំណត់បរទេសជាដើម
- គាំទ្រប្រព័ន្ធជួញដូរចល័តតាមគេហទំព័រ (MTS)
- គាំទ្រប្រព័ន្ធ IT ដោយឥតគិតថ្លៃ: គេហទំព័រ, ICSX,ព័ត៌មាន, ផ្សារហ៊ុន
- ទ្រទ្រង់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យានិងប្រតិបត្តិការដែលពាក់ព័ន្ធនឹង IT
- ពង្រឹងប្រព័ន្ធជួញដូរ, MTS និងប្រព័ន្ធព័ត៌មាន TI
- បង្កើតប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិត្រូនិច
- ប្តូរប្រព័ន្ធព័ត៌មានវិទ្យាឲ្យកាន់តែប្រសើរ
- បង្កើតប្រព័ន្ធទាមទារព័ត៌មានវិទ្យា និងកម្មវិធីដើម្បីគាំទ្រដល់កំណើនអាជីវកម្ម
- ការស្រាវជ្រាវលើបច្ចេកវិទ្យា និងសុវត្ថិភាពបណ្តាញអ៊ិនធើណេត
- រក្សាសៀវភៅគណនេយ្យរបស់ផ្សារមូលបត្រឲ្យបានត្រឹមត្រូវ
- ដាក់ឯកសារនិងបំពេញកាតព្វកិច្ចពន្ធដារពាក់ព័ន្ធជាមួយអគ្គនាយកដ្ឋានពន្ធដារ
- ធានាបាននូវមុខងារល្អៗ នៃឧបករណ៍និងគ្រឿងផ្គត់ផ្គង់ដើម្បីរក្សាប្រតិបត្តិការឱ្យបានរលូននៃ**ផ.ម.ក.**
- ធានាឱ្យមានបុគ្គលិកគ្រប់ផ្នែកនៃ**ផ.ម.ក.**
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរពាក់ព័ន្ធ
- ជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកក្នុងវិស័យមូលបត្រ ដើម្បីអាចទំនាក់ទំនងអ្នកវិនិយោគគ្រប់ជាតិសាស្ត្រ
- ទាក់ទងទៅគ្រប់អ្នកវិនិយោគដែលមានសក្តានុពល ដើម្បីបង្កើនការជួញដូរ ជាពិសេសអ្នកវិនិយោគជនជាតិចិន ដោយធ្វើសិក្ខាសាលាជាភាសាចិនដល់ពួកគេ ដើម្បីឲ្យអ្នកវិនិយោគចិនទាំងនោះយល់កាន់តែច្បាស់ពីផ្សារមូលបត្រកម្ពុជា និងមានការលើកឡើងនូវសំណើចុះបញ្ជីទៅក្រុមហ៊ុនចិនទាំងនោះ

- បង្កើនការបង្ហាញពីផលិតផលដែលមានស្រាប់ និងថ្មីៗវិធានក្នុងការជួញដូរ ដល់វិនិយោគិនសក្តានុពល
- ក្រៅពីធ្វើសិក្ខាសាលាតាមទីកន្លែងផ្សេងៗ ផ្សារមូលបត្រកម្ពុជាមានគម្រោងធ្វើបទបង្ហាញតាម Online ដើម្បីផ្សព្វផ្សាយបន្ថែមដល់អ្នកវិនិយោគ និងសាធារណជនទូទៅដែលមិនបានចូលរួមក្នុងសិក្ខាសាលា នៅតំបន់ឆ្ងាយៗ ជាពិសេសអ្នកដែលនិយមប្រើប្រាស់ប្រព័ន្ធព័ត៌មានសង្គម។

### ៥.៥.៣. កិច្ចការពារ និងការអប់រំវិនិយោគិន

ដើម្បីផ្តល់ការបណ្តុះបណ្តាល និងអប់រំពាក់ព័ន្ធនឹងមូលបត្រដល់សាធារណជន ស្ថាប័នពាក់ព័ន្ធក្នុងវិស័យមូលបត្រ បានធ្វើសិក្ខាសាលាស្តីពីការបង្កើនការយល់ដឹងពីទីផ្សារមូលបត្រនៅកម្ពុជាដល់រដ្ឋបាលនៅទូទាំងរាជធានីខេត្ត ជាពិសេសវិនិយោគិនដែលមានចំណាប់អារម្មណ៍ក្នុងវិស័យមូលបត្រ ក្នុងគោលដៅដើម្បីលើកកម្ពស់ការយល់ដឹង ជំរុញការជួញដូរមូលបត្រ ជាពិសេសសញ្ញាបណ្ណសាជីវកម្ម និងបង្កើនសន្ទនីយភាពនៅក្នុងទីផ្សារ។ ព្រមជាមួយគ្នានេះ **គ.ម.ក.** បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ **ផ.ម.ក.** និងក្រុមហ៊ុនមូលបត្រដើម្បីផ្សព្វផ្សាយចំណេះដឹងមូលបត្រដល់សាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការរៀបចំសិក្ខាសាលាតាមសាកលវិទ្យាល័យ សមាគមធុរកិច្ច ក្រុមហ៊ុនសក្តានុពល និងអ្នកចូលរួមដំទៃទៀតក្នុងទីផ្សារ ព្រមទាំងការចាត់បញ្ជូនមន្ត្រីជំនាញឲ្យចូលរួមធ្វើវាគ្មិនដើម្បីធ្វើបទបង្ហាញលើប្រធានបទផ្សេងៗនៅក្នុងសិក្ខាសាលាទាំងនោះ។ ដែលក្នុងនោះរួមមានបទបង្ហាញពាក់ព័ន្ធនឹងកិច្ចដំណើការអភិវឌ្ឍន៍ទីផ្សារមូលបត្របំណុល និងតួអង្គសំខាន់ៗនៅក្នុងវិស័យមូលបត្រ កិច្ចដំណើការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្ម និងនីតិវិធីនៃការជួញដូរសញ្ញាបណ្ណនៅកម្ពុជា និងការត្រៀមខ្លួនរបស់វិនិយោគិនមុនពេលជួញដូរមូលបត្រជាដើម។

ដើម្បីបញ្ចៀសនិងកាត់បន្ថយជាអតិបរិមានូវការរំលោភបំពានក្នុងទីផ្សារ គណៈកម្មការមូលបត្រកម្ពុជានឹងបន្តការរៀបចំការអប់រំវិនិយោគិន និងបើកផ្លូវឲ្យវិនិយោគិនទាំងអស់នោះអាចដាក់ពាក្យបណ្តឹងមកគណៈកម្មការមូលបត្រកម្ពុជាបាន នៅពេលពួកគេមានបញ្ហា ឬទំនាស់ក្នុងពេលវិនិយោគ។ ជាមួយគ្នានេះយន្តការ និងមជ្ឈមណ្ឌលដោះស្រាយវិវាទនឹងត្រូវបង្កើតឡើងដើម្បីដោះស្រាយវិវាទទីផ្សារ។

- ❖ **ការទទួលពាក្យបណ្តឹង** បណ្តឹងសុំដោះស្រាយវិវាទ និងបណ្តឹងពាក់ព័ន្ធនឹងអំពើល្មើស ឬបទល្មើសក្នុងវិស័យមូលបត្រ។

- **ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ** ក្រៅផ្លូវតុលាការ និងតាមផ្លូវតុលាការ។

ក្នុងស្មារតីនេះ **គ.ម.ក.** តែងស្វែងរកយន្តការ ការក៏សាងទំនុកចិត្ត និងផ្តល់យុត្តិធម៌ជូនវិនិយោគិន ជាពិសេសធ្វើឲ្យប្រាកដថាផលប្រយោជន៍របស់វិនិយោគិនត្រូវបានការពារ។

### ៥.៥.៤. ជំរុញការអប់រំ និងការយល់ដឹងរបស់សារព័ត៌មាន

វិស័យមូលបត្រនៅកម្ពុជា ត្រូវបានគេចាត់ទុកថា ជាវិស័យថ្មីមួយ និងមានភាពស្មុគស្មាញនៅឡើយ ដែលទាមទារឲ្យអ្នកសារព័ត៌មាន មានការស្វែងយល់ច្រើនពីវិស័យនេះ ដើម្បីផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនិងសង្គម។

ព្រមជាមួយនឹងការផ្តល់នូវការបណ្តុះបណ្តាលដល់តួរអង្គសំខាន់ៗក្នុងវិស័យមូលបត្រគណៈកម្មការមូលបត្រកម្ពុជា ដែលជាស្ថាប័នក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើនការរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពីសារៈសំខាន់របស់សារព័ត៌មាន ក្នុងការអភិវឌ្ឍន៍វិស័យមូលបត្រនៅកម្ពុជា។ ការរៀបចំវគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងក្នុងបំណងបង្កើនការយល់ដឹងបន្ថែមដល់អ្នកសារព័ត៌មានអំពីកិច្ចដំណើរការអភិវឌ្ឍន៍សំខាន់ៗថ្មីពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ច្បាប់ និងបទប្បញ្ញត្តិនានា ព្រមទាំងការប្រើប្រាស់ពាក្យបច្ចេកទេសក្នុងវិស័យមូលបត្រ ដែលជាច្រកសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានឲ្យកាន់តែទំលំទូលាយ ត្រឹមត្រូវ និងការកសាងទំនុកចិត្តដល់ទីផ្សារ ព្រោះថាប្រសិនបើព័ត៌មានផ្សព្វផ្សាយមិនពេញលេញណាមួយកើតឡើង ដែលអាចនឹងបង្ករឲ្យមានការភាន់ច្រឡំនៅក្នុងទីផ្សារ និងឈានទៅដល់ការជះឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា។ ដោយភាពលំបាកនៃការយកព័ត៌មានក៏ដូចជាភាពមិនច្បាស់លាស់នៃការផ្តល់ព័ត៌មាន ការបង្កើនចំណេះដឹងនេះ ជាឱកាសដែលឲ្យអ្នកសារព័ត៌មានបានសិក្សាស្វែងយល់បន្ថែមទៀតអំពីវិស័យមូលបត្រ ពិសេសពាក្យបច្ចេកទេសនិងការយកព័ត៌មានសំខាន់ដែលសាធារណជន និងវិនិយោគិនចង់ដឹងជាព័ត៌មានក្នុងការសម្រេចចិត្តវិនិយោគទៅលើក្រុមហ៊ុនបោះផ្សាយ។ ទន្ទឹមនឹងគ្នានេះ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រក៏ត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកសារព័ត៌មានដែរ ដើម្បីបានផ្សព្វផ្សាយព័ត៌មានល្អៗ និងបច្ចុប្បន្នភាព។ ការបើកវគ្គបណ្តុះបណ្តាលស្តីអំពីសារៈសំខាន់របស់សារព័ត៌មានក្នុងការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា នេះជាវគ្គបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពដល់អ្នកសារព័ត៌មាន។

បង្កើនការជំរុញក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ឲ្យបានទូលំទូលាយ និងមានភាព ព្រមទាំងចែករំលែកចំណេះដឹងស្តីពីទីផ្សារមូលបត្រ ទៅកាន់អ្នកសារព័ត៌មានឲ្យមានការយល់ដឹងកាន់តែច្បាស់ពីការវិវត្តនៃទីផ្សារមូលបត្រ ព័ត៌មានមូលបត្រសំខាន់ៗ និងការស្វែង

យល់ និងស្វែងរកព័ត៌មានពីទីផ្សារមូលបត្រនៅកម្ពុជា។ បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពីរបាយការហិរញ្ញវត្ថុ និងសារព័ត៌មានពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ កសាងសមត្ថភាពចំពោះការផ្សព្វផ្សាយសារព័ត៌មានជាភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងការផ្តល់ព័ត៌មានជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។

### ៥.៥.៥. ការកសាងសមត្ថភាព

ការកសាងសមត្ថភាពដែលពាក់ព័ន្ធនឹងអភិបាលកិច្ច និងការអប់រំដែលមានដូចជាៈ ការផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាន ការកសាងសមត្ថភាពសម្រាប់មន្ត្រី **គ.ម.ក.** និង **ផ.ម.ក.** តាមរយៈការចូលរួមក្នុងកម្មវិធីផ្សេងៗដូចជា ការអនុវត្តការងារដល់ទីកន្លែង ការដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សានិងកម្មវិធីបណ្តុះបណ្តាលនៅបរទេសផ្សេងៗទៀត។គណៈកម្មការមូលបត្រកម្ពុជាក៏បានផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុងដោយមានកិច្ចសហប្រតិបត្តិការជាមួយ មជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិដូចជា មជ្ឈមណ្ឌល **តូរ៉ុនតូ** គំនិតផ្តួចផ្តើមសម្រាប់ការបណ្តុះបណ្តាលដល់និយ័តករហិរញ្ញវត្ថុ (FRTI) វិទ្យាស្ថានមូលបត្រថៃ (TSI) និងអ្នកជំនាញការបរទេស។

### ៥.៥.៦. ពង្រឹងប្រព័ន្ធគណនេយ្យ និងសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន និងបានឆ្លុះបញ្ចាំងពីស្ថានភាពពិតរបស់ក្រុមហ៊ុនដូចជា លំហូសាច់ប្រាក់ លទ្ធផលប្រតិបត្តិការ បំណុល និងការប្រែប្រួលមូលធនមួយចំនួននៅក្នុងក្រុមហ៊ុនជាដើម វាសំខាន់ណាស់សម្រាប់ក្រុមហ៊ុនដែលមានបំណាងចង់ចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា។

ដើម្បីទទួលបាននូវប្រព័ន្ធគណនេយ្យ និងសវនកម្មប្រកបដោយស្តង់ដាខ្ពស់ និងមានគុណភាពទទួលស្គាល់ជាលក្ខណៈអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត និងដាក់ឲ្យអនុវត្តន៍នូវកាតព្វកិច្ចគណនេយ្យ សវនកម្ម និងវិជ្ជាជីវៈគណនេយ្យនៅកម្ពុជាដូចជាច្បាប់ស្តីពីគណនេយ្យសហគ្រាសសវនកម្ម គណនេយ្យសហគ្រាស វិជ្ជាជីវៈគណនេយ្យ បទប្បញ្ញត្តិស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ព្រមទាំងឈានដល់បង្កើតស្ថាប័នក្រុមប្រឹក្សាជាតិគណនេយ្យ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនកម្មកម្ពុជា ដែលកិច្ចការទាំងនោះមានដូចជាៈ

- ការត្រួតពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈ គណនេយ្យ ឬបង្កើតច្បាប់ស្តីពីគណនេយ្យនិងសវនកម្មថ្មី ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនានាដើម្បីៈ

១.លុបបំបាត់ចំណុចដែលមិនស្របគ្នានៃទំហំសហគ្រាស ដែលតម្រូវឲ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។

២.បង្កើតយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តច្បាប់និងស្តងដារគណនេយ្យ។

៣.ផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាជាតគណនេយ្យ និងវិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា។

- តាមដានការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ៖ រដ្ឋាភិបាលត្រូវពិចារណាពង្រឹងការចុះបញ្ជីពាណិជ្ជកម្ម ដែលតម្រូវឲ្យសហគ្រាសទាំងអស់ចុះបញ្ជី (អាចលើកលែងសហគ្រាសធុនតូច) និងធ្វើបច្ចុប្បន្នកម្មព័ត៌មានលម្អិតរបស់ខ្លួនប្រចាំឆ្នាំ។ ប្រព័ន្ធចុះបញ្ជីថ្មីមួយដែលបញ្ចូលគ្នានូវប្រព័ន្ធដែលមានស្រាប់ ត្រូវមានសកមត្ថភាពបញ្ចូលទិន្នន័យពីប្រព័ន្ធបច្ចុប្បន្នទៅប្រព័ន្ធថ្មី។
- ការកសាងសមត្ថភាព៖ រាជរដ្ឋាភិបាលពិចារណាពីលទ្ធផល

១. តម្រូវឲ្យសាកលវិទ្យាល័យនិងគ្រឹះស្ថានឧត្តមសិក្សាអនុវត្តកម្មវិធីសិក្សាផ្នែកគណនេយ្យនិងសវនកម្មស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។

២. បណ្តុះបណ្តាលគ្រូបង្គោល និងគ្រូឧទ្ទេសផ្នែកគណនេយ្យនិងសវនកម្ម។

៣. បង្កើតសទ្ទានុក្រមគណនេយ្យ និងសវនកម្មជាខេមរភាសា។

- ជំរុញការពង្រីកសមាជិកភាពគ្រឹះស្ថានគណនេយ្យករជំនាញ និងសវនកម្មកម្ពុជាតាមរយៈការប្រមូលផ្តុំគណនេយ្យករដែលមានគុណវឌ្ឍិនៅតាមក្រុមហ៊ុនសហគ្រាសអាជីវកម្ម អង្គការនានា ក្នុងគោលដៅជំរុញការអនុវត្តស្តង់ដាគណនេយ្យ និងសវនកម្មឲ្យកាន់តែមានភាពថែមទៀត។[47]
- គណៈកម្មការមូលបត្រកម្ពុជា ត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាជាតិគណនេយ្យលើការធ្វើឲ្យប្រសើរឡើងនូវការត្រួតពិនិត្យក្រុមហ៊ុនគណនេយ្យជំនាញ ផ្តល់សេវាក្នុងវិស័យមូលបត្ររបស់ KICPAA
- ពង្រឹងការកំណត់បទប្បញ្ញត្តិនិងស្តង់ដារគណនេយ្យនិងសវនកម្មនៅកម្ពុជាឲ្យមានភាព
- គ្រប់គ្រងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់ ស្តង់ដា និងវិធានពាក់ព័ន្ធនានា

[47] ហេង ធានី ចាន់ ហួរ, *ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា*,(ភ្នំពេញ ២០១២) ទំព័រ ៨៤

– ជំរុញការអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា ដើម្បីឲ្យមានតម្លាភាព គណនេយ្យភាព វិជ្ជាជីវៈនិយម និងការទទួលខុសត្រូវខ្ពស់។

## ៥.៦. ផែនការដើម្បីបង្កើនការចុះបញ្ជីនៅលើទីផ្សារ

ការបង្កើនចំនួនក្រុមហ៊ុនចុះបញ្ជីជួញដូរនៅលើទីផ្សារ ត្រូវបានផ្តោតការយកចិត្តទុកដាក់ខ្ពស់តាមរយៈការអភិវឌ្ឍ និងការអនុវត្តផែនការជំរុញការចុះបញ្ជីនៅលើទីផ្សារ។ ការផ្តល់ការលើកទឹកចិត្តនានាដល់ក្រុមហ៊ុនចុះបញ្ជីជួញដូរមូលបត្របំណុលនៅក្នុងទីផ្សារ ដូចជាការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ត្រូវបានដាក់ឲ្យអនុម័ត និងផ្សព្វផ្សាយព្រមជាមួយនឹងការដាក់ឲ្យអនុវត្តកម្មវិធីជំរុញការយល់ដឹងជាសាធារណៈ។ ការសម្របសម្រួលដើម្បីជំរុញឲ្យមានក្រុមហ៊ុនចុះបញ្ជីជួញដូរច្រើននៅលើទីផ្សារ ដោយមកពីវិស័យចម្រុះ ត្រូវបានធ្វើឡើងប្រកបដោយកិច្ចខិតខំប្រឹងប្រែងខ្ពស់។

ការជំរុញលើកទឹកចិត្តដល់សហគ្រាសឯកជន ឲ្យចុះបញ្ជីក្នុងផ្សារមូលបត្រ រាជរដ្ឋាភិបាលកំពុងពិនិត្យពិចារណាលើសហគ្រាសសាធារណៈផ្សេងទៀត ដើម្បីនាំមកចូលផ្សារមូលបត្រ ក្នុងគោលដៅមិនត្រឹមតែជំរុញការអភិវឌ្ឍទីផ្សារប៉ុណ្ណោះទេ តែក៏រួមចំណែកដល់ការងារជំរុញឯកជនភាវូបនីយកម្ម បង្កើនភាពផលិតភាព និងភាពប្រកួតប្រជែងរបស់សហគ្រាសទាំងនោះផងដែរ។ ការបោះផ្សាយមូលបត្របំណុលបានបង្កើតជាផលិតផលថ្មីមួយសម្រាប់វិនិយោគិន ហើយរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់រៀបចំបទប្បញ្ញត្តិ និងយន្តការនានា ដើម្បីត្រៀមខ្លួនបោះផ្សាយមូលបត្របំណុលរដ្ឋផងដែរ។ រាជរដ្ឋាភិបាលបានណែនាំឲ្យក្រុមការងារនៃគណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងសិក្សាអំពីលទ្ធភាពក្នុងការបង្កើតផលិតផលវិនិយោគផ្សេងៗ ដែលអាចជាមូលបត្របរទេស ឬផលិតផលក្នុងស្រុកថ្មីៗដើម្បីអនុញ្ញាតឲ្យវិនិយោគិនមានជម្រើសក្នុងការធ្វើពិពិធកម្មវិនិយោគក្នុងវិស័យមូលបត្រនេះដូចជា៖

– បង្កភាពងាយស្រួលក្នុងការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម៖ រៀបចំបទប្បញ្ញត្តិសម្រាប់សម្រួលដល់ការចុះបញ្ជីសហគ្រាសធុនតូច និងធនុមធ្យម។
– ទម្រង់សាមញ្ញ៖ អនុញ្ញាតឲ្យធនាគារ និងសហគ្រាសធុនតូច និងមធ្យមប្រើប្រាស់ទម្រង់សាមញ្ញជំនួសឯកសារផ្តល់ព័ត៌មានដ៏ស្មុគស្មាញ
– អនុវត្តលក្ខខណ្ឌតម្រូវការថ្មី និងអភិវឌ្ឍគោលនយោបាយដើម្បីជំរុញកំណើនទីផ្សារ។

## ៥.៧. ការអភិវឌ្ឍក្របខ័ណ្ឌគ្រប់គ្រង និងគតិយុត្ត

ស្របពេលដែលទីផ្សារមូលបត្រកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ ការពង្រឹង និងអភិវឌ្ឍក្របខ័ណ្ឌគ្រប់គ្រង និងគតិយុត្ត គឺជាធាតុមួយដ៏សំខាន់សម្រាប់ទ្រទ្រង់ដល់វិស័យមួយនេះ។ ចាប់តាំងពីទីផ្សារមូលបត្រត្រូវបានដាក់ឲ្យដំណើការ រាជរដ្ឋាភិបាលបានអនុម័តច្បាប់ពាក់ព័ន្ធនឹងមូលបត្រ ដែលច្បាប់ទាំងនោះផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ក្នុងនោះរួមមាន ច្បាប់ស្តីពីមូលបត្ររដ្ឋ ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីការបោះផ្សាយមូលបត្របំណុល ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀត។ ដើម្បីពង្រឹងការគ្រប់គ្រង និងការអនុវត្តនូវក្របខ័ណ្ឌច្បាប់ទាំងនេះឲ្យបានពេញលេញ និងមានភាពក្នុងការផ្តល់ជំនឿទុកចិត្តដល់សាធារណជន ជាពិសេសអ្នកចូលរួមក្នុង វិស័យនេះទាមទាឲ្យរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធត្រូវខិតខំបង្កើតច្បាប់ និងបទប្បញ្ញត្តិជាពិសេសតាមដាននូវការអនុវត្តដើម្បីធានាថាច្បាប់ទាំងនោះត្រូវបានប្រតិបត្តិយ៉ាងត្រឹមត្រូវ ដែលរួមមាន៖

- ❖ អនុវត្តឲ្យបានម៉ឺងម៉ាត់នូវការបង្ការការក្ស័យធន
- ❖ បន្តបង្កើន និងរក្សាទំនុកចិត្តក្នុងទីផ្សារមូលបត្រ តាមរយៈការការពារសុវត្ថិភាពទ្រព្យសកម្មរបស់អ្នកវិនិយោគ ដោយការជំរះបញ្ជីឲ្យទាន់ពេលវេលា និងមានភាព
- ❖ ផ្តល់ក្របខ័ណ្ឌគតិយុត្តឲ្យ **គ.ម.ក** ធ្វើសហប្រតិបត្តិការជាមួយប្បញ្ញត្តិពាក់ព័ន្ធចំពោះបុគ្គលបោះផ្សាយដែលមានប្រតិបត្តិការអាជីវកម្មស្ថិតក្រោមប្បញ្ញត្តិដាច់ដោយឡែក
- ❖ បន្តពង្រឹងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មដែលមានដូចជា៖ តុលាការពាណិជ្ជកម្ម កិច្ចសន្យាពាណិជ្ជកម្ម ដើម្បីធានាភាពស្មើភាពគ្នារបស់អ្នកចូលរួម ការជឿទុកចិត្តប្រព័ន្ធច្បាប់ក្នុងការកាត់ក្តីគូវិវាទឲ្យមានយុត្តិធម៌ក្នុងវិស័យមូលបត្រ។
- ❖ ការពង្រឹងការអនុវត្តច្បាប់ទាំងនោះមានដូចជា៖
  - ពង្រឹងការត្រួតពិនិត្យតួអង្គទាំងអស់ក្នុងផ្សារទាំងលើឯកសារ និងចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីបញ្ជាក់ថាតួអង្គទាំងនោះបានអនុវត្តយ៉ាងត្រឹមត្រូវ
  - បង្កើនការឃ្លាំមើលការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រដើម្បីធានារាល់ប្រតិបត្តិការជួញដូរត្រូវបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិដែលបានចែង
  - បង្កើនការស៊ើបអង្កេត និងតាមដានរាល់សកម្មភាពដែលសង្ស័យថាមានបទល្មើស ឬភាពមិនប្រក្រតីក្នុងទីផ្សារ
  - រឹតបន្តឹងការចាត់វិធានការពិន័យអន្តរការណ៍ និងទណ្ឌកម្មរដ្ឋបាលចំពោះអំពើល្មើស

– បញ្ជូនសំណុំរឿងទៅតុលាការចំពោះបទល្មើស

❖ ពិនិត្យឡើងវិញនូវការអភិវឌ្ឍតម្រូវការ និងការវិវត្តន៍ថ្មីនៃទីផ្សារពាក់ព័ន្ធនឹងប្រតិបត្តិការក្រោដហ្វាន់ឌីង និងកែសម្រួលបទប្បញ្ញត្តិ។

❖ រៀបចំបទប្បញ្ញត្តិដើម្បីពង្រឹងការត្រួតពិនិត្យដល់អ្នកផ្តល់សេវា និងវេទិកាក្រោដហ្វាន់ឌីង

❖ ពិនិត្យឡើងវិញនៅបទប្បញ្ញត្តិ និងគោលនយោបាយបច្ចុប្បន្ន កំណត់និងលុបចោលឧបសគ្គនានាដែលរាំងស្ទះដល់ការចុះបញ្ជីរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ជំរុញការចុះបញ្ជីលក់មូលបត្រ និងរៀបចំចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុ។

❖ កំណត់នូវគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុសំខាន់ៗដែលអាចមានលទ្ធភាពចុះបញ្ជីឲ្យបោះផ្សាយលក់មូលបត្រក្នុងកម្រិតណាមួយសម្រាប់បរិវិសកម្ម និងការចុះបញ្ជីជាសាធារណៈ។

❖ ពិនិត្យឡើងវិញនូវការអនុវត្តប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយនិងក្រុមហ៊ុនមិនបោះផ្សាយរួមទាំងសហគ្រាសធុនតូច និងមធ្យម។

❖ បន្តអភិវឌ្ឍ និងពង្រឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអភិបាលកិច្ចអាជីវកម្មដោយផ្អែកលើតម្រូវការចាំបាច់និងការអនុវត្តល្អៗ។

❖ ពង្រឹងការអនុវត្តក្របខ័ណ្ឌគតិយុត្តសម្រាប់មូលបត្របំណុល

❖ ស្រាវជ្រាវ និងបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់ក្រោដហ្វាន់ឌីងដើម្បីជំរុញក្រុមហ៊ុនបង្កើតថ្មី។

❖ ដាក់បទប្បញ្ញត្តិលើអន្តរការី និងអ្នកផ្តល់សេវាវិជ្ជាជីវៈជំនាញ។

## ៥.៨. ការបង្កើនការផ្សព្វផ្សាយ

ការផ្សព្វផ្សាយពីវិស័យមូលបត្រមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍទីផ្សារមូល-បត្របំណុលនៅកម្ពុជា ទោះបីជាវិស័យនេះបានដំណើរការរយៈពេលជិត១០ ឆ្នាំ តែនៅតែចាត់ទុកថាជាវិស័យថ្មីមួយនៅកម្ពុជា ដោយនៅតែមានសាធារណជនកម្ពុជាដ៏ច្រើនលើសលប់មិនទាន់បានយល់ច្បាស់ពីវិស័យនេះនៅឡើយ។ ដោយសង្កេតឃើញពីអត្ថប្រយោជន៍នេះ **គ.ម.ក.** និង **ផ.ម.ក.** បានបន្តបង្កើនធ្វើការផ្សព្វផ្សាយដូចខាងក្រោម៖

**ក. ការផ្សព្វផ្សាយតាមទូរទស្សន៍៖ គ.ម.ក.** និង **ផ.ម.ក.** បានបន្តបង្កើននិងពង្រីកការធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក ដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងទីផ្សារមូលបត្រឲ្យកាន់តែទូលំទូលាយដល់សាធារណជន តាមរយៈការជួបប្រជុំជាមួយដំណាងអ្នកសារព័ត៌មាន និងចាត់បញ្ចូលមន្ត្រីជំនាញរបសខ្លួន ក៏ដូចជាស្ថាប័នពាក់ព័ន្ធឲ្យចូលរួមជាវាគ្មិនកិត្តិយស

នៅក្នុងកម្មវិធីទូរទស្សន៍ ព្រមទាំងផ្តល់កិច្ចសម្ភាសដល់បណ្តាសារព័ត៌មាននានាពាក់ព័ន្ធនឹងបច្ចុប្បន្នភាពនៃដំណើរការអភិវឌ្ឍទីផ្សារមូលបត្រ អត្ថប្រយោជន៍របស់ទីផ្សារមូលបត្រ កិច្ចដំណើរការបោះផ្សាយលក់មូលបត្រ ការជួញដូរ ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយជាដើម។

**ខ. ការផ្សព្វផ្សាយតាមរយៈគេហទំព័រ និងបណ្តាញសង្គមៈ** ក្នុងគោលបំណងគាំទ្រដល់ភាពការងាររបស់ **គ.ម.ក.** និង **ផ.ម.ក.** និងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតរដ្ឋាភិបាលអេឡិចត្រូនិក (E-government) និងសម្របទៅតាមវប្បធម៌ការងារនាយុគសម័យព័ត៌មានវិទ្យានាពេលបច្ចុប្បន្ន ដើម្បីផ្តល់ភាពងាយស្រួលដល់សាធារណជន ក្នុងការតាមដានពីការវិវត្តនៃវិស័យមូលបត្រនៅកម្ពុជា ការផ្សព្វផ្សាយច្បាប់ សិក្ខាសាលា ដំណឹងផ្សេងៗ និងជាពិសេសជួយធានាឲ្យទីផ្សារមូលបត្រមានតម្លាភាព យុត្តិធម៌ភាព និងសណ្តាប់ធ្នាប់ **គ.ម.ក.** និង**ផ.ម.ក.** បានបង្កើតនូវគេហទំព័រ www.secc.gov.kh និង www.csx.com.kh ដែលមានលក្ខណៈ ឌីណាមិក។ តាមរយៈគេហទំព័រទាំងនេះ សាធារណជនអាចមើលព័ត៌មាន និងទាញយកឯកសារសំខាន់ៗពាក់ព័ន្ធនឹងមូលបត្រ។ គេហទំព័រទាំងនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ និងអនុញ្ញាតឲ្យអ្នកប្រើប្រាស់ចុះឈ្មោះតាម Online ដើម្បីទទួលបានព័ត៌មានថ្មីៗ តាមរយៈអ៊ីម៉ែលនៅពេលដែល **គ.ម.ក.** និង **ផ.ម.ក.** បានដាក់បញ្ចូលឯកសារទៅក្នុងគេហទំព័ររបស់ខ្លួន។

## ៥.៩. ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ[48]

ទីផ្សារមូលបត្ររដ្ឋអាចជួយជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងផ្តល់មូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍទីផ្សាររូបិយវត្ថុ។ មិនតែប៉ុណ្ណោះ ទីផ្សារមូលបត្ររដ្ឋជាមធ្យោបាយដែលមានសារៈប្រយោជន៍របស់រដ្ឋាភិបាលក្នុងការកៀរគរមូលនិធិក្នុងស្រុក ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកាចន្ត។ មូលបត្ររដ្ឋ ជាឧបករណ៍សំខាន់មួយសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីបង្កើនប្រាក់រៀល។ ទីផ្សារមូលបត្ររដ្ឋដែលមានមូលដ្ឋានទូលំទូលាយមានសារៈសំខាន់សម្រាប់ដំណើរការប្រតិបត្តិការទីផ្សារបើកចំហរ។ មូលបត្ររដ្ឋចារឹកជាប្រាក់រៀលអាចត្រូវបានបោះផ្សាយ និងអាចអនុញ្ញាត្តឲ្យដាក់ជាប្រាក់តម្កល់កម្រិតសមស្របណាមួយ ដើម្បីកាត់បន្ថយការចំណាយលើការដាក់តម្កល់ជាសាច់ប្រាក់ដែលមិនទទួលបានការប្រាក់ និងការជំរុញទទួលយកប្រាក់រៀលក្នុងការជួញដូរមូលបត្រ។ មូលបត្ររដ្ឋនិងផ្តល់នូវជម្រើសវិនិយោគមួយដែលគ្មានហានិភ័យ និងកាត់បន្ថយការទទួលយកហានិភ័យពីធនាគារទៅវិនិយោគិនមិនមែនធនាគារ ដូចជាក្រុមហ៊ុនធានា

[48] ធនាគារជាតិនៃកម្ពុជា, របាយការណ៍ឆ្នាំ២០១៨ និងផែនការសកម្មភាពឆ្នាំ២០១៩

រ៉ាប់រង់ជាដើម។ ទន្ទឹមនិងនេះ ក្រុមហ៊ុនធានារ៉ាប់រងអាចវិនិយោគលើមូលបត្ររដ្ឋ ដើម្បីកាត់បន្ថយការវិនិយោគគ្មានសុវត្ថិភាព ក្រោមកិច្ចព្រមព្រៀងទិញត្រឡប់មកវិញចៀសវាងការដាក់ប្រាក់បញ្ញើទាំងស្រុងនៅគ្រឹះដ្ឋានធនាគារ ដែលអាចមានហានិភ័យក្នុងករណីមានការដួលរលំគ្រឹះស្ថានធនាគារទាំងនោះ។ ការបោះផ្សាយមូលបត្ររដ្ឋត្រូវការចំណាយថវិកា ប៉ុន្តែរាជរដ្ឋាភិបាលនឹងទទួលបានអត្ថប្រយោជន៍ពីការបង្កើតប្រភពហិរញ្ញប្បទានដែលគ្មានសម្ពាធអតិផរណា។ ការបោះផ្សាយមូលបត្ររដ្ឋ គប្បីផ្សារភ្ជាប់ឲ្យសមស្របទៅនឹងកម្មវិធីខ្ចីរបស់រដ្ឋាភិបាលដើម្បីបំពេញលក្ខខណ្ឌខ្ចី។ នីតិវិធីនិងប្រព័ន្ធដេញថ្លៃគប្បីបង្កើតឡើងដើម្បីជំរុញការលក់ និងការបែងចែក។

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ នឹងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងយន្តការពាក់ព័ន្ធនឹងការបោះផ្សាយ និងការគ្រប់គ្រងប្រតិបត្តិការមូលបត្ររដ្ឋ។
- ក្រសួងសេដ្ឋនិងហិរញ្ញវត្ថុនឹងបន្តធ្វើការសិក្សាអំពីលទ្ធភាព ក្នុងការបោះផ្សាយមូលបត្ររដ្ឋ និងរៀបចំឯកសារយុទ្ធសាស្ត្រស្ដីពីការបោះផ្សាយមូលបត្ររដ្ឋ។
- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំនីតិវិធីប្រតិបត្តិការសម្រាប់មូលបត្ររដ្ឋ។
- ពិចារណាបង្កើតក្របខ័ណ្ឌ និងគោលនយោបាយលើកទឹកចិត្តដល់ការចុះបញ្ជីរបស់សហគ្រាសរដ្ឋ
- ពិនិត្យមើលលើអភិបាលកិច្ច និងស្ថាប័នអាជីវកម្មរបស់សហគ្រាសរដ្ឋ និងជំរុញការចុះបញ្ជីរបស់សហគ្រាសរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន។

**ក. ការអភិវឌ្ឍប្រតិបត្តិការ LPCO**

ដើម្បីអភិវឌ្ឍប្រតិបត្តិការLPCO ឲ្យកាន់តែប្រសើរនិងមានភាពទាក់ទាញសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅខែមីនា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានបង្កើតឲ្យមានប្រភេទឥណប្រតិទាន ៣ខែ និង ៦ខែ បន្ថែមលើឥណប្រតិទានដែលមានស្រាប់ (១ឆ្នាំ)។ ទន្ទឹមនេះ អត្រា Haircut ចំពោះ NCD ជាប្រាក់ដុល្លារអាមេរិក ត្រូវបានបន្ថយពី ៥% មកត្រឹម ៣%។ ការអភិវឌ្ឍ NBCP បានរួមចំណែកជំរុញភាពងាយស្រួល និងធ្វើឲ្យប្រតិបត្តិការនេះកាន់តែមានភាពទាក់ទាញ។

**ខ. វិធានការជំរុញតម្រូវការមូលបត្រអាចជួញដូរបាន (NDC)**

ក្នុងគោលដៅអភិវឌ្ឍន៍ NCD ឲ្យកាន់តែប្រសើរ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធាន

ការជាបន្តបន្ទាប់ដូចខាងក្រោមៈ

- ដំឡើងអត្រាការប្រាក់ NCD ពី ១/២ ទៅ៣/៤ នៃអត្រា LIBOR
- ទទួលទិញ NCD មកវិញក្នុងអត្រាអប្បហារ (Discount Rate)
- កាត់បន្ថយតម្លៃចារឹកនៃ NCD ពី ២ប៊ីលាន មក ២០០លានរៀល សម្រាប់ NCD ចារឹកជាប្រាក់រៀល និងពី៥០០ពាន់ដុល្លារអាមេរិកមក ៥០ពាន់ដុល្លារអាមេរិក សម្រាប់ NCD ចារឹកជាដុល្លារអាមេរិក
- បញ្ឈប់ការទទួលប្រាក់បញ្ញើមានកាលកំណត់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលដាក់នៅធនាគារជាតិនៃកម្ពុជា
- កែប្រែនីតិវិធីនៃការចេញផ្សាយ NCD ពីការចេញផ្សាយរាល់ថ្ងៃមកចេញផ្សាយតែមួយដងក្នុងមួយសប្តាហ៍
- កែប្រែថ្ងៃភាពនៃការទូទាត់ NCD ពី T+0 មក T+១
- កែប្រែគណប្រតិទាន NCD ជាចំនួនថ្ងៃដោយផ្អែកលើមូលដ្ឋានសប្តាហ៍ ៧ថ្ងៃ ១៤ថ្ងៃ ២៨ថ្ងៃ ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៥ថ្ងៃ
- បង្កើនគណប្រតិទាននៃ NCD ជាប្រាក់ដុល្លារអាមេរិករហូតដល់ ៣៦៥ថ្ងៃ
- អភិវឌ្ឍផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ដើម្បីជំរុញឲ្យមានប្រតិបត្តិការជួញដូរមូលបត្រនៅក្នុងទីផ្សារទី២ និងកែប្រែនីតិវិធីនៃការទទួលពាក្យសុំជាវ NCD ពីទម្រង់ឯកសាររូបវន្តមកជាទម្រង់អេឡិចត្រូនិចតាមរយៈប្រព័ន្ធ NBCP។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និង គណៈកម្មការមូលបត្រកម្ពុជា នឹងសហការរៀបចំផែនការ និងដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធដ៏ល្អបំផុតសម្រាប់ការគាំទ្រដល់ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ។

## ៥.១០. អត្ថប្រយោជន៍នៃការអភិវឌ្ឍទីផ្សារមូលបត្របំណុល

ការអភិវឌ្ឍទីផ្សារមូលបត្របំណុល គឺជាយន្តការមួយក្នុងការចូលរួមនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដូចជាៈ

- ការចូលរួមនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយហេតុថាទីផ្សារមូលបត្រ គឺជាសរសៃឈាមសេដ្ឋកិច្ច នឹងអាចកៀរគរមូលនិធិដែលនៅសេសសល់នៅក្នុងទីផ្សារឲ្យប្រើប្រាស់អស់ពីលទ្ធភាព ជួយបង្កើនការងារក្នុងស្រុក និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសក្នុងស្រុក ព្រមទាំងជំរុញនូវតម្លាភាពអាជីវកម្មនៅកម្ពុជាផងដែរ។

- ព្រមជាមួយនឹងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ វិនិយោគិនក្នុងទីផ្សារក៏ទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា ជាជម្រើសថ្មីមួយក្នុងការវិនិយោគសក្តានុពលនៃផែនការហិរញ្ញវត្ថុគ្រួសារ និងផ្ទាល់ខ្លួន កាត់បន្ថយហានិភ័យនៅក្នុងការវិនិយោគ ក្លាយជាម្ចាស់បំណុលរបស់ក្រុមហ៊ុនបោះផ្សាយ ទទួលបានការប្រាក់ ការលើកទឹកចិត្តផ្នែកពន្ធដារ និងងាយស្រួលក្នុងការបំលែងជាសាច់ប្រាក់ (ករណីមានសន្ទនីយភាព)។
- មិនថាតែវិនិយោគិនប៉ុណ្ណោះទេ ក្រុមហ៊ុនបោះផ្សាយក៏ទទួលបានអត្ថប្រយោជន៍ដ៏ច្រើនលើសលប់ពីទីផ្សារមូលបត្របំណុលផងដែរ ដូចជាការទទួលបានដើមទុនបន្ថែម ទំនុកចិត្តពីទីផ្សារ និរន្តរភាពអាជីវកម្ម កេរ្តិ៍ឈ្មោះ ការលើកទឹកចិត្តផ្នែកពន្ធដារនិងមិនមែនពន្ធដារជាដើម។
- មានអភិបាលកិច្ចសាជីវកម្ម ទីផ្សារមូលបត្រដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវទំនុកចិត្តរបស់វិនិយោគិនតាមរយៈយន្តការ នៃការគ្រប់គ្រងក្រុមហ៊ុនមួយដែលមានភាពរឹងមាំ ច្បាស់លាស់ តម្លាភាពនិងទំនួលខុសត្រូវខ្ពស់ ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះបញ្ជីក្នុងទីផ្សារ។
- មានភាពរឹងមាំនៃប្រព័ន្ធគណនេយ្យ និងសវនកម្មៈ ដើម្បីធានាទំនុកចិត្តវិនិយោគិនក្នុងទីផ្សារមូលបត្រត្រូវ បានលើកកម្ពស់ក្រុមហ៊ុនគណនេយ្យជំនាញ ក្រុមហ៊ុនសវនកម្មដែលផ្តល់សេវាក្នុងវិស័យមូលបត្រសម្រាប់ក្រុមហ៊ុនបោះផ្សាយជាសធារណៈ ក៏ដូចលើកទឹកចិត្តដល់ក្រុមហ៊ុនគណនេយ្យជំនាញនៅកម្ពុជាឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- បច្ចេកវិទ្យាកាន់តែទំនើបៈ ក្នុងការអភិវឌ្ឍផ្សារមូលបត្របំណុល រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធក្នុងវិស័យនេះបានស្វះស្វែងរិះរកនូវបច្ចេកវិទ្យាថ្មីៗ និងកាន់តែទំនើបពីប្រទេសជឿនលឿន ជាពិសេសប្រទេសកូរ៉េដែលជាដៃគូអភិវឌ្ឍផ្សារមូលបត្ររបស់យើងផ្ទាល់។
- បង្កើនធនធានមនុស្សយល់ដឹងក្នុងវិស័យមូលបត្រកាន់តែច្រើន ដែលរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធបានខិតខំជំរុញ ការបណ្តុះបណ្តាលធនធានមនុស្សជាច្រើនជាពិសេសបុគ្គលិកដែលធ្វើការទ្រទ្រង់ក្នុងវិស័យនេះ និងបានខិតខំបញ្ជ្រាបចំណេះដឹងទៅដល់សាធារណជនទូទៅនៅក្នុងប្រទេសកាន់តែច្រើនឡើងៗ។
- ជំរុញការអនុវត្ត SMEs ការអភិវឌ្ឍទីផ្សារមូលបត្របំណុលឲ្យរីកចម្រើនអនុញ្ញាតឲ្យ SMEs អាចប្រមូលបានមូលធនបន្ថែមក្នុងការពង្រីកប្រតិបត្តិការរបស់ខ្លួន ក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជាតាមរយៈសកម្មភាពអាជីវកម្មដ៏មមាញឹកនិងការផ្តល់ការងារដល់ប្រជាជនក្នុងស្រុក។

- ជំរុញការអានុវត្តអាជីវកម្មមហាអនុតំបន់ដងទន្លេមេគង្គ៖ ការអភិវឌ្ឍទីផ្សារមូលបត្របំណុល ក៏បានចូលរួមក្នុងការអភិវឌ្ឍអាជីវកម្មអនុតំបន់ដងទន្លេមេគង្គផងដែរ។
- អភិវឌ្ឍទីផ្សារការងារតាមរយៈការពង្រីកបត្រតិបត្តិការរបស់ក្រុមហ៊ុន ជាពិសេសការរីកចម្រើនរបស់ក្រុមហ៊ុនសាជីវកម្មបង្កឲ្យមានតម្រូវការកម្លាំងពលកម្មយ៉ាងច្រើននៅក្នុងទីផ្សារការងាររបស់កម្ពុជា។
- ពង្រឹងការប្រកួតប្រជែង៖ ការចូលរួមក្នុងការអភិវឌ្ឍទីផ្សារមូលបត្របំណុលធ្វើឲ្យក្រុមហ៊ុនសាជីវកម្មទទួលបានការទទួលស្គាល់ទូលំទូលាយមានតម្លាភាពនិងទំនុកចិត្តពីដៃគូវិនិយោគដែលអនុញ្ញាតឲ្យក្រុមហ៊ុនទាំងនោះទទួលបានចំណាប់អារម្មណ៍ពីសំណាក់សាធារណជន និងជាឱកាសក្នុងការប្រកួតប្រជែកជាមួយបណ្តាក្រុមហ៊ុនដទៃ។
- អភិវឌ្ឍសេដ្ឋកិច្ចឌីជីថល៖ ទីផ្សារមូលបត្រជាទីផ្សារមួយដែលផ្តោតទៅលើប្រតិបត្តិការសម័យទំនើប ដូចនេះការរីកចម្រើននៃទីផ្សារនេះនឹងបង្កើននូវបច្ចេកវិទ្យាថ្មីៗសម្រាប់ផ្តល់ជូនអ្នកចូលរួមក្នុងប្រតិបត្តិការសេដ្ឋកិច្ច។
- រក្សាបានប្រក្រតីភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ និងការផ្គត់ផ្គង់សាច់ប្រាក់ក្នុងទីផ្សារដោយសារទីផ្សារនេះ ជាភ្នាក់ងារផ្គត់ផ្គង់វិស័យហិរញ្ញវត្ថុដ៏សំខាន់ ជាទីផ្សារទុនដ៏ចម្បងសម្រាប់សហគ្រាស និងជាប្រភពចំណូលរបស់រដ្ឋាភិបាលសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជំនួសការខ្ចីពីបរទេស។ ការរីចម្រើនរបស់ទីផ្សារនេះនឹងធ្វើឲ្យរីកចម្រើនវិស័យហិរញ្ញវត្ថុជាតិ។
- បង្កើតផលិតផលហិរញ្ញវត្ថុថ្មី៖ ធ្វើឲ្យមានផលិតផលហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់វិនិយោគ និងជាមធ្យោបាយក្នុងការប្រមូលមូលធនរបស់សហគ្រាសសាជីវកម្ម។

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ និងចុះកម្មសិក្សារយៈពេល ៣ខែនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លើប្រធានបទស្តីពី "ការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជា" យើងឃើញថា វិស័យមូលបត្រដើរតួរយ៉ាងសំខាន់ក្នុងការជំរុញវិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលប្រៀបដូចជាសរសៃឈាមមួយនៅក្នុងការចូលរួមអភិវឌ្ឍវិស័យផ្សេងៗទៀត ដើម្បីធ្វើឲ្យសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើន។ ចាប់តាំងពីការបើកឲ្យដំណើរការនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មកដល់ពេលបច្ចុប្បន្ន វិស័យនេះមានការរីកចម្រើនបន្តិចម្តងៗគួរឲ្យកត់សម្គាល់ ដូចជាការកើនឡើងនៃក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ ការកើនឡើងនូវផលិតផលថ្មីៗសម្រាប់ផ្តល់ជូនវិនិយោគិនក្នុងការវិនិយោគ ជាពិសេស សញ្ញាបណ្ណសាជីវកម្មដែលមកដល់ពេលនេះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនពីរបានបោះផ្សាយសញ្ញាបណ្ណសាជីវកម្មដែលសរុបទាំងអស់មានប្រមាណ ២លានប័ណ្ណ និងសរុបជាទឹកប្រាក់ប្រមាណ ៥០លានដុល្លារសហរដ្ឋអាមេរិក និងមានក្រុមហ៊ុនមានគម្រោងចុះបញ្ជីលក់សញ្ញាបណ្ណជាច្រើនទៀតផងដែរ ក្នុងនោះដែរចំនួនវិនិយោគិនក៏មានការកើនឡើងពី១ឆ្នាំទៅ ១ ឆ្នាំ ដែលលេខអត្តសញ្ញាណវិនិយោគិនគិតត្រឹមត្រីមាសទី១ នៃឆ្នាំ២០១៩ គឺមានការកើនឡើងដល់ ២០.៥៤៩។

ទោះយ៉ាងណាក៏ដោយ ទីផ្សារមូលបត្រ តួយ៉ាងគឺវិស័យមូលបត្រទាំងមូលនៅមិនទាន់មានភាពរឹងមាំនៅឡើយទេ គឺមានភាពខ្វះចន្លោះ និងបញ្ហាជាច្រើនដូចជា កង្វះខាតធនធានមនុស្ស ឧបករណ៍ទំនើបៗ កង្វះខាតអ្នកចូលរួម មិនសូវមានទំនុកចិត្តក្នុងទីផ្សារ ទីផ្សារមូលបត្របំណុលនៅមិនទាន់មានការជួញដូរនៅឡើយ ពុំសូវមានចំណាប់អារម្មណ៍ពីសំណាក់សាធារណជនទូទៅខ្លាំង និងចំណុចខ្វះចន្លោះជាច្រើនទៀតដែរត្រូវកែល្អ និងពង្រឹងបន្ថែម។ ទាំងការបោះផ្សាយមូលបត្ររដ្ឋ និងមូលបត្របំណុលមហាជន សុទ្ធតែដេញថ្លៃសម្រាប់តែវិនិយោគិនស្ថាប័ន គឺមិនទាន់មានការជួញដូរសម្រាប់វិនិយោគិនសាធារណៈទេ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ពាន់ដ៏ទៃទៀតដូចជា គណៈកម្មការមូលបត្រ ផ្សារមូលបត្រកម្ពុជា កំពុងខិតខំរិះរកមធ្យោបាយដើម្បីបំពេញភាពខ្វះចន្លោះ ពង្រឹង និងអភិវឌ្ឍវិស័យនេះឲ្យកាន់តែរឹងមាំ កសាងទំនុកចិត្ត ពង្រឹងក្របខ័ណ្ឌគតិយុត្ត បទប្បញ្ញត្តិ បង្កើនផលិតផលថ្មីៗឲ្យកាន់តែសម្បូរបែប ផ្សព្វផ្សាយ និងធ្វើយ៉ាងណាឲ្យមានការចាប់អារម្មណ៍ពីសំណាក់ប្រជាជនទូទៅមកលើវិស័យមូលបត្រ និងការវិនិយោគក្នុងវិស័យនេះឲ្យកាន់តែច្រើន។ ជាងនេះទៅទៀត ដើម្បីធ្វើឲ្យយុទ្ធសាស្ត្រអភិវឌ្ឍ វិស័យនេះកាន់តែមានភាព រាជរដ្ឋាភិបាល ក៏ដូចជា គណៈកម្មការមូលបត្រ ផ្សារមូលបត្រ និងក្រុមហ៊ុនបម្រើ

សេវាកម្មក្នុងវិស័យមូលបត្រនៅកម្ពុជាទាំងអស់ គួរតែបង្កើននូវការអប់រំបណ្តុះបណ្តាលបន្តនៅក្នុងស្រុក និងក្រៅស្រុកឲ្យយល់ដឹងក្នុងវិស័យនេះ ដើម្បីធានាសមត្ថភាពបុគ្គលិក អ្នកជំនាញ អ្នកឯកទេសក្នុងវិស័យនេះឲ្យកាន់តែមានគុណវុឌ្ឍិ។ ជាពិសេសគួរតែយល់ដឹងបន្ថែមពីបណ្តាលប្រទេសនៅក្នុងតំបន់ ដូចជាប្រទេសថៃឡង់ វៀតណាម សឹង្ហបុរី ម៉ាឡេស៊ី ជាដើម។ ចំពោះ ធនធានមនុស្ស ត្រូវចេះប្រើប្រាស់ឲ្យចំគោលដៅ បង្កើតឲ្យមានក្រុមការងារឲ្យច្បាស់លាស់ និងត្រូវបញ្ជូលមន្ត្រីទៅធ្វើ (OJT) កាន់តែច្រើនដើម្បីដកស្រង់បទពិសោធ និងរបៀបធ្វើការផងដែរ។

យើងសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា **គ.ម.ក.** និង**ផ.ម.ក.** នឹងអាចសម្រេចគោលដៅរបស់ខ្លួនក្នុងការអភិវឌ្ឍវិស័យនេះឲ្យកាន់តែរីកចម្រើនឆាប់រហ័ស និងមានការចាប់អារម្មណ៍ពីសំណាក់សាធារណជនកាន់តែច្រើន ជាពិសេស អ្នកវិនិយោគ ក្រុមហ៊ុនចុះបញ្ជី និងតួអង្គសំខាន់ដ៏ទៃផ្សេងៗទៀតឲ្យចូលរួមក្នុងផ្សារមូលបត្រកម្ពុជា។

# ការផ្តល់អនុសាសន៍

ក្នុងការរួមចំណែកដល់ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាឲ្យរីកចម្រើន យើងខ្ញុំសូមចូលរួមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់គួរតែពិនិត្យលទ្ធភាពបន្ថែម ដើម្បីបន្ថែមតួរអង្គចាំបាច់នានា ដើម្បីឲ្យរចនាសម្ព័ន្ធទីផ្សារកាន់តែរឹងមាំ សម្រួលដល់វិនិយោគិនក្នុងការស្វែងរកព័ត៌មានវិនិយោគ សម្រួលបន្ថែមដល់ការជួញដូរដោយមិនមានប្រាក់ដំកល់១០០%និងបញ្ជ្រាបប្រព័ន្ធឌីជីថលចូលទៅក្នុងផ្សារហ៊ុនដូចជាការស្នើសុំគណនេយ្យជួញដូរតាមអនឡាញជាដើម។

- បង្កើតផលិតផលថ្មីនៅក្នុងទីផ្សារឲ្យបានច្រើនបង្កើនសន្ទនីភាពនៅលើទីផ្សារ ជាពិសេសទីផ្សារបំណុល ដោយអាចកាត់ចំណែកក្នុងភាគរយណាមួយទុកសម្រាប់អ្នកវិនិយោគសាធារណៈក្រៅពីអ្នកវិនិយោគធំៗកាត់បន្ថយថ្លៃនៃការចូលទៅក្នុងទីផ្សារ ដើម្បីទាក់ទាញតួរអង្គអ្នកចូលរួមក្នុងទីផ្សារឲ្យកាន់តែច្រើន រៀបចំនិងការដាក់ឲ្យអនុវត្តបទប្បញ្ញត្តិដ៏សមរម្យមួយ ដែលឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ។
- ជំរុញបង្កើតសមាគមពាណិជ្ជករមូលបត្រ ដើម្បីធ្វើឲ្យពួកគេមានសក្តានុពលក្នុងការអប់រំសមាជិករបស់ខ្លួនអំពីបញ្ហារចនាសម្ព័ន្ធទីផ្សារ និងធ្វើឱ្យអ្នកចូលរួមបានដឹងអំពីនិន្នាការ និងផ្តល់ឱកាសក្នុងការបង្កើតបណ្តាញដែលមានលក្ខណៈពិសេសដែលរួមចំណែកដល់ការអភិវឌ្ឍទីផ្សារ។
- ការបោះផ្សាយប័ណ្ណភាគហ៊ុន ក៏ដូចជាសញ្ញាបណ្ណនៅកម្ពុជាត្រូវបានកំណត់ជាប្រាក់រៀលខ្មែរដើម្បីលើកតម្កើងរូបិយវត្ថុជាតិ ប៉ុន្តែដើម្បីសម្រួល និងបំពេញតម្រូវការដល់វិនិ-យោគិនបរទេស ដែលកំពុងនិងមានគម្រោងមកវិនិយោគក្នុងទីផ្សារមូលបត្ររបស់យើង រាជរដ្ឋាភិបាល និងស្ថានប័នពាក់ព័ន្ធគួរតែពិចារណាលើការបោះផ្សាយជាប្រាក់ដុល្លារអាមេរិក។
- រាជរដ្ឋាភិបាល គួរតែបោះផ្សាយលក់មូលបត្របំណុលឡើងវិញ (Short and Long time) ក្រោយពីបានបញ្ឈប់ក្នុងឆ្នាំ២០០៦ ដើម្បីបង្កើនផលិតផល ក្នុងទីផ្សារមូលបត្ររដ្ឋ និងធ្វើឲ្យមូលបត្របំណុលមានចរាចរនៅលើទីផ្សារកាន់តែច្រើន និងបង្កើនសកម្មភាពជួញដូរ និងកាត់បន្ថយកម្ចីពីបរទេស។ ប័ណ្ណរតនាគារត្រូវបានបោះផ្សាយនៅឆ្នាំ២០០៣ ចំនួន៨

លើក ដែលមានទឹកប្រាក់ប្រមាណ ១៣២ពាន់លានរៀល ឆ្នាំ២០០៥ ចំនួន១១ លើក និងឆ្នាំ២០០៦ ចំនួន ២លើក ដែលមានទឹកប្រាក់ប្រមាណ៩,៨ ពាន់លានរៀល។

- ពង្រឹងការអនុវត្តច្បាប់គណនេយ្យ និងសវនកម្ម សម្រាប់ក្រុមហ៊ុនទាំងអស់ជាពិសេសក្រុមហ៊ុនដែលមានគម្រោងចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា ដើម្បីធានាគុណភាពមូល-បត្រ។ រាជរដ្ឋាភិបាលគួរតែបង្កើនការរកជំនួយបច្ចេកទេសដើម្បីក៏សាងសមត្ថភាពពង្រឹងកាអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងគណនេយ្យ សវនកម្ម និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។
- គួរតែជំរុញឲ្យមានតុលាការពាណិជ្ជកម្មក្នុងវិស័យមូលបត្រ ដើម្បីធានានូវវិវាទដែលកើតមានឡើងត្រូវបានដោះស្រាយដោយមានតម្លាភាព ធ្វើឲ្យក្រុមហ៊ុនកាន់តែស្មើភាពគ្នាក្នុងការចូលរួមក្នុងទីផ្សារ និងការប្រកួតប្រជែងប្រកបដោយតម្លាភាព ជាពិសេសការដោះស្រាយវិវាទប្រកបដោយយុត្តិធម៌ ដែលនេះជាចំណុចសំខាន់មួយក្នុងការបង្កើនក្រុមហ៊ុនចុះបញ្ជីនិងអ្នកវិនិយោគ។
- កង្វះខាតធនធានមនុស្ស ជាបញ្ហាប្រឈមខ្លាំងបំផុតដែលរាំងស្ទះការអភិវឌ្ឍទីផ្សារមូលបត្របំណុល ដូច្នេះ រាជរដ្ឋាភិបាល **គ.ម.ក. ផ.ម.ក.** និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដូចជាក្រសួងអប់រំ គួរតែបង្កើនការអប់រំបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមូលបត្រឲ្យបានកាន់តែច្រើនដល់សាធារណជន ជាពិសេសគួរដាក់បញ្ចូលមុខវិជ្ជាពាក់ព័ន្ធនឹងវិស័យមូលបត្រ អត្ថប្រយោជន៍នៃវិស័យមូលបត្របំណុលឲ្យបានកាន់តែលម្អិត និងទូលំទូលាយក្នុងកម្មវិធីសិក្សា។
- ធ្វើឲ្យមានស្ថិរភាពមីក្រូសេដ្ឋកិច្ច រក្សាប្រក្រតីភាពនៃការប្រតិបត្តិហិរញ្ញវត្ថុ ការផ្គត់ផ្គង់សាច់ប្រាក់ ឥណទាន ស្ថិរភាពអត្រាប្តូរប្រាក់ និងស្ថិរភាពថ្លៃ ដើម្បីឲ្យអាជីវកម្មខ្នាតតូច មធ្យម និងខ្នាតធំ មានលំនឹងក្នុងប្រតិបត្តិការអាជីវកម្ម និងភាពរីកចម្រើន ដែលនេះជាសក្តានុពលរបស់ក្រុមហ៊ុនទាំងនោះក្នុងការចុះបញ្ជី ជាពិសេសត្រូវចូលរួមថែរក្សាស្ថិរភាពនយោបាយ និងសន្តិសុខសង្គមឲ្យបានល្អប្រសើរឡើង
- ក្រុមហ៊ុនមូលបត្រ គួរតែមានសកម្មភាពខ្លាំងក្លាក្នុងការចូលរួមអភិវឌ្ឍទីផ្សារ ត្រូវតែសកម្មខ្លាំងក្នុងការងារផ្សេងៗដែលជាប្រយោជន៍ក្នុងវិស័យនេះ។
- គួរតែអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារហិរញ្ញវត្ថុដែលបានទិញមូលបត្ររដ្ឋ និងមូលបត្រមហាជនអាចយកធ្វើជាទុនបម្រុងកាតព្វកិច្ចបាន។

- ចំពោះក្រុមហ៊ុនធានារ៉ាប់រង ក្រោយពីប្រមូលបានបុព្វលាភ គួរតែយកលុយទៅវិនិ-យោគលើមូលបត្រឲ្យបានច្រើន។
- ដាក់ឲ្យជួញដូរនៅលើទីផ្សារ ដោយមានការលើកទឹកចិត្តដល់វិនិយោគិនសាធារណៈ (លើកទឹកចិត្តផ្នែកពន្ធដារ)
- រដ្ឋាភិបាលគួរតែមានគោលនយោបាយលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយបន្ថែមទៀត
- ជាពិសេស រាជរដ្ឋាភិបាលគួរតែរក្សាឲ្យបាននូវទំនាក់ទំនងល្អជាមួយនឹងបណ្តាប្រទេសនានានៅក្នុងតំបន់ និងនៅក្នុងពិភពលោក និងការអនុគ្រោះពន្ធពី (EBA)&(GSP) ដើម្បីធានានូវការរក្សាស្ថិរភាពសេដ្ឋកិច្ចជាតិ ទាំងនេះក៏ជាផ្នែកមួយដ៏សំខាន់នៃការទាក់ទាញអ្នកវិនិយោគមកលើកកម្ពុជាបន្ថែម។
- បើសិនជា EBA ត្រូវបានកាត់ផ្តាច់ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើនទីផ្សារការងារ លុបបំបាត់អំពើពុករលួយ និងកាត់បន្ថយការិយាល័យធិបតេយ្យ និងពង្រឹងសមត្ថភាពស្ថាប័នរដ្ឋឲ្យកាន់តែប្រសើឡើងជាងមុន ជាពិសេសបង្កើនច្រកនាំចេញខាងវិស័យកាត់ដេរ។
- រាជរដ្ឋាភិបាលគួរតែបង្កើន លើកស្ទួយ និងពង្រឹងការអនុវត្តគោលការគ្រប់ចំណុចដែលបានដាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គួយ៉ាងគឺវិស័យមូលបត្រ។
- ត្រូវមានគោលនយោបាយទាក់ទាញវិនិយោគិនសក្តានុពលពីប្រទេសនានាទាំងក្នុងតំបន់ និងពិភពលោក។
- យើងទាំងអស់គ្នា ត្រូវរួមសហការគ្នា ទាំងទិដ្ឋភាពផ្នែកច្បាប់ និងផ្នែកបច្ចេកទេស ដើម្បីបង្កើនការយល់ដឹងឲ្យកាន់តែស៊ីជម្រៅក្នុងវិស័យ័យមូលបត្រនេះ ក្នុងគោលបំណងជំរុញការវិនិយោគមូលបត្រឲ្យកាន់តែទូលំទូលាយនៅពេលខាងមុខនេះ។

# ឯកសារយោង

❖ **ឯកសារភាសាខ្មែរ**

➢ **ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ**


១. ប្រកាស ស្តីពី ការទទួលស្គាល់ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ លេខ ០០២/១៨ គ.ម.ក/ប្រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨

២. ប្រកាស ស្តីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ ០១៧/១៧ គ.ម.ក/ប្រ.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

៣. ប្រកាស ស្តីពី ការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ ០១៦/១៧ គ.ម.ក/ប្រ.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

៤. ប្រកាស ស្តីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ ០០៤/១៦ គ.ម.ក /ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦

៥. ប្រកាស ស្តីពី ការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ លេខ ០០៦/១៥ គ. ម.ក /ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

៦. ប្រកាស ស្តីពី ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា, ភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

៧. ប្រកាស ស្តីពី អភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ លេខ ០១៣/១០ គ.ម.ក/ប្រ.ក ចុះថ្ងៃ១៥ ខែធ្នូ ឆ្នាំ២០១០

៨. ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាស់ឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧

៩. ច្បាប់ ស្តីពី មូលបត្ររដ្ឋ ដែលបានអនុម័តនៅថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៦

១០. សេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)


➢ **សៀវភៅ និងអត្ថបទស្រាវជ្រាវផ្សេងៗ**


១៣. សាស្ត្រាចារ្យ សួន ចំរើន (២០១៨),ទី*ផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១*

១៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥

១៥. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០


➢ **ឯកសាររបាយការណ៍បញ្ចប់ការសិក្សា និងសារណាបញ្ចប់ការសិក្សារ**


១៦. លឹម វិភា(២០១៨), *ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា*, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

១៧. គឹម ច័ន្ទសុវណ្ណលក្ខណា(២០១៧), *ការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា,* សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
១៨. ហេង ធានី និង ចាន់ ហួរ(២០១២), *ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា,* សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
➢ **របាយការណ៍ និងសិក្ខាសាលាផ្សេងៗ**
១៩. មតិអបអរសាទររបស់ឯកឧត្តម ហុង សុហួរ អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា "ពិធីចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី" ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩
២០. សុន្ទរកថាស្វាគមន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្នុងកម្មវិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First Stock" រាជធានីភ្នំពេញ (AEON Mall), ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៩
២១. សុន្ទរកថាស្វាគមន៍របស់ឯកឧត្តម ស៊ូ សុជាតិ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជាក្នុងកម្មវិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First Stock" រាជធានីភ្នំពេញ (AEON Mall), ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៩
២២. សុន្ទរកថាស្វាគមន៍របស់ឯកឧត្តម ហុង សុហួរ អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្នុងកម្មវិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First Stock" រាជធានីភ្នំពេញ (AEON Mall), ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៩
២៣. សុន្ទរកថាលោក ហាំ ចងហាន់ អគ្គទីប្រឹក្សា និងអគ្គកុងស៊ុល នៃស្ថានទូតសាធារណរដ្ឋកូរ៉េ ក្នុងកម្មវិធី ពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជាឆ្នាំ២០១៩ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៩
២៤. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បទបង្ហាញស្តីពីសេដ្ឋកិច្ចកម្ពុជា ស្ថានភាព និងទស្សនវិស័យ ថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១៩
២៥. និន្នាការសេដ្ឋកិច្ចសង្គម ខែមករា-កុម្ភៈ ឆ្នាំ២០១៩
២៦. ឯកសារ ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC ឆ្នាំ២០១៩
២៧. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ៦ ឆ្នាំ២០១៩
២៨. ធនាគារជាតិនៃកម្ពុជា វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០១៨ និងទស្សនវិស័យឆ្នាំ២០១៩

២៩. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្របខ័ណ្ឌគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ឆ្នាំ២០១៨-២០២៣
៣០. ធនាគារនៃជាតិកម្ពុជា របាយការណ៍ប្រចាំឆ្នាំ២០១៨
៣១. ឯកសារ ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហាត្ថាកសិករ ឆ្នាំ២០១៨
៣២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស៤ ឆ្នាំ២០១៨
៣៣. សមាគមធានារ៉ាប់រងកម្ពុជា សេចក្តីប្រកាសព័ត៌មាន ស្តីពី វិស័យធានារ៉ាប់រងនៅកម្ពុជា មានភាពរីជួមាននៅឆ្នាំ២០១៨
៣៤. ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយលេខ២ ឆ្នាំ២០១៧
៣៥.គណៈកម្មការមូលបត្រកម្ពុជា របាយការណ៍សមិទ្ធផលការងារឆ្នាំ២០១២-២០១៧
៣៦. គណៈកម្មការមូលបត្រកម្ពុជា កម្រងប្រកាសក្នុងវិស័យមូលបត្រនៅកម្ពុជា ភាគ១ ឆ្នាំ២០១២
៣៧. សមាគមធានារ៉ាប់រងកម្ពុជា ជ្រុងមួយនៃទីផ្សារធានារ៉ាប់រងនៅកម្ពុជា
៣៨. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, នាយកដ្ឋានប្រតិបត្តិការទីផ្សារ, មគ្គុទេសក៍ក្នុងការវិនិយោគលើសញ្ញាបណ្ណ
៣៩. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, នាយកដ្ឋានចុះបញ្ជី និងការផ្តល់ព័ត៌មាន, សេចក្តីសង្ខេបពីការចុះបញ្ជី

- **ឯកសារជាភាសាបរទេស**

៤០. C.Michie, Ranald. The GloBal Security Market. New York: Oxford University Press, 2006.
៤១.JENNIFER HUANG, JIANG WANG. Macroeconomic Dynamics, 1 (MARKET STRUCTURE, SECURITY PRICES, AND INFORMATIONAL EFFICIENCY). United States of America, 1997.
៤២. Mr. Siddharth Bagri, Mr. G.C. Sharma, Mr. Ashok Wadhwa, Mr. Ramakara Jha, Mr. A. Palanivel. Introduction to Financial Market Part 1. India: The Secaretary, Central Board of Secondary Eduction, Shiksha Kendra, 2 Community Centrel, Preetvihar, Delhi-110092, 2007.

៤៣. Economic Importance of the Corporate Bond Markets, March, 2013

៤៤. C H A P T E R 5, FINANCIAL MARKETS AND INSTITUTIONS

- **គេហទំព័រ**

៤៥. http://www.csx.com.kh/

៤៦. http://www.secc.gov.kh/khmer/

៤៧. http://www.nbc.org.kh/

៤៨. https://www.worldbank.org/en/country/cambodia/publication/cambodia-economic-update-may-2019

៤៩. ច័ន្ទលាភ, គឹម. https://www.bizkhmer.com/articles/59658#. October 17, 2018. (accessed April 11, 2019).

៥០. http://iac.org.kh/index.php/publication/guide-on-insurance

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ ០០៥/១៧........គ.ម.ក./ប្រ.ក

# ប្រកាស
# ស្តីពី
# ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ យន្តការ បែបបទ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១- ខ្ទង់ក្រៅតារាងតុល្យការ (Off-Balance Sheet Items) សំដៅដល់ខ្ទង់ទាំងឡាយណាដែលមិនបានបង្ហាញក្នុងតារាងតុល្យការ ប៉ុន្តែអាចនាំឱ្យមានហានិភ័យលំហូរសាច់ប្រាក់អនាគត។

២- គូប៉ុង (Coupon) សំដៅដល់ការប្រាក់ដែលបុគ្គលបោះផ្សាយសន្យាធ្វើការទូទាត់តាមលក្ខខណ្ឌនៃមូលបត្របំណុល។

៣- ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៤- បុគ្គលបោះផ្សាយ សំដៅដល់បុគ្គលដែលស្នើសុំ ឬបានបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៥- បុគ្គលធានា(Guarantor) សំដៅដល់នីតិបុគ្គល ឬស្ថាប័ន ដែលផ្តល់ការធានាលើមូលបត្របំណុល ដោយអនុលោមទៅតាមលក្ខខណ្ឌនៃការធានា។

៦- ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល (Bondholders Representative) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីធ្វើជាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ស្របទៅតាមបទប្បញ្ញត្តិដែលមានជាធរមាន។

៧- ភ្នាក់ងារវាយតម្លៃលទ្ធភាពសង (Credit Rating Agency) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីផ្តល់សេវាធ្វើចំណាត់ថ្នាក់លើបុគ្គលរងការធ្វើចំណាត់ថ្នាក់ ឬមូលបត្របំណុលដែលត្រូវបោះផ្សាយលក់។

៨- សញ្ញាបណ្ណធម្មតា (Plain Bond) សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុននៅកាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រឡប់ (Call Option) ឬសិទ្ធិលក់ (Put Option) និងមិនមានការធានា។

៩- សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond) សំដៅដល់មូលបត្របំណុលដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើមនឹងត្រូវបានទូទាត់សងដោយភាគីទីបីដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជា អសាធនភាព ឬក្ស័យធន។

១០- សញ្ញាបណ្ណមានវត្ថុធានា (Secured Bond) សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែមូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

១១- សញ្ញាបណ្ណសាជីវកម្ម (Corporate Bond) សំដៅដល់ប្រភេទមួយនៃមូលបត្របំណុលដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានកាតព្វកិច្ចក្នុងការបង់ប្រាក់ដើម ការប្រាក់ និងកាតព្វកិច្ចផ្សេងទៀតចំពោះម្ចាស់មូលបត្របំណុល។

១២- អត្រាគូប៉ុង (Coupon Rate) សំដៅដល់អត្រាការប្រាក់ដែលបុគ្គលបោះផ្សាយសន្យាធ្វើការទូទាត់ក្នុងរយៈពេលនៃមូលបត្របំណុល។

១៣- អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ៣.- ប្រភេទមូលបត្របំណុលដែលធ្វើសំណើលក់**

មូលបត្របំណុលដែលត្រូវធ្វើសំណើលក់អនុលោមតាមប្រកាសនេះ សំដៅដល់សញ្ញាបណ្ណសាជីវកម្មដែលរួមមានសញ្ញាបណ្ណធម្មតា សញ្ញាបណ្ណមានវត្ថុធានា និងសញ្ញាបណ្ណមានបុគ្គលធានា។

សំណើលក់សញ្ញាបណ្ណសាជីវកម្មប្រភេទផ្សេងទៀត ដូចជា សញ្ញាបណ្ណបរិវត្ត និងសញ្ញាបណ្ណដទៃទៀតជាដើម ត្រូវអនុវត្តតាមលក្ខខណ្ឌផ្សេងទៀតក្នុងបទប្បញ្ញត្តិដោយឡែក និងត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

មូលបត្របំណុលផ្សេងទៀតត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

**ប្រការ ៤.- លក្ខណៈនៃមូលបត្របំណុល**

មូលបត្របំណុលដែលត្រូវធ្វើសំណើលក់អនុលោមតាមប្រកាសនេះត្រូវមាន÷

១- អត្តសញ្ញាណរបស់បុគ្គលបោះផ្សាយ។

២- តម្លៃចារឹក។

៣- អត្រាគូប៉ុង ឬមិនមានអត្រាគូប៉ុងក្នុងករណីមូលបត្របំណុលបោះផ្សាយលក់ក្នុងតម្លៃអប្បហារ។

៤-កាលបរិច្ឆេទនៃការបោះផ្សាយលក់មូលបត្របំណុល។

៥-ឥណប្រតិទាន។

**ប្រការ ៥.- សំណើលក់មូលបត្របំណុលជាឯកជន**

សំណើលក់មូលបត្របំណុលដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូលបត្របំណុលជាឯកជន÷

១-សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប ហើយសំណើលក់មូលបត្រនេះមិនត្រូវធ្វើលើសពីរយៈពេល ១២ (ដប់ពីរ) ខែ ឡើយ និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមទម្រង់ ឬមធ្យោបាយណាក៏-ដោយរួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្របំណុល។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្របំណុលជាឯកជន និងបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានបំណងធ្វើសំណើលក់មូលបត្របំណុលជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះជាមុនមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលទាំងនោះត្រូវរាយការណ៍ពីលទ្ធផលឱ្យបានឆាប់ជូន **គ.ម.ក.**។

សំណើលក់មូលបត្របំណុលទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្របំណុលជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

**ប្រការ ៦.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

២-មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៣-មានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំ

នោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤-មានកម្រិតអភិបាលកិច្ចសាជីវកម្មរឹងមាំ ដោយមានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់។

៥-ទទួលបានការធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៦-ទទួលបានការបញ្ជាក់ជាមុនអំពីការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល និងការដាក់តម្លៃមូលបត្របំណុលពីទីផ្សារមូលបត្រប្រតិស្រុត ស្របតាមមាត្រា ៧ នៃអនុក្រឹត្យ។

**ប្រការ ៧.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-បំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។

២-មានវត្ថុធានា ដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

-មានវិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

-ករណីវត្ថុធានាជាអចលនវត្ថុ ឬសិទ្ធិជួលអចិន្ត្រៃយ៍ តម្លៃនៃវត្ថុធានានោះត្រូវវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៣-ចំនួនទឹកប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវមានតម្លៃអតិបរមាស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃតម្លៃវត្ថុធានា គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

**ប្រការ ៨.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-បំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ លើកលែងចំណុចទី ៥។

២-ត្រូវមានបុគ្គលធានាដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ហើយបុគ្គលធានានោះត្រូវធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

**ប្រការ ៩.-ការបោះផ្សាយលក់មូលបត្របំណុលរបស់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ**

បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយមានបំណងស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៦ ឬប្រការ ៧ ឬប្រការ ៨ នៃប្រកាសនេះលើកលែងលក្ខខណ្ឌរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃ

ប្រការ ៦ ខាងលើ តម្រូវឱ្យមានសម្រាប់រយៈពេលតែ ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងមានរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ប្រសិនមាន។

**ប្រការ ១០.- ឯកសារប្រើសម្រាប់ស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវមាន÷

១- ពាក្យស្នើសុំបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ខ- លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

គ- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ឃ- លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃបុគ្គលបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

ង- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ច- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ក្នុងករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៦ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.**។

ឆ- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

ជ- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ពី **គ.ម.ក.**។

ឈ- របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

ញ- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ ដែលមាន។

ដ- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនមាន។

ឋ- កិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញជាមួយក្រុមហ៊ុនធានាទិញមូលបត្រ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឌ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឍ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ណ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ត-ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

ថ-ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម÷

ថ.១-ភ័ស្តុតាងអំពីវត្ថុធានា។

ថ.២-វិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

ថ.៣-របាយការណ៍ស្តីពីការវាយតម្លៃទ្រព្យសកម្មដែលចេញដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

ទ-ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម÷

ទ.១-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

ទ.២-កិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

ធ-ឯកសារផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៣
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

**ប្រការ ១១.- ការដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវដាក់ពាក្យស្នើសុំដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ ដើម្បីស្នើសុំការអនុញ្ញាតលើសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដោយអនុលោមតាមមាត្រា ១២ និងមាត្រា ១៧ នៃច្បាប់

មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៣ នៃអនុក្រឹត្យ និងប្រកាសនេះ។

ឯកសារផ្ដល់ព័ត៌មានត្រូវមានយ៉ាងហោចណាស់នូវព័ត៌មានពីប្រការ ១២ ដល់ប្រការ ២២ នៃប្រកាសនេះ។ ឯកសារផ្ដល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិ និងនាយកហិរញ្ញវត្ថុរបស់បុគ្គលដាក់ពាក្យស្នើសុំ។

**ប្រការ ១២.- ឯកសារផ្ដល់ព័ត៌មាន**

ឯកសារផ្ដល់ព័ត៌មានត្រូវមានមាតិកាអប្បបរមាដូចខាងក្រោម÷

១-សេចក្ដីជូនដំណឹងចំពោះវិនិយោគិន។

២-គម្រោងពេលវេលារំពឹងទុកនៃការបោះផ្សាយ។

៣-អត្តសញ្ញាណនៃបុគ្គលពាក់ព័ន្ធនឹងការរៀបចំឯកសារផ្ដល់ព័ត៌មាន។

៤-និយមន័យ អក្សរកាត់ និងពាក្យបច្ចេកទេស។

៥-សេចក្ដីសង្ខេបឯកសារផ្ដល់ព័ត៌មាន។

៦-ព័ត៌មានស្ដីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧-ព័ត៌មានស្ដីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៨-ព័ត៌មានទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-ព័ត៌មានស្ដីពីប្រតិបត្តិការ ដោយរួមបញ្ចូលទាំងយុទ្ធសាស្ត្រ និងផែនការធុរកិច្ច។

១០-ព័ត៌មានស្ដីពីកត្តាហានិភ័យ។

១១-ព័ត៌មានស្ដីពីអភិបាលកិច្ចសាជីវកម្ម។

១២-ព័ត៌មានស្ដីពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

១៣-ព័ត៌មានហិរញ្ញវត្ថុ និង/ឬព័ត៌មានហិរញ្ញវត្ថុរួម។

១៤-ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ។

១៥-ព័ត៌មានផ្សេងៗ។

១៦-ឧបសម្ព័ន្ធ។

ឯកសារផ្ដល់ព័ត៌មានត្រូវមានសេចក្ដីបញ្ជាក់ថា *"ព័ត៌មានដែលមាននៅក្នុងឯកសារផ្ដល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បុគ្គលដាក់ពាក្យស្នើសុំ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្ដល់ព័ត៌មាននេះ"* ។

**ប្រការ ១៣.- សេចក្ដីសង្ខេបឯកសារផ្ដល់ព័ត៌មាន**

ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានសង្ខេបដូចជា÷

១-ទិដ្ឋភាពទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ។

២-ព័ត៌មានស្ដីពីយុទ្ធសាស្ត្រ និងផែនការធុរកិច្ច។

៣-ព័ត៌មានស្ដីពីអភិបាល និងភាគហ៊ុនិក។

៤-ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ។

៥-ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៦-ព័ត៌មានស្ដីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧-ព័ត៌មានស្ដីពីកត្តាហានិភ័យ។

**ប្រការ ១៤.- ព័ត៌មានស្ដីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានស្ដីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈដូចខាងក្រោម÷

១-ការពិពណ៌នាអំពីមូលបត្របំណុលដែលធ្វើសំណើលក់ ដោយបញ្ជាក់អំពីសិទ្ធិ និងលក្ខខណ្ឌដែលភ្ជាប់នឹងមូលបត្របំណុលដែលបោះផ្សាយលក់។

២-លក្ខខណ្ឌនៃមូលបត្របំណុល (Terms and Conditions)។

៣-ថ្លៃ និងអត្រាគូប៉ុង នៃមូលបត្របំណុលដែលធ្វើសំណើលក់។

៤-វិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលបត្របំណុល។

៥-ផែនការបែងចែកមូលបត្របំណុល។

៦-ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧-ការតែងតាំង សិទ្ធិអំណាច និងកាតព្វកិច្ច របស់ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

៨-លក្ខខណ្ឌក្នុងការដកភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

៩-កិច្ចប្រជុំម្ចាស់មូលបត្របំណុល។

១០-នីតិវិធី កាលបរិច្ឆេទ និងទីកន្លែង សម្រាប់ការទូទាត់គូប៉ុង និងប្រាក់ដើមនៃមូលបត្របំណុល។

១១-ព្រឹត្តិការណ៍ដែលនាំឱ្យមានការខកខានមិនបានទូទាត់សងមូលបត្របំណុល។

១២-ព័ត៌មានសំខាន់ពាក់ព័ន្ធនឹងកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញ ជាមួយក្រុមហ៊ុនធានាទិញមូលបត្រ។

១៣-ការធ្វើចំណាត់ថ្នាក់លទ្ធភាពសង។

១៤-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា ត្រូវមានព័ត៌មានបន្ថែមដូចខាងក្រោម÷

១-ទ្រព្យដែលប្រើសម្រាប់ដាក់ជាវត្ថុធានា។

២-ព័ត៌មានស្ដីពីការធានា ដែលរួមមាន លក្ខណៈ និងលក្ខខណ្ឌនៃការធានា។

ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា ត្រូវមានព័ត៌មានបន្ថែមដូចខាងក្រោម÷

១-ព័ត៌មានស្តីពីបុគ្គលធានា។

២-ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

៣-ការធ្វើចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា។

**ប្រការ ១៥.- ព័ត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។ ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវប្រើប្រាស់សម្រាប់ការធានាការចំណាយពាក់ព័ន្ធនឹងសកម្មភាពតាមកិច្ចសន្យាណាមួយរបស់បុគ្គលដាក់ពាក្យស្នើសុំ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

ករណីសំណើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីផែនការវិនិយោគនោះ។ ករណីមានផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នា ជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ១៦.- ព័ត៌មានស្តីពីបុគ្គលដាក់ពាក្យស្នើសុំ**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញព័ត៌មានស្តីពីបុគ្គលដាក់ពាក្យស្នើសុំដូចជា÷

១-ប្រវត្តិ និងការវិវត្តន៍។

២-យុទ្ធសាស្ត្រ និងផែនការអាជីវកម្ម។

៣-ព័ត៌មានស្តីពីធុរកិច្ច។

៤-ទិដ្ឋភាពទូទៅក្នុងវិស័យ។

៥-សម្ព័ន្ធភាពបុគ្គលបោះផ្សាយ។

៦-ព័ត៌មានពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែងរបស់បុគ្គលបោះផ្សាយ។

៧-ព័ត៌មានស្តីពីកាតព្វកិច្ចពន្ធ។

**ប្រការ ១៧.- ព័ត៌មានស្តីពីកត្តាហានិភ័យ**

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញព័ត៌មានស្តីពីកត្តាហានិភ័យទាំងឡាយណាដែលពាក់ព័ន្ធនឹងធុរកិច្ច

របស់បុគ្គលដាក់ពាក្យស្នើសុំ ដោយរាប់បញ្ចូលទាំងហានិភ័យដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ ហានិភ័យនៃវិស័យរបស់ធុរកិច្ច ព្រមទាំងឥទ្ធិពលដោយផ្ទាល់ ឬប្រយោលនៃហានិភ័យទាំងនេះទៅលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការធុរកិច្ច និងការវិនិយោគរបស់បុគ្គលដាក់ពាក្យស្នើសុំ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការវិភាគកត្តាហានិភ័យ និងទស្សនៈរបស់អ្នកគ្រប់គ្រង ព្រមទាំងវិធានការទប់ទល់ទៅនឹងកត្តាហានិភ័យទាំងនោះ។

**ប្រការ ១៨.- ព័ត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្មដូចខាងក្រោម÷

១-ព័ត៌មានស្តីពីភាគហ៊ុនិក។

២-ព័ត៌មានស្តីពីអភិបាល បុគ្គលិកជាន់ខ្ពស់ លេខាធិការក្រុមហ៊ុន និងបុគ្គលិកជាន់ខ្ពស់ទទួលបន្ទុកផ្តល់ព័ត៌មាន។

៣-ព័ត៌មានស្តីពីក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល។

៤-ព័ត៌មានស្តីពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់។

៥-ព័ត៌មានស្តីពីលាភការ ឬប្រាក់បំណាច់ របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

៦-ព័ត៌មានស្តីពីភាគីពាក់ព័ន្ធរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៧-ព័ត៌មានស្តីពីលក្ខខណ្ឌអភិបាលកិច្ចផ្សេងទៀតដូចមានកំណត់ក្នុងច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ១៩.- ព័ត៌មានស្តីពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីប្រតិបត្តិការសំខាន់ៗក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទ នៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងបុគ្គលដាក់ពាក្យស្នើសុំជាមួយនឹងភាគីពាក់ព័ន្ធដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ។

២-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

៣-សមាជិកគ្រួសារផ្ទាល់ (រួមមាន ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬបងប្អូនស្រី) របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលដាក់ពាក្យស្នើសុំ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលដាក់ពាក្យស្នើសុំ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៦-អភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលដាក់ពាក្យស្នើសុំ។

៧-អភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលដាក់ពាក្យស្នើសុំ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

ករណីបុគ្គលដាក់ពាក្យស្នើសុំមានប្រតិបត្តិការជាមួយអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះរបស់អភិបាល ឬភាគហ៊ុនិក។

២-ប្រភេទ និងតម្លៃ នៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំដោយផ្ទាល់ ឬដោយប្រយោល។

៣-ការពិពណ៌នាពីប្រតិបត្តិការ ដោយបញ្ជាក់ពីទំហំ លក្ខណៈ និងទំនាស់ផលប្រយោជន៍ ដែលអាចកើតមាន។

ប្រសិនបើបុគ្គលដាក់ពាក្យស្នើសុំបានទិញ ឬនឹងទិញចលនវត្ថុ និង/ឬអចលនវត្ថុពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២០.- ព័ត៌មានហិរញ្ញវត្ថុ**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួមដែលបំពេញតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២១.- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១-លទ្ធផលប្រតិបត្តិការ។

២-សន្ទនីយភាព និងប្រភពទុន។

៣-ព័ត៌មាននិន្នាការនិងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

៤-ការចាត់ចែងខ្ទង់ក្រៅតារាងតុល្យការ ប្រសិនមាន។

**ប្រការ ២២.- ឧបសម្ព័ន្ធនៃឯកសារផ្តល់ព័ត៌មាន**

ឯកសារផ្តល់ព័ត៌មានត្រូវមានភ្ជាប់មកជាមួយនូវឯកសារជាឧបសម្ព័ន្ធដូចខាងក្រោម÷

១-លក្ខខណ្ឌនៃមូលបត្របំណុល។

២-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

៣-របាយការណ៍សង្ខេបស្តីពីការវាយតម្លៃទ្រព្យសកម្ម ប្រសិនមាន។

៤-របាយការណ៍សវនកម្ម ឬរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៥-របាយការណ៍សវនកម្ម របស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលមិនទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៦-របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ដែលត្រូវធ្វើការពិនិត្យឡើងវិញដោយសវនករឯករាជ្យ ប្រសិនមាន។

៧-របាយការណ៍សង្ខេបនៃចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលបោះផ្សាយ ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៨-របាយការណ៍សង្ខេបនៃចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា។

៩-សេចក្តីថ្លែងរបស់បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈដែលបញ្ជាក់ពីភាពត្រឹមត្រូវ និងពីការគោរពតាមច្បាប់បទប្បញ្ញត្តិជាធរមាននៃឯកសារនិងព័ត៌មានដែលបានផ្តល់ជូន **គ.ម.ក.**។

១០-លិខិតយល់ព្រមឱ្យធ្វើការផ្សព្វផ្សាយសេចក្តីថ្លែង ឬរបាយការណ៍របស់អ្នកជំនាញក្នុងឯកសារផ្តល់ព័ត៌មាន ប្រសិនមាន។

### ប្រការ ២៣.- ការទទួលខុសត្រូវរបស់អ្នកជំនាញ

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ និងភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

### ប្រការ ២៤.- ការទទួលខុសត្រូវរបស់បុគ្គលបោះផ្សាយ និងភាគីពាក់ព័ន្ធចំពោះព័ត៌មានដែលមានក្នុងឯកសារផ្តល់ព័ត៌មាន

បុគ្គលដាក់ពាក្យស្នើសុំត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ ភាពពេញលេញ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

### ប្រការ ២៥.- ការផ្តល់ព័ត៌មានបន្ថែម ព័ត៌មានជំនួស សេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់ព័ត៌មានបន្ថែម ព័ត៌មានជំនួស

សេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមសំណើនេះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីបុគ្គលដាក់ពាក្យស្នើសុំមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចសម្រេចទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២៦.- ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានជាគោលការណ៍**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ ពីការអនុញ្ញាត ឬមិនអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានជាគោលការណ៍ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

**ប្រការ ២៧.- ការបដិសេធលើសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈរបស់បុគ្គលដាក់ពាក្យស្នើសុំ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១-បុគ្គលដាក់ពាក្យស្នើសុំមិនបំពេញលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ ឬប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈមិនពេញលេញ ក្លែងបន្លំ ឬនាំឱ្យយល់ខុស ឬមានរំលងព័ត៌មានសំខាន់ផ្សេងទៀត។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមមាត្រា ៤២ នៃអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបានក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧- ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨- នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក- អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ- មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩- ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំនឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

## ជំពូកទី ៤
## ការដាក់លក់មូលបត្រចំណុលជាសាធារណៈ

### ប្រការ ២៨.- ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាគោលការណ៍លើឯកសារផ្តល់ព័ត៌មាន អាចទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.** បន្ទាប់ពី÷

១- បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្របំណុលដែលការកំណត់ថ្លៃលក់មូលបត្របំណុលនេះទទួលបានការបញ្ជាក់ពីទីផ្សារមូលបត្រប្រតិស្រុត និង

២- បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្របំណុលជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើ ពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

### ប្រការ ២៩.- ការធ្វើបរិវិសកម្ម

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មមូលបត្របំណុល ត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាពសម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មមូលបត្របំណុលត្រូវបាន

បញ្ចប់ពេញលេញ បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មមូលបត្របំណុលនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជ ដោយអនុលោមតាមមាត្រា ១៨ នៃអនុក្រឹត្យ។ បញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មមូលបត្របំណុលត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មនឹងត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣២ ប្រការ ៣៣ និងប្រការ ៣៤ នៃប្រកាសនេះ។

### ប្រការ ៣០.- ការធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្មមូលបត្របំណុល ករណីមូលបត្របំណុលធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់បុគ្គលបោះផ្សាយ ត្រូវធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ទៅឱ្យបុគ្គលបោះផ្សាយក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់មក **គ.ម.ក.** ភ្លាម។

### ប្រការ ៣១.- ការបែងចែកមូលបត្របំណុល

ក្រុមហ៊ុនមូលបត្រ ត្រូវចែកចាយមូលបត្របំណុលក្នុងថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជី។

បុគ្គលបោះផ្សាយ ភ្នាក់ងារបញ្ជិកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបែងចែក និងបញ្ជូនមូលបត្របំណុលទៅឱ្យអ្នកដែលបានធ្វើបរិវិសកម្មដោយជោគជ័យក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្មមូលបត្របំណុល។

### ប្រការ ៣២.- ការព្យួរឯកសារផ្តល់ព័ត៌មានដែលចុះបញ្ជីរួច

ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមមាត្រា ២១ នៃច្បាប់។ ករណីនេះ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួល

ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុល និងត្រូវជូនដំណឹងភ្លាមអំពីការព្យួរនេះទៅដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មមូលបត្របំណុលថាមានសិទ្ធិអាចដកស្ទីការដែលបានធ្វើឡើងចំពោះសំណើលក់មូលបត្របំណុលជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលឡើងវិញបន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរឯកសារផ្តល់ព័ត៌មានត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៣.- ការផ្សព្វផ្សាយជាសាធារណៈអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន**

បុគ្គលបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-កាលបរិច្ឆេទនៃការសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀប នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ប្រាក់រួច ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះ ត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៤.- ការធ្វើបរិវិសកម្មមូលបត្របំណុលមិនបានជោគជ័យ**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន អាចត្រូវបានលុបចោលផងដែរក្នុងករណីដែលការធ្វើបរិវិសកម្មមូលបត្របំណុលមិនបានជោគជ័យ។

**ប្រការ ៣៥.- ការរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្របំណុលជាសាធារណៈទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជអំពីចំនួនទឹកប្រាក់នៅក្នុងគណនីដាច់ដោយឡែកដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះនៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៣៦.- ការបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត**

បុគ្គលបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី ៥
# ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៣៧.- ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងសំណើបោះផ្សាយ និងការលក់មូលបត្របំណុលជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន បុគ្គលបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន បុគ្គលបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្ង និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

បុគ្គលបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ព័ត៌មានសម្រាប់ផ្តល់ឱ្យសាធារណជន នៅបុគ្គលបោះផ្សាយក្រុមហ៊ុនមូលបត្រ និងប្រតិបត្តិករទីផ្សារមូលបត្រ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៨.- ការជូនដំណឹងជាសាធារណៈ**

ក្នុងរយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្មមូលបត្របំណុល បុគ្គលបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ពី **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀតរបស់បុគ្គលបោះផ្សាយ។

២-ចំនួន និងប្រភេទមូលបត្របំណុលដែលត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុល។

៤-កាលបរិច្ឆេទនៃការធ្វើបរិវិសកម្មមូលបត្របំណុល។

៥- សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជីពី **គ.ម.ក.**។

៦- សេចក្តីថ្លែងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកលើឯកសារសំណើលក់មូលបត្របំណុល។

៧- សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្របំណុលឡើយ។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមលើនេះ បុគ្គលបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែបុគ្គលបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់អេឡិចត្រូនិច ឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៦
## លក្ខខណ្ឌតម្រូវក្រោយពេលបោះផ្សាយលក់មូលបត្របំណុល

### ប្រការ ៣៩.- ព័ត៌មានដែលត្រូវបង្ហាញ

បុគ្គលបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម និងត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ករណីមានព្រឹត្តិការណ៍ដូចខាងក្រោម÷

១- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំកិច្ចប្រជុំម្ចាស់មូលបត្របំណុល ដោយលម្អិតអំពីទីកន្លែង ពេលវេលា របៀបវារៈប្រជុំ និងលក្ខខណ្ឌសម្រាប់ការចូលរួម និងអ្នកចូលរួម។

២- សេចក្តីសម្រេចរបស់ម្ចាស់មូលបត្របំណុលក្រោយពេលកិច្ចប្រជុំ។

៣- នៅពេលមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន។

៤- នៅពេលដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពបង់ការប្រាក់ និង/ឬប្រាក់ដើមទៅតាមរយៈពេលនៃការទូទាត់ដូចមានចែងក្នុងលក្ខខណ្ឌនៃមូលបត្របំណុល។

៥- នៅពេលមានការបង់ការប្រាក់។

៦- នៅពេលមានគម្រោងធ្វើការពន្យារពេលបង់ការប្រាក់នៃមូលបត្របំណុល។

៧- នៅពេលដែលបុគ្គលបោះផ្សាយទិញមកវិញនូវមូលបត្របំណុលមួយផ្នែក ឬទាំងអស់របស់ខ្លួនពីទីផ្សារបន្ទាប់។

៨- រាយការណ៍ជូន **គ.ម.ក.** ជាប្រចាំឆ្នាំបន្ទាប់ពីទទួលបានរបាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង

ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** នូវការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុលដូចមានចែងក្នុងចំណុចទី ៥ ប្រការ ៦ នៃប្រកាសនេះ រហូតដល់ការសងត្រឡប់ប្រាក់ដើមបញ្ចប់។ អគ្គនាយកនៃ**គ.ម.ក.** អាចលើកលែងនូវការរាយការណ៍អំពីការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុលដោយពិចារណាពីភាពចាំបាច់នៃព័ត៌មានអំពីការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុលចំពោះវិនិយោគិន។

៩-ករណីមានការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

១០-ករណីមានការផ្លាស់ប្តូរ ឬកែប្រែលក្ខខណ្ឌ និង/ឬទ្រព្យធានានៃមូលបត្របំណុលដោយត្រូវដាក់ជូន **គ.ម.ក.** នូវឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។ ការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំម្ចាស់មូលបត្របំណុលដោយត្រូវបញ្ជាក់ពីមូលហេតុនៃការផ្លាស់ប្តូរ ឬការកែប្រែ និងវិបាកដែលកើតមាន ឬអាចនឹងកើតមានចំពោះការសម្រេចចិត្តរបស់ម្ចាស់មូលបត្របំណុល។

១១-នៅពេលដែលគណនីរបស់បុគ្គលបោះផ្សាយនៅធនាគារត្រូវបានបង្កក ឬគណនីរបស់បុគ្គលបោះផ្សាយត្រូវបានអនុញ្ញាតឱ្យដំណើរការវិញបន្ទាប់ពីមានការបង្កកគណនីនោះ។

១២-នៅពេលមានព័ត៌មានដែលអាចមានឥទ្ធិពលលើបុគ្គលបោះផ្សាយ និង/ឬមានឥទ្ធិពលលើទំនុកចិត្តឥណទាន (Credit Worthiness) របស់បុគ្គលបោះផ្សាយ។

### ប្រការ ៤០.- កាតព្វកិច្ចរក្សាកម្រិតអនុបាតហិរញ្ញវត្ថុ

បុគ្គលបោះផ្សាយត្រូវរក្សាឱ្យបាននូវកម្រិតអនុបាតហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការ ៤៨ នៃប្រកាសនេះ។

### ប្រការ ៤១.- កាតព្វកិច្ចរាយការណ៍អំពីការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

បុគ្គលបោះផ្សាយត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** អំពីការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ហើយបន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល បុគ្គលបោះផ្សាយត្រូវដាក់ជូន **គ.ម.ក.** នូវកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលថ្មីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទតែងតាំង។

## ជំពូកទី ៧
## កម្រៃសេវាក្នុងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

### ប្រការ ៤២.- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវបង់ថ្លៃពាក្យស្នើសុំ និង

សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១-ជាប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ។

២-ជាប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម។

**ប្រការ ៤៣.- សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ត្រូវបង់សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួសនៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១-ជាប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ។

២-ជាប្រាក់ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម។

**ប្រការ ៤៤.- សោហ៊ុយសិក្សាចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ត្រូវបង់សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានឡើងវិញឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១-ជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ។

២-ជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម។

**ប្រការ ៤៥.- ការមិនសងត្រឡប់វិញនូវថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារ**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារ ដូចមានចែងក្នុងប្រការ ៤២ ប្រការ ៤៣ និងប្រការ ៤៤ នៃប្រកាសនេះមិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយទោះជាឯកសារផ្តល់ព័ត៌មានមិនទទួលបានការអនុញ្ញាត និងចុះបញ្ជីក៏ដោយ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

### ប្រការ ៤៦.- វិធានការរដ្ឋបាល

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ការព្រមាន ឬដាស់តឿន។

២-ការស្នើឱ្យដាក់អនុស្សារណៈ។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៥-ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ឬការចែកចាយបន្ទាប់។

### ប្រការ ៤៧.- វិធានការផាកពិន័យអន្តរការណ៍

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា បុគ្គលបោះផ្សាយ ឬក្រុមហ៊ុនធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

### ប្រការ ៤៨.- លក្ខខណ្ឌលើកលែង

ករណីពុំទាន់មានភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ពី **គ.ម.ក.** បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍អនុបាតហិរញ្ញវត្ថុសំខាន់ៗដែលមានដូចជា អនុបាតចំណេញភាព និងលំហូរសាច់ប្រាក់ (Profitability and Cash Flow Ratio) អនុបាតឡេវើរ៉េច (Leverage Ratio) និងអនុបាតលទ្ធភាពសង (Coverage Ratio) ជាដើម ដែលមានការបញ្ជាក់ពីភាពសមស្របដោយអ្នកជំនាញ ឬក្រុមហ៊ុនធានាទិញមូលបត្ររបស់បុគ្គលបោះផ្សាយ។

ករណីពុំទាន់មានភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលដែលទទួលស្គាល់ពី **គ.ម.ក.** បុគ្គលបោះ-ផ្សាយអាចជ្រើសរើសភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ដើម្បីផ្តល់សេវាជាប់ពាក់ព័ន្ធនឹងការចុះបញ្ជីមូលបត្របំណុល ការផ្ទេរមូលបត្របំណុល និងការទូទាត់ជូនម្ចាស់មូលបត្របំណុល។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

### ប្រការ ៤៩.- ការចេញគោលការណ៍ណែនាំ

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

### ប្រការ ៥០.- បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

### ប្រការ ៥១.- ការអនុវត្ត

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៧

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជក្រម

នស/រកម/០១០៧/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រ កត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

7/13

# ច្បាប់

# ស្តីពី

# មូលបត្ររដ្ឋ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់ការបោះផ្សាយ និងការគ្រប់គ្រងមូលបត្ររដ្ឋប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាកាតព្វកិច្ចទូទាត់សងចំពោះតម្រូវការហិរញ្ញប្បទានរបស់រដ្ឋ ត្រូវចំណាយក្នុងតម្លៃមួយដែលទាបបំផុត សម្រាប់មូលបត្ររយៈពេលមធ្យម ឬ វែង ហើយត្រូវសមស្របទៅតាមកម្រិតហានិភ័យ ដែលអាចកើតមានឡើង និងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ មានដូចខាងក្រោម៖

១-**មូលបត្ររដ្ឋ** សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅក្រោមច្បាប់នេះ រួមមាន៖

ក-ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ ។

ខ-សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ ។

គ-សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអតិផរណា ឬ អត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។

ឃ-មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ ។

ង-មូលបត្ររដ្ឋផ្សេងៗដទៃទៀត ។

មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រ ដែលបោះផ្សាយដោយអាជ្ញាធរខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ឬ ការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់នេះទេ ។

**២-មូលបត្ររដ្ឋមិនអាចជួញដូរបាន** សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឱ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬ សន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និងការកំណត់របស់ប្រកាសដែលដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនពេញសិទ្ធិមានសិទ្ធិស្នើសុំការទូទាត់សងមុនកាលបរិច្ឆេទ ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ ។

**៣-វិញ្ញាបនបត្រមូលបត្ររដ្ឋ** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ដោយមានការធានានូវការបំពេញកាតព្វកិច្ចទូទាត់ពេញលេញពីរាជរដ្ឋាភិបាលកម្ពុ-ជា ដោយមានចែងអំពីរយៈពេល លក្ខខណ្ឌ និងកាតព្វកិច្ចផ្សេងៗទៀតរបស់មូលបត្រនោះ ។

**៤-គណនី** សំដៅដល់គណនីទូទៅ និងគណនីពិសេសរបស់រតនាគារជាតិដូចមានចែងនៅក្នុងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងគណនីពិសេសផ្សេងទៀត ដែលបានបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**៥-សន្តតិជន** សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតក-ជនតាមរយៈសន្តតិកម្ម ។

**៦-សន្តតិកម្ម** សំដៅដល់ការផ្ទេរសិទ្ធិ និងករណីកិច្ចរបស់មតកជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់ ។

**៧-មូលនិធិផ្សេងៗ** សំដៅដល់មូលនិធិពិសេស ដែលបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ មូលនិធិនេះ ត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការមួយជាក់លាក់ក្នុងគោលបំណងច្បាស់លាស់ ហើយប្រតិបត្តិការនៃមូលនិធិនេះ មិនពាក់ព័ន្ធនឹងថវិកាចំណូល-ចំណាយរបស់រាជរដ្ឋាភិបាល ដែលស្ថិតនៅក្រោមច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នោះទេ លើកលែងតែមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ហៅកាត់ថា **ម.គ.ម.រ.** ដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។

**៨-មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ (ម.គ.ម.រ.)** សំដៅដល់ប្រាក់ដែលផ្តល់ឱ្យ

ដោយរាជរដ្ឋាភិបាល និងប្រាក់ដែលបានមកពីស្ថាប័នឯកជន និងសាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់កិច្ចការទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋទាំងឡាយណាដែលបានបោះផ្សាយរួច ។ មូលនិធិនេះ មិនមែនជាមូលនិធិដែលបង្កើតឡើងក្នុងគោលដៅមនុស្សធម៌នោះទេ ។

**៩-ប្រធានស្ថាប័នរដ្ឋបាលកណ្តាល** សំដៅដល់ថ្នាក់ដឹកនាំក្រសួងនានា និងថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀត ដែលទទួលបានសិទ្ធិស្របច្បាប់ និងមានតួនាទីស្មើក្រសួងនានា ។

**១០-កាលប្រតិទាន** សំដៅដល់កាលបរិច្ឆេទមូលបត្រត្រូវដល់កាលកំណត់សង ។

**១១-រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**១២-ច្បាប់ធនាគារជាតិ** សំដៅដល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ។

**១៣-ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២

## ការបោះផ្សាយ និង ការដាក់លក់មូលបត្ររដ្ឋ

**មាត្រា ៣.-**

ការបោះផ្សាយ និងការដាក់លក់មូលបត្ររដ្ឋ ត្រូវអនុវត្តដូចខាងក្រោម :

ក-មានតែរដ្ឋមន្ត្រីម្នាក់ប៉ុណ្ណោះ ដែលអាចបោះផ្សាយមូលបត្ររដ្ឋក្នុងក្របខ័ណ្ឌចំណាយនៃ ច.គ.ម.វ. ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។ រដ្ឋមន្ត្រីអាចទិញ ទូទាត់សង និងផ្តល់ប្រាក់វិញនូវរាល់មូលបត្ររដ្ឋដែលដល់ ឬ មិនទាន់ដល់កាលប្រតិទាន ។ ប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋត្រូវបានធានាដោយគ្មានលក្ខខណ្ឌពីរាជរដ្ឋាភិបាល ។

ﾀ

ខ-រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធ ដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រី ត្រូវទទួលបន្ទុករាល់កិច្ចការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ លើកលែងតែរដ្ឋមន្ត្រីបានផ្ទេរសិទ្ធិអំណាចជាលាយលក្ខណ៍អក្សរទៅឱ្យស្ថាប័នរដ្ឋដទៃទៀត ។

គ-ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ធនាគារជាតិ រាល់ការងារបច្ចេកទេស និងប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ដោយមានការណែនាំពីរដ្ឋមន្ត្រី ដែលមានចែងនៅក្នុងអនុក្រឹត្យ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត ។ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវបង្កើតនូវនីតិវិធីដើម្បីបែងចែកឱ្យដាច់ដោយឡែកពីគ្នានូវមុខងារប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ និងមុខងារគោលនយោបាយរូបិយវត្ថុ ។

ប្រសិនបើប្រធានស្ថាប័នរដ្ឋបាលកណ្តាលណាមួយ ដែលគ្រប់គ្រងគណនី និងមូលនិធិដទៃទៀត ដែលស្ថិតនៅក្រោមច្បាប់ផ្សេង ហើយមានបំណងបោះផ្សាយមូលបត្ររដ្ឋ ត្រូវធ្វើសំណើទៅរដ្ឋមន្ត្រីអំពីការបោះផ្សាយមូលបត្រនោះ ។

អាជ្ញាធរខេត្ត-ក្រុង គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈមិនអាចបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដោយពុំមានការយល់ព្រមពីរដ្ឋមន្ត្រីជាមុននោះទេ ។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយជារូបិយវត្ថុជាតិ ឬ ជារូបិយប័ណ្ណបរទេស ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ត្រូវបានអនុម័តដោយរដ្ឋសភា ។

នាយករដ្ឋមន្ត្រី ត្រូវធ្វើជូនរដ្ឋសភានូវចំនួនទឹកប្រាក់សរុបនៃមូលបត្ររដ្ឋ ដែលត្រូវបោះផ្សាយ ដែលជាផ្នែកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ។

នាយករដ្ឋមន្ត្រី អាចធ្វើសំណើទៅរដ្ឋសភា ដើម្បីសុំការអនុម័តលើការបោះផ្សាយមូលបត្ររដ្ឋបន្ថែម ទៅលើចំនួនទឹកប្រាក់សរុប ដែលរដ្ឋសភាបានអនុម័តរួចហើយ ។ ជាមួយនឹងសំណើនេះ នាយករដ្ឋមន្ត្រី ត្រូវផ្តល់នូវការពន្យល់ឱ្យបានច្បាស់លាស់នូវហេតុផលដ៏ចាំបាច់នៃការបោះផ្សាយមូលបត្របន្ថែមនេះ ។

**មាត្រា ៥.-**

មូលបត្ររដ្ឋត្រូវបានបោះផ្សាយលក់ជាសាធារណៈ នៅលើទីផ្សារក្នុងតម្លៃសមស្រប តាមវិសាលភាពដែលអាចធ្វើទៅបាន ព្រមទាំងផ្តល់និកាសស្មើភាពគ្នាដល់សាធារណជន ក្នុងការចូលរួមទិញមូលបត្រទាំងនេះ ។

រដ្ឋមន្ត្រីអាចសម្រេចលើការបោះផ្សាយមូលបត្ររដ្ឋ តាមវិធីសាស្ត្រផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលកំណត់ក្នុងអនុក្រឹត្យ ។ ការបោះផ្សាយមូលបត្ររដ្ឋរួមទាំងរបៀបបោះផ្សាយ និងអត្រាការប្រាក់ត្រូវកំណត់ក្នុងអនុក្រឹត្យ ។

មូលបត្ររដ្ឋត្រូវបានដាក់លក់ជាសាធារណៈ នៅទីផ្សារដំបូងដោយការដេញថ្លៃ ។ នៅពេលដែលមានមូលបត្ររដ្ឋនៅសល់ពីការលក់ដោយការដេញថ្លៃ រដ្ឋមន្ត្រីអាចប្រើប្រាស់គណនីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទិញមូលបត្រទាំងនោះមកវិញតាមលក្ខខណ្ឌ និង រយៈពេលដូចដែលបានលក់តាមរយៈការដេញថ្លៃ ។

**មាត្រា ៦.-**

រាល់បញ្ហាទាក់ទងនឹងការគ្រប់គ្រងវិញ្ញាបនប័ត្រមូលបត្ររដ្ឋ ការចុះបញ្ជី និងការទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ក្នុងអនុក្រឹត្យ ។

## ជំពូកទី ៣
## មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ

**មាត្រា ៧.-**

រាជរដ្ឋាភិបាលត្រូវបង្កើត ម.គ.ម.រ. ដើម្បីគ្រប់គ្រងការបោះផ្សាយ និងការទូទាត់សងមូលបត្ររដ្ឋ ប្រកបដោយប្រសិទ្ធភាព និងបញ្ហាពាក់ព័ន្ធផ្សេងទៀត ។

ម.គ.ម.រ. អាចធ្វើប្រតិបត្តិការ ក្រៅនីតិវិធីហិរញ្ញវត្ថុ ដែលកំណត់ដោយច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

៖

8/13

**មាត្រា ៨.-**

រដ្ឋមន្ត្រីដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រង **ម.គ.ម.រ.** ។

រដ្ឋមន្ត្រីប្រគល់សិទ្ធិ ជូនទេសាភិបាលធនាគារជាតិនៃកម្ពុជា ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រង **ម.គ.ម.រ.** ។

ក្នុងករណីមានការប្រគល់សិទ្ធិ ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនទៅរដ្ឋមន្ត្រីអំពីការទូទាត់លើគណនីរបស់ **ម.គ.ម.រ.** នៅមុនដំណាច់ខែកុម្ភៈនៃឆ្នាំសារពើពន្ធបន្ទាប់ ។ របាយការណ៍ប្រចាំឆ្នាំនេះ ត្រូវមានចំណុចដូចខាងក្រោម :

-របាយការណ៍ស្តីពីស្ថានភាពទូទៅ និងការវិភាគលើ **ម.គ.ម.រ.**

-តារាងតុល្យការ

-របាយការណ៍ចំណូល-ចំណាយ

-របាយការណ៍លំហូរសាច់ប្រាក់ និងឯកសារដើមផ្សេងៗ

-ឯកសារពាក់ព័ន្ធផ្សេងៗដែលទាក់ទងនឹងការទូទាត់លើគណនីរបស់ **ម.គ.ម.រ.** ។

បញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងប្រតិបត្តិការ និងការគ្រប់គ្រងនៃ **ម.គ.ម.រ.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.-**

·ប្រភពហិរញ្ញវត្ថុរបស់ **ម.គ.ម.រ.** អាចបានមកពីប្រភពចំណូលដូចខាងក្រោម :

-ចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋ

-ចំណូលការប្រាក់ដែលបានពីគណនីប្រាក់បញ្ញើ និងមូលនិធិផ្សេងទៀត

-អតិរេកនៃការទូទាត់ប្រចាំឆ្នាំ

-វិភាគទានពីរាជរដ្ឋាភិបាល

-ចំណូលបានពីប្រតិបត្តិការផ្សេងៗរបស់ **ម.គ.ម.រ.** ។

**ម.គ.ម.រ.** ត្រូវបានប្រើប្រាស់ដើម្បីបំពេញគោលដៅដូចខាងក្រោម :

-ទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋដែលបានបោះផ្សាយ

-ដាក់ទៅក្នុងគណនី និងក្នុងមូលនិធិផ្សេងៗនូវប្រាក់ចំណូលរបស់ ម.គ.ម.រ.

-ទូទាត់សងរាល់ចំណាយចាំបាច់នៃការគ្រប់គ្រង ម.គ.ម.រ.

-អាចទិញមូលបត្ររដ្ឋ និងសញ្ញាប័ណ្ណមហាជនផ្សេងៗ និងដាក់ប្រាក់បញ្ញើរយៈពេលខ្លី ឬ ផ្តល់ឥណទានរយៈពេលខ្លីទៅឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនានា ។ រដ្ឋមន្ត្រីអាចចេញប្រកាសឱ្យប្រើប្រាស់សាច់ប្រាក់ ដែលនៅសល់ក្នុងគោលបំណងផ្សេងៗ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីត្រូវធ្វើផែនការប្រតិបត្តិការរបស់ ម.គ.ម.រ. ហៅថា "ផែនការប្រតិបត្តិការ" ដោយលើកមកពិចារណានូវតម្រូវការចាំបាច់នៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ ។

រដ្ឋមន្ត្រីត្រូវដាក់ផែនការប្រតិបត្តិការនេះ ជូនទៅគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សានិងសម្រេច ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ និងតួនាទីរបស់រដ្ឋក្នុងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ

**មាត្រា ១១.-**

អាជ្ញាធរសវនកម្មជាតិ អាចត្រួតពិនិត្យនូវរាល់បញ្ហាទាក់ទងនឹងមូលបត្ររដ្ឋនានារបស់ក្រសួង និងរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានផ្ទេរសិទ្ធិដោយរដ្ឋមន្ត្រី ដោយអនុលោមតាមច្បាប់នេះ ។

នាយកដ្ឋាន ឬ អង្គភាពទទួលបន្ទុកត្រួតពិនិត្យរបស់ក្រសួង និងធនាគារជាតិនៃកម្ពុជាត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើធនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធរបស់ខ្លួន ដែលទទួល

4

ខុសត្រូវទូទៅរាល់បញ្ហាទាក់ទងនឹងមូលបត្ររដ្ឋទៅតាមការទទួលខុសត្រូវរៀងៗខ្លួន ហើយត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី និងទេសាភិបាលធនាគារជាតិនៃកម្ពុជា ពិនិត្យ និងផ្តល់អនុសាសន៍ ។

**មាត្រា ១២.-**

គណៈកម្មាធិការចម្រុះសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្ររដ្ឋ អាចត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីដើម្បីពិភាក្សា និងសម្រេចលើគោលនយោបាយសំខាន់ៗដែលទាក់ទងនឹងការអភិវឌ្ឍន៍ទីផ្សារមូលបត្ររដ្ឋ ។

គណៈកម្មាធិការចម្រុះនេះត្រូវមានសមាសភាពដូចតទៅ :

-រដ្ឋមន្ត្រី

-ទេសាភិបាលធនាគារជាតិនៃកម្ពុជា

-ប្រធានស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀតដែលពាក់ព័ន្ធ ប្រសិនបើមាន

-ជំនាញការមកពីផ្នែកឯកជន ។

រដ្ឋមន្ត្រីអាចបង្កើតក្រុមការងារជំនាញ ដើម្បីសិក្សាពីវិធីសាស្ត្រ និងមធ្យោបាយសម្រាប់អភិវឌ្ឍទីផ្សារដំបូង និងទីផ្សារបន្ទាប់នៃមូលបត្ររដ្ឋឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់អនុសាសន៍ជូនដល់រដ្ឋមន្ត្រី ។

**មាត្រា ១៣.-**

បន្ទាប់ពីបានពិភាក្សា និងសម្រេចពីគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីត្រូវដាក់របាយការណ៍ប្រចាំឆ្នាំ ស្តីពីប្រតិបត្តិការបំណុលសាធារណៈរបស់ក្រសួងក្នុងនោះរួមមានព័ត៌មានទាំងអស់ ដែលទាក់ទងនឹងបំណុលសាធារណៈសរុប បំណុលសាធារណៈសុទ្ធ ឥណប្រតិទានតារាងពេលវេលាសងប្រាក់ដើម និងការប្រាក់ ព័ត៌មានម្ចាស់បំណុលសាធារណៈ ប្រតិបត្តិ-ការរបស់ម.គ.ម.វ. និងផ្តល់សេចក្តីពន្យល់លើយុទ្ធសាស្ត្រហិរញ្ញប្បទាន សម្រាប់ឆ្នាំសារពើ-ពន្ធបច្ចុប្បន្ន និង សម្រាប់ ៥ឆ្នាំ (ប្រាំឆ្នាំ) សារពើពន្ធបន្តបន្ទាប់ជូនទៅរដ្ឋសភា ។

**មាត្រា ១៤.-**

ក្នុងករណីចាំបាច់ដើម្បីឱ្យការបោះផ្សាយ និងការគ្រប់គ្រងមូលបត្ររដ្ឋ ប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ រដ្ឋមន្ត្រីអាចស្នើសុំប្រធានស្ថាប័នរដ្ឋបាលកណ្តាលបង្ហាញនូវឯកសារពាក់ព័ន្ធផ្សេងៗ ។

បន្ទាប់ពីទទួលបានការស្នើសុំឱ្យបង្ហាញនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌទី ១ ប្រធានស្ថាប័នរដ្ឋបាលកណ្តាលពាក់ព័ន្ធ ត្រូវអនុវត្តតាមការស្នើសុំនោះ លើកលែងតែមានមូលហេតុពិសេសផ្សេងទៀត ។

**មាត្រា ១៥.-**

រាជរដ្ឋាភិបាលមិនត្រូវបង្កើតកិច្ចសន្យា ឬ ការបញ្ជាំណាមួយ ឬ ការដាក់ទ្រព្យសកម្មសាធារណៈ ឬ ធនធានផ្សេងៗ ដើម្បីធានាការបោះផ្សាយមូលបត្ររដ្ឋឡើយ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត ។ ទ្រព្យសកម្មសាធារណៈ និងប្រាក់ចំណូលរបស់រដ្ឋ ត្រូវបានការពារពីការរឹបអូស និងការហាមឃាត់ផ្សេងៗ ។

សិទ្ធិប្តឹងទាមទារសំណងនូវចំនួនទឹកប្រាក់នៃមូលបត្ររដ្ឋត្រូវអនុវត្តក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ ចំពោះប្រាក់ដើម និង ២ (ពីរ)ឆ្នាំ ចំពោះការប្រាក់គិតចាប់ពីកាលបរិច្ឆេទឥណ-ប្រតិទាន ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៦.-**

បុគ្គលដែលក្លែងមូលបត្ររដ្ឋ តាមរូបភាពណាក៏ដោយ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរ-មាន ។

**មាត្រា ១៧.-**

បុគ្គល ឬមន្ត្រី ដែលពាក់ព័ន្ធក្នុងការអនុវត្តដេញថ្លៃ ឬ ពាក់ព័ន្ធក្នុងកាតព្វកិច្ចផ្សេងទៀត ហើយមិនបានបំពេញត្រឹមត្រូវតាមការកំណត់របស់ច្បាប់នេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា ១៨.-**

ក្នុងករណីមូលបត្ររដ្ឋណាមួយ ដែលបានបោះផ្សាយហើយ មិនទាន់បានទូទាត់សង ដោយគិតត្រឹមថ្ងៃដែលច្បាប់នេះចូលជាធរមាន មូលបត្ររដ្ឋទាំងនោះ ត្រូវតែទទួលបានការទូទាត់សងតាមគណនី និងនីតិវិធីដែលបានបោះផ្សាយ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នសរកម.០១០៧.០១៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ: ៣១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:..................................គ.ម.ក

# កាលបរិច្ឆេទសំខាន់ៗ
# នៃដំណើរការបង្កើតទីផ្សារមូលបត្រនៅកម្ពុជា

វិស័យហិរញ្ញវត្ថុ ដែលរួមមានវិស័យធនាគារ វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ គឺជាសរសៃឈាមសេដ្ឋកិច្ច ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវភាពរស់រានរបស់សេដ្ឋកិច្ចក្នុងប្រទេសមួយ។ ដោយមើលឃើញពីភាពចាំបាច់នៃតួនាទីវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យនេះ ដោយបានដាក់ចេញនូវ "**ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០**" ហើយបានធ្វើបច្ចុប្បន្នកម្មទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥**" និងទើបត្រូវបានធ្វើបច្ចុប្បន្នភាពទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០**"។ "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២**" របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យនេះផងដែរ។ តាមរយៈ ផែនការយុទ្ធ-សាស្ត្រទាំងនេះ គម្រោងនៃការបង្កើតទីផ្សារមូលបត្រត្រូវបានបង្កើតឡើង ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឱ្យរឹងមាំ ដោយផ្អែកលើយន្តការទីផ្សារ ដើម្បីគាំទ្រប្រកបដោយសមធម៌ និងចីរភាពនូវការគៀរគរ និងបែងចែកធនធានហិរញ្ញវត្ថុ។ នៅក្នុងដំណើរការនៃការបង្កើតទីផ្សារមូលបត្រនៅកម្ពុជា មានដំណាក់កាលដូចតទៅ÷

**១.** ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១: អនុម័ត "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០១-២០១០" ដោយសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**២.** ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦: ចុះអនុស្សារណៈយោគយល់គ្នា រវាងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ដុក ស៊ូ ហាន់** (Duck-Soo Han) រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកូរ៉េ នៅទីក្រុង Hyderabad ប្រទេសឥណ្ឌា ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន+៣ ជាប់គ្នានឹងកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដែលតាមរយៈអនុស្សារណៈនេះ ភាគីទាំងពីរបានព្រមព្រៀងសហការគ្នាដើម្បីលើកស្ទួយដល់ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

**៣**. ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦: ចុះអនុស្សារណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្កើតទីផ្សារមូលបត្ររវាងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX)។

**៤**. ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧: អនុម័ត "យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥" ដែលកើតចេញពីការធ្វើបច្ចុប្បន្នកម្មលើ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០" ដោយសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**៥**. ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧: ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវគម្រោងបង្កើតទីផ្សារមូលបត្រនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

**៦**. ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧: ដាក់ឱ្យអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដោយព្រះរាជក្រមរបស់ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**៧**. ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨: ដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**៨**. ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨: តែងតាំងមន្ត្រីថ្នាក់ដឹកនាំបច្ចេកទេសជាន់ខ្ពស់នៃគណៈកម្មការមូលបត្រកម្ពុជា ជាអគ្គនាយក និងអគ្គនាយករង ដោយព្រះរាជក្រឹត្យរបស់ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

**៩**. ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨: តែងតាំងមន្ត្រីថ្នាក់ដឹកនាំបច្ចេកទេសនៃគណៈកម្មការមូលបត្រកម្ពុជា ជាប្រធាននាយកដ្ឋាន និងអង្គភាព នៃគណៈកម្មការមូលបត្រកម្ពុជា ដោយអនុក្រឹត្យរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**១០**. ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩: តែងតាំងសមាសភាពគណៈកម្មការមូលបត្រកម្ពុជា ដែលមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធានគណៈកម្មការមូលបត្រកម្ពុជាដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**១១**. ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩: ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួមទុនស្តីពី ការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Joint-Venture Agreement on the Establishment of the Cambodia Securities Exchange Co., Ltd) រវាងឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX)។

**១២.** ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩: ដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

**១៣.** ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩: សម្ពោធទីស្នាក់ការបណ្តោះអាសន្នរបស់គណៈកម្មការមូលបត្រកម្ពុជា ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា និងបើកកិច្ចប្រជុំលើកទី១ របស់គណៈ-កម្មការមូលបត្រកម្ពុជា។

**១៤.** ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០: ពិធីប្រគល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។

**១៥.** ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១: ប្រារព្ធពិធីផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ, ផ្តល់ការទទួលស្គាល់ធនាគារធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ, ផ្តល់ការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ និងផ្តល់ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យផ្តល់សេវាក្នុងវិស័យមូលបត្រក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។

**១៦.** ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១: សម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។

**១៧.** ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២: គណៈកម្មការមូលបត្រកម្ពុជាផ្តល់ការអនុញ្ញាត និងចុះបញ្ជីជាគោលការណ៍នូវឯកសារផ្តល់ព័ត៌មានរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង (IPO) នៅព្រះរាជាណាចក្រកម្ពុជា។

**១៨.** ចាប់ពីថ្ងៃទី ២៩ ខែ កុម្ភៈ ដល់ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២: ធ្វើប៊ុកបៀលឌីង (Book-Building) មូលបត្រកម្មសិទ្ធិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

**១៩.** ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២: គណៈកម្មការមូលបត្រកម្ពុជាផ្តល់ការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរនូវឯកសារផ្តល់ព័ត៌មានរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង (IPO)។

**២០.** ចាប់ពីថ្ងៃទី ២៩ ខែ មីនា ដល់ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២: ធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅក្នុងទីផ្សារដំបូង។

**២១.** ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២: ធ្វើការបែងចែកមូលបត្រកម្មសិទ្ធិ និងការប្រកាសពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

**២២.** **នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩:០៩ នាទីព្រឹក:** ប្រកាសបើកជាផ្លូវការនូវការជួញដូរមូលបត្រកម្មសិទ្ធិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាជាប្រវត្តិសាស្ត្រ តាមរយៈសារវីដេអូដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានតំណាងដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។

<u>*សមាសភាពគណៈកម្មការមូលបត្រកម្ពុជា:*</u>

- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
- លោកជំទាវ **នាង ច័ន្ទថាណា** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ជាសមាជិក
- ឯកឧត្តម **ការ ច័ន្ទមេត្តា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក
- ឯកឧត្តម **កើត រិទ្ធ** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាសមាជិក
- ឯកឧត្តម **គីម រ័ត្នវិសិដ្ឋ** ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
- ឯកឧត្តមបណ្ឌិត **មិញ ចាន់កុសល** អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ជាសមាជិក
- លោកបណ្ឌិត **សំ យន្នី** តំណាងវិជ្ជាជីវៈឯកជន ជាសមាជិក
- លោកបណ្ឌិត **សំ សុខុម** តំណាងវិជ្ជាជីវៈឯកជន ជាសមាជិក

<u>*សមាសភាពថ្នាក់ដឹកនាំបច្ចេកទេសនៃគណៈកម្មការមូលបត្រកម្ពុជា:*</u>

- ឯកឧត្តមបណ្ឌិត **មិញ ចាន់កុសល** អគ្គនាយក
- ឯកឧត្តម **ស៊ូ សុជាតិ** អគ្គនាយករង
- ឯកឧត្តម **កៅ ថាច** អគ្គនាយករង
- ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយករង ជំនួសឯកឧត្តមបណ្ឌិត **ហួត ពុំ** អគ្គនាយករង ដែលព្យួរការងារថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២
- ឯកឧត្តម **ឈុន សម្បត្តិ** ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

| | | |
|---|---|---|
| - លោក | **សៀង ធីរិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត |
| - លោក | **សូរ្យ ម៉ុំឡៃន** | ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ជំនួសលោក **ចន ណារិទ្ធ** ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ដែលព្យួរការងារថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ |
| - លោក | **ទិន តក្កី** | ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ |
| - លោក | **ទ៉ា សុវី** | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ |
| - លោក | **ឈុំ សេរីវុធ** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| - លោក | **ឆាយ ឃុនឡុង** | ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង |

**រៀបចំដោយ គណៈកម្មការមូលបត្រកម្ពុជា**

*********

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០១៦/១៧ គ.ម.ក. /ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុល
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ០០៩/១៧ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- យោងតាមសំណើសុំអនុម័តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

**សម្រេច**

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ...អង្គារ...៩...កើត... ខែ...បុស្ស... ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៦... ខែ...ធ្នូ.... ឆ្នាំ...២០១៧...

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធប្រកាសលេខ ០១៦/១៧
# ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧
# ស្ដីពី
# វិធានចុះបញ្ជីលក់មូលបត្របំណុល
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

វិធាននេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌតម្រូវ នីតិវិធី និងការគ្រប់គ្រងពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្របំណុលនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះនិងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត÷

-**បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល** សំដៅដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុល នៅ **ផ.ម.ក.** ។

-**បុគ្គលចុះបញ្ជីលក់មូលបត្របំណុល** សំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនោះជាផ្លូវការនៅ **ផ.ម.ក.**។

-**បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ** សំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនោះជាផ្លូវការនៅ **ផ.ម.ក.**។

**ប្រការ ៣.- វិសាលភាព**

វិធាននេះមានវិសាលភាពអនុវត្តទៅលើមូលបត្របំណុលដែលបោះផ្សាយលក់ជាសាធារណៈ ដែលជាសញ្ញាបណ្ណសាជីវកម្ម ដែលមានប្រភេទជាសញ្ញាបណ្ណធម្មតា (Plain Bond) សញ្ញាបណ្ណមានវត្ថុធានា (Secured Bond) សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond) និងប្រភេទមូលបត្របំណុលដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

## ជំពូកទី ២

## លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល

**ប្រការ ៤.- ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល ដោយត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃការចុះបញ្ជីលក់មូលបត្របំណុលនៅ **ផ.ម.ក.**។

**ប្រការ ៥.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលត្រូវផ្តល់ព័ត៌មាន និងឯកសារភ្ជាប់ដូចខាងក្រោម ÷

១-ព័ត៌មានទូទៅ

ក-ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ជាភាសាខ្មែរ និងអក្សរឡាតាំង

ខ-អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល

គ-កាលបរិច្ឆេទនៃការបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល

ឃ-កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល។

២-លក្ខន្តិកៈរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ ។

៤-វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៥-លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៦- លិខិតប្រគល់សិទ្ធិជូនបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលនិងឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលតំណាង។

៧-ព័ត៌មានអំពីភាគហ៊ុនិក ។

៨- ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម។

៩-ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលរួមមាន ព័ត៌មានអំពីធុរកិច្ច និងព័ត៌មានអំពីហានិភ័យ។

១០-ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលរួមមាន÷

ក-ព័ត៌មានសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុ ដោយរាប់បញ្ចូលទាំងព័ត៌មានអំពីមូលបត្របំណុល និងមូលបត្រកម្មសិទ្ធិទាំងអស់ និងលទ្ធភាពទទួលបានប្រាក់ចំណេញ។

ខ-ការវាយតម្លៃទ្រព្យសកម្ម និង/ ឬ ការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

គ-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម អនុលោមតាមលក្ខខណ្ឌតម្រូវនៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

១១-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ឬរបាយការណ៍ស្តីពីអនុបាតចំណេញភាព និងលំហូរសាច់ប្រាក់ (Profitability and Cash Flow Ratio) អនុបាតឡេវើរ៉េច (Leverage Ratio) និងអនុបាតលទ្ធភាពសង (Coverage Ratio) ជាដើម ដែលមានការបញ្ជាក់ពីភាពសមស្របដោយអ្នកជំនាញ ឬក្រុមហ៊ុនធានាទិញមូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលដែលជាសញ្ញាបណ្ណធម្មតា ករណីពុំទាន់មានភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ពី **គ.ម.ក.**។

១២-ព័ត៌មានពាក់ព័ន្ធនឹងវត្ថុធានា ករណីបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា។

១៣-ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលធានាដែលរួមមាន ព័ត៌មានទូទៅ របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា និងកិច្ចព្រមព្រៀងធានាជាមួយបុគ្គលធានា ករណីបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា ដែលបានការទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

១៤-ឯកសារស្តីពីមូលបត្របំណុលដែលស្នើសុំចុះបញ្ជីលក់ដែលមានព័ត៌មានដូចខាងក្រោម÷

ក-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលឱ្យធ្វើការបោះផ្សាយមូលបត្របំណុល។

ខ-សេចក្តីលម្អិតពីមូលបត្របំណុលដែលស្នើសុំចុះបញ្ជី÷

-អត្រាគូប៉ុង និងកាលវិភាគទូទាត់ការប្រាក់

-តម្លៃចារឹកនៃមូលបត្របំណុល

-កាលបរិច្ឆេទបោះផ្សាយ និងឥណប្រតិទាន

-ផែនការបែងចែកមូលបត្របំណុល

គ-ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយមូលបត្របំណុល។

ឃ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងអ្នកកាន់កាប់មូលបត្របំណុលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

១៥-ព័ត៌មានចាំបាច់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ បំណុល។

ករណីបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ឯកសារតម្រូវនៅក្នុងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ ទី៧ ទី៨ និងទី៩ ខាងលើ ត្រូវបានលើកលែង ប្រសិនបើព័ត៌មានទាំងនោះត្រូវបានធ្វើបច្ចុប្បន្នកម្មមក **ផ.ម.ក.** រួចហើយ។

## ប្រការ ៦.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពដែលអាចចុះបញ្ជីលក់មូលបត្របំណុល

ផ.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលទៅបុគ្គល ស្នើសុំចុះបញ្ជីលក់មូលបត្របំណុលក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។ រយៈពេលនៃការពិនិត្យត្រូវបានកាត់បន្ថយមកត្រឹមយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

ករណី **ផ.ម.ក.** បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល **ផ.ម.ក.** ត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលអាចស្នើសុំការបំភ្លឺពី **ផ.ម.ក.**។ បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលដែលត្រូវបានបដិសេធអាច ធ្វើការតវ៉ាមក **គ.ម.ក.** ចំពោះការបដិសេធនោះ ដើម្បីពិនិត្យនិងសម្រេច។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្របំណុល

## ប្រការ ៧.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្របំណុល

ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមូលបត្របំណុលត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការនៅ **ផ.ម.ក.** ។

## ប្រការ ៨.- លក្ខខណ្ឌចុះបញ្ជីលក់មូលបត្របំណុល

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលអាចចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការបាននៅ **ផ.ម.ក** ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**÷

១-មូលធនភាគហ៊ុនិកសរុប ត្រូវមានយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល លើកលែងចំពោះការចុះបញ្ជីសញ្ញាបណ្ណមានវត្ថុធានា។

២-ទំហំមូលបត្របំណុលដែលបោះផ្សាយនិងចុះបញ្ជី ត្រូវមានយ៉ាងតិចចំនួន ១.០០០.០០០.០០០ (មួយប៊ីលាន) រៀល ឬយ៉ាងតិចចំនួន ៥០០.០០០.០០០(ប្រាំរយលាន) រៀល ចំពោះសញ្ញាបណ្ណមានវត្ថុធានា។

៣-តម្លៃចារឹក ត្រូវមានតម្លៃ ១០០.០០០(មួយរយពាន់) រៀល។

៤-មូលបត្របំណុលទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក.។

## ប្រការ ៩.- ឯកសារភ្ជាប់ដែលត្រូវផ្តល់ជូន ផ.ម.ក.

ក្នុងការបំពេញនីតិវិធីនៃការចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារភ្ជាប់ខាងក្រោម÷

១-ឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជីជាស្ថាពររួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់ពីការទូទាត់បរិវិសកម្មមូលបត្របំណុល។

៣-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្របំណុលនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក.។

៤-របាយការណ៍បែងចែកមូលបត្របំណុល។

៥-ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងដែលធ្វើឡើងជាមួយនឹងភ្នាក់ងារតំណាងអ្នកកាន់កាប់មូលបត្របំណុល ឬភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់។

៦-ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងធានាទិញមូលបត្រ។

## ប្រការ ១០.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុល

មុននឹងត្រូវបានចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវចុះកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុល ជាមួយ ផ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុលដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ។

## ប្រការ ១១.- ការចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ ៩ នៃវិធាននេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ ១២.- ការមិនសងត្រលប់ទៅវិញនូវឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់ និង ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុល**

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលវិញទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវបានព្យួរក៏ដោយ។

## ជំពូកទី ៤

## លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្របំណុលជាផ្លូវការ

**ប្រការ ១៣.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្របំណុលជាផ្លូវការ**

ផ.ម.ក. អាចដកចេញពីបញ្ជីលក់មូលបត្របំណុលជាផ្លូវការនូវមូលបត្របំណុលរបស់បុគ្គលចុះបញ្ជីលក់មូលបត្របំណុល ក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. ÷

១-បុគ្គលចុះបញ្ជីលក់មូលបត្របំណុលបានបំពានធ្ងន់ធ្ងរលើកាតព្វកិច្ចនៃការបង្ហាញព័ត៌មានសាជីវកម្មជាញឹកញាប់។

២-បុគ្គលចុះបញ្ជីលក់មូលបត្របំណុលមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ឬក្នុងរយៈពេលណាមួយដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។

៣-នៅក្នុងរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ មានយោបល់ជំទាស់ ឬបដិសេធ រយៈពេល ២ (ពីរ) ឆ្នាំជាប់គ្នា។

៤-លទ្ធភាពសងបំណុលនៃបុគ្គលចុះបញ្ជីលក់មូលបត្របំណុល ត្រូវបានធ្វើចំណាត់ថ្នាក់ក្រោមចំណាត់ថ្នាក់នៃហានិភ័យដែលអាចទទួលយកបាន ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង។

៥-បុគ្គលចុះបញ្ជីលក់មូលបត្របំណុលស្ថិតក្រោមករណីណាមួយនៃមូលហេតុរំលាយក្រុមហ៊ុនដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៦-បុគ្គលចុះបញ្ជីលក់មូលបត្របំណុលមិនមានលទ្ធភាពទូទាត់សងការប្រាក់ ផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ។

៧-ទំហំមូលបត្របំណុលដែលចុះបញ្ជីនៅតិចជាង ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

៨-មូលបត្របំណុលដល់ឥណប្រតិទាន។

**ប្រការ ១៤.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រកំណុល ដែលដកចេញពីបញ្ជីលក់មូលបត្រកំណុលជាផ្លូវការ**

នៅពេលដកចេញពីបញ្ជីនូវមូលបត្របំណុលណាមួយជាផ្លូវការ ផ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្របំណុលនោះ។

ករណីដកចេញពីបញ្ជីនូវមូលបត្របំណុលណាមួយ ផ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្របំណុលនោះ សម្រាប់រយៈពេល ១០(ដប់) ថ្ងៃនៃថ្ងៃជួញដូរ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

## ជំពូកទី ៥
## ការគ្រប់គ្រងលើមូលបត្របំណុលដែលបានចុះបញ្ជីលក់

**ប្រការ ១៥.- ភារកិច្ច និងនីតិវិធីផ្តល់ព័ត៌មាន**

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវដាក់ជូន ផ.ម.ក. ឱ្យទាន់ពេលវេលានូវព័ត៌មានសាជីវកម្ម និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចបង្ហាញព័ត៌មានសាជីវកម្មរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ១៦.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី**

ផ.ម.ក. អាចព្យួរការជួញដូរមូលបត្របំណុលដែលចុះបញ្ជី ក្នុងករណីណាមួយដូចខាងក្រោម÷

១-ករណីមូលបត្របំណុលចុះបញ្ជីមួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីបុគ្គលចុះបញ្ជីលក់មូលបត្របំណុលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្របំណុលជាផ្លូវការ ដូចមានចែងក្នុងប្រការ ១៣ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្របំណុលមិនទាន់បានអនុវត្ត។

៣-ករណីប្រតិបត្តិការរបស់បុគ្គលចុះបញ្ជីលក់មូលបត្របំណុលជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្របំណុលដែលអនុលោមតាមកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច ។

### ប្រការ ១៧.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្របំណុល

ករណីមានការកែប្រែទាក់ទងនឹងព័ត៌មានមូលបត្របំណុលដែលចុះបញ្ជីលក់ បុគ្គលចុះបញ្ជីលក់មូលបត្របំណុល ត្រូវបំពេញពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្របំណុលនៅ **ផ.ម.ក.** និងត្រូវផ្សព្វផ្សាយភ្លាម នូវព័ត៌មានអំពីការកែប្រែនេះជាសាធារណៈ បន្ទាប់ពីទទួលបានការអនុញ្ញាតលើការកែប្រែនេះពី **ផ.ម.ក.**។

## ជំពូកទី ៦
## ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុល

### ប្រការ ១៨.- ថ្លៃសេវាសម្រាប់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា **ផ.ម.ក.** លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលចំនួន ១.០០០.០០០(មួយលាន) រៀល នៅពេលដាក់ពាក្យស្នើសុំ។

### ប្រការ ១៩.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុល

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្របំណុល ចំនួន ២.០០០.០០០ (ពីរលាន) រៀល ឬ ០,០១% (សូន្យក្បៀសសូន្យមួយភាគរយ) នៃតម្លៃមូលបត្របំណុលសរុបដែលបោះផ្សាយ ដោយយកចំនួនណាមួយដែលធំជាង និងថ្លៃអតិបរមាមិនលើសពី ១០.០០០.០០០(ដប់លាន) រៀល។ ថ្លៃសេវា នេះត្រូវបង់មុនពេលចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ។

### ប្រការ ២០.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្របំណុល ចំនួន ៥០០.០០០(ប្រាំរយពាន់) រៀល។ ថ្លៃសេវានេះត្រូវបង់យ៉ាងយូររយៈពេល៣០(សាមសិប) ថ្ងៃ ក្រោយពេលចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ និងសម្រាប់ឆ្នាំបន្តបន្ទាប់ ត្រូវបង់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែមករា ជារៀងរាល់ឆ្នាំ។

************************